# ព្រះ
# ត្រៃបិដកបាលី
និង
សេចក្ដីប្រែជាភាសាខ្មែរ
## សុត្តន្តបិដក
## ខុទ្ទកនិកាយ អបទាន
## ទុតិយភាគ
# ៧៣

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

សុត្តន្តបិដក

ខុទ្ទកនិកាយ អបទាន

ទុតិយភាគ

៧៣

ព.ស. ២៥០៦

# សុត្តន្តបិដកេ
## ខុទ្ទកនិកាយស្ស អបទានំ
## ទុតិយោ ភាគោ

---

## ឯកាទសមោ ភិក្ខាទាយិវគ្គោ
### បឋមំ ភិក្ខាទាយកត្ថេរាបទានំ

(១) សុវណ្ណវណ្ណំ សម្ពុទ្ធំ អាហុតីនម្បដិគ្គហំ
បវរា(១) អភិនិក្ខន្តំ វនា និព្វានមាគតំ(២) ។
កដច្ឆុភិក្ខាទាសឹ សិទ្ធត្ថស្ស មហេសិនោ
បញ្ញស្ស ឧបសន្តស្ស មហាវីរស្ស តាទិនោ ។
បទេនានុបទាយន្តំ(៣) និព្វាបេន្តំ(៤) មហាជនំ
វិត្តិ មេ បាហុតា តាវ ពុទ្ធស្សាទិច្ចពន្ធុនោ(៥) ។
ចតុន្នវុតេ ឥតោ កប្បេ យំ ទានមទទឹ តទា
ទុគ្គតឹ នាភិជានាមិ ភិក្ខាទានស្សិទំ ផលំ ។

---

១ ម. បវរា ។ ២ ឱ. វនា និព្វនមាគតំ ។ ៣ ម. បទេនានុបទាយន្តំ និព្វាបេន្តេ មហាជនំ ។ ៥ ម. វិត្តិ មេ តាតា ពុទ្ធេ អាទិច្ចពន្ធុនោ ទិស្សន្តិ ។

# សុត្តន្តបិដក
## ខុទ្ទកនិកាយ អបទាន
## ទុតិយភាគ

---

## ភិក្ខាទាយិវគ្គ ទី ១១
### ភិក្ខាទាយកត្ថេរាបទាន ទី ១

(១) ខ្ញុំបានឃើញព្រះសម្ពុទ្ធមានវណ្ណៈដូចមាស ទ្រង់គួរទទួលគ្រឿងបូជា ទ្រង់ចេញចាកព្រៃដ៏ពីភណ្ហាមកកាន់ព្រះនិព្វាន ។ ខ្ញុំទៅតាមស្នាមព្រះបាទនៃព្រះពុទ្ធ ទ្រង់ញ៉ាំងជនច្រើនឲ្យរលត់ទុក្ខ ហើយបានថ្វាយភិក្ខាមួយវែក ដល់ព្រះមហេសីព្រះនាមសិទ្ធត្ថៈ ទ្រង់មានប្រាជ្ញា មានព្រះហឫទ័យស្ងប់រម្ងាប់ មានព្យាយាមច្រើន ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ សេចក្ដីត្រេកអររបស់ខ្ញុំ មានប្រមាណច្រើន ចំពោះព្រះពុទ្ធ ជាអាទិច្ចពន្ធុ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានថ្វាយទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃការថ្វាយភិក្ខា ។

សត្តាសីតិម្ហិតោ កប្បេ មហារេណុសនាមកា
សត្តរតនសម្បន្នា សត្តេតេ ចក្កវត្តិនោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ភិក្ខាទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ភិក្ខាទាយកត្ថេរស្ស អបទានំ សមត្តំ ។

## ទុតិយំ ញាណសញ្ញិកត្ថេរាបទានំ

(៦) សុវណ្ណវណ្ណំ សម្ពុទ្ធំ និសភាជានិយំ យថា
តិធាបភិន្នំ មាតង្គំ កុញ្ជរំ មហេសិនំ ។
ឱភាសេន្តំ ទិសា សព្វា សាលរាជំវ បុប្ផិតំ(១)
រថិយា បដិបជ្ជន្តំ លោកជេដ្ឋំ នរុត្តមំ ។
ញាណេ ចិត្តំ បសាទេត្វា បគ្គហេត្វាន អញ្ជលឹ
បសន្នចិត្តោ សុមនោ សិទ្ធត្ថំ អភិវាទយឹ ។

១ ឱ. ចម្បកំវ ផុល្លិតំ ។



ក្នុងកប្បទី ៨៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៧ ជាតិ ព្រះនាមមហារេណុដូចគ្នា ប្រកបរួចហើយដោយកែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះភិក្ខាទាយកត្ថេរមានអាយុ បានសំដែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ភិក្ខាទាយកត្ថេរាបទាន ។

## ញាណសញ្ញិកត្ថេរាបទាន ទី ២

(៦) (ខ្ញុំបានឃើញ) នូវព្រះសម្ពុទ្ធ ទ្រង់មានវណ្ណៈដូចមាស ទ្រង់ដូចជាគោឧសភដ៏ប្រសើរ ឬទ្រង់ដូចដំរីឈ្មោះមាតង្គៈ ដែលចុះប្រេងបីយ៉ាង ព្រះអង្គស្វែងរកនូវគុណដ៏ធំ ទ្រង់ញុំាងទិសទាំងពួងឲ្យភ្លឺច្បាស់ ទ្រង់ដូចដើមសាលរាជមានផ្ការីកហើយ ទ្រង់ជាច្បងក្នុងត្រៃលោក ទ្រង់ខ្ពង់ខ្ពស់ជាងនរៈ ទ្រង់ស្តេចនិមន្តទៅតាមច្រក បានញុំាងចិត្តខ្ញុំឲ្យជ្រះថ្លាក្នុងញាណ (របស់ព្រះអង្គ) ខ្ញុំបានផ្គងអញ្ជលី មានចិត្តជ្រះថ្លា មានចិត្តរីករាយ ហើយថ្វាយបង្គំព្រះសិទ្ធត្ថៈ ។

ឯកនវុតេ ឥតោ កប្បេ  យំ សញ្ញមលភឹ តទា
ទុគ្គតឹ នាភិជានាមិ  ញាណសញ្ញាយិទំ ផលំ ។
តេសត្តតិម្ហិតោ កប្បេ  សោឡសាសុំ នរុត្តមា
សត្តរតនសម្បន្នា  ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនំ ។
ឥត្ថំ សុទំ អាយស្មា ញាណសញ្ញិកោ ថេរោ
ឥមា គាថាយោ អភាសិត្ថាតិ ។

ញាណសញ្ញិកត្ថេរស្ស អបទានំ សមត្តំ ។

## តតិយំ ឧប្បលហត្ថិយត្ថេរាបទានំ

(៣) តិវរាយំ និវាសីហំ(១) អហោសឹ មាលិកោ តទា
អទ្ទសំ វិរជំ ពុទ្ធំ  សិទ្ធត្ថំ លោកបូជិតំ ។

១ ម. និវាសហំ ។



ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសេចក្ដីសំគាល់ក្នុងញាណ ។ ក្នុងកប្បទី ៧៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ ១៦ ជាតិ ជាស្ដេចឧត្ដមជាងជន ប្រកបដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះញាណសញ្ញិកត្ថេរមានអាយុ បានសំដែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ញាណសញ្ញិកត្ថេរាបទាន ។

## ឧប្បលហត្ថិយត្ថេរាបទាន ទី ៣

(៣) ក្នុងកាលនោះ ខ្ញុំកើតជាអ្នកក្រងផ្កា នៅអាស្រ័យក្នុងក្រុងឈ្មោះតិវរ បានឃើញព្រះពុទ្ធព្រះនាមសិទ្ធត្ថៈ មានធូលីគឺរាគៈទៅប្រាសហើយ ដែលសត្វលោកបូជាហើយ ។

បសន្នចិត្តោ សុមនោ  បុប្ផហត្ថំ អទាសហំ
យត្ថ យត្ថុបបជ្ជាមិ  តស្ស កម្មស្ស វាហសា ។
អនុភោមិ ផលំ ឥដ្ឋំ  បុព្វេ(១) សុកតមត្តនោ
បរិក្ខិត្តោ សុមល្លេហិ  សសញ្ញាយ ឥទំ ផលំ(២) ។
ចតុន្នវុតេ ឥតោ កប្បេ  យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ  ពុទ្ធបូជាយិទំ ផលំ ។
ចតុន្នវុតេ ឥតោ កាយ  បមេត្វា វត្ថានកំ
បញ្ច រថសតា តត្ថ  ឧទ្ធបមសេវាមកា ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ឧប្បលហត្ថិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឧប្បលហត្ថិយត្ថេរស្ស អបទានំ សមត្តំ ។

១ ម. បុព្វ ។ ២ ម. បុប្ផទានស្សិទំ ផលំ ។





ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយផ្កា ១ ក្តាប់ ខ្ញុំទៅកើតក្នុងភពណា ៗ តែងសោយផលជាទីប្រាថ្នាដែលខ្ញុំធ្វើល្អហើយក្នុងកាលមុន (ក្នុងភពនោះ ៗ) ដោយអំណាចផលសម្បៀននៃកម្មនោះ ខ្ញុំមានផ្កាម្លិះព័ទ្ធជុំហើយ នេះជាផលនៃសេចក្តីសំគាល់ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្រោយកប្បទាំង ៩៤ ទៀតលើកប្បបច្ចុប្បន្ននេះទៅ ខ្ញុំបានកើតជាស្តេច ៥០០ ជាតិ ព្រះនាមឧទ្ធបៈ ដូចគ្នា ក្នុងកប្បនោះ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧប្បលហត្ថិយត្ថេរមានអាយុ បានសំដែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឧប្បលហត្ថិយត្ថេរាបទាន ។

## បញ្ចមំ បទបូជកត្ថេរាបទានំ

(៥) សិទ្ធត្ថស្ស ភគវតោ ជាតិបុប្ផមទាសហំ
បាទេសុ សត្ត បុប្ផានិ ហាសេនោកិរិតានិ(១) មេ ។
តេន កម្មេនហំ អជ្ជ អភិភោមិ នរាមរេ
ធារេមិ អន្តិមំ ទេហំ សម្មាសម្ពុទ្ធសាសនេ ។
ចតុន្នវុតេ ឥតោ កប្បេ យំ បុប្ផមភិបូជយិំ
ទុគ្គតិំ នាភិជានាមិ បុប្ផបូជាយិទំ ផលំ ។
សមន្តគន្ធនាមាសុំ តេរស ចក្កវត្តិនោ
ឥតោ បញ្ចមកេ កប្បេ ចាតុរន្តា មហព្ពលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បទបូជកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បទបូជកត្ថេរស្ស អបទានំ សមត្តំ ។

១ ម. ហាសេនោក្កិរិតានិ ។



## បទបូជកត្ថេរាបទាន ទី ៥

(៥) ខ្ញុំបានថ្វាយផ្កាម្លិះ ដល់ព្រះមានព្រះភាគទ្រង់ព្រះនាមសិទ្ធត្ថៈ ខ្ញុំបានរោយរាយផ្កា ៧ ត្រង់ព្រះបាទ ដោយសេចក្តីរីករាយ ។ ខ្ញុំគ្របសង្កត់ពួកជននិងទេវតាក្នុងថ្ងៃនេះ ដោយកុសលកម្មនោះ ខ្ញុំទ្រទ្រង់នូវរាងកាយជាទីបំផុត ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាផ្កា ។ ក្នុងកប្បទី ៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១៣ អង្គ ព្រះនាមសមន្តគន្ធៈដូចគ្នា ទ្រង់ផ្សាយការគ្របគ្រងលើផែនដីមានទិស ៤ ជាទីបំផុត ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបទបូជកត្ថេរមានអាយុ បានសំដែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បទបូជកត្ថេរាបទាន ។

## បញ្ចមំ មុដ្ឋិបុប្ផិយត្ថេរាបទានំ

[៥] សុទស្សនោតិ នាមេន មាលាការោ អហំ តទា

អទ្ទសំ វិរជំ ពុទ្ធំ លោកជេដ្ឋំ នរាសភំ ។

ជាតិបុប្ផំ គហេត្វាន បូជយឹ បទុមុត្តរំ

វិសុទ្ធចក្ខុ សុមនោ ទិព្វចក្ខុំ សមជ្ឈគំ ។

ឯតិស្សា បុប្ផបូជាយ ចិត្តស្ស បណិធីហិ ច

កប្បានំ សតសហស្សំ ទុគ្គតឹ នុបបជ្ជហំ ។

សោឡសាសឹសុ រាជានោ ទេវុត្តរសនាមកា

ឆត្តឹសម្ហិ ឥតោ កប្បេ ចក្កវត្តី មហព្ពលា ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា មុដ្ឋិបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

មុដ្ឋិបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។





## មុដ្ឋិបុប្ផិយត្ថេរាបទាន ទី ៥

(៥) ក្នុងកាលនោះ ខ្ញុំកើតជាអ្នកក្រងផ្កា ឈ្មោះសុទស្សនៈ បានឃើញព្រះពុទ្ធ ព្រះអង្គប្រាសចាកធូលីគឺកិលេស ជាច្បងក្នុងលោក ទ្រង់ប្រសើរជាងនរជន ។ ខ្ញុំកាន់យកផ្កាម្លិះ បូជាចំពោះព្រះបទុមុត្តរៈ ខ្ញុំមានចក្ខុស្អាត មានចិត្តរីករាយ បានសម្រេចទិព្វចក្ខុ ។ ខ្ញុំមិនដែលទៅកាន់ទុគ្គតិអស់ ១ សែនកប្ប ដោយបុប្ផបូជានេះផង ដោយការតាំងទុកចិត្តផង ។ ក្នុងកប្បទី ៣៦ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១៦ ជាតិ ព្រះនាមទេវុត្តរៈដូចគ្នា មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះមុដ្ឋិបុប្ផិយត្ថេរមានអាយុ បានសំដែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មុដ្ឋិបុប្ផិយត្ថេរាបទាន ។

## ឆដ្ឋំ ឧទកបូជកត្ថេរាបទានំ

(៦) សុវណ្ណវណ្ណំ សម្ពុទ្ធំ គច្ឆន្តំ អនិលញ្ជសេ
ឃតាសនំវ ជលិតំ អាទិត្តំវ ហុតាសនំ ។
បាណិនា ឧទកំ គយ្ហ អាកាសេ ឧក្ខិបឹ អហំ
សម្បដិច្ឆិ មហាវីរោ ពុទ្ធោ ការុណិកោ ឥសិ(១) ។
អន្តលិក្ខេ ឋិតោ សត្ថា បទុមុត្តរនាមកោ
មម សង្កប្បមញ្ញាយ ឥមំ គាថំ អភាសថ ។
ឥមិនា ទកទានេន បីតិឧប្បាទនេន ច
កប្បសតសហស្សម្បិ ទុគ្គតឹ នុបបជ្ជតិ ។
តេន កម្មេន ទ្វិបទិន្ទ លោកជេដ្ឋ នរាសភ
បត្តោម្ហិ អចលំ ឋានំ ហិត្វា ជយបរាជយំ ។
សហស្សរាជនាមេន តយោ តេ ចក្កវត្តិនោ
បញ្ចសដ្ឋិកប្បសតេ ចាតុរន្តា ជនាធិបា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

១ ម. ឥសី ។



## ឧទកបូជកត្ថេរាបទាន ទី ៦

(៦) ព្រះសម្ពុទ្ធមានវណ្ណៈដូចមាស ស្ដេចនិមន្តទៅក្នុងអាកាស រុងរឿងដូចភ្លើងដែលឆេះខ្លាញ់ ឬដូចភ្លើងដែលកំពុងឆេះភ្លឺភ្លាល ។ ខ្ញុំកាន់យកទឹកដោយដៃ សាចទៅក្នុងអាកាស ព្រះពុទ្ធមានព្យាយាមធំ ប្រកបដោយសេចក្ដីករុណាចំពោះខ្ញុំ ទ្រង់ទទួល (នូវទឹកនោះ) ព្រះសាស្ដាព្រះនាមបទុមុត្តរៈ ឋិតនៅក្នុងអាកាស ទ្រង់ជ្រាបនូវតម្រិះរបស់ខ្ញុំ ហើយទ្រង់សំដែងនូវគាថានេះថា ក្នុង ១ សែនកប្ប អ្នកនឹងមិនទៅកាន់ទុគ្គតិ ដោយការឲ្យទឹកនេះផង ដោយការញុំាងបីតិឲ្យកើតឡើងផង ។ បពិត្រព្រះអង្គជាធំជាងសត្វជើងពីរ ជាច្បងក្នុងលោក ទ្រង់ប្រសើរជាងពួកនរៈ ខ្ញុំព្រះអង្គលះបង់នូវការឈ្នះនិងការចាញ់ហើយ បានដល់នូវអចលដ្ឋានដោយកុសលកម្មនោះ ។ ក្នុងកប្បទី ១៦៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ ៣ ជាន់ ទ្រង់ព្រះនាមសហស្សរាជដូចគ្នា ទ្រង់ផ្សាយអាណាចក្រទៅលើផែនដីមានសមុទ្រទាំង ៤ ទ្រង់ជាធំជាងពួកជន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា ឧទកបូជកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឧទកបូជកត្ថេរស្ស អបទានំ សមត្តំ ។

## សត្តមំ នឡមាលិយត្ថេរាបទានំ

(៧) បទុមុត្តរពុទ្ធស្ស លោកជេដ្ឋស្ស តាទិនោ
តិណត្ថរេ និសិន្នស្ស ឧបសន្តស្ស តាទិនោ ។
នឡមាលំ គហេត្វាន ពន្ធិត្វា វីជនី(១) អហំ
ពុទ្ធស្ស ឧបនាមេសឹ ទិបទិន្ទស្ស តាទិនោ ។
បដិគ្គហេត្វា សព្វញ្ញូ វីជនឹ លោកនាយកោ
មម សង្កប្បមញ្ញាយ ឥមំ គាថំ អភាសថ ។
យថា មេ កាយោ និព្វាយិ បរិឡាហោ ន វិជ្ជតិ
តថេវ តិវិធគ្គីហិ ចិត្តំ តវ វិមុច្ចតុ ។

១ ម. ពិជិត្វា ពិជនិំ ។



បានឮថា ព្រះឧទកបូជកត្ថេរមានអាយុ បានសំដែងនូវគាថា ទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ឧទកបូជកត្ថេរាបទាន ។

## នឡមាលិយត្ថេរាបទាន ទី ៧

(៧) ព្រះបទុមុត្តរសម្ពុទ្ធ ជាច្បងក្នុងលោក ជាតាទិបុគ្គល ទ្រង់គង់លើកម្រាលស្មៅ មានព្រះហឫទ័យស្ងប់ល្ងាប់ ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ ខ្ញុំកាន់យកផ្កាបបុស បក់ធ្វើជាផ្លិត បង្អោនថ្វាយព្រះពុទ្ធ ទ្រង់ជាធំជាងសត្វជើងពីរ ព្រះអង្គមិនញាប់ញ័រដោយលោកធម៌ ។ ព្រះសព្វញ្ញូជាលោកនាយក ទ្រង់ទទួលផ្លិតហើយ ទ្រង់ជ្រាបនូវតំរិះរបស់ខ្ញុំ ទើបទ្រង់សំដែងគាថានេះថា កាយរបស់តថាគត រលត់ទុក្ខហើយ សេចក្តីក្តៅក្រហាយមិនមានឡើយ យ៉ាងណាមិញ ចិត្តរបស់អ្នក ចូររួចស្រឡះចាកភ្លើងទាំងបីប្រការ យ៉ាងនោះដែរ ។

### សង្ខេប ឧទាហរណ៍យកត្តោយកន

សព្វេ ឆេក សមាគម្ម    យេ កេចិ ទុមនិស្សិតា
សុសង្ឃរ ពុទ្ធវចនំ    ហាសយន្តា ជយគ្គំ ។
និសិន្នោ ភគវា តត្ថ    ទេវសង្ឃបុរក្ខតោ
ជយគ្គំ សម្បហំសេន្តោ    ឥមា គាថា អភាសថ ។
ឥមិនា វីជនិជានេន    ចិត្តស្ស បណិធីហិ ច
សុព្វតោ ជាម ជាមេន    ចក្កវត្តិ ភវិស្សតិ ។
តេន កម្មាវសេសេន    សុក្កម្មលេន ហោតិតោ
មាលុតោ ជាម ជាមេន    ចក្កវត្តិ ភវិស្សតិ ។
ឥមិនា វីជនិជានេន    សម្មាធិមុលេន ច
កប្បសត្តសហស្សម្ហិ    ទុគ្គតិំ ឧបបជ្ជតិ ។
តឹស កប្បសហស្សម្ហិ    សុព្វតា អដ្ឋតឹស តេ
ឯកូនតឹសសហស្ស    អដ្ឋ មាលុតជាមកា ។
បដិសម្ភិទា ចតស្សោ    វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនន្តិ ។



### ឧទាហរណ៍យកត្តោយកន ទី ៨

ទៅកាលណាមួយ អាស្រ័យដើមឈើ ទៅតាំងទឹកសំនោះ មកប្រជុំគ្នា (ដោយបំណងថា) ពួកយើងនឹងស្តាប់ នូវពុទ្ធវចនៈ ដែលញុំាងឱ្យកើតអំណរ ។ ឯព្រះមានព្រះភាគ មានពួកទេវតាចោមរោម ទ្រង់គង់លើកម្រាលនោះ ទ្រង់ញុំាងឱ្យកើតអំណរ ហើយសម្តែងនូវគាថាទាំងនេះថា កុលបុត្តនេះ នឹងកើតជាស្តេចចក្រពត្តិ មាននាមថាសុព្វតជ ដោយការថ្វាយនូវផ្លែនេះផង ដោយការតាំងចិត្តផង កុលបុត្តនោះ ជាបុគ្គលត្រៀមកុសលមូលជាសំខាន់ហើយ នឹងបាន ជាស្តេចចក្រពត្តិទៀត មាននាមថាមាលុតជ ដោយសេសផលនៃកម្មនោះ ។ ក្នុង ១ សែនកប្ប កុលបុត្តនេះមិនដែលទៅកាន់ទុគ្គតិ ដោយការថ្វាយផ្លែនេះផង ដោយការកប់ភាន ស៊ីនិទ្ធលាយផង ។ ក្នុង៣០.០០០កប្ប នឹងបានជាក្សត្រ ៣៨ ជាតិ ក្សត្រទាំងនោះ ព្រះនាមថាសុព្វតជ, ក្នុង ៦៩.០០០ កប្ប បានជាក្សត្រ៨ជាតិ ទ្រង់ព្រះនាមមាលុតជ ។ បដិសម្ភិទា ៤ វិមោក្ខ៨ និងអភិញ្ញា៦នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា ឧប្បមាលិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឧប្បមាលិយត្ថេរស្ស អបទានំ សមត្តំ ។

សត្តមំ ភាណវារំ ។

## អដ្ឋមំ អាសនុបដ្ឋាយកត្ថេរាបទានំ

(៨) កាននំ វនមោគ្គយ្ហ  អប្បសទ្ទំ និរាកុលំ
សីហាសនំ មយា ទិន្នំ  អត្ថទស្សិស្ស តាទិនោ ។
មាលាហត្ថំ គហេត្វាន  កត្វា ច នំ បទក្ខិណំ
សត្ថារំ បយិរុបាសិត្វា  បក្កាមឹ ឧត្តរាមុខោ ។
តេន កម្មេន ទិបទិន្ទ  លោកជេដ្ឋ នរាសភ
សន្និព្វាបេមិ(១) អត្តានំ  ភវា សព្វេ សមូហតា ។
អដ្ឋារសេ កប្បសតេ  យំ ទានមទទិំ តទា
ទុគ្គតិំ នាភិជានាមិ  សីហាសនស្សិទំ ផលំ ។

១ ម. សន្និព្វាបេមិ ។ ក្នុងបិ ហោន្តេវ យំ និព្វាបេសិ អត្តានន្តិ ទិស្សតិ ។



បានឮថា ព្រះឧប្បមាលិយត្ថេរមានអាយុ បានសំដែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឧប្បមាលិយត្ថេរាបទាន ។

ចប់ភាណវារៈ ទី ៧ ។

## អាសនុបដ្ឋាយកត្ថេរាបទាន ទី ៨

(៨) ខ្ញុំចូលទៅកាន់ព្រៃធំ ដ៏ស្ងាត់មិនមានសំឡេង មិនវឹកវរ ខ្ញុំថ្វាយសីហាសនៈ ដល់ព្រះសម្ពុទ្ធព្រះនាមអត្ថទស្សី ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ ខ្ញុំកាន់យកផ្កាមួយក្តាប់ ធ្វើប្រទក្សិណព្រះអង្គ ហើយចូលទៅអង្គុយជិតព្រះសាស្តា រួចដើរចេញទៅ បែរមុខឆ្ពោះទៅកាន់ទិសខាងជើង ។ បពិត្រព្រះអង្គជាធំជាងសត្វជើងពីរ ទ្រង់ជាច្បងក្នុងលោក ទ្រង់ប្រសើរជាងនរៈ ខ្ញុំធ្វើខ្លួនឲ្យរលត់ ឥតមានសេសសល់ ភពទាំងអស់ ខ្ញុំគាស់រំលើងហើយ ដោយសារកម្មនោះ ។ ក្នុងកប្បទី ១.៨០០ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែល ខ្ញុំបានឲ្យទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសីហាសនៈ ។

ឥតោ សត្តកប្បសតេ សន្និព្វាបកខត្តិយោ(១)
សត្តរតនសម្បន្នោ ចក្កវត្តី មហព្ពលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា អាសនុបដ្ឋាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អាសនុបដ្ឋាយកត្ថេរស្ស អបទានំ(២) សមត្តំ ។

## នវមំ ពិឡាលិទាយកត្ថេរាបទានំ

(៩) ហិមវន្តស្ស អវិទូរេ វសាមិ បណ្ណសន្ថរេ
ឃាសេសុ គេធមាបន្នោ សេយ្យសីលោ វហំ តទា ។
ខណមាលុកលម្ពានិ(៣) ពិឡាលិតក្កលានិ ច
កោលំ ភល្លាតកំ ពេល្លំ(៤) អាហត្វា បដិយាទិតំ ។
បទុមុត្តរោ លោកវិទូ អាហុតីនំ បដិគ្គហោ
មម សង្កប្បមញ្ញាយ អាគច្ឆិ មម សន្តិកំ ។

---

១ ឱ. សន្និព្វា នាម ខត្តិយោ ។ ២ ឱ. អាសនុបដ្ឋាហកត្ថេរស្សាបទានំ ។ ៣ ឱ. ខណេត្តាលុកលម្ពានិ ។ ៤ ឱ. ពិល្លំ ។



ក្នុងកប្ប ទី ៧០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមសន្និព្វាបកៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអាសនុបដ្ឋាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អាសនុបដ្ឋាយកត្ថេរាបទាន ។

## ពិឡាលិទាយកត្ថេរាបទាន ទី ៩

(៩) ខ្ញុំនៅជិតព្រៃហិមពាន្ត អាស្រ័យលើកម្រាលស្លឹកឈើ ក្នុងកាលនោះ ខ្ញុំមានសេចក្តីជាប់ចំពាក់ ក្នុងគ្រឿងទទួលទាន ដូចបុរសល្មោភដេក ។ ខ្ញុំកំពុងជីកមើមដំឡូងជ្វាផង ដំឡូងល្ហុងផង ដំឡូងដៃខ្លា និងដំឡូងជ្រូកផង ខ្ញុំនាំមកនូវផ្លែពុទ្រា ផ្លែក្រទុប និងផ្លែព្នៅដែលខ្ញុំតាក់តែងហើយ ។ ព្រះលោកវិទូ ទ្រង់ព្រះនាមបទុមុត្តរៈ ជាអ្នកទទួលគ្រឿងបូជា ទ្រង់ជ្រាបនូវតម្រិះរបស់ខ្ញុំ ទើបនិមន្តមកកាន់សំណាក់ខ្ញុំ ។

ឧបាគតំ មហានាគំ ជេវជេវំ ឆកសកំ
ពិឡាលិំ បគ្គហេត្វាន បត្តម្ហិ ឱកិរឹ អហំ ។
បរិភុញ្ជិ មហាវីរោ តោសយន្តោ មមំ តទា
បរិភុញ្ជិត្វាន សព្វញ្ញូ ឥទំ វាចំ អភាសថ ។
សកំ ចិត្តំ បសាទេត្វា ពិឡាលិំ មេ អទា តុវំ
កប្បានំ សតសហស្សំ ទុគ្គតឹ នុបបជ្ជសិ ។
ចរិមំ វត្តតេ មយ្ហំ ភវា សព្វេ សមូហតា
ធារេមិ អន្តិមំ ទេហំ សម្មាសម្ពុទ្ធសាសនេ ។
ចតុប្បញ្ញាសិតោ កប្បេ សុមេខលិយសវ្ហយោ
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ពិឡាលិទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ពិឡាលិទាយកត្ថេរស្ស អបទានំ សមត្តំ ។



ខ្ញុំបានឃើញនូវព្រះមហានាគជាទេវតា ប្រសើរជាងទេវតា ជានរាសភៈ ទ្រង់ចូលមកជិត ខ្ញុំក៏យកដំឡូងវៃផ្កាដាក់ចុះក្នុងបាត្រ ។ ក្នុងកាលនោះ ព្រះសម្ពុទ្ធ ជាមហាវីរៈ ទ្រង់ញុំាងខ្ញុំឲ្យត្រេកអរហើយ ទ្រង់សោយ លុះព្រះសព្វញ្ញូសោយរួចហើយ ទើបសំដែងនូវគាថានេះថា អ្នកបានញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ហើយថ្វាយដំឡូងវៃផ្កាដល់តថាគត អ្នកនឹងមិនទៅកាន់ទុគ្គតិ អស់ ១ សែនកប្ប ។ ភពជាទីបំផុតរបស់ខ្ញុំក៏ពុំប្រព្រឹត្តទៅ ភពទាំងអស់ខ្ញុំបានគាស់រំលើងហើយ ខ្ញុំទ្រទ្រង់នូវកាយជាទីបំផុត ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ។ ក្នុងកប្បទី ៥៤ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ ឈ្មោះសុមេខលិយៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះពិឡាលិទាយកត្ថេរមានអាយុ បានសំដែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ពិឡាលិទាយកត្ថេរាបទាន ។

## ទសមំ រេណុបូជកត្ថេរាបទានំ

(១០) សុវណ្ណវណ្ណំ សម្ពុទ្ធំ សតរំសឹវ ភាណុមំ
ឱភាសេន្តំ ទិសា សព្វា ឧឡុរាជំវ បុណ្ណមំ ។
បុរក្ខតំ សាវកេហិ សាគរេវ មេទនឹ
នាគំ បគ្គយ្ហ រេណូហិ វិបស្សិស្សាភិរោបយឹ ។
ឯកនវុតេ ឥតោ កប្បេ យំ រេណុមភិរោបយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
បណ្ណាសិតោ កប្បេ រេណុ នាមាសិ ខត្តិយោ
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្ពលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា រេណុបូជកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

រេណុបូជកត្ថេរស្ស អបទានំ សមត្តំ ។



## រេណុបូជកត្ថេរាបទាន ទី ១០

(១០) ព្រះសម្ពុទ្ធ មានវណ្ណៈដូចមាស ទ្រង់ដូចព្រះអាទិត្យ មានរស្មីច្រើន ញុំាងទិសទាំងពួងឲ្យភ្លឺស្វាង ឬដូចព្រះចន្ទពេញវង់ ទ្រង់មានពួកសាវ័កហែហមរោម ដូចផែនដីមានសមុទ្រ (ព័ទ្ធជុំវិញ) ខ្ញុំយកលំអងផ្កានាគទាំងឡាយបូជាចំពោះព្រះវិបស្សី ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាលំអងផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៥០ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ ១ អង្គ ទ្រង់ព្រះនាមរេណុរាជ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះរេណុបូជកត្ថេរមានអាយុ បានសំដែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ រេណុបូជកត្ថេរាបទាន ។

## ឧទ្ទានំ

ភិក្ខាទាយី ញាណសញ្ញី ហត្ថិយោ បទបូជកោ
មុដ្ឋិបុប្ផី ឧទកទោ នឡមាលី អាធារកោ(១)
ពិឡាលិទាយី រេណុ ច គាថាយោ ឆ ច សដ្ឋិ ច ។

ភិក្ខាទាយិវគ្គោ ឯកាទសមោ ។

---

១ ម. នឡមាលិ ឧបត្ថាកោ ។



## ឧទ្ទាន

ភិក្ខាទាយកត្ថេរាបទាន ១ ញាណសញ្ញិកត្ថេរាបទាន ១ ហត្ថិយត្ថេរាបទាន ១ បទបូជកត្ថេរាបទាន ១ មុដ្ឋិបុប្ផិយត្ថេរាបទាន ១ ឧទកបូជកត្ថេរាបទាន ១ នឡមាលិយត្ថេរាបទាន ១ អាសនុបដ្ឋាយកត្ថេរាបទាន ១ ពិឡាលិទាយកត្ថេរាបទាន ១ រេណុបូជកត្ថេរាបទាន ១ មានគាថា ៦៦ ។

ចប់ ភិក្ខាទាយិវគ្គ ទី ១១ ។

## ទ្វាទសមោ មហាបរិវារវគ្គោ

### បឋមំ មហាបរិវារត្ថេរាបទានំ

(១១) វិបស្សី នាម ភគវា លោកជេដ្ឋោ នរាសភោ
អដ្ឋសដ្ឋិសហស្សេហិ បាវិសិ ពន្ធុមំ តទា ។
នគរា អភិនិក្ខម្ម អគមំ ទីបចេតិយំ
អទ្ទសំ វិរជំ ពុទ្ធំ អាហុតីនំ បដិគ្គហំ ។
ចុល្លាសីតិសហស្សានិ យក្ខា មយ្ហំ ឧបន្តិកេ
ឧបដ្ឋហន្តិ សក្កច្ចំ(១) ឥន្ទំវ តិទសា គណា ។
ភវនា អភិនិក្ខម្ម ទុស្សំ បគ្គយ្ហហំ តទា
សិរសា អភិវាទេសិំ តញ្ចាទាសិំ មហេសិនោ ។
អហោ ពុទ្ធា អហោ ធម្មា អហោ នោ សត្ថុសម្បទា
ពុទ្ធស្ស អានុភាវេន វសុធាយំ បកម្បថ ។
តញ្ច អច្ឆរិយំ ទិស្វា អព្ភុតំ លោមហំសនំ
ពុទ្ធេ ចិត្តំ បសាទេមិ ទិបទិន្ទម្ហិ តាទិនេ ។

១ ម. ឧបដ្ឋហន្តិ មំ និច្ចំ ។

## មហាបរិវារវគ្គ ទី ១២

### មហាបរិវារត្ថេរាបទាន ទី ១

(១១) ក្នុងកាលនោះ ព្រះមានព្រះភាគ ព្រះនាមវិបស្សី ជាច្បងក្នុងលោក ជានរាសភៈ ស្តេចចូលទៅកាន់ក្រុងពន្ធុមៈ ជាមួយនឹងពួកភិក្ខុ ៦៨.០០០ អង្គ ។ ខ្ញុំចេញទៅអំពីក្រុង ដើរសំដៅទៅកាន់ទីបចេតិយ បានឃើញព្រះសម្ពុទ្ធ មានធូលីកិលេសទៅប្រាសហើយ ទ្រង់គួរទទួលនូវគ្រឿងបូជា ។ ពួកយក្ខ ៨៤.០០០ រូប តែងបំរើខ្ញុំ ដោយគោរព ដូចពួកទេវតា បំរើព្រះឥន្ទ្រ ។ គ្រានោះ ខ្ញុំចេញអំពីលំនៅ កាន់យកសំពត់ ក្រាបថ្វាយបង្គំដោយសិរសា ហើយថ្វាយសំពត់នោះដល់ព្រះមហេសីសម្ពុទ្ធ (ដោយសេចក្តីជ្រះថ្លាថា) ឱព្រះពុទ្ធទាំងឡាយ ឱព្រះធម៌ទាំងឡាយ ឱសម្បទារបស់ព្រះសាស្តានៃយើង ផែនដីនេះញាប់ញ័រ ដោយអានុភាពរបស់ព្រះពុទ្ធ ។ ខ្ញុំឃើញនូវហេតុ ដ៏អស្ចារ្យ ចំឡែក គួរព្រឺរោមនោះ ក៏ញុំាងចិត្តឲ្យជ្រះថ្លាក្នុងព្រះពុទ្ធ ជាធំជាងសត្វជើងពីរ ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។

សោហំ ចិត្តំ បសាទេត្វា ទុស្សំ ទត្វាន សត្ថុនោ
សរណញ្ច ឧបាគញ្ឆឹ សាមច្ចោ សបរិជ្ជនោ ។
ឯកនវុតេ ឥតោ កប្បេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
ឥតោ បណ្ណរសេ កប្បេ សោឡសាសឹសុ វាហនា
សត្តរតនសម្បន្នា ចក្កវត្តី មហព្វលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា មហាបរិវារកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

មហាបរិវារកត្ថេរស្ស អបទានំ(១) សមត្តំ ។

## ទុតិយំ សុមង្គលត្ថេរាបទានំ

(១៦) អត្ថទស្សី ជិនវរោ លោកជេដ្ឋោ នរាសភោ
វិហារា អភិនិក្ខម្ម តឡាកំ ឧបសង្កមិ ។

១ ម. មហាបរិវារត្ថេរស្សាបទានំ ។



លុះខ្ញុំញុំាងចិត្តឲ្យជ្រះថ្លាហើយ ក៏ថ្វាយសំពត់ដល់ព្រះសាស្តា ខ្ញុំព្រមទាំងអាមាត្យ និងជនជាបរិវារ ក៏បានដល់នូវព្រះពុទ្ធជាទីពឹង ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃពុទ្ធបូជា ។ ក្នុងកប្បទី ១៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១៦ ជាតិ ទ្រង់ព្រះនាមវាហនៈ ជួបផ្តុំ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះមហាបរិវារកត្ថេរមានអាយុ បានសម្តែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មហាបរិវារកត្ថេរាបទាន ។

## សុមង្គលត្ថេរាបទាន ទី ២

(១៦) ព្រះជិនស្រីដ៏ប្រសើរ ព្រះនាមអត្ថទស្សី ជាច្បងក្នុងលោក ជានរាសភៈ ស្តេចចេញអំពីវិហារ ចូលសំដៅទៅកាន់ស្រះ ។

## ទុតិយំ សុមង្គលត្ថេរាបទានំ

ញាត្វា ចិត្តំ ច សត្ថុនោ    ឧត្តរិត្វាន ចីវរំ
អដ្ឋាសិ ភគវា តត្ថ    វិលោកេន្តោ ទិសោទិសំ ។
ភវនំ ឧបគច្ឆាហំ    អទ្ទសំ លោកនាយកំ
ហដ្ឋោ ហដ្ឋេន ចិត្តេន    អប្ផោដេសឹ(១) អហំ តទា ។
សតាំសិរំ ជោតន្តិ    ឧបាសន្តិ កញ្ញាំ(២)
វាទេ គីតេ ច យុត្តាហំ    បញ្ចង្គតុរិយេន ច(៣)
យំ យំ យោនុបបជ្ជាមិ    ទេវត្តំ អថ មានុសំ
សព្វេ សត្តេ អភិភោមិ    វិបុលោ ហោតិ មេ យសោ ។
នមោ តេ បុរិសាជញ្ញ    នមោ តេ បុរិសុត្តម
អត្តានំ តោសយិត្វាន    បរេ តោសេសិ ត្វំ មុនិ ។
បរិគ្គហិត្វា(៤) និសីទិត្វា    ហាសំ កត្វាន សុព្វតោ
ឧបដ្ឋហិត្វាន សម្ពុទ្ធំ    តុសិតំ ឧបបជ្ជហំ ។
សោឡសិតោ កប្បសតេ ទ្វិនវ ឯកចិន្តិតា
សត្តរតនសម្បន្នា    ចក្កវត្តី មហព្ពលា ។

---

១ ម. អប្ផោដេសិ ។ ២ កត្ថចិ បោត្ថកេ ហេត្វាន ទិស្សតិ ។ ៣ ម. បញ្ចង្គិយោនាហំ ។
៤ ម. បរិគ្គហេន ។



## សុមង្គលត្ថេរាបទាន ទី ២

លុះព្រះសម្ពុទ្ធទ្រង់ស្រង់ទឹកសោយរួចហើយ ទ្រង់មានតែចីវរមួយស្ដេចយាងទៀងមក ព្រះមានព្រះភាគ ទ្រង់ឈរក្រឡេកមើលទិសតូចទិសធំ ក្នុងទីនោះ ។ ខ្ញុំចូលទៅក្នុងលំនៅបានឃើញព្រះលោកនាយក កាលនោះខ្ញុំជាអ្នករីករាយ ក៏ពេញដោយចិត្តរីករាយ ។ ទើបខ្ញុំប្រកបក្នុងការកំប្លែង និងប្រគំភ្លេងគ្រឿងប្រគំដោយអង្គ ៥ (ប្រាំ) ចំពោះព្រះសម្ពុទ្ធទ្រង់ផ្ទុំរៀងដូចព្រះអាទិត្យ ភ្លឺប្រាលដូចមាស ខ្ញុំទៅកើតក្នុងកំណើតណា ៗ គឺទេវតា ឬជាមនុស្ស ខ្ញុំតែងត្រេកសន្តោសក្នុងគុណទាំងពួងបាន ខ្ញុំតែងមានយសធំ ៗ បពិត្រព្រះអង្គ ជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការចំពោះព្រះអង្គបពិត្រព្រះអង្គជាបុរសដ៏ខ្ពង់ខ្ពស់ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះមុនី ព្រះអង្គទ្រង់ធ្វើព្រះអង្គឲ្យត្រេកអរ ហើយធ្វើអ្នកដទៃឲ្យត្រេកអរផង ។ ខ្ញុំស្ដីយកំណត់ធ្វើនូវសេចក្ដីរីករាយ ជាអ្នកមានវត្តល្អ បម្រើនូវព្រះសម្ពុទ្ធ ហើយបានទៅកើតក្នុងតុសិត ។ ក្នុងកប្បទី ១.៦០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ ១៤ ជាតិ ព្រះនាមឯកចិន្តិតៈដូចគ្នាទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ទ្រង់មានកម្លាំងច្រើន ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា សុមង្គលោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សុមង្គលត្ថេរស្ស អបទានំ សមត្តំ ។

## តតិយំ សរណាគមនិយត្ថេរាបទានំ

(១៣) ឧភិន្នំ ទេវរាជូនំ សង្គាមោ សមុបដ្ឋិតោ(១)
អហោសិ សមុបព្យូឡ្ហោ មហាឃោសោ អវត្តថ ។
បទុមុត្តរោ លោកវិទូ អាហុតីនំ បដិគ្គហោ
អន្តលិក្ខេ ឋិតោ សត្ថា សំវេជេសិ មហាជនំ ។
សព្វេ ទេវា អត្តមនា និក្ខិត្តកវចាវុធា
សម្ពុទ្ធំ អភិវាទេត្វា ឯកគ្គាសិំសុ តាវទេ ។

១ ម. សមុបដ្ឋិតោ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសុមង្គលត្ថេរមានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សុមង្គលត្ថេរាបទាន ។

## សរណាគមនិយត្ថេរាបទាន ទី ៣

(១៣) សង្គ្រាមរបស់ពួកទេវរាជទាំងពីរព្រះអង្គ កាន់ផ្តើមឡើង មានការចិតតាំងឡើងក្រែម សំឡេងគឹកកងខ្ទាំង ប្រព្រឹត្តទៅ ។ ព្រះលោកវិទូ ព្រះនាមបទុមុត្តរៈ ព្រះអង្គគួរទទួលនូវគ្រឿងបូជា ជាព្រះសាស្តា ទ្រង់ឋិតនៅនាអាកាស ហើយញ៉ាំងមហាជនឲ្យកើតសង្វេគ ។ ទេវតាទាំងអស់ មានចិត្តរីករាយ ក៏ទំលាក់អាវក្រោះនិងអាវុធចុះ ហើយថ្វាយបង្គំព្រះសម្ពុទ្ធ ជាពួកទេពមានចិត្តមូលតែមួយក្នុងវេលានោះ ។

មយ្ហំ សត្ថុប្បមញ្ញាយ ភគវា សកិមុទីរយិ
អនុកម្បកោ លោកវិទូ ធិញ្ញាបេសិ មហាជនំ ។
រជុជ្ជិតេត្តា មនុជោ ឃរំ តាណំ វិហាយយំ
គេន ចិត្តប្បសាទេន អគាយំ ទុបបជ្ជតិ ។
សត្ថុមសីសេ ឆាតោវ តហុតាលោ វិហោវយំ
ធិញ្ញាបេជ បកាំ ចិត្តំ នា ហញ្ញិត្ថ បុនប្បុនំ ។
ទុទ្ធិបំ យក្ខកជ្ជនំ សេណាចំ សមិតា អហុ(១)
សរណាញ្ញ ទុតាគញ្ញំ លោកជេដ្ឋំ សុគានិធំ ។
សញ្ញាបេក្ខាន ផនំ ទុទ្ធរំ បន ទក្ខមា
បេក្ខាមាតោវ នេវហិ បញ្ញាម៉ ទុក្ខកមុខោ ។
បឋមំ សរណំ គញ្ញំ ធិមគិទ្ធុស្ស តាធិនោ
កប្បានំ សតសហស្សំ ទុគ្គតិំ ទុបបជ្ជហំ ។
មហាបុគ្គកិតាមា ច សោឡសាសុំ រជេសកា
កិសកប្បសហស្សម្ហិ ភគោនោ ធញ្ញកត្តិនោ ។

១ ឧ. សោតា សោវត្ថិកា អហុ ។





ព្រះលោកវិទូទ្រង់អនុគ្រោះ ទ្រង់ជ្រាបនូវតម្រិះរបស់ខ្ញុំ ហើយទ្រង់បន្លឺឡើងនូវវាចាដ៏អង់អាច ទ្រង់ញ៉ាំងមហាជនឲ្យរលត់ទុក្ខ (ដោយព្រះពុទ្ធដីកាថា) មនុស្សមានចិត្តប្រះថ្លា ទៀតទៀនតែសក្កមួយ នឹងទៅកើតក្នុងអបាយដោយចិត្តប្រះថ្លានោះ ។ អ្នកទាំងឡាយខ្ញុំញ៉ាំងចិត្តរបស់ខ្លួនឲ្យរលត់ អ្នកទាំងឡាយក៏ទៀតទៀនសក្ករៀងវាឡើយ ដូចជាដីដ៏ប្រសើរដែលទៀនទៀនសក្កច្រើន ក្នុងប្រមាណនៃស្រុកមានរឡើយ ។ ឯពួកសេនារបស់ស្ដេច នៃទៅកាត់ដីសង់គាន់បានស្ងប់ ហើយបានដល់នូវព្រះលោកជេដ្ឋ ជាតាទិបុគ្គលដ៏ប្រសើរជាទីពឹង ។ ព្រះពុទ្ធសម្ពុទ្ធ ទ្រង់ធ្វើប្រជុំជនឲ្យយល់ច្បាស់ ទ្រង់ស្រោចស្រង់ប្រជុំជន ហើយទ្រង់ក្រឡេកមើល នៃព្រះកក្រៅទៅកាន់ទក្ខិណទិស ទៀសចេញទៅតាកពួកនេះ ។ ខ្ញុំបានដល់នូវសរណគមន៍ជាដំបូង ចំពោះព្រះពុទ្ធជាម្ចាស់ជាទីពឹងនៃសត្វដ៏ក៏ជាតាទិបុគ្គល ខ្ញុំមិនដែលទៅកាន់ទុគ្គតិអស់ ១ សែនកប្ប ។ ក្នុងកប្បទី ៣០.០០០ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ ១៦ ជាតិ ទ្រង់ព្រះនាមមហាទុន្ទុភិ ដូចគ្នា ទ្រង់ប្រសើរក្នុងរថ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សរណគមនិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សរណគមនិយត្ថេរស្ស អបទានំ សមត្តំ ។

## បញ្ចមំ ឯកាសនិយត្ថេរាបទានំ

(៦៤) វរុណោ នាម នាមេន ទេវរាជា អហំ តទា
ឧបដ្ឋេសិំ សម្ពុទ្ធំ សយោគ្គពលវាហនោ
និព្វុតេ លោកនាថម្ហិ អត្ថទស្សិជិនុត្តមេ
តុរិយំ សព្វមាទាយ អគមំ ពោធិមុត្តមំ ។
វាទិតេន ច នច្ចេន សម្មតាឡសមាហិតោ
សម្មុខា វិយ សម្ពុទ្ធំ ឧបដ្ឋឹ ពោធិមុត្តមំ ។
ឧបដ្ឋហិត្វា តំ ពោធិំ ធរណីរុហបាទបំ
បល្លង្កំ អាភុជិត្វាន តត្ថ កាលង្កតោ អហំ ។





បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសរណគមនិយត្ថេរមានអាយុ បានសំដែងហើយ នូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សរណគមនិយត្ថេរាបទាន ។

## ឯកាសនិយត្ថេរាបទាន ទី ៥

(៦៤) គ្រានោះ ខ្ញុំកើតជាទេវរាជឈ្មោះវរុណៈ មានយាន ពលពាហនៈ បានចូលទៅបំរើព្រះសម្ពុទ្ធ កាលព្រះអត្ថទស្សី ឧត្តមជាងសត្វជើងពីរ ជាលោកនាថ ទ្រង់បរិនិព្វានហើយ ខ្ញុំនាំយកតូរ្យតន្ត្រីទាំងពួង ទៅកាន់ពោធិព្រឹក្សដ៏ប្រសើរ ។ ខ្ញុំប្រមូលគ្រឿងដេញផ្គំទាំងអស់ ចូលទៅបម្រើដើមពោធិព្រឹក្សដ៏ប្រសើរ ដោយការប្រគំនិងការរាំ ដូចជាបម្រើព្រះសម្ពុទ្ធចំពោះព្រះភក្ត្រ ។ ខ្ញុំបម្រើដើមពោធិព្រឹក្សនោះ ជាឈើដុះលើផែនដី ខ្ញុំអង្គុយផ្គត់ភ្នែនធ្វើកាលកិរិយាក្នុងទីនោះ ។

សោភាកាញ្ចិករំសាយំ   បសន្នោ ពោធិមុត្តមេ
តេន ចិត្តប្បសាទេន   និម្មានំ ឧបបជ្ជហំ ។
សដ្ឋី តុរិយសហស្សានិ   បរិវារេន្តិ មំ សទា
មនុស្សេសុ ច ទេវេសុ   វត្តមានំ ភវាភវេ ។
តិណគ្គី និព្វុតា មយ្ហំ   ភវា សព្វេ សមូហតា
ធារេមិ អន្តិមំ ទេហំ   សម្មាសម្ពុទ្ធសាសនេ ។
សុភាហុ នាម នាមេន   ចតុត្តឹសាសុ ខត្តិយា
សត្តរតនសម្បន្នា   បញ្ចកប្បសតេ ឥតោ ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឯកាសនិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឯកាសនិយត្ថេរស្ស អបទានំ សមត្តំ ។



ឯកាសនិយត្ថេរាបទាន ទី ៤

ខ្ញុំព្រះអង្គនៅកំណើតរបស់ខ្លួន មានចិត្តជ្រះថ្លាចំពោះពោធិព្រឹក្ស ដ៏ប្រសើរ ក៏បាននៅកើតក្នុងឋាននិម្មានរតី ដោយចិត្តជ្រះថ្លា នោះ ។ តូរ្យតន្ត្រី ៦ ម៉ឺន តែងតែហែហមខ្ញុំសព្វកាល ដែល កំពុងប្រព្រឹត្តទៅ ក្នុងពួកមនុស្សនិងទេវតា ក្នុងភពតូចនិង ភពធំ ។ ភ្លើង ៣ ប្រការរបស់ខ្ញុំរលត់ហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំទ្រទ្រង់នូវកាយ ជាទីបំផុត ក្នុងសាសនា របស់ព្រះសម្មាសម្ពុទ្ធ ។ ក្នុងកប្បទី ៥០០ អំពី កប្បនេះ ខ្ញុំបានកើតជាក្សត្រ ៣៤ ជាតិ មានព្រះនាមសុភាហុ ដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកាសនិយត្ថេរមានអាយុ បានសំដែងហើយ នូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឯកាសនិយត្ថេរាបទាន ។

## បញ្ចមំ សុវណ្ណបុប្ផិយត្ថេរាបទានំ

(១៨) វិបស្សី នាម ភគវា លោកជេដ្ឋោ នរាសភោ
និសិន្នោ ជនកាយស្ស ទេសេសិ អមតំ បទំ ។
តស្សាហំ ធម្មំ សុត្វាន ទិបទិន្ទស្ស តាទិនោ
សោវណ្ណបុប្ផានិ ចត្តារិ ពុទ្ធស្ស អភិរោបយិំ ។
សុវណ្ណច្ឆទនំ អាសិ យាវតា បរិសា តទា
ពុទ្ធាភា ច សុវណ្ណាភា អាលោកោ វិបុលោ អហុ ។
ឧទគ្គចិត្តោ សុមនោ វេទជាតោ កតញ្ជលី
វិត្តិសញ្ជននោ តេសំ ទិដ្ឋធម្មសុខាវហោ ។
អាយាចិត្វាន សម្ពុទ្ធំ វន្ទិត្វាន ច សុព្វតំ
បាមោជ្ជំ ជនយិត្វាន សកំ ភវនុបាគមិំ ។
ភវនេ ឧបវិដ្ឋោហំ ពុទ្ធសេដ្ឋំ អនុស្សរិំ
តេន ចិត្តប្បសាទេន តុសិតំ ឧបបជ្ជហំ ។



## សុវណ្ណបុប្ផិយត្ថេរាបទាន ទី ៥

(១៨) ព្រះមានព្រះភាគព្រះនាមវិបស្សី ជាច្បងក្នុងលោក ជានរាសភៈ ទ្រង់គង់សំដែងអមតបទដល់ពួកជន ។ ខ្ញុំស្តាប់ធម៌របស់ព្រះមានព្រះភាគអង្គនោះ ទ្រង់ជាធំជាងសត្វជើងពីរ ជាតាទិបុគ្គល ហើយបានបូជាផ្កាជាវិការៈនៃមាស ៤ ទង ចំពោះព្រះសម្ពុទ្ធ ។ ក្នុងកាលនោះ បរិស័ទមានចំនួនត្រឹមណា ដំបូលជាវិការៈនៃមាស ក៏មានចំនួនត្រឹមនោះ ពន្លឺដ៏ធំទូលាយក៏កើតប្រាកដឡើង ព្រោះរស្មីព្រះពុទ្ធនិងរស្មីមាស ។ ខ្ញុំមានចិត្តខ្ពស់ឯក មានចិត្តរីករាយ មានសេចក្តីត្រេកអរកើតឡើង ខ្ញុំធ្វើអញ្ជលី ញុំាងវិត្តិឲ្យកើតឡើងចំពោះពួកជនទាំងនោះ នាំមកនូវសេចក្តីសុខក្នុងបច្ចុប្បន្ន ទើបថ្វាយបង្គំអារាធនាព្រះសម្ពុទ្ធទ្រង់មានវត្តល្អ ញុំាងព្រាមោជ្យឲ្យកើត ហើយចូលទៅកាន់លំនៅរបស់ខ្លួន ។ លុះខ្ញុំចូលទៅកាន់លំនៅហើយ ក៏រឭកនូវព្រះពុទ្ធដ៏ប្រសើរ ខ្ញុំក៏បានទៅកើតក្នុងឋានតុសិត ដោយសេចក្តីជ្រះថ្លានោះឯង ។

ឯកនវុតេ ឥតោ កប្បេ យំ ពុទ្ធមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
សោឡសាសឹសុ រាជានោ នេមិសម្មតនាមកា
តេសដ្ឋិសេ ឥតោ កប្បេ ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សុវណ្ណបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សុវណ្ណបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

## ឆដ្ឋំ ចិតកបូជកត្ថេរាបទានំ

(១៦) វសាមិ រាជាយតនេ សាមច្ចោ សបរិជ្ជនោ
បរិនិព្វុតេ ភគវតិ សិខិនោ លោកពន្ធុនោ ។
បសន្នចិត្តោ សុមនោ ចិតកំ អគមាសហំ
តូរិយំ តត្ថ វាទេត្វា គន្ធមាលំ សមោកិរឹ ។



ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាព្រះពុទ្ធ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៦៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេច ១៦ ជាតិ ព្រះនាមនេមិសម្មតៈ ដូចគ្នា ជាស្ដេចចក្រពត្តិ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសុវណ្ណបុប្ផិយត្ថេរមានអាយុ បានសំដែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សុវណ្ណបុប្ផិយត្ថេរាបទាន ។

## ចិតកបូជកត្ថេរាបទាន ទី ៦

(១៦) ខ្ញុំនឹងអាមាត្យព្រមទាំងជនជាបរិវារ នៅក្នុងរាជាយតនៈ (ដើមកែស) កាលព្រះមានព្រះភាគ ទ្រង់បរិនិព្វាន ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ ដើរទៅកាន់ជើងថ្ករបស់ព្រះសិខី ជាលោកពន្ធុ ខ្ញុំប្រគំតូរ្យតន្ត្រី ហើយបានរោយរាយគ្រឿងក្រអូប និងផ្កាកម្រង ក្នុងទីនោះ ។

ចិតកម្ហិ បូជំ កត្វាន វន្ទិត្វា ចិតកំ អហំ
បសន្នចិត្តោ សុមនោ សកំ ភវនុបាគមឹ ។
ភវេ ឧបវិដ្ឋោហំ ចិតកបូជំ អនុស្សរឹ
តេន កម្មេន ទ្វិបទិន្ទ លោកជេដ្ឋ នរាសភ ។
អនុភោត្វាន សម្បត្តឹ ទេវេសុ មានុសេសុ ច
បត្តោម្ហិ អចលំ ឋានំ ហិត្វា ជយបរាជយំ ។
ឯកត្តឹសេ ឥតោ កប្បេ យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ចិតកបូជាយិទំ ផលំ ។
ឯកូនត្តឹសេ កប្បម្ហិ ឥតោ សោឡសរាជានោ
ឧគ្គតា នាម នាមេន ចក្កវត្តី មហព្វលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ចិតកបូជកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ចិតកបូជកត្ថេរស្ស អបទានំ សមត្តំ ។



ខ្ញុំបូជាជើងថ្ករហើយ ថ្វាយបង្គំជើងថ្ករ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ ទើបចូលទៅកាន់លំនៅរបស់ខ្លួន ។ លុះចូលទៅក្នុងលំនៅហើយ ក៏រឭកនូវការបូជាជើងថ្ករ បពិត្រព្រះអង្គជាធំជាងសត្វជើងពីរ ជាច្បងក្នុងលោក ជានរាសភៈ ខ្ញុំសោយសម្បត្តិក្នុងទេវលោកនិងមនុស្សលោក លះបង់នូវការឈ្នះនិងការចាញ់ ហើយបានដល់នូវអចលដ្ឋាន ដោយកុសលកម្មនោះ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាជើងថ្ករ ។ ក្នុងកប្បទី ២៩ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ ១៦ ជាតិ ព្រះនាមឧគ្គតៈ ដ៏មានពលច្រើនមានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះចិតកបូជកត្ថេរមានអាយុ បានសម្ដែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ចិតកបូជកត្ថេរាបទាន ។

## សត្តមំ ពុទ្ធសញ្ញកត្ថេរាបទានំ

(១៧) យទា វិបស្សី លោកគ្គោ អាយុសង្ខារមោស្សជិ
បថវី សម្បកម្បិត្ថ មេទនីជលមេខលា ។
ឱតតំ វិតតំ មយ្ហំ សុចិ ចិត្តំ បបញ្ចកំ(១)
ភវនំ បកម្បិត្ថ ពុទ្ធស្ស អាយុសង្ខយេ ។
តាសោ មយ្ហំ សមុប្បន្នោ ភវនេ សម្បកម្បិតេ
ឧប្បាទោ នុ កិំ និមិត្តាយ អាលោកោ វិបុលោ មហា ។
វេស្សវណោ ឥធាគម្ម និព្វាបេសិ មហាជនំ
បាណភូតំ ភយំ នត្ថិ ឯកគ្គា ហោថ សំវុតា ។
អហោ ពុទ្ធោ អហោ ធម្មោ អហោ នោ សត្ថុសម្បទា
យស្មិំ ឧប្បជ្ជមានស្មិំ បថវី សម្បកម្បតិ ។
ពុទ្ធានុភាវំ កិត្តេត្វា កប្បំ សគ្គម្ហិ មោទហំ
អវសេសេសុ កប្បេសុ កុសលំ ការិតំ(២) មយា ។

១ ឧ. ឧចិតំ វិតតំ មយ្ហំ សុចិត្តបសិលកំ ។ ២ ម. ការិតំ ។



## ពុទ្ធសញ្ញកត្ថេរាបទាន ទី ៧

(១៧) ព្រះវិបស្សីសម្ពុទ្ធ ជាកំពូលក្នុងលោក ទ្រង់ដាក់អាយុសង្ខារ ក្នុងកាលណា ផែនដីដ៏មានសមុទ្រក៏កក្រើកញាប់ញ័រ ក្នុងកាលនោះ ។ សូម្បីលំនៅរបស់ខ្ញុំដ៏វិចិត្រល្អទូលាយ ប្រាកដដូចផ្កាកំពុះ ឃ្លាតចេញ កក្រើកញាប់ញ័រ ក្នុងកាលជាទីអស់ទៅ នៃព្រះជន្មាយុរបស់ព្រះពុទ្ធ ។ កាលដែលលំនៅនៃខ្ញុំញាប់ញ័រហើយ ខ្ញុំក៏មានសេចក្តីតក់ស្លុតកើតឡើងថា ពន្លឺដ៏ធំបានកើតឡើងហើយ ដើម្បីអ្វីហ្ន៎ ឬក៏ព្រះបាទវេស្សវណ្ណស្តេចមកក្នុងទីនេះ ញ៉ាំងមហាជនឲ្យរលត់ទុក្ខ ទៀត ភ័យដែលកើតដល់សត្វមិនមានទេ ពួកអ្នកឯងត្រូវតែមានសេចក្តីគោរព ត្រូវមានចិត្តនឹងតែមួយ ឱព្រះពុទ្ធ ឱព្រះធម៌ ឱសម្បទា របស់ព្រះសាស្តានៃយើង ព្រោះកាលដែលព្រះអង្គត្រាស់ឡើង (ក្នុងលោក) មហាប្រថពីក៏កក្រើក ញាប់ញ័រដែរ ។ ខ្ញុំសរសើរ នូវពុទ្ធានុភាព (យ៉ាងនេះ) ក៏បានរីករាយ ក្នុងឋានសួគ៌ អស់មួយកប្ប ដែលខ្ញុំបានធ្វើកុសលកម្ម ក្នុងកប្បដ៏សេសទាំងឡាយ ។

ឯកាទសេ ឥតោ កប្បេ យំ សញ្ញមលភឹ តទា
ទុគ្គតិំ នាភិជានាមិ ពុទ្ធសញ្ញាយិទំ ផលំ ។
ឥតោ ចុទ្ទសកប្បម្ហិ រាជា អាសឹ បតាបវា
សមិតោ នាម នាមេន ចក្កវត្តិ មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ពុទ្ធសញ្ញកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ពុទ្ធសញ្ញកត្ថេរស្ស អបទានំ សមត្តំ ។

## អដ្ឋមំ មគ្គសញ្ញកត្ថេរាបទានំ

(១៨) បទុមុត្តរពុទ្ធស្ស សាវកា វនចារិនោ
វិប្បនដ្ឋា ព្រហារញ្ញេ អន្ធាវ អនុសុយ្យរេ ។





ក្នុងកប្បទី ៨១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានខ្ជាប់សេចក្តីសំគាល់ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសេចក្តីសំគាល់ក្នុងព្រះពុទ្ធ ។ ក្នុងកប្បទី ១៤ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ មានព្រះនាមសមិតកជ ប្រទីមានព្យាយាម មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះពុទ្ធសញ្ញកត្ថេរមានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ពុទ្ធសញ្ញកត្ថេរាបទាន ។

## មគ្គសញ្ញកត្ថេរាបទាន ទី ៨

(១៨) ពួកសាវ័ករបស់ព្រះពុទ្ធ ព្រះនាមបទុមុត្តរៈ ជាអ្នកត្រាច់ទៅក្នុងព្រៃ វង្វេងក្នុងព្រៃធំ ដូចជាមនុស្សខ្វាក់ ។

អដ្ឋមំ មគ្គសញ្ញកត្ថេរាបទានំ

អនុស្សរិត្វា សម្ពុទ្ធំ  បទុមុត្តរនាយកំ
តស្ស តេ មុនិនោ បុត្តា  វិប្បនដ្ឋា មហាវនេ ។
ឃរតោ ឱរុហិត្វាន  អាគមិំ ភិក្ខុសន្តិកេ
តេសំ មគ្គញ្ច អាចិក្ខិំ  ភោជនញ្ច អទាសហំ ។
តេន កម្មេន ទ្វិបទិន្ទ  លោកជេដ្ឋ នរាសភ
ជាតិយា សត្តវស្សេន  អរហត្តំ អបាបុណិំ ។
សចក្ខុ នាម នាមេន  ទ្វាទស ចក្កវត្តិនោ
សត្តរតនសម្បន្នា  បញ្ចកប្បសតេ ឥតោ ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា មគ្គសញ្ញកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

មគ្គសញ្ញកត្ថេរស្ស អបទានំ សមត្តំ ។



មគ្គសញ្ញកត្ថេរាបទាន ទី ៨

ពួកសាវ័កទាំងនោះ ជាបុត្ររបស់ព្រះមុនីនោះ វង្វេងក្នុងព្រៃធំ ក៏រឭកនូវព្រះសម្ពុទ្ធបទុមុត្តរៈជានាយក ។ ខ្ញុំក៏ចុះចាកលំនៅ ដើរទៅកាន់សំណាក់របស់ភិក្ខុ ហើយប្រាប់ផ្លូវផង ប្រគេនភោជនផង ដល់សាវ័កទាំងនោះ ។ បពិត្រព្រះអង្គជាធំជាងសត្វជើងពីរ ទ្រង់ជាច្បងក្នុងលោក ជានរាសភៈ ខ្ញុំមានអាយុ ៧ ឆ្នាំអំពីកំណើត ក៏បានដល់នូវអរហត្ត ដោយកុសលកម្មនោះ ។ ក្នុងកប្បទី ៥០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១២ ជាតិ ព្រះនាមសចក្ខុដ៏ឧត្តម ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះមគ្គសញ្ញកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មគ្គសញ្ញកត្ថេរាបទាន ។

## នវមំ បុប្ផុបដ្ឋានសញ្ញកត្ថេរាបទានំ

(១៩) អត្ថទស្សិម្ហិ សុគតេ និព្វុតេ សមនន្តរា
យក្ខយោនឹ ឧបបជ្ជឹ យសំ បត្តោ តហំ តទា ។
ទុល្លទ្ធំ វត មេ អាសិ ទុប្បភាតំ ទុរុដ្ឋិតំ
យំ មេ ភោគេ វិជ្ជមានេ បរិនិព្វាយិ ចក្ខុមា ។
មម សង្កប្បមញ្ញាយ សាគរោ នាម សាវកោ
មមុទ្ធរិតុកាមោ សោ អាគញ្ឆិ មម សន្តិកេ ។
កឹ នុ សោចសិ មា ភាយិ ចរ ធម្មំ សុមេធស
អនុប្បទិន្នា ពុទ្ធេន សព្វេសំ វីជសម្បទា ។
យោ ច បូជេយ្យ សម្ពុទ្ធំ តិដ្ឋន្តំ លោកនាយកំ
ធាតុំ សាសបមត្តម្បិ និព្វុតស្សាបិ បូជយេ ។
សមេ ចិត្តេ បសាទម្ហិ សមំ បុញ្ញំ មហគ្គតំ
តស្មា ថូបំ ករិត្វាន បូជេហិ ជិនធាតុយោ ។





## បុប្ផុបដ្ឋានសញ្ញកត្ថេរាបទាន ទី ៩

(១៩) កាលព្រះសុគតព្រះនាមអត្ថទស្សី ទ្រង់បរិនិព្វាន ខ្ញុំបានទៅកើតក្នុងកំណើតយក្ខក្នុងលំដាប់ស្មើគ្នា កាលនោះ ខ្ញុំបានដល់នូវយស ។ ខ្ញុំគិតថា អត្តភាពជាមនុស្ស គាត្មាអញបានមិនល្អ ភ្ញាក់ស្វាងមិនល្អ តាំងឡើងមិនល្អ ព្រោះថា កាលដែលភោគៈ របស់គាត្មាអញនៅមាន ព្រះសម្ពុទ្ធមានចក្ខុ ទ្រង់បរិនិព្វាន ។ សាវ័កឈ្មោះសាគរៈ ជ្រាបច្បាស់នូវតម្រិះ របស់ខ្ញុំ លោកប្រាថ្នានឹងស្រង់ខ្ញុំ ទើបចូលមកក្នុងសំណាក់ខ្ញុំ (ហើយពោលថា) នែបុរសអ្នកមានប្រាជ្ញាល្អ អ្នកយំសោកពីរឿងអ្វី អ្នកកុំខ្លាចឡើយ ចូរប្រព្រឹត្តធម៌ចុះ ការបរិបូណ៌ ដោយពូជគឺកុសល របស់សត្វទាំងអស់ ព្រះពុទ្ធជាម្ចាស់បានប្រគល់ឲ្យហើយ ។ បុគ្គលណាបូជាព្រះសម្ពុទ្ធជាលោកនាយក ដែលទ្រង់គង់ព្រះជន្មនៅក្តី បូជាព្រះសារីរិកធាតុ ប្រមាណប៉ុនគ្រាប់ស្ពៃ របស់ព្រះសម្ពុទ្ធដែលបរិនិព្វានហើយក្តី កាលបើចិត្តមានសេចក្តីជ្រះថ្លាស្មើ បុណ្យជាមហគ្គតកុសលស្មើគ្នា (គឺទាំងពីរនេះដល់បុគ្គលនោះ) ហេតុនោះ អ្នកចូរធ្វើព្រះស្តូប បញ្ចុះព្រះសារីរិកធាតុ របស់ព្រះជិនស្រីចុះ ។

សាសនស្ស អហោ សុត្វា    ពុទ្ធដ្ឋំ អកាសិហំ
បញ្ច វស្ស សតានី    ទុតិយោ ជនុត្តមំ ។
តេន កម្មេន ជិនជិន្នុ    លោកជេដ្ឋ នរាសភ
សម្បត្តិ អនុភោត្វាន    អរហត្តំ អបាបុណិំ ។
ទ្វិបញ្ញាសេ ចត្តាហេ    សត្តកប្បសតេ ឥតោ
សត្តរតនសម្បន្នា    ចក្កវត្តិ មហព្វលា ។
បដិសម្ភិទា ចតស្សោ    វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បទុមច្ឆាទនសញ្ញកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បទុមច្ឆាទនសញ្ញកត្ថេរស្ស អបទានំ សមត្តំ ។

## ទសមំ ជាតិបុប្ផិកត្ថេរាបទានំ

(៦០) ជាយន្តស្ស វិបស្សិស្ស អាលោកោ វិបុលោ អហុ
ពថវី ច បកម្បិត្ថ    សសាគរា សបព្វតា ។
នេមិត្តា ច វិយាកំសុ    ពុទ្ធោ លោកេ ភវិស្សតិ
អគ្គោ ច សព្វសត្តានំ    ជនតំ ឧទ្ធរិស្សតិ ។





ខ្ញុំបានស្តាប់ព្រះសាសនរត្នហើយ ខ្ញុំកសាងនូវពុទ្ធស្តូប ថែទាំព្រះស្តូបដ៏ប្រសើររបស់ព្រះមុនី អស់ ៥ ឆ្នាំ ។ បពិត្រព្រះអង្គជាធំជាងសត្វជើងពីរ ជាច្បងក្នុងលោក ជានរាសភៈ ខ្ញុំសោយសម្បត្តិ បានដល់នូវអរហត្ត ដោយកុសលកម្មនោះ ។ ក្នុងកប្បទី ៧០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៦ ជាតិ ទ្រង់មានប្រាជ្ញាក្រាស់ជុំផែនដី បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបទុមច្ឆាទនសញ្ញកត្ថេរមានអាយុ បានសម្តែងហើយ នូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បទុមច្ឆាទនសញ្ញកត្ថេរាបទាន ។

## ជាតិបុប្ផិកត្ថេរាបទាន ទី ១០

(៦០) កាលព្រះវិបស្សីទ្រង់ប្រសូត ពន្លឺដ៏ធំក៏កើតឡើង ទាំងផែនដី សមុទ្រនិងភ្នំ ក៏ញាប់ញ័រ ។ ពួកជនអ្នកទាយនិមិត្ត (ហោរ) បានទាយថា ព្រះសម្ពុទ្ធនឹងកើតឡើងក្នុងលោក ទ្រង់ជាកំពូលសព្វសត្វ នឹងស្រង់ឡើងនូវប្រជុំជន ។

នេមិត្តានំ សុណិត្វាន   ជាតិព្វំ អកាសហំ
បដិសា បូជតា ឥត្ថិ   យាចិសា ជាតិព្វជតា ។
សំហរិត្វាន កុសលំ   សកំ ចិត្តំ បសាទយិំ
ជាតិព្វំ ការិត្វាន   តត្ថ កាលំ កតោ អហំ ។
យំ យំ យោនុបបជ្ជាមិ   ទេវត្តំ អថ មានុសំ
សព្វេ សត្តេ អតិភោមិ(១)   ជាតិព្វជាយិនំ ផលំ ។
ជាតិយោ មំ ឧបដ្ឋន្តិ   មម ចិត្តវសានុគា
ន តេ សក្កោន្តិ កោបេតុំ   ជាតិព្វជាយិនំ ផលំ
ឯកនវុតេ ឥតោ កប្បេ   យំ បូជមការិំ តទា
ទុគ្គតឹ នាភិជានាមិ   ជាតិព្វជាយិនំ ផលំ ។
សុបារិចរិយា នាម   ចតុត្តិំស ជនាធិបា
ឥតោ តតិយកប្បម្ហិ   ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

១ ឱ. អតិភោមិ ។



ខ្ញុំបានឮទំនាយពួកហោរាហើយ ក៏ធ្វើនូវជាតិបុប្ផ (បុប្ផកម្មដ៏ប្រសើរ) ជាតិបុប្ផនោះ ផលមានបុប្ផណាប្រៀបផ្ទឹមឡើយ ។ ខ្ញុំប្រមូលកុសល ធ្វើចិត្តរបស់ខ្លួនឲ្យជ្រះថ្លា លុះខ្ញុំធ្វើជាតិបុប្ផហើយ ក៏ធ្វើមរណកាលក្នុងទីនោះ ។ ខ្ញុំចូលទៅកើតក្នុងកំណើតណា ៗ ទោះបីជាទេវតា ឬជាមនុស្ស តែងគ្របសង្កត់ពួកសត្វទាំងអស់ នេះជាផលនៃជាតិបុប្ផ ។ ពួកញាតិ តែងចាំបំរើខ្ញុំ ជាទីជនដ៏សេស ក៏ប្រព្រឹត្តតាមចិត្តរបស់ខ្ញុំ ជនទាំងនោះមិនអាចនឹងធ្វើខ្ញុំឲ្យក្រោធឡើយ នេះជាផលនៃជាតិបុប្ផ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានបូជាបុប្ផ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃជាតិបុប្ផ ។ ក្នុងកប្បទី ៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៣៤ ជាតិ ព្រះនាមសុបារិចរិយៈ ដូចគ្នា ទ្រង់ជាធំជាងជន មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

ប្រែ

ឥត្ថំ សុទំ អាយស្មា ជាតិបុប្ផកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ជាតិបុប្ផិកត្ថេរស្ស អបទានំ សមត្តំ ។

## ឧទ្ទានំ

បរិវារសុមង្គល្យា សរណាសនបុប្ផិកា
ចិតកបូជី ពុទ្ធសញ្ញី មគ្គុបដ្ឋានជាតិកា(១)
គាថាយោ នវុតិ វុត្តា គណិតាយោ វិភាវិភីតិ ។

មហាបរិវារវគ្គោ ទុតិយោ ។

---

១ ម. បរិវារសុមង្គលា សរណាគមនឯកាសនិ សុវណ្ណបុប្ផិចិតកបូជា ពុទ្ធសញ្ញី មគ្គដ្ឋាន. ជាតិកាបិ ទិសន្តិ ។



ប្រែ

បានឮថា ព្រះជាតិបុប្ផកត្ថេរមានអាយុ បានសំដែងហើយ នូវគាថា ទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ជាតិបុប្ផកត្ថេរាបទាន ។

## ឧទ្ទាន

មហាបរិវារត្ថេរាបទាន ១ សុមង្គលត្ថេរាបទាន ១ សរណ-គមនិយត្ថេរាបទាន ១ ឯកាសនិយត្ថេរាបទាន ១ សុវណ្ណ-បុប្ផិយត្ថេរាបទាន ១ ចិតកបូជកត្ថេរាបទាន ១ ពុទ្ធសញ្ញកត្ថេ-រាបទាន ១ មគ្គសញ្ញកត្ថេរាបទាន ១ បច្ចុបដ្ឋានសញ្ញកត្ថេរាប-ទាន ១ ជាតិបុប្ផកត្ថេរាបទាន ១ ឯគាថា ៩០ អស់ ពួកអ្នក ប្រាជ្ញបានពោលទុកច្បាស់ហើយ ។

ចប់ មហាបរិវារវគ្គ ទី ២ ។

# តេរសមោ សេរេយ្យវគ្គោ

## បឋមំ សេរេយ្យកត្ថេរាបទានំ

(៦១) អជ្ឈាយកោ មន្តធរោ តិណ្ណំ វេទាន បារគូ
អព្ភោកាសេ(១) ឋិតោ សន្តោ អទ្ទសំ លោកនាយកំ
សីហំ យថា វនចរំ ព្យគ្ឃរាជំវ និត្តសំ
តិធប្បភិន្នំ មាតង្គំ កុញ្ជរំវ មហេសិនំ ។
សេរេយ្យកំ គហេត្វាន អាកាសេ ឧក្ខិបឹ អហំ
ពុទ្ធស្ស អានុភាវេន បរិវារេន្តិ សព្វសោ ។
អធិដ្ឋហិ មហាវីរោ សព្វញ្ញូ លោកនាយកោ
សមន្តា បុប្ផឆទនំ ឱកិរឹសុ នរាសភំ ។
តតោ សា បុប្ផកញ្ចុកា អន្តោវណ្ដា ពហិមុខា
សត្តាហំ ឆទនំ កត្វា តតោ អន្តរធាយថ ។
តញ្ច អច្ឆរិយំ ទិស្វា អព្ភុតំ លោមហំសនំ
ពុទ្ធេ ចិត្តំ បសាទេសឹ សុគតេ លោកនាយកេ ។
តេន ចិត្តប្បសាទេន សុក្កមូលេន ចោទិតោ

១ ម. អព្ភោកាសេ ។

# សេរេយ្យវគ្គ ទី ១៣

## សេរេយ្យកត្ថេរាបទាន ទី ១

(៦១) ខ្ញុំជាអ្នកស្វាធ្យាយមន្ត អ្នកចងចាំមន្ត អ្នកដល់នូវត្រើយនៃវេទទាំង ៣ កំពុងឈរនៅក្នុងទីវាល បានឃើញព្រះលោកនាយក ទ្រង់ស្វែងរកនូវគុណធំ ដូចជារាជសីហ៍ត្រាច់ទៅក្នុងព្រៃ ឬដូចស្តេចខ្លាដែលមិនតក់ស្លុត ឬដូចដំរីឈ្មោះមាតង្គៈ ដែលកំពុងចុះប្រេង ៣ កន្លែង ។ ខ្ញុំកាន់យកផ្កាសេរេយ្យៈ បោះឡើងទៅអាកាស ផ្កាទាំងនោះ ក៏ព័ទ្ធជុំវិញដោយអានុភាពព្រះពុទ្ធ ។ ព្រះសព្វញ្ញូជាលោកនាយក មានព្យាយាមធំ ទ្រង់អធិដ្ឋាន ផ្កាទាំងឡាយខ្ចរខ្ចាយជាផ្ទាំងផ្កាជុំវិញនូវជនអគ្គ ដ៏ប្រសើរជាងនរៈ ។ សំពត់ផ្កានោះ មានទងនៅខាងក្នុង មានមុខចេញក្រៅ ធ្វើជាម្លប់ប្រក់អស់ ៧ ថ្ងៃ តពីនោះមក ក៏បាត់អស់ទៅ ។ លុះខ្ញុំបានឃើញហេតុជាអស្ចារ្យចម្លែក គួរព្រឺរោមនោះ បានញុំាងចិត្តឲ្យជ្រះថ្លាក្នុងព្រះពុទ្ធ ជាព្រះសុគត លោកនាយក ។

កប្បានំ សតសហស្សំ ទុគ្គតឹ នុបបជ្ជហំ ។
បណ្ណាសសហស្សម្ហិ កប្បានំ បញ្ចវីសតេ
វិលាមាលាសនាមា ច(១) ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សោរេយ្យកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សោរេយ្យកត្ថេរស្ស អបទានំ សមត្តំ ។

## ទុតិយំ បុប្ផថូបិយត្ថេរាបទានំ

(៦៦) ហិមវន្តស្ស អវិទូរេ កុក្កុរោ នាម បព្វតោ
វេមជ្ឈេ តស្ស វសតិ ព្រាហ្មណោ មន្តបារគូ ។
បញ្ច សិស្សសហស្សានិ បរិវារេន្តិ មំ សទា
បុព្វុដ្ឋាយី ច តេ សិស្សា មន្តេសុ ច វិសារទា ។

---
១ ឱ. វិមលាសនាមា ច ។





ខ្ញុំត្រេកអរក្នុងពុទ្ធសាសនា មិនដែលទៅកើត ក្នុងទុគ្គតិ អស់មួយសែនកប្ប ដោយចិត្តជ្រះថ្លានោះ ។ ក្នុងកប្បទី ១៥.០២៥ ខ្ញុំបានកើតជាស្ដេចចក្រពត្តិច្រើនជាតិ ព្រះនាម វិលាមាលាសនៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ពាក្យសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសោរេយ្យកត្ថេរមានអាយុ បានសម្ដែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សោរេយ្យកត្ថេរាបទាន ។

## បុប្ផថូបិយត្ថេរាបទាន ទី ២

[៦៦] មានភ្នំមួយ ឈ្មោះកុក្កុរៈ នៅជិតព្រៃហិមពាន្ត ព្រាហ្មណ៍អ្នកដល់នូវត្រើយនៃមន្ត (គឺខ្ញុំនេះឯង) រមែងអាស្រ័យនៅកណ្ដាលភ្នំនោះ ។ មានសិស្ស ៥.០០០ នាក់ ចោមរោមខ្ញុំសព្វ ៗ កាល សិស្សទាំងនោះ ក្រោកឡើងមុនផង ជាអ្នកក្លៀវក្លា ក្នុងមន្តទាំងឡាយផង (ប្រាកដគ្នាថា)

ពុទ្ធោ លោកេ សមុប្បន្នោ តំ វិជានថ ភោ ភវំ

អសីតិ ព្យញ្ជនានស្ស ពត្តឹស វរលក្ខណា ។

ព្យាមប្បភោ ជិនវរោ អាទិច្ចោវ វិរោចតិ

សិស្សានំ វចនំ សុត្វា ព្រាហ្មណោ មន្តបារគូ ។

អស្សមា អភិនិក្ខម្ម ទិសំ បុច្ឆតិ ព្រាហ្មណោ

យម្ហិ ទេសេ មហាវីរោ វសតិ លោកនាយកោ ។

តាហំ ទិស្វា ធមស្សិរិ ជិនំ អប្បដិបុគ្គលំ

ឧទគ្គចិត្តោ សុមនោ បូជេសិំ តំ តថាគតំ ។

ឯថ សិស្សា គមិស្សាម ទក្ខិស្សាម តថាគតំ

វន្ទិត្វា សត្ថុនោ បាទេ សោស្សាម ជិនសាសនំ ។

ឯកាហំ អភិនិក្ខម្ម ព្យាធិំ បដិលភី អហំ

ព្យាធិតោ បីឡិតោ សន្តោ សាលន្តោ សយិំ តទា ។



ព្រះសម្ពុទ្ធត្រាស់ហើយក្នុងលោក អ្នកទាំងឡាយចូរដឹងច្បាស់ នូវព្រះសម្ពុទ្ធនោះ ថាជាបុគ្គលប្រសើររបស់យើងទាំងឡាយ ព្រះសម្ពុទ្ធនោះ ទ្រង់មានព្យញ្ជនៈ ៨០ មានលក្ខណៈដ៏ប្រសើរ ៣២ ព្រះជិនស្រីដ៏ប្រសើរ មានរស្មីមួយព្យាម តែងរុងរឿងដូចព្រះអាទិត្យ ។ ព្រាហ្មណ៍អ្នកដល់នូវត្រើយនៃមន្ត គឺខ្ញុំនេះឯង លុះឮពាក្យរបស់សិស្សហើយ ក៏ចេញអំពីអាស្រម សួរកទិសថា ព្រះលោកនាយក មានព្យាយាមធំ ស្ដេចគង់នៅ ក្នុងប្រទេសណា ។ លុះខ្ញុំបានឃើញព្រះជិនស្រីអង្គនោះ មិនមានបុគ្គលប្រៀបផ្ទឹមហើយ ក៏បាននមស្ការ ខ្ញុំមានចិត្តអណ្ដែតឡើង មានចិត្តរីករាយ បូជាចំពោះព្រះតថាគតនោះ ។ ខ្ញុំបបួលសិស្សថា នែសិស្សទាំងឡាយ អ្នកចូរមក ពួកយើង នឹងទៅគាល់ព្រះតថាគត យើងនឹងថ្វាយបង្គំព្រះបាទទាំងទ្វេរបស់ព្រះសាស្ដា ហើយស្ដាប់នូវពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រី ។ ខ្ញុំតែម្នាក់ឯង ចេញទៅ ខ្ញុំបានជម្ងឺ ត្រូវជម្ងឺបៀតបៀន ក៏ដើរទៅប្រុងនឹងដេក ក្រោមដើមឈើ ។

សព្វេ សិស្សេ សមានេត្វា អបុច្ឆិំ តេ តថាគតំ
កីទិសំ លោកនាថស្ស គុណំ បរមពុទ្ធិនោ ។
តេ មេ បុដ្ឋា ព្យាការិំសុ(១) យថា ទស្សាវិនោ តថា
សក្កច្ចំ ពុទ្ធសេដ្ឋំ តំ ទស្សេសុំ មម សម្មុខា ។
តេសាហំ វចនំ សុត្វា សកំ ចិត្តំ បសាទយឹ
បុប្ផេហិ ថូបំ ការិត្វាន តត្ថ កាលំ កតោ អហំ ។
តេ មេ សរីរំ ឈាបេត្វា អគមុំ ពុទ្ធសន្តិកេ
អញ្ជលឹ បគ្គហេត្វាន សត្ថារំ អភិវាទយុំ ។
បុប្ផេហិ ថូបំ ការិត្វាន សុគតស្ស មហេសិនោ
កប្បានំ សតសហស្សំ ទុគ្គតឹ នុបបជ្ជហំ ។
ចត្តាឡីសសហស្សម្ហិ កប្បេ សោឡស ខត្តិយា
នាមេនគ្គិសមា នាម ចក្កវត្តី មហព្ពលា ។
វីសកប្បសហស្សម្ហិ ឃតាសនោ ចក្កវត្តិនោ
ឃតាសនសមា នាម អដ្ឋតឹស មហីបតី ។

---

១ ម. តេ មេ បុដ្ឋា វិយាកំសុ ។





ខ្ញុំប្រជុំពួកសិស្សទាំងអស់ ហើយបានសួរអំពីព្រះតថាគត និង សិស្សទាំងនោះថា គុណរបស់ព្រះលោកនាថ ប្រសើរមាន ប្រាជ្ញាដ៏ក្រៃលែង តើដូចម្តេច ។ ពួកសិស្សទាំងនោះដែល ខ្ញុំសួរហើយ ក៏ពួកគេរៀបរាប់អំពីព្រះពុទ្ធដ៏ប្រសើរនោះ ដោយ គោរពចំពោះមុខខ្ញុំ តាមដែលគេបានឃើញ ។ លុះខ្ញុំបាន ស្តាប់ពាក្យរបស់ពួកសិស្សទាំងនោះហើយ ក៏ញុំាងចិត្តរបស់ ខ្លួនឲ្យជ្រះថ្លា បានសាងព្រះស្តូបដោយផ្កាទាំងឡាយ ហើយ ក៏ធ្វើកាលកិរិយាក្នុងទីនោះ ។ ពួកសិស្សទាំងនោះ ធ្វើសរីរៈ របស់ខ្ញុំរួចហើយ នាំគ្នាទៅក្នុងសំណាក់របស់ព្រះសម្ពុទ្ធ ធ្វើ អញ្ជលីថ្វាយបង្គំព្រះសាស្តា ។ ខ្ញុំកសាងព្រះស្តូបដោយផ្កា ទាំងឡាយ ថ្វាយព្រះសុគតមហេសី ខ្ញុំមិនដែលទៅកាន់ទុគ្គតិ អស់មួយសែនកប្បដោយកុសលនេះ ។ ក្នុងកប្បទី ៤០.០០០ ខ្ញុំបានកើតជាក្សត្រ ១៦ ជាតិ ព្រះនាមអគ្គិសមៈ ដូចគ្នា ដោយព្រះនាម ជាស្តេចចក្រពត្តិ ប្រសើរមានកម្លាំងច្រើន ។ ក្នុងកប្បទី ២០.០០០ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៣៨ ជាតិ ជាម្ចាស់ផែនដី ព្រះនាមឃតាសនសមៈ ដូចគ្នា ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ។
ឥត្ថំ សុទំ អាយស្មា បុប្ផត្ថូបិយោ ថេរោ ឥមា
គាថាយោ អភាសិត្ថាតិ ។

បុប្ផត្ថូបិយត្ថេរស្ស អបទានំ សមត្តំ ។

## តតិយំ បាយាសទាយកត្ថេរាបទានំ

(៦៣) សុវណ្ណវណ្ណំ សម្ពុទ្ធំ ទ្វត្តិំសវរលក្ខណំ
បវនា អភិនិក្ខន្តំ ភិក្ខុសង្ឃបុរក្ខតំ ។
មហច្ចា កំសបាតិយា វឌ្ឍេត្វា បាយាសំ អហំ
អាហុតិំ យិដ្ឋុកាមោ សោ អភរឹ សព្ពលឹ អហំ ។
ភគវា តម្ហិ សមយេ លោកជេដ្ឋោ នរាសភោ
ចង្កមំ សុសមារូឡ្ហោ អម្ពរេ អនិលាយនេ ។
តញ្ច អច្ឆរិយំ ទិស្វា អព្ភុតំ លោមហំសនំ
ឋបយិត្វា កំសបាតឹ វិបស្សឹ អភិវាទយឹ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបុប្ផត្ថូបិយត្ថេរមានអាយុ បានសម្តែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បុប្ផត្ថូបិយត្ថេរាបទាន ។

## បាយាសទាយកត្ថេរាបទាន ទី៣

(៦៣) ព្រះសម្ពុទ្ធមានវណ្ណៈដូចមាស មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ មានភិក្ខុសង្ឃហែហម ទ្រង់ចេញអំពីព្រៃធំ ។ ខ្ញុំផ្គងបាយាសដាក់ក្នុងភាជន៍សំរឹទ្ធ ដោយដៃរបស់ខ្លួន ខ្ញុំប្រាថ្នានឹងបូជានូវគ្រឿងបូជា ក៏ដើរសំដៅទៅកាន់ទីបូជា ។ ក្នុងសម័យនោះ ព្រះមានព្រះភាគជាច្បងក្នុងលោក ជានរាសភៈ ទ្រង់ឡើងកាន់ទីចង្ក្រម ក្នុងអាកាស ជាផ្លូវខ្យល់ ។ ខ្ញុំឃើញហេតុដ៏អស្ចារ្យ ចម្លែក ព្រឺរោមនោះ ក៏ដាក់ចុះនូវភាជន៍សំរឹទ្ធ ថ្វាយបង្គំព្រះវិបស្សី ([illegible])

បាយាសទាយកត្ថេរាបទានំ

តុដ្ឋំ បុព្ភាសំ(១) សព្វញ្ញូ  សារទេវោ សមាគតេ
អនុកម្បំ ឧបាទាយ  បដិគ្គណ្ហ មហាមុនិ ។
បដិគ្គណ្ហាសិ ភគវា  សព្វញ្ញូ លោកនាយកោ
មម សង្កប្បមញ្ញាយ  សត្ថា លោកេ អនុត្តរោ(២)។
ឯកនវុតេ ឥតោ កប្បេ  យំ ទានមទទិំ តទា
ទុគ្គតឹ នាភិជានាមិ  បាយាសស្ស ឥទំ ផលំ។
ឯកត្តាឡីសិតោ កប្បេ  ពុទ្ធោ នាមាសិ ខត្តិយោ
សត្តរតនសម្បន្នោ  ចក្កវត្តិ មហព្ពលោ ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនន្តិ។

ឥត្ថំ សុទំ អាយស្មា បាយាសទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បាយាសទាយកត្ថេរស្ស អបទានំ សមត្តំ ។

១ ម. ទេកសំ ។ ២ ម. មហាមុនិ ។



បាយាសទាយកត្ថេរាបទាន ទី ៣

បពិត្រព្រះមហាមុនី ព្រះអង្គជាសព្វញ្ញូ ក្នុងមនុស្សលោក និងទេវលោក សូមព្រះអង្គអាស្រ័យសេចក្តីអនុគ្រោះ ទទួលយក ។ ព្រះមានព្រះភាគជាសព្វញ្ញូ លោកនាយក ជាសាស្តាដ៏ប្រសើរក្នុងលោក ទ្រង់ជ្រាបតំរិះរបស់ខ្ញុំ ហើយទ្រង់ទទួលយក ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបាយាស ។ ក្នុងកប្បទី ៤១ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១ ជាតិ ព្រះនាមពុទ្ធជ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបាយាសទាយកត្ថេរមានអាយុ បានសំដែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បាយាសទាយកត្ថេរាបទាន

## ចតុត្ថំ គន្ធោទកិយត្ថេរាបទានំ

(៦៦) និសជ្ជ បាសាទវរេ វិបស្សឹ អទ្ទសំ ជិនំ
កកុធំ វិលសន្តំវ សព្វញ្ញុតមនាយកំ ។
បាសាទស្សាវិទូរេ ច គច្ឆតិ លោកនាយកោ
បភា និទ្ធាវតេ តស្ស សតរំសិម្ហិ ឧគ្គតេ(១) ។
គន្ធោទកំ ច បគ្គយ្ហ ពុទ្ធសេដ្ឋំ សមោកិរឹ
តេន ចិត្តប្បសាទេន តត្ថ កាលំ កតោ អហំ ។
ឯកនវុតេ ឥតោ កប្បេ យំ គន្ធោទកមោកិរឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
ឯកត្តឹសេ ឥតោ កប្បេ សុគន្ធោ នាម ខត្តិយោ
សត្តរតនសម្បន្នោ ចក្កវត្តី មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា គន្ធោទកិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

គន្ធោទកិយត្ថេរស្ស អបទានំ សមត្តំ ។

១ ម. យថា ច សតរំសិនោ ។



## គន្ធោទកិយត្ថេរាបទាន ទី ៤

(៦៦) ខ្ញុំអង្គុយក្នុងប្រាសាទដ៏ប្រសើរ បានឃើញព្រះជិនស្រីព្រះនាមវិបស្សី ជាសព្វញ្ញូនាយកដ៏ឧត្តម ទ្រង់ល្អស ល្អន់ដូចដើមថ្កូវត្រៀវឡូល ។ ព្រះលោកនាយក ទ្រង់ត្រាច់ដំណើរទៅជិតប្រាសាទ ពន្លឺរបស់ព្រះអង្គ ផ្សាយចេញក្នុងកាលព្រះអាទិត្យរះស្គន់ ។ ខ្ញុំកាន់យកទឹកអប់មកប្រោះព្រំព្រះសម្ពុទ្ធដ៏ប្រសើរ ដោយចិត្តជ្រះថ្លានោះ ខ្ញុំក៏ធ្វើកាលកិរិយាក្នុងទីនោះ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំប្រោះព្រំទឹកអប់ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមសុគន្ធ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះគន្ធោទកិយត្ថេរមានអាយុ បានសំដែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ គន្ធោទកិយត្ថេរាបទាន ។

## បញ្ចមំ សម្មុខាថវិកត្ថេរាបទានំ

(៦៨) ជាយមានេ វិបស្សិម្ហិ និមិត្តំ ព្យាករឹ អហំ
និព្វាបយិំ(១) ច ជនតំ ពុទ្ធោ លោកេ ភវិស្សតិ ។
យស្មឹ ច ជាយមានស្មឹ ទសសហស្សិ បកម្បតិ
សោ ទានិ ភគវា សត្ថា ធម្មំ ទេសេតិ ចក្ខុមា ។
យស្មឹ ច ជាយមានស្មឹ អាលោកោ វិបុលោ អហុ
សោ ទានិ ភគវា សត្ថា ធម្មំ ទេសេតិ ចក្ខុមា ។
យស្មឹ ច ជាយមានស្មឹ សរិតាយោ ន សន្ទិសុំ(២)
សោ ទានិ ភគវា សត្ថា ធម្មំ ទេសេតិ ចក្ខុមា ។
យស្មឹ ច ជាយមានស្មឹ អវីចគ្គិ ន បជ្ជលិ
សោ ទានិ ភគវា សត្ថា ធម្មំ ទេសេតិ ចក្ខុមា ។
យស្មឹ ច ជាយមានស្មឹ បក្ខិសង្ឃោ ន សញ្ចរិ
សោ ទានិ ភគវា សត្ថា ធម្មំ ទេសេតិ ចក្ខុមា ។
យស្មិញ្ច ជាយមានស្មឹ វាតក្ខន្ធោ ន វាយតិ
សោ ទានិ ភគវា សត្ថា ធម្មំ ទេសេតិ ចក្ខុមា ។

១ ម. និព្វាបយឹ ។ ២ ម. ន សន្ទយុំ ។



## សម្មុខាថវិកត្ថេរាបទាន ទី ៥

(៦៨) កាលដែលព្រះវិបស្សីទ្រង់ប្រសូត ខ្ញុំបានទាយនិមិត្តថា ព្រះពុទ្ធនឹងញ៉ាំងប្រជុំជន ក្នុងលោកឲ្យរលត់ទុក្ខ ។ កាលព្រះមានព្រះភាគអង្គណា ទ្រង់ប្រសូត លោកធាតុ ១០.០០០ កែងញាប់ញ័រ ឥឡូវនេះ ព្រះមានព្រះភាគអង្គនោះ ជាសាស្តា ទ្រង់មានបញ្ញាចក្ខុ នឹងសំដែងធម៌ ។ កាលព្រះមានព្រះភាគអង្គណា ទ្រង់ប្រសូត ពន្លឺដ៏ធំកើតប្រាកដ ឥឡូវនេះ ព្រះមានព្រះភាគអង្គនោះ ជាសាស្តា ទ្រង់មានបញ្ញាចក្ខុ នឹងសំដែងធម៌ ។ កាលព្រះមានព្រះភាគ អង្គណា ទ្រង់ប្រសូត ស្ទឹងទាំងឡាយមិនហូរ ឥឡូវនេះ ព្រះមានព្រះភាគអង្គនោះ ជាសាស្តា ទ្រង់មានបញ្ញាចក្ខុ នឹងសំដែងធម៌ ។ កាលព្រះមានព្រះភាគ អង្គណា ទ្រង់ប្រសូត ភ្លើងអវិចីមិនឆេះ ឥឡូវនេះ ព្រះមានព្រះភាគ អង្គនោះ ជាសាស្តា ទ្រង់មានបញ្ញាចក្ខុ នឹងសំដែងធម៌ ។ កាលព្រះមានព្រះភាគអង្គណា ទ្រង់ប្រសូត ពួកសត្វស្លាបមិនហើរ ឥឡូវនេះ ព្រះមានព្រះភាគអង្គនោះ ជាសាស្តា ទ្រង់មានបញ្ញាចក្ខុ នឹងសំដែងធម៌ ។

យស្មិញ្ច ជាយមានស្មឹ សព្វកេជាតិ ជោតិសុំ
សោភតិ កតកំ សព្វា ធម្មំ ទេសេតិ ចក្ខុមា ។
យស្មិញ្ច ជាយមានស្មឹ សត្តាសុំ បទវិក្កមា
សោភតិ កតកំ សព្វា ធម្មំ ទេសេតិ ចក្ខុមា ។
ជាតមត្តោ សម្ពុទ្ធោ ទិសា សព្វា វិលោកយិ
វាចាសភិមុទីរេសិ ឯសា ពុទ្ធាន ធម្មតា ។
សំវេជយិត្វា ជនតំ ថវិត្វា លោកនាយកំ
សម្ពុទ្ធំ អភិវាទិត្វា បក្កាមឹ បាចិនាមុខោ ។
ឯកសត្តតេ ឥតោ កប្បេ យំ ពុទ្ធមភិថោមយឹ
ទុគ្គតឹ នាភិជានាមិ ថោមនាយ ឥទំ ផលំ ។



កាលព្រះមានព្រះភាគអង្គណា ទ្រង់ប្រសូត ផែនដីរញ្ជួយ កក្រើក ឥឡូវនេះ ព្រះមានព្រះភាគអង្គនោះ ជាសាស្តា ទ្រង់មានបញ្ញាចក្ខុ នឹងសម្តែងធម៌ ។ កាលព្រះមានព្រះភាគអង្គណា ទ្រង់ប្រសូត ពួកកៅតាំងពួងក៏រុងរឿង ឥឡូវនេះ ព្រះមានព្រះភាគអង្គនោះ ជាសាស្តា ទ្រង់មានចក្ខុ នឹងសម្តែងធម៌ ។ កាលព្រះមានព្រះភាគអង្គណា ទ្រង់ប្រសូត ទ្រង់ឈានដើរបាន ៧ ជំហាន ឥឡូវនេះ ព្រះមានព្រះភាគអង្គនោះ ជាសាស្តា ទ្រង់មានបញ្ញាចក្ខុ នឹងសម្តែងធម៌ ។ ព្រះសម្ពុទ្ធគ្រាន់តែទ្រង់ប្រសូតរួចភ្លាម ទ្រង់មើលមើលសព្វទិស ទ្រង់បន្លឺ នូវវាចាដ៏អង់អាច នេះជាធម្មតារបស់ព្រះពុទ្ធទាំងឡាយ ។ ខ្ញុំញ៉ាំងប្រជុំជនឲ្យកើតសង្វេគ ហើយសរសើរព្រះលោកនាយក ថ្វាយបង្គំព្រះសម្ពុទ្ធ ហើយបែរមុខទៅកាន់ទិសខាងកើត ដើរចេញទៅ ។ ក្នុងកប្បទី ៧១ អំពីកប្បនេះ ព្រោះហេតុដែល ខ្ញុំបានសរសើរព្រះសម្ពុទ្ធ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការសរសើរ ។

បឋមំ សម្មុខាថវិកត្ថេរាបទានំ

ឥតោ នវុតិកប្បម្ហិ    សម្មុខាថវិកវ្ហយោ
សត្តរតនសម្បន្នោ    ចក្កវត្តិ មហព្ពលោ ។
បឋវីទុន្ទុភិ នាម    ឯកូននវុតិម្ហិតោ
សត្តរតនសម្បន្នោ    ចក្កវត្តិ មហព្ពលោ ។
អដ្ឋាសីតិម្ហិតោ កប្បេ    ឱភាសោ នាម ខត្តិយោ
សត្តរតនសម្បន្នោ    ចក្កវត្តិ មហព្ពលោ ។
សត្តាសីតិម្ហិតោ កប្បេ    សរិតច្ឆទនវ្ហយោ
សត្តរតនសម្បន្នោ    ចក្កវត្តិ មហព្ពលោ ។
អគ្គិនិព្វាបនោ នាម    កប្បានំ ឆឡសីតិយា
សត្តរតនសម្បន្នោ    ចក្កវត្តិ មហព្ពលោ ។
រាជា វាតសមោ នាម    កប្បានំ បញ្ចសីតិយា(១)
សត្តរតនសម្បន្នោ    ចក្កវត្តិ មហព្ពលោ ។
គតិបច្ឆេទនោ នាម    កប្បានំ ចុល្លសីតិយា(២)
សត្តរតនសម្បន្នោ    ចក្កវត្តិ មហព្ពលោ ។
រតនប្បជ្ជលោ នាម    កប្បានំ តេអសីតិយា
សត្តរតនសម្បន្នោ    ចក្កវត្តិ មហព្ពលោ ។

១ ឱ. បុញ្ញសីតិយា ។ ២ ឱ. បញ្ចសីតិកា ។



ក្នុងកប្បទី ៩០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ឈ្មោះសម្មុខាថវិកកៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ ក្នុងកប្បទី ៨៩ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ឈ្មោះបឋវីទុន្ទុភិកៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ ក្នុងកប្បទី ៨៨ អំពីកប្បនេះ ខ្ញុំកើតជាក្សត្រ ឈ្មោះឱភាសកៈ ជាស្តេចចក្រពត្តិ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ ក្នុងកប្បទី ៨៧ អំពីកប្បនេះ ខ្ញុំកើតជាស្តេចចក្រពត្តិ ឈ្មោះសរិតច្ឆទនកៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការមានកម្លាំងច្រើន ។ ក្នុងកប្បទី ៨៦ ខ្ញុំកើតជាស្តេចចក្រពត្តិ ឈ្មោះអគ្គិនិព្វាបនកៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ ក្នុងកប្បទី ៨៥ ខ្ញុំកើតជាស្តេចចក្រពត្តិ ឈ្មោះវាតសមកៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ ក្នុងកប្បទី ៨៤ ខ្ញុំកើតជាស្តេចចក្រពត្តិ ឈ្មោះគតិបច្ឆេទនកៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ ក្នុងកប្បទី ៨៣ ខ្ញុំកើតជាស្តេចចក្រពត្តិ ឈ្មោះរតនប្បជ្ជលកៈ បរិបូណ៌ដោយកែវ៧ប្រការ មានកម្លាំងច្រើន ។

ពលវិក្កមនោ នាម កប្បានំ ឆឡសីតិយា
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្ពលោ ។
រាជា វិលោកនោ នាម កប្បានំ បញ្ចសីតិយា
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្ពលោ ។
គិរិសារោតិ នាមេន កប្បេសីតិម្ហិ ខត្តិយោ
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្ពលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សត្តបាដលិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សត្តបាដលិយត្ថេរស្ស អបទានំ សមត្តំ ។

## ឆដ្ឋំ កុសុមាសនិយត្ថេរាបទានំ

(៦៦) នគរេ ធញ្ញវតិយា អហោសិ ព្រាហ្មណោ តទា
លក្ខណេ ឥតិហាសេ ច សនិឃណ្ឌុសកេដុភេ ។



ក្នុងកប្បទី ៨៦ ខ្ញុំកើតជាស្តេចចក្រពត្តិ ឈ្មោះពលវិក្កមនរាជ ប្រកបដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ ក្នុងកប្បទី ៨៥ ខ្ញុំកើតជាស្តេចចក្រពត្តិ ឈ្មោះវិលោកនរាជ ប្រកបដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ ក្នុងកប្បទី ៨០ ខ្ញុំកើតជាស្តេចចក្រពត្តិ ឈ្មោះគិរិសាររាជ ប្រកបដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសត្តបាដលិយត្ថេរមានអាយុ បានសំដែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សត្តបាដលិយត្ថេរាបទាន ។

## កុសុមាសនិយត្ថេរាបទាន ទី ៦

(៦៦) គ្រានោះ ខ្ញុំបានកើតជាព្រាហ្មណ៍ នៅក្នុងក្រុងធញ្ញវតី ជាអ្នកឈ្លាស ក្នុងគម្ពីរលក្ខណសាស្ត្រ ឥតិហាសសាស្ត្រ ព្រមទាំងនិឃណ្ឌុសាស្ត្រ និងកេដុភសាស្ត្រ ។

### កុសុមាសនិយត្ថេរាបទាន

បទកោ វេយ្យាករណោ និមិត្តេ កោវិទោ អហំ
មន្តេ ច សិស្សេ វាចេសិំ តិណ្ណំ វេទាន បារគូ ។
បញ្ច ឧប្បលហត្ថានិ បិដ្ឋិយំ ឋបិតានិ មេ
អាហុតឹ យិដ្ឋុកាមោហំ បិតុមាតុសមាគតេ ។
តទា វិបស្សី ភគវា ភិក្ខុសង្ឃបុរក្ខតោ
ឱភាសេន្តោ ទិសា សព្វា អាគច្ឆតិ នរាសភោ ។
អាសនំ បញ្ញបេត្វាន និមន្តេត្វា មហាមុនឹ
សន្ថរិត្វាន តំ បុប្ផំ អភិនេសឹ សកំ ឃរំ ។
យំ មេ អត្ថិ សកេ គេហេ អាមិសំ បច្ចុបដ្ឋិតំ
តាហំ ពុទ្ធស្ស បាទាសឹ បសន្នោ សេហិ បាណិភិ ។
ភុត្តាវឹ កាលមញ្ញាយ ឯកំ ហត្ថំ អទាសហំ
អនុមោទិត្វាន សព្វញ្ញូ បក្កាមិ ឧត្តរាមុខោ ។
ឯកត្តឹសេ ឥតោ កប្បេ យំ បុប្ផមទទឹ តទា
ទុគ្គតឹ នាភិជានាមិ បុប្ផទានស្សិទំ ផលំ ។





ជាអ្នកឈ្លាស ក្នុងបទ ក្នុងវេយ្យាករណ៍ ក្នុងនិមិត្ត ចេះចប់ត្រៃវេទ បានបង្រៀនមន្តចំពោះពួកសិស្ស ។ ខ្ញុំតម្កល់ផ្កាឧប្បល ៥ ក្រញ៉ាំលើខ្នង ខ្ញុំមានប្រាថ្នា ដើម្បីបូជានូវគ្រឿងបូជា ក្នុងការជួបជុំបិតានិងមាតា ។ វេលានោះ ព្រះមានព្រះភាគព្រះនាមវិបស្សី ទ្រង់ជានរាសភៈ មានភិក្ខុសង្ឃហែហម ទ្រង់ញុំាងទិសទាំងពួងឲ្យភ្លឺ ហើយស្តេចនិមន្តមក ។ ខ្ញុំបានក្រាលអាសនៈ ហើយនិមន្តព្រះមហាមុនី បានក្រាលផ្កានោះហើយ នាំព្រះអង្គឲ្យស្តេចទៅកាន់ផ្ទះរបស់ខ្លួន ។ អាមិសៈណាដែលខ្ញុំបានតម្កល់ទុក មានក្នុងផ្ទះរបស់ខ្ញុំ ខ្ញុំជ្រះថ្លាបានថ្វាយអាមិសៈនោះចំពោះព្រះសម្ពុទ្ធ ដោយដៃរបស់ខ្លួន ។ ខ្ញុំដឹងនូវកាលដែលព្រះសម្ពុទ្ធ ទ្រង់សោយរួចហើយ ក៏បានថ្វាយផ្កាមួយកញ្ចប់ ព្រះសព្វញ្ញុ ទ្រង់អនុមោទនារួចហើយ បែរព្រះភក្ត្រទៅកាន់ទិសឧត្តរ និមន្តចេញទៅ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបុប្ផទាន ។

អធន្តកេ ឥតោ កប្បេ ភជាហុ វរធស្សគោ
សត្តរតនសម្បន្នោ ចក្កវត្តី មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា កុសុមាសនិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កុសុមាសនិយត្ថេរស្ស អបទានំ សមត្តំ ។

## សត្តមំ ផលទាយកត្ថេរាបទានំ

(៦៧) អជ្ឈាយកោ មន្តធរោ តិណ្ណំ វេទាន បារគូ
ហិមវន្តស្សាវិទូរេ វសាមិ អស្សមេ អហំ ។
អគ្គិហុត្តញ្ច មេ អត្ថិ បុណ្ឌរីកផលានិ ច
បុដកោ និក្ខិបិត្វាន ទុមគ្គេ លគ្គិតំ មយា ។
បទុមុត្តរោ លោកវិទូ អាហុតីនំ បដិគ្គហោ
មមុទ្ធរិតុកាមោ សោ ភិក្ខន្តោ មមុបាគមិ ។
បសន្នចិត្តោ សុមនោ ផលំ ពុទ្ធស្សទាសហំ
បីតិសញ្ជននោ មយ្ហំ ទិដ្ឋធម្មសុខាវហោ ។



ក្នុងកប្បជាលំដាប់ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ឈ្មោះវរទស្សនៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះកុសុមាសនិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កុសុមាសនិយត្ថេរាបទាន ។

## ផលទាយកត្ថេរាបទាន ទី ៧

(៦៧) ខ្ញុំជាអ្នកស្វាធ្យាយមន្ត ចងចាំមន្ត ចេះចប់ត្រៃវេទ នៅក្នុងអាស្រម ជិតព្រៃហិមពាន្ត ។ ការបូជាភ្លើង របស់ខ្ញុំក៏មាន ខ្ញុំដាក់ផ្លែឈូកទាំងឡាយក្នុងកញ្ចប់ ហើយព្យួរលើចុងឈើ ។ ព្រះលោកវិទូ ព្រះនាមបទុមុត្តរៈ ទ្រង់គួរទទួលនូវគ្រឿងបូជា ទ្រង់មានព្រះប្រាថ្នា នឹងស្រង់ខ្ញុំ ស្តេចនិមន្តទៅដើម្បីភិក្ខា ក៏ចូលមកកាន់សំណាក់នៃខ្ញុំ ។

សត្តមំ ផលទាយកត្ថេរាបទានំ

សុវណ្ណវណ្ណោ សម្ពុទ្ធោ   អាហុតីនំ បដិគ្គហោ
អន្តលិក្ខេ ឋិតោ សត្ថា   ឥមំ គាថំ អភាសថ ។
ឥមិនា ផលទានេន   ចេតនាបណិធីហិ ច
កប្បានំ សតសហស្សំ   ទុគ្គតឹ នុបបជ្ជតិ ។
តេនេវ សុក្កមូលេន   អនុភោត្វាន សម្បទា
បត្តោម្ហិ អចលំ ឋានំ   ហិត្វា ជយបរាជយំ ។
ឥតោ សត្តកប្បសតេ   រាជា អាសិ សុមង្គលោ
សត្តរតនសម្បន្នោ   ចក្កវត្តី មហព្ពលោ ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ផលទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ផលទាយកត្ថេរស្ស អបទានំ សមត្តំ ។



ផលទាយកត្ថេរាបទាន

ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តសោមនស្ស បានថ្វាយនូវផ្លែឈើនោះ ចំពោះព្រះពុទ្ធ ព្រះសម្ពុទ្ធជាសាស្តា ទ្រង់មានវណ្ណៈដូចមាស ទ្រង់ញ៉ាំងចិត្តខ្ញុំឲ្យកើត ទ្រង់នាំមកនូវសេចក្តីសុខដល់ខ្ញុំក្នុងបច្ចុប្បន្ន គួរទទួលនូវគ្រឿងបូជា ទ្រង់ឋិតនៅនាអាកាសហើយសម្តែងគាថានេះថា កុលបុត្តនេះ នឹងមិនទៅកាន់ទុគ្គតិអស់មួយសែនកប្ប ដោយផលនៃការថ្វាយផ្លែឈើនេះផង ដោយផលនៃការតម្កល់ទុកនូវចេតនានេះផង ។ ព្រោះកុសលមូលនោះឯង ខ្ញុំបានសោយសម្បត្តិទាំងឡាយ ហើយបានដល់នូវព្រះនិព្វាន ជាឋានមិនញាប់ញ័រ ខ្ញុំលះចោលនូវការឈ្នះនិងការចាញ់ ។ ក្នុងកប្បទី ៧០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ឈ្មោះសុមង្គលៈ ទ្រង់បរិបូណ៌ដោយកែវទាំង ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះផលទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ផលទាយកត្ថេរាបទាន ។

## អដ្ឋមំ ញាណសញ្ញកត្ថេរាបទានំ

(៦៨) បព្វតេ ហិមវន្តម្ហិ វសាមិ បព្វតន្តរេ
បុលិនំ សោភនំ ទិស្វា ពុទ្ធសេដ្ឋំ អនុស្សរឹ ។
ញាណេ ឧបនិធំ នត្ថិ សង្គាមំ នត្ថិ សត្ថុនោ
សព្វធម្មំ អភិញ្ញាយ ញាណេន អធិមុច្ចតិ ។
នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម
ញាណេន តេ សមោ នត្ថិ យាវតា ញាណមុត្តមំ ។
ញាណេ ចិត្តំ បសាទេត្វា កប្បំ សគ្គម្ហិ មោទហំ
អវសេសេសុ កប្បេសុ កុសលំ ករិតំ(១) មយា ។
ឯកនវុតេ ឥតោ កប្បេ យំ សញ្ញមលភឹ តទា
ទុគ្គតឹ នាភិជានាមិ ញាណសញ្ញាយិទំ ផលំ ។

១ ម. ករិយំ ។



## ញាណសញ្ញកត្ថេរាបទាន ទី ៨

(៦៨) ខ្ញុំនៅតាមភ្នំហិមពាន្ត ឃើញផ្នែកខ្សាច់ដ៏ល្អក្នុងចន្លោះភ្នំ ខ្ញុំរឭកនូវព្រះសម្ពុទ្ធដ៏ប្រសើរជាង ការប្រៀបធៀប ក្នុងញាណ (របស់ព្រះសាស្តា) មិនមានឡើយ សង្គ្រាមរបស់ព្រះសាស្តា ក៏មិនមានដែរ ព្រះសាស្តាបានជ្រាបនូវធម៌ទាំងពួង ទ្រង់ស៊ប់ស្ងួនដោយញាណ ។ បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមថ្វាយបង្គំចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរសដ៏ឧត្តម ខ្ញុំសូមថ្វាយបង្គំព្រះអង្គ សភាពដទៃស្មើដោយញាណរបស់ព្រះអង្គមិនមានឡើយ មានតែញាណរបស់ព្រះអង្គ ទើបឧត្តមជាកំណត់ ។ ខ្ញុំញុំាងចិត្តឲ្យជ្រះថ្លា ក្នុងញាណហើយ ក៏បានត្រេកអរក្នុងឋានសួគ៌ អស់មួយកប្ប ខ្ញុំបានកសាងកុសល ក្នុងកប្បដ៏សេស ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបាននូវសេចក្តីសំគាល់ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសេចក្តីសំគាល់ក្នុងញាណ ។

ឥតោ តេសត្តតិកប្បេ　ឯកោ បុលិនបុប្ផិយោ
សត្តរតនសម្បន្នោ　ចក្កវត្តី មហព្ពលោ ។
បដិសម្ភិទា ចតស្សោ　វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា　កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ញាណសញ្ញកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ញាណសញ្ញកត្ថេរស្ស អបទានំ សមត្តំ ។

## នវមំ គន្ធបុប្ផិយត្ថេរាបទានំ

(៦៩) សុវណ្ណវណ្ណោ សម្ពុទ្ធោ　វិបស្សី ទក្ខិណារហោ
បុរក្ខតោ សាវកេហិ　អារាមា អភិនិក្ខមិ ។
ទិស្វានហំ ពុទ្ធសេដ្ឋំ　សព្វញ្ញុំ តមនាសវំ
បសន្នចិត្តោ សុមនោ　គតមគ្គំ អបូជយឹ ។
តេន ចិត្តប្បសាទេន　ទិបទិន្ទស្ស តាទិនោ
ហដ្ឋោ ហដ្ឋេន ចិត្តេន　បុន វន្ទិំ តថាគតំ ។





ក្នុងកប្បទី ៧៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១ ជាតិ ព្រះនាមបុលិនបុប្ផិយៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះញាណសញ្ញកត្ថេរមានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ញាណសញ្ញកត្ថេរាបទាន ។

## គន្ធបុប្ផិយត្ថេរាបទាន ទី ៩

(៦៩) ព្រះមានព្រះភាគព្រះនាមវិបស្សី មានវណ្ណៈដូចមាស ទ្រង់គួរទទួលនូវទក្ខិណាទាន មានពួកសាវ័កហែហមកោម ស្តេចចេញអំពីអារាម ។ ខ្ញុំឃើញព្រះពុទ្ធដ៏ប្រសើរ ជាសព្វញ្ញូ មិនមានអាសវៈ ក៏មានចិត្តជ្រះថ្លា មានចិត្តសោមនស្ស បានបូជាផ្លូវដែលស្តេចនិមន្តទៅ ។ ខ្ញុំជាអ្នករីករាយ មានចិត្តរីករាយ ចំពោះព្រះសម្ពុទ្ធជាតាទិបុគ្គល ប្រសើរជាងសត្វជើងពីរ ទើបថ្វាយបង្គំព្រះតថាគតម្តងទៀត ដោយចិត្តជ្រះថ្លានោះ ។

ឯកនវុតេ ឥតោ កប្បេ យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
ឯកត្តឹសេ ឥតោ កប្បេ វរុណោ នាម(១) ខត្តិយោ
សត្តរតនសម្បន្នោ ចក្កវត្តី មហព្ពលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា គន្ធបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

គន្ធបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

## ទសមំ បទុមបូជកត្ថេរាបទានំ

[៣០] ហិមវន្តស្សាវិទូរេ គោតមោ នាម បព្វតោ
នានារុក្ខេហិ សញ្ឆន្នោ មហាភូតគណាលយោ ។
វេមជ្ឈម្ហិ ច តស្សាសិ អស្សមោ អភិនិម្មិតោ
បុរក្ខតោ សសិស្សេហិ វសាមិ អស្សមេ អហំ ។

១ ម. ធរណោ នាម ។



ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ខ្ញុំកើតជាក្សត្រចក្រពត្តិ ឈ្មោះវរុណៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះគន្ធបុប្ផិយត្ថេរមានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់គន្ធបុប្ផិយត្ថេរាបទាន ។

## បទុមបូជកត្ថេរាបទាន ទី ១០

[៣០] មានភ្នំ ១ ឈ្មោះគោតមៈ នៅក្បែរហិមពាន្ត ដេរដាសដោយឈើផ្សេងៗ ជាទីអាស្រ័យនៅនៃពួកភូតច្រើន ។ ខ្ញុំបានសាងអាស្រម ត្រង់កណ្តាលភ្នំនោះ មានពួកសិស្សចោមរោម តែងនៅក្នុងអាស្រម (ខ្ញុំបបួលពួកសិស្សថា)

អាយន្តុ មេ សិស្សគណា បទុមំ អាហរន្តុ មេ
ពុទ្ធបូជំ ករិស្សាមិ ទិបទិន្ទស្ស តាទិនោ ។
ឯវន្តិ តេ បដិស្សុត្វា បទុមំ អាហរឹសុ មេ
តថា និមិត្តំ កត្វាន ពុទ្ធស្ស អភិរោបយឹ ។
សិស្សេ តទា សមានេត្វា សាធុកំ អនុសាសហំ
មា ខោ តុម្ហេ បមជ្ជិត្ថ អប្បមាទោ សុខាវហោ ។
ឯវំ សមនុសាសិត្វា តេ សិស្សេ វចនក្ខមេ
អប្បមាទគុណេ យុត្តោ តទា កាលង្កតោ អហំ ។
ឯកនវុតេ ឥតោ កប្បេ យំ បុប្ផមភិរោបយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
ឯកបញ្ញាសកប្បម្ហិ រាជា អាសឹ ជលុត្តមោ
សត្តរតនសម្បន្នោ ចក្កវត្តី មហព្ពលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។



សូមពួកសិស្ស មកកាន់សំណាក់យើង សូមពួកសិស្សនាំផ្កាឈូកមកឲ្យយើង ។ យើងនឹងធ្វើពុទ្ធបូជា ចំពោះព្រះពុទ្ធជាតាទិបុគ្គល ទ្រង់ប្រសើរជាងសត្វជើងពីរ ។ ពួកសិស្សទាំងនោះ ទទួលពាក្យខ្ញុំថា យ៉ាងហ្នឹងហើយ ។ បានយកផ្កាឈូកមកឲ្យខ្ញុំ ខ្ញុំធ្វើនិមិត្តតាមទំនងដូច្នោះហើយ បានបង្ហាញថ្វាយដល់ព្រះពុទ្ធជាម្ចាស់ ។ ក្នុងកាលនោះ ខ្ញុំបានប្រជុំពួកសិស្ស ហើយប្រៀនប្រដៅដោយប្រពៃថា អ្នកទាំងឡាយ ចូរកុំប្រមាទ សេចក្តីមិនប្រមាទជាគុណនាំមកនូវសេចក្តីសុខ ។ ខ្ញុំនោះបានប្រៀនប្រដៅពួកសិស្សដែលជាអ្នកគួរដល់ពាក្យនេះហើយ ខ្ញុំប្រកបក្នុងអប្បមាទគុណ ក៏បានធ្វើមរណកាលក្នុងពេលនោះ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៥១ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមជលុត្តមៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា បទុមបូជកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បទុមបូជកត្ថេរស្ស អបទានំ សមត្តំ ។

ឧទ្ទានំ

សោរេយ្យកោ បុប្ផថូបិ បាយាសោ គន្ធោទកោ(១)
អាសនី ផលសញ្ញី ច គន្ធបទុមបុប្ផិយោ
បញ្ចុត្តរសតា គាថា គណិតា អត្ថទស្សិភិ ។

សោរេយ្យវគ្គោ តេរសមោ ។

---

១ ម. បាយាសោ គន្ធោទកោ ។



បានឮថា បទុមបូជកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងឡាយនេះ ដោយប្រការដូច្នេះ ។

ចប់ បទុមបូជកត្ថេរាបទាន ។

ឧទ្ទាន

សោរេយ្យកត្ថេរាបទាន ១ បុប្ផថូបិយត្ថេរាបទាន ១ បាយាស-ទាយកត្ថេរាបទាន ១ គន្ធោទកិយត្ថេរាបទាន ១ អាសនកត្ថេរ-បទាន ១ សម្មុខាថវិកត្ថេរាបទាន ១ កុសុមាសនិយត្ថេរាបទាន ១ ផលទាយកត្ថេរាបទាន ១ ញាណសញ្ញកត្ថេរាបទាន ១ គន្ធបុប្ផិយត្ថេរាបទាន ១ បទុមបុប្ផិយត្ថេរាបទាន ១ មាន គាថា ១០៨ ពួកអ្នកប្រាជ្ញបានរាប់ហើយ ។

ចប់ សោរេយ្យវគ្គ ទី ១៣ ។

## ចុទ្ទសមោ សោភិតវគ្គោ

## បឋមំ សោភិតត្ថេរាបទានំ

(៣១) បទុមុត្តរោ នាម ជិនោ លោកជេដ្ឋោ នរាសភោ
មហតោ ជនកាយស្ស ទេសេតិ អមតំ បទំ ។
តស្សាហំ វចនំ សុត្វា វាចាសភិមុទីរិតំ
អញ្ជលឹ បគ្គហេត្វាន ឯកគ្គោ អាសហំ តទា ។
យថា សមុទ្ទោ ឧទធីនមគ្គោ
នេរុ នគានំ បវរោ សិលុច្ចយោ
តថេវ យេ ចិត្តវសេន វត្តរេ
ន ពុទ្ធញាណស្ស កលំ ឧបេន្តិ តេ ។
ធម្មវិធឹ ឋបេត្វាន ពុទ្ធោ ការុណិកោ ឥសិ
ភិក្ខុសង្ឃេ និសីទិត្វា ឥមា គាថា អភាសថ ។
យោ សោ ញាណំ បកិត្តេសិ ពុទ្ធម្ហិ លោកនាយកេ
កប្បានំ សតសហស្សំ ទុគ្គតឹ សោ ន គច្ឆតិ ។

## សោភិតវគ្គ ទី ១៤

## សោភិតត្ថេរាបទាន ទី ១

(៣១) ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ជាច្បងក្នុងលោក ទ្រង់ជានរាសភៈ ទ្រង់សម្តែងធម៌ ជាចំណែកព្រះនិព្វាន ដល់ពួកជនច្រើន ។ កាលនោះ ខ្ញុំបានស្តាប់នូវព្រះពុទ្ធដីកា របស់ព្រះអង្គនោះ ដែលទ្រង់ពោលដោយវាចា ដ៏អង់អាច ខ្ញុំផ្គងអញ្ជលី មានចិត្តនឹងក្នុងអារម្មណ៍តែមួយ ។ សមុទ្រប្រសើរជាងស្ទឹងទាំងឡាយ ភ្នំព្រះសុមេរុ ប្រសើរជាងភ្នំទាំងឡាយ យ៉ាងណាមិញ ជនណាប្រព្រឹត្តដោយអំណាចចិត្ត ជននោះមិនដល់មួយចំណិត នៃពុទ្ធញាណឡើយ ក៏យ៉ាងនោះដែរ ។ លុះព្រះសម្ពុទ្ធជាឥសី ប្រកបដោយសេចក្តីករុណា ទ្រង់បញ្ចប់នូវធម្មវិធី គង់ក្នុងកណ្តាលជំនុំភិក្ខុសង្ឃ ហើយសម្តែងនូវគាថាទាំងឡាយនេះថា ជនណាបានសរសើរ នូវញាណនៃព្រះពុទ្ធ ជាលោកនាយក ជននោះឯង រមែងមិនទៅកាន់ទុគ្គតិ អស់មួយសែនកប្ប

កិលេសេ ឈាបយិត្វាន ឯកគ្គោ សុសមាហិតោ
សោភិតោ នាម នាមេន ហេស្សតិ សត្ថុសាវកោ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បញ្ញាសេ កប្បសហស្សម្ហិ សត្តកសិ សមុគ្គតា
សត្តរតនសម្បន្នា ចក្កវត្តី មហព្វលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សោភិតោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សោភិតត្ថេរស្ស អបទានំ សមត្តំ ។

## ទុតិយំ សុទស្សនត្ថេរាបទានំ

(៣២) វិនតាយ(១) នទិយា តីរេ បិលក្ខុ ផលិតោ(២) អហុ
តាហំ រុក្ខំ គវេសន្តោ អទ្ទសំ លោកនាយកំ ។

១ ម. វិតតា ។ ២ ម. បិលក្ខុផលិតោ ។



នឹងដុតបំផ្លាញកិលេសទាំងឡាយ មានចិត្តនឹងនួនមានអារម្មណ៍តែមួយ មានចិត្តតម្កល់មាំ នឹងបានឈ្មោះថាសោភិតៈ ជាសាវ័កនៃព្រះសាស្តា ។ ខ្ញុំបានដុតបំផ្លាញនូវកិលេសហើយ ភពទាំងពួងខ្ញុំបានដកចេញហើយ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។ ក្នុងកប្បទី ៥០.០០០ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៧ ជាតិ ព្រះនាមសមុគ្គតៈដូចគ្នា ប្រកបដោយកែវទាំង ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសោភិតត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សោភិតត្ថេរាបទាន ។

## សុទស្សនត្ថេរាបទាន ទី ២

(៣២) ដើមឈើបិលក្ខុមានផ្លែ នៅត្រើយស្ទឹងវិនតា ខ្ញុំ
កំពុងតែស្វែងរកឈើនោះ បានឃើញព្រះលោកនាយក ។

ទុតិយំ សុទស្សនត្ថេរាបទានំ

កេតកំ(១) បុប្ផិតំ ទិស្វា  វណ្ដេ ឆេត្វានហំ តទា
ពុទ្ធស្ស អភិរោបេសិំ  សិខិនោ លោកពន្ធុនោ ។
យេន ញាណេន បត្តោសិ  អច្ចុតំ អមតំ បទំ
តំ ញាណំ អភិបូជេសិំ  ពុទ្ធសេដ្ឋ មហាមុនិ ។
ញាណម្ហិ បូជំ កត្វាន  មិលក្ខុំ អទ្ទសំ អហំ
បដិលទ្ធោម្ហិ តំ សញ្ញំ  ញាណបូជាយិទំ ផលំ ។
ឯកត្តិំសេ ឥតោ កប្បេ  យំ ពុទ្ធមភិបូជយិំ
ទុគ្គតិំ នាភិជានាមិ  ញាណបូជាយិទំ ផលំ ។
ឥតោ តេរសកប្បម្ហិ  សោឡសាសុំ ពលុត្តមា
សត្តរតនសម្បន្នា  ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា សុទស្សនោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សុទស្សនត្ថេរស្ស អបទានំ សមត្តំ ។

១ ម. កេតកិំ ។



សុទស្សនត្ថេរាបទាន ទី ២

ក្នុងកាលនោះ ខ្ញុំឃើញដើមកេតកមានផ្ការីក ទើបកាច់ផ្កាទាំងទង នាំចូលទៅថ្វាយចំពោះព្រះសម្ពុទ្ធ ព្រះនាមសិខី ជាលោកពន្ធុ ក្រាបទូលថា បពិត្រព្រះសម្ពុទ្ធ ទ្រង់ប្រសើរ ជាមហាមុនី ព្រះអង្គដល់ហើយ នូវអមតបទ ជាទីមិនឃ្លាត ដោយញាណណា ខ្ញុំបូជាចំពោះញាណនោះ ។ លុះខ្ញុំធ្វើការបូជាចំពោះញាណហើយ ទើបបានឃើញនូវឈើមិលក្ខុ ខ្ញុំជាបុគ្គលបាននូវការសំគាល់នោះ នេះជាផលនៃញាណបូជា ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃញាណបូជា ។ ក្នុងកប្បទី ១៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១៦ ជាតិ ព្រះនាមពលុត្តមៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសុទស្សនត្ថេរមានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សុទស្សនត្ថេរាបទាន ។

## តតិយំ បុប្ផធរកត្ថេរាបទានំ

(៣១) ចន្ទភាគានទីតីរេ    អហោសឹ កិន្នរោ តទា
បុប្ផភក្ខោ ចហំ អាសឹ    បុប្ផនិវសនោ អហំ[១] ។
អត្ថទស្សី តុ ភគវា    លោកជេដ្ឋោ នរាសភោ
បវនគ្គេន[២] និយ្យាសិ    ហំសរាជាវ អម្ពរេ ។
នមោ តេ បុរិសាជញ្ញ    ចិត្តំ តេ សុវិសោធិតំ
បសន្នមុខវណ្ណោសិ    វិប្បសន្នមុខិន្ទ្រិយោ ។
ឱរោហិត្វាន អាកាសា    ភូរិបញ្ញោ សុមេធសោ
សង្ឃាដឹ បត្ថរិត្វាន    បល្លង្កេន ឧបាវិសិ ។
វិលីនំ ចន្ទនាទាយ    អគមាសឹ ជិនន្តិកំ
បសន្នចិត្តោ សុមនោ    ពុទ្ធស្ស អភិរោបយឹ ។
អភិវាទេត្វាន សម្ពុទ្ធំ    លោកជេដ្ឋំ នរាសភំ
បាមោជ្ជំ ជនយិត្វាន    បក្កាមឹ ឧត្តរាមុខោ ។

១ ម. តបិ ។ ២ ម. វិបិនគ្គេន ។





## បុប្ផធរកត្ថេរាបទាន ទី ៣

(៣១) គ្រានោះ ខ្ញុំកើតជាកិន្នរ នៅទៀបឆ្នេរស្ទឹងចន្ទភាគា ជាអ្នកទទួលទានផ្កាឈើ ជាអ្នកស្លៀកផ្កាឈើ ។ កាលនោះ ព្រះមានព្រះភាគព្រះនាមអត្ថទស្សី ជាច្បងក្នុងលោក ជានរាសភៈ ស្តេចហោះទៅតាមទីចុងនៃព្រៃធំ ដូចស្តេចហង្ស (ហើរទៅ) តាមអាកាស (ខ្ញុំសរសើរក្នុងគាថាថា) បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមថ្វាយបង្គំចំពោះព្រះអង្គ ព្រះហឫទ័យរបស់ព្រះអង្គ ស្អាតល្អហើយ ព្រះអង្គមានសម្បុរព្រះភក្ត្រជ្រះថ្លា មានឥន្ទ្រិយគឺព្រះភក្ត្រស្រស់បស់ ។ លុះព្រះអត្ថទស្សី មានបញ្ញាដូចផែនដី មានបញ្ញាជាគ្រឿងគុះគោរ ស្តេចចុះអំពីអាកាស ហើយក្រាលសង្ឃាដី ទ្រង់គង់ពែនភ្នែន ។ ខ្ញុំបានយកខ្លឹមចន្ទន៍ដ៏ល្អិតផង ហើយដើរចូលមកក្នុងសំណាក់ព្រះជិនស្រី ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តសោមនស្ស បានបូជាចំពោះព្រះពុទ្ធ ។ ខ្ញុំថ្វាយបង្គំព្រះសម្ពុទ្ធជាច្បងក្នុងលោក ជានរាសភៈ ហើយក៏កើតប្រាមោទ្យ ឈមមុខទៅកាន់ឧត្តរទិស ដើរចេញទៅ ។

អដ្ឋារសេ កប្បសតេ ពុទ្ធំ យំ អបូជយិំ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
ចតុទ្ទសេ កប្បសតេ ឥតោ អាសឹសុ តេ តយោ
រោហិណី នាម នាមេន ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ពុទ្ធបូជកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ពុទ្ធបូជកត្ថេរស្ស អបទានំ សមត្តំ ។

ចតុត្ថំ ភាណវារំ ។

## បញ្ចមំ បុប្ផច្ឆទនិយត្ថេរាបទានំ

(៣៥) សុនន្ទោ នាម នាមេន ព្រាហ្មណោ មន្តបារគូ
អជ្ឈាយកោ យាចយោគោ វាជបេយ្យំ អយាជយិ ។
បទុមុត្តរោ លោកវិទូ អគ្គោ ការុណិកោ ឥសិ
ជនតំ អនុកម្បន្តោ អម្ពរេ ចង្កមី តទា ។





ក្នុងកប្បទី ១៨០០ អំពីកប្បនេះ ព្រោះហេតុតែខ្ញុំបានបូជាព្រះពុទ្ធ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ១៤០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៣ ជាតិ ព្រះនាមរោហិណីដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះពុទ្ធបូជកត្ថេរមានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ពុទ្ធបូជកត្ថេរាបទាន ។

ចប់ ភាណវារៈ ទី ៤ ។

## បុប្ផច្ឆទនិយត្ថេរាបទាន ទី ៥

(៣៥) មានព្រាហ្មណ៍ម្នាក់ មាននាមសុនន្ទៈ ជាអ្នករៀនចប់មន្ត ស្វាធ្យាយមន្ត គួរគេសូមបាន បានបូជានូវយញ្ញឈ្មោះវាជបេយ្យៈ ។ កាលនោះ ព្រះលោកវិទូជាអគ្គបុគ្គល ព្រះនាមបទុមុត្តរៈ ទ្រង់ប្រកបដោយសេចក្តីករុណា ទ្រង់ស្វែងរកនូវគុណ អនុគ្រោះដល់ពួកជន ស្តេចចង្ក្រមនាអាកាស ។

ចង្កមិត្វាន សម្ពុទ្ធោ សព្វញ្ញូ លោកនាយកោ
មេត្តាយ អផរី សត្តេ អប្បមាណេ និរូបធី(១) ។
វណ្ណំ ជិត្វាន ពុទ្ធានំ ព្រាហ្មណោ មន្តបារគូ
សព្វេ សិស្សេ សមានេត្វា អាកាសេ ឧក្ខិបាបយិ ។
យាវតា ឆទំ អាសិ បុប្ផានំ ឆទនំ តទា
ពុទ្ធស្ស អនុភាវេន សត្តាហំ ន វិកម្បថ ។
តេនេវ សុក្កមូលេន អនុភោត្វាន សម្បទា
សព្វាសវេ បរិញ្ញាយ តិណ្ណោ លោកេ វិសត្តិកំ ។
ឯការសេ កប្បសតេ បញ្ចតឹសាសុំ ខត្តិយា
អម្ពរំសសនាមា(២) ចក្កវត្តី មហព្វលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា បុប្ផឆទនិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បុប្ផឆទនិយត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. អប្បមាណោ និរូបធិ ។ ២ ម. គន្ធិ បោត្ថកេ អមាតាមា ច កដាតេនំ ទិស្សន្តិ ។



លុះព្រះសម្ពុទ្ធ ជាសព្វញ្ញូ ជាលោកនាយក ទ្រង់ចង្ក្រមរួចហើយ ក៏ផ្សាយមេត្តាចំពោះពួកសត្វ (សព្វទិស) មិនមានប្រមាណ មិនមានឧបធិ ។ ព្រាហ្មណ៍ជាអ្នកចេះចប់មន្ត បានបេះយកផ្កាទាំងឡាយ ប្រជុំពួកសិស្សទាំងអស់ ហើយបោះទៅលើអាកាស ។ ក្នុងកាលនោះ ដរាបណាមានគ្រឿងប្រក់ដោយផ្កាជាកំណត់ ហេតុនៃអានុភាពនៃព្រះពុទ្ធ ផ្កាមិនបានរំភាយ អស់៧ថ្ងៃ ។ ដោយកុសលមូលនោះឯង ខ្ញុំបានសោយសម្បត្តិ កំណត់ដឹងនូវអាសវៈទាំងពួង ឆ្លងនូវតណ្ហាជាគ្រឿងជាប់ក្នុងលោក ។ ក្នុងកប្បទី ១០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៣៥ ជាតិ មានព្រះនាមអម្ពរំសៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបុប្ផឆទនិយត្ថេរមានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បុប្ផឆទនិយត្ថេរាបទាន ។

## បញ្ចមំ រហោសញ្ញកត្ថេរាបទានំ

[៣៥] ហិមវន្តស្សាវិទូរេ វសភោ នាម បព្វតោ
តស្មឹ បព្វតបាទម្ហិ អស្សមោ អាសិ មាបិតោ ។
តីណិ សិស្សសហស្សានិ វាចេសឹ ព្រាហ្មណោ តទា
សំសាវិត្វាន តេ សិស្សេ ឯកមន្តំ ឧបាវិសឹ ។
ឯកមន្តំ និសីទិត្វា ព្រាហ្មណោ មន្តបារគូ
ពុទ្ធវេទំ គវេសន្តោ ញាណេ ចិត្តំ បសាទយឹ ។
តត្ថ ចិត្តំ បសាទេត្វា និសីទឹ បណ្ណសន្ថរេ
បល្លង្កំ អាភុជិត្វាន តត្ថ កាលំកតោ អហំ ។
ឯកត្តឹសេ ឥតោ កប្បេ យំ សញ្ញមលភឹ តទា
ទុគ្គតឹ នាភិជានាមិ ញាណសញ្ញាយិទំ ផលំ ។
សត្តវីសតិ កប្បម្ហិ រាជា សិរីធរោ អហុ
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្ពលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។



## រហោសញ្ញកត្ថេរាបទាន ទី ៥

(៣៥) មានភ្នំមួយឈ្មោះវសភៈ នៅជិតព្រៃហិមពាន្ត ខ្ញុំសាងអាស្រមនៅជើងភ្នំនោះ ។ កាលនោះ ខ្ញុំជាព្រាហ្មណ៍ បានបង្រៀនសិស្សបីពាន់នាក់ លុះបង្រៀនសិស្សទាំងនោះរួចហើយ ក៏ចូលទៅកាន់ទីសមគួរ ។ លុះព្រាហ្មណ៍ គឺខ្ញុំនេះឯង ជាអ្នកចេះចប់មន្ត អង្គុយក្នុងទីសមគួរហើយ ស្វែងរកមើលវេទរបស់ព្រះពុទ្ធ ក៏បាននាំចិត្តឲ្យជ្រះថ្លាក្នុងញាណ ។ លុះខ្ញុំនាំចិត្តឲ្យជ្រះថ្លា ក្នុងញាណនោះរួចហើយ ក៏អង្គុយលើកម្រាលស្លឹកឈើ ពែនភ្នែនធ្វើមរណកាលក្នុងទីនោះ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានដល់នូវសេចក្តីសំគាល់ (ក្នុងញាណ) ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃញាណសញ្ញា ។ ក្នុងកប្បទី ២៧ អំពីកប្បនេះ ខ្ញុំកើតជាស្តេចចក្រពត្តិ ព្រះនាមសិរីធរៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ពាក្យសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា រហោសញ្ញិកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

រហោសញ្ញិកត្ថេរស្ស អបទានំ សមត្តំ ។

## ឆដ្ឋំ ចម្បកបុប្ផិយត្ថេរាបទានំ

(៣៦) កណិការំវ ជោតន្តំ និសិន្នំ បព្វតន្តរេ
ឱភាសេន្តំ ទិសា សព្វា ឱសធី វិយ តារកំ(១) ។
តយោ មាណវកា អាសុំ សកេ សិប្បេ សុសិក្ខិតា
ខារិភារំ គហេត្វាន អន្វេន្តិ មម បច្ឆតោ ។
បុដកេ សត្ត បុប្ផានិ និក្ខិត្តានិ តបស្សិនា
គហេត្វា តានិ ញាណម្ហិ វេស្សភុស្សាភិរោបយិំ ។
ឯកត្តិំសេ ឥតោ កប្បេ យំ បុប្ផមភិរោបយិំ
ទុគ្គតិំ នាភិជានាមិ ញាណបូជាយិទំ ផលំ ។
ឯកូនតិំសកប្បម្ហិ វិហតាភាសនាមកោ(២)
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្ពលោ(៣) ។

១ ម. ឱសធិ វិយ តារកា ។ ២ ម. វិគុណាភាសនាមកោ ។ ៣ ម. រាជាហោសិ មហព្ពលោ ។





បានឮថា ព្រះរហោសញ្ញកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ រហោសញ្ញកត្ថេរាបទាន ។

## ចម្បកបុប្ផិយត្ថេរាបទាន ទី ៦

(៣៦) (ព្រះសម្ពុទ្ធ) ទ្រង់រុងរឿងដូចផ្កាកណិការ ទ្រង់គង់នៅតាមចន្លោះភ្នំ ញុំាងទិសទាំងពួងឲ្យភ្លឺដូចផ្កាយព្រឹក មាណព ៣ នាក់ ជាអ្នកសិក្សាជំនាញក្នុងសិល្បសាស្ត្ររបស់ខ្លួន នាំគ្នាកែកស្បែកដើរមកអំពីក្រោយខ្ញុំ ខ្ញុំបានយកផ្កាទាំង ៧ ដែលតាបសដាក់ក្នុងកញ្ចប់នោះ ហើយបូជាផ្កាទាំងនោះ ចំពោះញាណ របស់ព្រះវេស្សភូសម្ពុទ្ធ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃញាណបូជា ។ ក្នុងកប្បទី ២៩ អំពីកប្បនេះ ខ្ញុំកើតជាស្តេចចក្រពត្តិ ព្រះនាមវិហតាភាសៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ។
ឥត្ថំ សុទំ អាយស្មា ធម្មរុចិយោ ថេរោ
ឥមា គាថាយោ អភាសិត្ថាតិ ។

ធម្មរុចិយត្ថេរស្ស អបទានំ សមត្តំ ។

## សត្តមំ អត្ថសន្ទស្សកត្ថេរាបទានំ

(៣៧) វិសាលមាឡេ អាសីនោ អទ្ទសំ លោកនាយកំ
ខីណាសវំ ពលប្បត្តំ ភិក្ខុសង្ឃបុរក្ខតំ ។
សតសហស្សា តេវិជ្ជា ឆឡភិញ្ញា មហិទ្ធិកា
បរិវារេន្តិ សម្ពុទ្ធំ កោ ទិស្វា នប្បសីទតិ។
ញាណេ ឧបនិធាយស្ស ន វិជ្ជតិ សទេវកេ
អនន្តញាណំ សម្ពុទ្ធំ កោ ទិស្វា នប្បសីទតិ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះធម្មរុចិយត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ធម្មរុចិយត្ថេរាបទាន ។

## អត្ថសន្ទស្សកត្ថេរាបទាន ទី ៧

(៣៧) ខ្ញុំអង្គុយនៅក្នុងរោងធំ បានឃើញ (ព្រះពុទ្ធមុនី) ជាលោកនាយក ទ្រង់អស់អាសវៈ ទ្រង់ដល់នូវពលធម៌ មានភិក្ខុសង្ឃហែហមរោម ។ (ខ្ញុំសរសើរថា) ភិក្ខុសង្ឃទាំងមួយសែនអង្គ សុទ្ធតែជាអ្នកបានវិជ្ជា ៣ អភិញ្ញា ៦ មានឫទ្ធិច្រើន តែងហែហមរោមព្រះសម្ពុទ្ធ អ្នកណាឃើញហើយ នឹងមិនជ្រះថ្លាបាន ។ (ក្នុងលោក) ព្រមទាំងទេវលោក ឥតមានញាណណានឹងប្រៀបផ្ទឹមក្នុងញាណព្រះសម្ពុទ្ធបានឡើយ អ្នកណាឃើញព្រះសម្ពុទ្ធមានញាណរកទីបំផុតគ្មានហើយ នឹងមិនជ្រះថ្លាបាន ។

ធម្មកាយញ្ច ទីបេន្តិ(១) កេវលំ រតនាករំ
វិកោបេតុំ ន សក្កោន្តិ កោ ទិស្វា នប្បសីទតិ។
ឥមាហិ តីហិ គាថាហិ នាយកោ បុរក្ខិ សោ(២)
បទុមុត្តរំ ជវិត្វាន សម្ពុទ្ធំ អបរាជិតំ ។
តេន ចិត្តប្បសាទេន ពុទ្ធសន្ទីទេន ច
កប្បានំ សតសហស្សំ ទុគ្គតឹ នុបបជ្ជហំ ។
ឥតោ តីសេ កប្បសតេ សុមិត្តា នាម ខត្តិយា
សត្តរតនសម្បន្នា ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ។

ឥត្ថំ សុទំ អាយស្មា អគ្គសន្ទស្សកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អគ្គសន្ទស្សកត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. ទីបេន្តិ ។ ២ ម. [illegible] ។



មួយទៀត សាវ័កទាំងឡាយសម្ដែងនូវធម្មកាយ ជាទីកើតនៃរតនៈតែប៉ុណ្ណោះ តែមិនអាចឲ្យព្រះសម្ពុទ្ធកម្រើកបានទេ អ្នកណាឃើញហើយ នឹងមិនជ្រះថ្លាបាន ។ នាថបុរសខ្ញុំនោះ ដើរទៅពីគាថានុះ ហើយពោលសរសើរ នូវព្រះបទុមុត្តរៈសម្មាសម្ពុទ្ធ ទ្រង់ឥតមានបុគ្គលផ្ចាលផ្ចាញ់បាន ដោយគាថាទាំង ៣ នេះ ។ ដោយចិត្តជ្រះថ្លានោះផង ដោយការស្ងើចស្ងាលនឹងព្រះពុទ្ធជាម្ចាស់ផង ខ្ញុំមិនដែលទៅកើតក្នុងទុគ្គតិអស់មួយសែនកប្ប ។ ក្នុងកប្បទី ១៣០ អំពីកប្បនេះ ខ្ញុំបានកើតជាក្សត្រចក្រពត្តិ ព្រះនាមសុមិត្តៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអគ្គសន្ទស្សកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់អគ្គសន្ទស្សកត្ថេរាបទាន ។

## អដ្ឋមំ ឯកាសនិយត្ថេរាបទានំ

[៣៨] នារទោ ឥតិ នាមេន កេសរោ(១) ឥតិ មំ វិទូ
កុសលាកុសលំ ឯសំ អគមំ ពុទ្ធសន្តិកំ ។
មេត្តចិត្តោ ការុណិកោ អត្ថទស្សី មហាមុនិ
អស្សាសយន្តោ សត្តេ សោ ធម្មំ ទេសេតិ ចក្ខុមា។
សកំ ចិត្តំ បសាទេត្វា សិរេ កត្វាន អញ្ជលិំ
សត្ថារំ អភិវាទេត្វា បក្កាមិំ បាចិនាមុខោ ។
សត្តរសេ កប្បសតេ រាជា អាសិ មហីបតិ
អមិត្តតបនោ នាម ចក្កវត្តិ មហព្ពលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ។

ឥត្ថំ សុទំ អាយស្មា ឯកាសនិយោ(២) ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឯកាសនិយត្ថេរស្ស អបទានំ សមត្តំ ។

---

១ កត្ថចិ បោត្ថកេ កស្សបោតិ ទិស្សតិ ។ ២ ម. ឯកបទាសនិយោ ។



## ឯកាសនិយត្ថេរាបទាន ទី ៨

(៣៨) ខ្ញុំឈ្មោះនារទៈ ដែលគេស្គាល់ខ្ញុំថា កេសរៈវិញ ខ្ញុំកំពុងតែស្វែងរកកុសលអកុសល ក៏បានទៅកាន់សំណាក់ព្រះពុទ្ធជាម្ចាស់ ។ ព្រះអត្ថទស្សីមហាមុនី មានព្រះហឫទ័យប្រកបដោយមេត្តាករុណា ព្រះពុទ្ធមានព្រះចក្ខុអង្គនោះ ទ្រង់ញ៉ាំងសត្វឲ្យស្រស់ស្រួល ហើយទ្រង់តែងសំដែងធម៌ (ចំពោះសត្វ) ។ ខ្ញុំបានញ៉ាំងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ហើយធ្វើអញ្ជលីលើសិរ្សៈ ថ្វាយបង្គំព្រះសាស្តា រួចឈមមុខទៅកាន់បាចីនទិស ចៀសចេញទៅ ។ ក្នុងកប្បទី ១៧០០ ខ្ញុំបានកើតជាស្តេចចក្រពត្តិជាម្ចាស់ផែនដី ព្រះនាមអមិត្តតបនៈ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកាសនិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឯកាសនិយត្ថេរាបទាន ។

## នវមំ សាលទាយកត្ថេរាបទានំ

(៣៩) មិគរាជា តទា អាសឹ អភិជាតោ សុកេសរី
គិរិទុគ្គំ គវេសន្តោ អទ្ទសំ លោកនាយកំ
អយំ នុ ខោ មហាវីរោ និព្វាបេតិ មហាជនំ
យន្នូនាហំ(១) ឧបាសេយ្យំ ទេវទេវំ នរាសភំ ។
សាខំ សាលស្ស ភញ្ជិត្វា សកោដំ(២) បុប្ផមាហរឹ
ឧបគន្ត្វាន សម្ពុទ្ធំ អទាសឹ បុប្ផមុត្តមំ ។
ឯកនវុតេ ឥតោ កប្បេ យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ បុប្ផទានស្សិទំ ផលំ ។
ឥតោ ច នវមេ កប្បេ វិរោចនសនាមកា
តយោ អាសឹសុ រាជានោ ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សាលទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សាលទាយកត្ថេរស្ស អបទានំ សមត្តំ ។

១ ម. យន្នូនាហំ ។ ២ ម. សកោសំ ។



## សាលទាយកត្ថេរាបទាន ទី ៩

(៣៩) គ្រានោះ ខ្ញុំកើតជាកេសរមិគរាជ ជាអភិជាត កំពុងស្វែងរកភ្នំដែលរកទៅបានដោយកម្រ ក៏បានឃើញព្រះលោកនាយក (ទើបគិតថា) ចុះហ្ន៎ ព្រះមហាវីរៈនេះហើយ ទ្រង់ញុំាងមហាជន ឲ្យរលត់ទុក្ខ បើដូច្នោះ គួរអាត្មាអញចូលទៅអង្គុយជិតព្រះពុទ្ធនេះ ព្រះអង្គជាទេវតារបស់ទេវតា ជានរាសភៈ ។ ទើបខ្ញុំកាច់យកមែករាំង ព្រមទាំងចង្កោមផ្កា ចូលទៅគាល់ព្រះសម្ពុទ្ធ ហើយថ្វាយផ្កាដ៏ប្រសើរ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបុប្ផទាន ។ ក្នុងកប្បទី ៩ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៣ ជាតិ ព្រះនាមវិរោចនៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសាលទាយកត្ថេរមានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សាលទាយកត្ថេរាបទាន ។

## ទសមំ ផលទាយកត្ថេរាបទានំ

[៦០] ជាវេនកោ(១) តទា អាសិំ  បរមាទុទកេនកោ
បព្ភារេ សេយ្យំ កប្បេមិ  អវិទូរេ សិខិសត្ថុនោ ។
សាយំ បាតញ្ច បស្សាមិ  ពុទ្ធំ លោកគ្គនាយកំ
ទេយ្យធម្មោ ច មេ នត្ថិ  ទិបទិន្ទស្ស តាទិនោ ។
បិយាលផលមាទាយ  អគមំ ពុទ្ធសន្តិកំ
បដិគ្គហេសិ ភគវា  លោកជេដ្ឋោ នរាសភោ ។
តតោ បរំ ឧបាទាយ  បរិចារឹ(២) វិនាយកំ
តេន ចិត្តប្បសាទេន  កត្វា កាលំ តតោ អហំ ។
ឯកត្តិំសេ ឥតោ កប្បេ  យំ ផលំ អទទិំ អហំ
ទុគ្គតិំ នាភិជានាមិ  ផលទានស្សិទំ ផលំ ។
ឥតោ បណ្ណរសេ កប្បេ  តយោ អាសុំ មាលភិ(៣)
សត្តរតនសម្បន្នា  ចក្កវត្តី មហព្ពលា ។

១ ម. បារេវតោ ។ ២ ម. ឋារីនំ ។ ៣ ម. តយោ អាសុំ បិយាលិនោ ។



## ផលទាយកត្ថេរាបទាន ទី ១០

[៦០] គ្រានោះ ខ្ញុំកើតជាសត្វបរកេតកៈ(១) ជាសត្វបរកេតកៈ យ៉ាងក្លួចបំផុត ទទួលទានដំណេកនៅក្បែរភ្នំ ក្នុងទីជិតសំណាក់ព្រះសាស្តា ព្រះនាមសិខី ។ ខ្ញុំតែងឃើញព្រះពុទ្ធជាលោកគ្គនាយក ទាំងល្ងាចព្រឹក តែខ្ញុំមិនមានទេយ្យ-ធម៌ថ្វាយព្រះសម្ពុទ្ធ មានព្រះទ័យនឹង ប្រសើរជាងសត្វជើងពីរ ក៏ពុំបាន ។ ខ្ញុំបានយកផ្លែព្រីងនឹង ទៅកាន់សំណាក់ព្រះពុទ្ធ ព្រះមានព្រះភាគ ជាច្បងក្នុងលោក ជានរាសភៈ ទ្រង់ក៏បានទទួលយក ។ លំដាប់តពីនោះ ខ្ញុំធ្វើមរណកាលក្នុងទីនោះ ដោយចិត្តជ្រះថ្លា ក្រោយព្រះវិនាយកដែលខ្ញុំបម្រើហើយនោះ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃផលទាន ។ ក្នុងកប្បទី ១៥ អំពីកប្បនេះ បានជាកើតស្តេចចក្រពត្តិ ៣ ជាតិ ព្រះនាមមាលភិ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។

១ ក្នុងបាលីព្រះត្រៃបិដកភូមាថា "បារេវតោ" ប្រែថា "ព្រាប" ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ។
ឥត្ថំ សុទំ អាយស្មា ផលទាយកោ ថេរោ ឥមា
គាថាយោ អភាសិត្ថាតិ ។

ផលទាយកត្ថេរស្ស អបទានំ សមត្តំ ។

## ឧទ្ទានំ

សោភិតោ សុទស្សនោ ចេវ ចន្ទនោ បុប្ផឆទនោ
រហោ ចម្បកបុប្ផី ច អត្ថសន្ទស្សកោ ច ។
ឯកំសី សាលទទោ ទសមោ ផលទាយកោ
គាថាយោ សត្តតិ ទ្វេ ច គណិតាយោ វិភាវិភិ។

សោភិតវគ្គោ ចុទ្ទសមោ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះផលទាយកត្ថេរមានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ផលទាយកត្ថេរាបទាន ។

## ឧទ្ទាន

សោភិតត្ថេរាបទាន ១ សុទស្សនត្ថេរាបទាន ១ ចន្ទនបូជកត្ថេរាបទាន ១ បុប្ផឆទនិយត្ថេរាបទាន ១ រហោសញ្ញិកត្ថេរាបទាន ១ ចម្បកបុប្ផិយត្ថេរាបទាន ១ អត្ថសន្ទស្សកត្ថេរាបទាន ១ ឯកំសនិយត្ថេរាបទាន ១ សាលទាយកត្ថេរាបទាន ១ ផលទាយកត្ថេរាបទាន ជាគម្រប់ ១០ គាថា ៧២ គឺអ្នកប្រាជ្ញ បានគណនាហើយ ។

ចប់ សោភិតវគ្គ ទី ១៤ ។

## បណ្ណរសមោ ឆត្តវគ្គោ

## បឋមំ អតិឆត្តិយត្ថេរាបទានំ

(៦១) បរិនិព្វុតេ ភគវតិ អត្ថទស្សីនរុត្តមេ
ឆត្តាតិច្ឆត្តំ ការេត្វា ថូបម្ហិ អភិរោបយឹ ។
កាលេន កាលំ អាគន្ត្វា នមស្សឹ លោកនាយកំ
បុប្ផច្ឆទនំ កត្វាន ឆត្តម្ហិ អភិរោបយឹ ។
សត្តរសេ កប្បសតេ ទេវរជ្ជមការយឹ
មនុស្សត្តំ ច លទ្ធាហំ ថូបបូជាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា អតិឆត្តិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អតិឆត្តិយត្ថេរស្ស អបទានំ បឋមំ ។

## ឆត្តវគ្គ ទី ១៥

## អតិឆត្តិយត្ថេរាបទាន ទី ១

(៦១) កាលព្រះមានព្រះភាគ ព្រះនាមអត្ថទស្សី ទ្រង់ប្រសើរជាងពួកនរៈ ទ្រង់បរិនិព្វានហើយ ខ្ញុំបានឲ្យគេធ្វើឆត្រ ហើយឲ្យលើកឡើងត្រង់ព្រះស្តូប ។ ខ្ញុំបានមកនមស្ការព្រះលោកនាយក សព្វ ១ កាល ហើយធ្វើគ្រឿងប្រក់ដោយផ្កា លើកឡើងតម្កល់ពីខាងលើឆត្រ ។ ក្នុងកប្បទី ១៧០០ អំពីកប្បនេះ ខ្ញុំបានសោយជាទេវរាជ ខ្ញុំមិនដែលទៅកើតជាមនុស្សម្តងឡើយ នេះជាផលនៃថូបបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអតិឆត្តិយត្ថេរមានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អតិឆត្តិយត្ថេរាបទាន ។

## ទុតិយំ ថម្ភារោបកត្ថេរាបទានំ

(៦៦) និព្វុតេ លោកនាថម្ហិ ធម្មទស្សីនរាសភេ
អារោបេសឹ ធជត្ថម្ភំ ពុទ្ធសេដ្ឋស្ស ចេតិយេ ។
និស្សេណឹ មាបយិត្វាន ថូបសេដ្ឋំ សមារុហឹ(១)
ជាតិបុប្ផំ គហេត្វាន ថូបម្ហិ អភិរោបយឹ ។
អហោ ពុទ្ធោ អហោ ធម្មោ អហោ នោ សត្ថុសម្បទា
ទុគ្គតឹ នាភិជានាមិ ថូបបូជាយិទំ ផលំ ។
ចតុន្នវុតេ ឥតោ កប្បេ ថូបសិខសនាមកា
សោឡសាសឹសុ រាជានោ ចក្កវត្តី មហព្វលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ថម្ភារោបកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ថម្ភារោបកត្ថេរស្ស អបទានំ សមត្តំ ។

១ ម. សមារុហឹ ។





## ថម្ភារោបកត្ថេរាបទាន ទី ២

(៦៦) កាលព្រះលោកនាថព្រះនាមធម្មទស្សី ជានរាសភៈ ទ្រង់បរិនិព្វាន ខ្ញុំបានលើកដងទង់ ត្រង់ចេតិយរបស់ព្រះសម្ពុទ្ធដ៏ប្រសើរ ។ ខ្ញុំបានធ្វើជណ្ដើរសម្រាប់ឡើងទៅកាន់ព្រះស្តូបដ៏ប្រសើរ បានកាន់យកផ្កាជាតព្រឹក្សទៅដោតលើព្រះស្តូប ដោយកាន់ចិត្តថា ព្រះពុទ្ធ ជាបុគ្គលអស្ចារ្យ ព្រះធម៌ជាសភាពអស្ចារ្យ សម្បទារបស់ព្រះសាស្តានៃយើង ជារបស់អស្ចារ្យ ។ ដោយសារកុសលកម្មនេះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃថូបបូជា ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១៦ ជាតិ ព្រះនាមថូបសិខៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះថម្ភារោបកត្ថេរមានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ថម្ភារោបកត្ថេរាបទាន ។

## តតិយំ វេទិការកត្ថេរាបទានំ

(៤៣) និព្វុតេ លោកនាថម្ហិ បិយទស្សីនរុត្តមេ

បសន្នចិត្តោ សុមនោ ពុទ្ធវេទិមកាសហំ ។

មណីហិ បរិវារេត្វា អកាសិំ វេទិមុត្តមំ(១)

វេទិកាយ មហំ កត្វា តត្ថ កាលំ កតោ អហំ ។

យំ យំ យោនុបបជ្ជាមិ ទេវត្តំ អថ មានុស្សំ

មណី ធារេន្តិ អាកាសេ បុញ្ញកម្មស្សិទំ ផលំ ។

សោឡសិតោ កប្បសតេ មណិប្បកាសនាមកា

ចត្តាឡីសុ(២) ខត្តិយា ចក្កវត្តី មហព្វលា ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា វេទិការកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

វេទិការកត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. អាកាសិំ វេទមុត្តមំ ។ ២ ម. ចត្តាឡីសំ ។



## វេទិការកត្ថេរាបទាន ទី ៣

(៤៣) កាលព្រះលោកនាថ ព្រះនាមបិយទស្សី ជានរៈដ៏ឧត្តម ទ្រង់បរិនិព្វានហើយ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តសោមនស្ស បានសាងនូវវេទិកាសម្រាប់ជាពុទ្ធបូជា ។ ខ្ញុំព័ទ្ធនូវវេទិកានោះ ដោយកែវមណី ហើយរៀបចំធ្វើបុណ្យឆ្លងវេទិកាដ៏ប្រសើរ ហើយក៏ធ្វើមរណកាល ក្នុងវេលានោះ ។ ខ្ញុំទៅកើតក្នុងកំណើតណា ៗ ទោះបីជាទេវតា ឬជាមនុស្ស ទេវតាទាំងឡាយ តែងកាន់នូវកែវមណីឰដ៏អាកាស (ចំពោះខ្ញុំ) នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បទី ១១៦ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៣៤ ជាតិ ព្រះនាមមណិប្បកាស ផ្ទួនគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះវេទិការកត្ថេរមានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ វេទិការកត្ថេរាបទាន ។

## ឆដ្ឋំ សបរិវារិយត្ថេរាបទានំ

(៦៦) បទុមុត្តរោ នាម ជិនោ លោកជេដ្ឋោ នរាសភោ
ជលិត្វា អគ្គិក្ខន្ធោវ សម្ពុទ្ធោ បរិនិព្វុតោ ។
និព្វុតេ ច មហាវីរេ ថូបោ វិត្ថារិកោ អហុ
ថូបឆត្តំ(១) ឧបដ្ឋេន្តិ ធាតុគេហេ វរុត្តមេ(២) ។
បសន្នចិត្តោ សុមនោ អកំ ចន្ទនវេទិកំ
ទិស្សតិ ថូបកោ ច ថូបានុច្ចារិតំ សទា ។
ភវេ និព្វត្តមានម្ហិ ទេវត្តេ អថ មានុសេ
ឱមត្តំ មេ ន បស្សាមិ បុព្វកម្មស្សិទំ ផលំ ។
បញ្ចទសេ កប្បសតេ ឥតោ អដ្ឋ ជនា អហុំ
សព្វេ សមត្តនាមា តេ ចក្កវត្តី មហព្វលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

១ ម. ទូរតោ ។ ២ ម. ធាតុគេហវរុត្តមេ ។



## សបរិវារិយត្ថេរាបទាន ទី ៦

(៦៦) ព្រះជិនស្រីសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ជាច្បងក្នុងលោក ជានរាសភៈ ទ្រង់រុងរឿងដូចគំនរភ្លើង ទ្រង់បរិនិព្វានហើយ ។ លុះព្រះមហាវីរៈ ទ្រង់បរិនិព្វានហើយ ព្រះស្តូបជារបស់ធំសម្បើមក៏កើតមានឡើង (ក្នុងកាលនោះ) ពួកជនតែងនាំគ្នាចូលទៅបម្រើព្រះស្តូប ត្រង់ល្វែងតម្កល់ព្រះធាតុ ដ៏ប្រសើរឧត្តម ។ កាលនោះខ្ញុំមានចិត្តជ្រះថ្លា មានចិត្តសោមនស្ស បានសាងរឿនខ្លឹមចន្ទន៍ បានឃើញស្តូបនិងរឿនក្រស្តូប ដ៏សមគួរដល់ព្រះស្តូប ។ កាលខ្ញុំកើតក្នុងភព (ណាៗ) ទោះជាទេវតា ឬជាមនុស្ស ខ្ញុំមិនបានជួបនូវភាពថោកទាបឡើយ នេះជាផលនៃបុព្វកម្ម ។ ក្នុងកប្បទី ១១៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៨ ជាតិ ព្រះនាមសមត្តៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា សបរិករិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សបរិករិយត្ថេរស្ស អបទានំ សមត្តំ ។

## បញ្ចមំ ឧម្មាបុប្ផិយត្ថេរាបទានំ

(៤៩) និព្វុតេ លោកមហិតេ អាហុតីនំ បដិគ្គហេ
សិទ្ធត្ថេ គតវតិ មហាថូបមហោ អហុ ។
មហេ បវត្តមានម្ហិ សិទ្ធត្ថស្ស មហេសិនោ
ឧម្មាបុប្ផំ គហេត្វាន ថូបម្ហិ អភិរោបយឹ ។
ចតុន្នវុតេ ឥតោ កប្បេ យំ បុប្ផមភិរោបយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
ឥតោ ច នវមេ កប្បេ សោមទេវសនាមកា
បញ្ចាសីតិសុ រាជានោ ចក្កវត្តី មហព្វលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។



បានឮថា ព្រះសបរិករិយត្ថេរមានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សបរិករិយត្ថេរាបទាន ។

## ឧម្មាបុប្ផិយត្ថេរាបទាន ទី ៥

(៤៩) កាលព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ ដែលពួកសត្វលោកបូជាហើយ ជាអ្នកទទួលនូវគ្រឿងបូជា ទ្រង់បរិនិព្វានហើយ ក៏មានការឆ្លងព្រះស្តូបដ៏ធំ ។ កាលដែលកំពុងរៀបចំឆ្លងព្រះស្តូប ខ្ញុំក៏បានយកផ្កាទៅដាក់លើព្រះស្តូប នៃព្រះសិទ្ធត្ថៈមហេសី ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៩ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៨៥ ជាតិ ព្រះនាមសោមទេវៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា ឧម្មាបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឧម្មាបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

## ឆដ្ឋំ អនុលោមទាយកត្ថេរាបទានំ

(៦៦) អនោមទស្សិស្ស មុនិនោ ពោធិវេទឹ អការយឹ

សុធាយ បិណ្ឌំ ទត្វាន  បាណិកម្មំ អការយឹ ។
ទិស្វា តំ សុកតំ កម្មំ  អនោមទស្សី នរុត្តមោ
ភិក្ខុសង្ឃេ ឋិតោ សត្ថា  ឥមំ គាថំ អភាសថ
ឥមិនា សុធកម្មេន  ចេតនាបណិធីហិ ច
សម្បត្តឹ អនុភោត្វាន  ទុក្ខស្សន្តំ ករិស្សតិ ។
បសន្នមុខវណ្ណោម្ហិ  ឯកគ្គោ សុសមាហិតោ
ធារេមិ អន្តិមំ ទេហំ  សម្មាសម្ពុទ្ធសាសនេ ។
ឥតោ កប្បសតេ អាសិ  បរិបុណ្ណោ អនូនកោ
រាជា សព្វស្សនោ[១] នាម  ចក្កវត្តី មហព្ពលោ ។

១ ឱ. សព្វឃោសោ នាម ។



បានឮថា ព្រះឧម្មាបុប្ផិយត្ថេរមានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឧម្មាបុប្ផិយត្ថេរាបទាន ។

## អនុលោមទាយកត្ថេរាបទាន ទី ៦

(៦៦) ខ្ញុំបានធ្វើវេទិកាពោធិព្រឹក្ស នៃព្រះមុនីព្រះនាមអនោមទស្សី បានដាក់ដុំបាយអ ហើយធ្វើនូវបាណិកម្ម (ប្លូក) ។ ព្រះសាស្តាព្រះនាមអនោមទស្សី ប្រសើរជាងនរៈ គង់ក្នុងកណ្តាលភិក្ខុសង្ឃ ឃើញអំពើដែលខ្ញុំធ្វើល្អនោះហើយ ទើបសំដែងគាថានេះថា កុលបុត្តនេះ បាននូវសម្បត្តិ ដោយការប្លុកបាយអនេះផង ដោយការតម្កល់ទុកនូវចេតនាផង ហើយនឹងធ្វើនូវព្រះនិព្វានជាទីបំផុតទុក្ខ ។ ខ្ញុំមានសម្បុរមុខថ្លាស្រស់ មានចិត្តនឹងនៅក្នុងអារម្មណ៍តែមួយ មានចិត្តតម្កល់មាំល្អ ខ្ញុំទ្រទ្រង់នូវកាយជាទីបំផុត ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ។ ក្នុងកប្បទី ១០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមសព្វស្សនៈ ទ្រង់បរិបូណ៌ មិនខ្វះខាត (ដោយសម្បត្តិ) មានកម្លាំងច្រើន ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា អនុលោមទាយកោ(១) ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អនុលោមទាយកត្ថេរស្ស អបទានំ ឆដ្ឋំ ។

## សត្តមំ មគ្គទាយកត្ថេរាបទានំ

(៦៧) ឧត្តរិត្វាន នទិកំ វនំ គច្ឆតិ ចក្ខុមា
តមទ្ទសាសិំ សម្ពុទ្ធំ សិទ្ធត្ថំ វរលក្ខណំ ។
កុទ្ទាលបិដកមាទាយ សមំ កត្វាន តំ បថំ
សត្ថារំ អភិវាទេត្វា សកំ ចិត្តំ បសាទយឹ ។
ឯកនវុតេ ឥតោ កប្បេ យំ មគ្គមករឹ តទា
ទុគ្គតឹ នាភិជានាមិ មគ្គទានស្សិទំ ផលំ ។

១ ម. អនុឡោមទាយកោ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអនុលោមទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អនុលោមទាយកត្ថេរាបទាន ។

## មគ្គទាយកត្ថេរាបទាន ទី ៧

(៦៧) ព្រះសម្ពុទ្ធមានបញ្ញាចក្ខុ ព្រះនាមសិទ្ធត្ថៈ ទ្រង់ឆ្លងស្ទឹង ស្តេចពុទ្ធដំណើរទៅកាន់ព្រៃ ខ្ញុំបានឃើញព្រះសម្ពុទ្ធ ព្រះនាមសិទ្ធត្ថៈនោះ ទ្រង់មានលក្ខណៈដ៏ប្រសើរ ទើបខ្ញុំកាន់យកចបនិងកញ្ជើ ធ្វើផ្លូវនោះឲ្យរាបស្មើ ហើយថ្វាយបង្គំព្រះសាស្តា ហើយញ៉ាំងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លូវ ។

សត្តបញ្ញាសកប្បម្ហិ ឯកោ អាសឹ ជនាធិបោ
នាមេន សុប្បពុទ្ធោតិ នាយកោ សោ នរិស្សរោ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ។
ឥត្ថំ សុទំ អាយស្មា ឆត្តទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឆត្តទាយកត្ថេរស្ស អបទានំ សត្តមំ ។

## អដ្ឋមំ ផលកទាយកត្ថេរាបទានំ

[៦៨] យានការោ បុរេ អាសឹ ទារុកម្មេ សុសិក្ខិតោ
ចន្ទនេន ផលកំ កត្វា អទាសឹ លោកពន្ធុនោ។
បភាសតិ ឥទំ ព្យម្ហំ សុវណ្ណស្ស សុនិម្មិតំ
ហត្ថិយានំ អស្សយានំ ទិព្វយានំ ឧបដ្ឋិតំ ។



ក្នុងកប្បទី ៥៧ អំពីកប្បនេះ ខ្ញុំនោះបានកើតជាស្តេច ១ អង្គ ព្រះនាមសុប្បពុទ្ធ ជាធំជាងជន ជានាយក ជាឥស្សរៈលើពួកនរជន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឆត្តទាយកត្ថេរមានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឆត្តទាយកត្ថេរាបទាន ។

## ផលកទាយកត្ថេរាបទាន ទី ៨

[៦៨] កាលពីដើមខ្ញុំជាអ្នកធ្វើយាន បានសិក្សាស្ទាត់ក្នុងការឈើ បានធ្វើផែនក្តារដោយខ្លឹមចន្ទន៍ ថ្វាយចំពោះព្រះលោក-ពន្ធុ ។ (ដោយកុសលកម្មនោះ) ទើបវិមាននេះ ដែលបុញ្ញកម្មតាក់តែងដោយមាស តែងភ្លឺស្វាងរុងរឿង មានដំរីយាន សេះយាន ទិព្វយាន កើតប្រាកដឡើង (ដល់ខ្ញុំ) ។

អដ្ឋមំ ផលទាយកត្ថេរាបទានំ

បាសាទា សិវិកា ចេវ    និព្វត្តន្តិ យទិច្ឆកំ
អក្ខុព្ភំ រតនំ មយ្ហំ    ផលទានស្សិទំ ផលំ ។
ឯកនវុតេ ឥតោ កប្បេ    ផលំ យំ អហំ ទទឹ
ទុគ្គតឹ នាភិជានាមិ    ផលទានស្សិទំ ផលំ ។
សត្តបញ្ញាសកប្បម្ហិ    ចតុរោ ករិម្មិតា
សត្តរតនសម្បន្នា    ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ    វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ផលទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ផលទាយកត្ថេរស្ស អបទានំ សមត្តំ ។

## នវមំ វិធិសកិយត្ថេរាបទានំ

(៤៨) សុមេធោ នាម នាមេន    សយម្ភូ អបរាជិតោ
វិវេកមនុព្រូហន្តោ    អជ្ឈោគាហិ មហាវនំ ។



ផលទាយកត្ថេរាបទាន ទី ៨

ទាំងប្រាសាទ និងគ្រែស្នែង ក៏កើតឡើង (ដល់ខ្ញុំ) កែវរបស់ខ្ញុំមិនកំរើក គួរតាមប្រាថ្នា (ក៏កើតឡើង) ដល់ខ្ញុំ នេះជាផល នៃផ្លែឈើ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផ្លែឈើ ។ ក្នុងកប្បទី ៥៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ ៤ ជាតិ ព្រះនាមករិម្មិតៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះផលទាយកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ផលទាយកត្ថេរាបទាន ។

## វិធិសកិយត្ថេរាបទាន ទី ៩

(៤៨) ព្រះសយម្ភូ ព្រះនាមសុមេធៈ ឥតមានបុគ្គលឈ្នះបាន ទ្រង់ចម្រើនវិវេក ស្ដេចចូលទៅកាន់ព្រៃធំ ។

សលលំ ពុប្ផិតំ ទិស្វា គន្ធិត្វាន វដំសកំ
ពុទ្ធស្ស អភិរោបេសឹ សម្មុខា លោកនាយកំ ។
តឹសកប្បសហស្សម្ហិ យំ បុប្ផមភិរោបយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
ឯកវីសេ កប្បសតេ សោឡសាសឹសុ និម្មិតា
សត្តរតនសម្បន្នា ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា វដំសកិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

វដំសកិយត្ថេរស្ស អបទានំ សមត្តំ ។



ខ្ញុំបានឃើញដើមស្រល់មានផ្ការីក (ទើបកាច់យកមក) ហើយក្រងធ្វើជាគ្រឿងប្រដាប់ក្បាល បង្អោនថ្វាយព្រះពុទ្ធ ជាលោកនាយក ចំពោះព្រះភក្ត្រ ។ ក្នុងកប្បទី ៣០.០០០ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ១១៨ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១៦ ជាតិ ព្រះនាមនិម្មិតៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះវដំសកិយត្ថេរមានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ វដំសកិយត្ថេរាបទាន ។

## ទសមំ បល្លង្កទាយកត្ថេរាបទានំ

(៩០) សុមេធស្ស ភគវតោ លោកជេដ្ឋស្ស តាទិនោ
បល្លង្កោ ហិ មយា ទិន្នោ សឧត្តរសបច្ឆទោ ។
សត្តរតនសម្បន្នោ បល្លង្កោ អាសិ សោ តទា
មម សង្កប្បមញ្ញាយ និព្វត្តតិ សទា មម ។
តឹសកប្បសហស្សម្ហិ យំ បល្លង្កមទទិន្តទា
ទុគ្គតឹ នាភិជានាមិ បល្លង្កស្ស ឥទំ ផលំ ។
វីសកប្បសហស្សម្ហិ សុវណ្ណាភា តយោ ជនា
សត្តរតនសម្បន្នា ចក្កវត្តី មហព្វលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ។
ឥត្ថំ សុទំ អាយស្មា បល្លង្កទាយកោ ថេរោ
ឥមា គាថាយោ អភាសិត្ថាតិ ។

បល្លង្កទាយកត្ថេរស្ស អបទានំ សមត្តំ ។



## បល្លង្កទាយកត្ថេរាបទាន ទី ១០

(៩០) ខ្ញុំបានថ្វាយបល្ល័ង្ក (គ្រែ) ព្រមទាំងកំរាល ចំពោះព្រះមានព្រះភាគព្រះនាមសុមេធៈ ជាច្បងក្នុងលោក ប្រកបដោយតាទិគុណ ។ ពេលនោះ បល្ល័ង្កនឹងបរិបូណ៌ដោយកែវ ៧ ប្រការនោះ (ហាក់ដូចជា) នឹងតម្រិះរបស់ខ្ញុំ តែងកើតសម្រាប់ខ្ញុំ សព្វៗកាល ។ ក្នុងកប្បទី ៣០.០០០ អំពីកប្បនេះក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយបល្ល័ង្ក ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយបល្ល័ង្ក ។ ក្នុងកប្បទី ២០.០០០ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៣ ជាតិ ព្រះនាមសុវណ្ណាភា ប្រកបដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបល្ល័ង្កទាយកត្ថេរមានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បល្លង្កទាយកត្ថេរាបទាន ។

## ឧទ្ទានំ

ជត្តជង្គោ(១) ច សេតុ ច   សបរិវារុម្មាបុប្ផិយោ(២)

អនុលោមោ ច មគ្គោ ច   ផលកោ ច វដំសកោ

បល្លង្កទាយី(៣) គាថាយោ   ឆប្បញ្ញាស បកិត្តិតា ។

វគ្គោ បញ្ញាសមោ ។

១ ម. ជត្តុ ។ ២ ម. បរិវារុម្មាបុប្ផិយោ ។ ៣ ម. បល្លង្កទោ ច ។



## ឧទ្ទាន

អភិសន្តិយត្ថេរាបទាន ១ ជង្ឃាបេតកត្ថេរាបទាន ១ សេតុការ-កត្ថេរាបទាន ១ សបរិវារិយត្ថេរាបទាន ១ ឧម្មាបុប្ផិយត្ថេរ-បទាន ១ អនុលោមទាយកត្ថេរាបទាន ១ មគ្គទាយកត្ថេរ-បទាន ១ ផលកទាយកត្ថេរាបទាន ១ វដំសកិយត្ថេរាបទាន ១ បល្លង្កទាយកត្ថេរាបទាន ១ គាថាទាំង ៥៦ អ្នកប្រាជ្ញបាន ពោលទុកហើយ ។

ចប់ វគ្គទី ៥០ ។

# សោឡសមោ ពន្ធុជីវកវគ្គោ

## បឋមំ ពន្ធុជីវកត្ថេរាបទានំ

[៨១] ចន្ទំវ វិមលំ សុទ្ធំ  វិប្បសន្នមនាវិលំ
នន្ទិភវបរិក្ខីណំ(១)  តិណ្ណំ លោកេ វិសត្តិកំ ។
និព្វាបយន្តំ ជនតំ  តិណ្ណំ តារយតំ មុនឹ(២)
វនស្មឹ ឈាយមានន្តំ  ឯកគ្គំ សុសមាហិតំ ។
ពន្ធុជីវកបុប្ផានិ  លគេត្វា សុត្តកេ អហំ(៣)
ពុទ្ធស្ស អភិរោបេសឹ  សិខិនោ លោកពន្ធុនោ ។
ឯកត្តឹសេ ឥតោ កប្បេ  យំ កម្មមការឹ តទា
ទុគ្គតឹ នាភិជានាមិ  ពុទ្ធបូជាយិទំ ផលំ ។
ឥតោ សត្តមកេ កប្បេ  មនុជិន្ទោ មហាយសោ
សមន្តចក្ខុ នាមាសិ  ចក្កវត្តិ មហព្ពលោ ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនំ ។

១ ម. នន្ទីភវបរិក្ខីណំ ។ ២ ម. រឹ ។ ៣ ម. សុត្តកេនហំ ។

# ពន្ធុជីវកវគ្គ ទី ១៦

## ពន្ធុជីវកត្ថេរាបទាន ទី ១

[៨១] (ខ្ញុំបានឃើញព្រះពុទ្ធព្រះនាមសិខី) ទ្រង់បរិសុទ្ធ ប្រាសចាកមន្ទិលដូចព្រះចន្ទ មានព្រះហឫទ័យថ្លាស្អាត មិនល្អក់ មាននន្ទិភវៈគឺតណ្ហាអស់ហើយ ព្រះអង្គឆ្លងហើយនូវវិសត្តិកាតណ្ហាក្នុងលោក ព្រះអង្គញុំាងប្រជុំជនឲ្យរលត់ទុក្ខ ទ្រង់ឆ្លងហើយ ជាព្រះមុនីរបស់ពួកជនអ្នកឆ្លង កំពុងចម្រើនឈាន មានព្រះហឫទ័យនឹងក្នុងអារម្មណ៍តែមួយ តាំងមាំល្អក្នុងព្រៃ ។ ខ្ញុំចាក់ផ្កាចាប្បាលើខ្សែអំបោះ ហើយថ្វាយចំពោះព្រះពុទ្ធ ព្រះនាមសិខី ជាផៅពង្សនៃលោក ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះនោះ ព្រោះហេតុដែលខ្ញុំបានធ្វើបូជាកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមសមន្តចក្ខុ ទ្រង់មានយសច្រើន ជាធំក្នុងមនុស្ស មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ ហើយតាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា ពន្ធុជីវកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ពន្ធុជីវកត្ថេរស្ស អបទានំ សមត្តំ ។

## ទុតិយំ តម្ពបុប្ផិយត្ថេរាបទានំ

(៨៦) បរកម្មាយនេ យុត្តោ អបរាធំ អកាសហំ
វនន្តំ អភិធាវិស្សំ ភយវេរសមប្បិតោ ។
បុប្ផិតំ បាទបំ ទិស្វា បិណ្ឌិពន្ធំ សុនិម្មិតំ
តម្ពបុប្ផំ គហេត្វាន ពោធិយំ ឱកិរឹ អហំ ។
សម្មជ្ជិត្វាន តំ ពោធឹ បាដលឹ បាទបុត្តមំ
បល្លង្កំ អាភុជិត្វា ពោធិមូលំ ឧបាវិសឹ ។
គតមគ្គំ គវេសន្តា អាគច្ឆុំ មម សន្តិកំ
តេ ច ទិស្វានហំ តត្ថ អាវជ្ជឹ ពោធិមុត្តមំ ។
វន្ទិត្វាន អហំ ពោធឹ វិប្បសន្នេន ចេតសា
អនេកតាលេ បបតឹ គិរិទុគ្គេ ភយានកេ ។



បានឮថា ព្រះពន្ធុជីវកត្ថេរមានអាយុ បានសំដែងនូវគាថា ទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ពន្ធុជីវកត្ថេរាបទាន ។

## តម្ពបុប្ផិយត្ថេរាបទាន ទី ២

(៨៦) ខ្ញុំប្រកបក្នុងការងាររបស់អ្នកដទៃ បានធ្វើនូវកំហុស ជាអ្នកពេញប្រៀបដោយភ័យនិងពៀរ ហើយក៏ស្ទុះរត់ទៅ ក្នុងកណ្ដាលព្រៃ ។ ខ្ញុំឃើញដើមឈើ ដែលមានផ្កាវីកស្គុះស្គាយពន់ជាចង្កោម ដែលធម្មតានិម្មិតល្អហើយ កាន់យកនូវផ្កាក្រហមហើយយកមករោយចុះទៀបពោធិព្រឹក្ស ។ ខ្ញុំបោសដើមប្រទៀងដែលជាឈើដ៏ឧត្ដមជាពោធិព្រឹក្សនោះ ហើយចូលទៅជិតគល់ពោធិព្រឹក្ស អង្គុយផ្គត់ភ្នែន ។ កាលពួកជនស្វែងរកផ្លូវដែលខ្ញុំទៅ ក៏មកកាន់សំណាក់ខ្ញុំ លុះខ្ញុំឃើញនូវពួកជនទាំងនោះ ក៏នឹកដល់ពោធិព្រឹក្សដ៏ឧត្ដម ក្នុងទីនោះ ។ ខ្ញុំមានចិត្តជ្រះថ្លា ថ្វាយបង្គំដើមពោធិព្រឹក្ស រួចហើយក៏ធ្លាក់ទៅក្នុងជ្រោះភ្នំដែលគួរខ្លាច មានជម្រៅច្រើនជួរដើមត្នោត ។

ឯកនវុតេ ឥតោ កប្បេ យំ បុប្ផមភិបូជយិំ
ទុគ្គតិំ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
ឥតោ ច តតិយេ កប្បេ រាជា សម្មសិតោ អហុ
សត្តរតនសម្បន្នោ ចក្កវត្តី មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា កទម្ពបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កទម្ពបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

## តតិយំ វីថិសម្មជ្ជកត្ថេរាបទានំ

(៨៣) ឧទេន្តំ សតរំសិំវ បីតរំសិំវ ភាណុមំ
បណ្ណរសេ យថា ចន្ទំ និយ្យន្តំ លោកនាយកំ ។
អដ្ឋសដ្ឋីសហស្សានិ សព្វេ ខីណាសវា អហុំ
បរិវារិំសុ សម្ពុទ្ធំ ទិបទិន្ទំ នរាសភំ ។





ក្នុងកប្បទី៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាព្រះពុទ្ធ ។ ក្នុងកប្បទី ៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិព្រះនាមសម្មសិតៈ ទ្រង់មានកម្លាំងច្រើន បរិបូណ៌ដោយកែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះកទម្ពបុប្ផិយត្ថេរមានអាយុ បានសម្តែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កទម្ពបុប្ផិយត្ថេរាបទាន ។

## វីថិសម្មជ្ជកត្ថេរាបទាន ទី ៣

(៨៧) ខ្ញុំបានឃើញព្រះពុទ្ធជានាយកនៃលោក កំពុងស្តេចទៅ ដូចព្រះអាទិត្យមានរស្មីច្រើន កាលរះឡើងមានរស្មីគណកំលឿង ឬដូចព្រះចន្ទក្នុងថ្ងៃទី ១៥ កើត ។ ពួកព្រះខីណាស្រពទាំងឡាយមានប្រមាណ ៦៨,០០០ ហោមរោមព្រះសម្ពុទ្ធ ព្រះអង្គជាធំជាងសត្វជើងពីរ ជានរាសភៈ ។

សម្ពុទ្ធិត្វាន តំ វីរំ   និយ្យន្តំ លោកនាយកំ
ទុស្សព្ឋេសិ ធជំ តត្ថ   វិប្បសន្នេន ចេតសា ។
ឯកនវុតេ ឥតោ កប្បេ   យំ ធជំ អភិទេបយិំ
ទុគ្គតឹ នាភិជានាមិ   ធជទានស្សិទំ ផលំ ។
ឥតោ ចតុត្ថកេ កប្បេ   រាជាហោសិ មហារថោ
សព្វាការេន សម្បន្នោ   សុធជោ ឥតិ វិស្សុតោ ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា វិជសម្ពុទ្ធកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

វិជសម្ពុទ្ធកត្ថេរស្ស អបទានំ សមត្តំ ។

## ចតុត្ថំ កក្ការុប្បជកត្ថេរាបទានំ

(៥៤) ទេវបុត្តោ អហំ សន្តោ   បូជយិំ សិខិនាយកំ
កក្ការុបុប្ផំ បគ្គយ្ហ   ពុទ្ធស្ស អភិរោបយិំ ។
ឯកត្តឹសេ ឥតោ កប្បេ   យំ បុប្ផមភិរោបយិំ
ទុគ្គតឹ នាភិជានាមិ   ពុទ្ធបូជាយិទំ ផលំ ។



កាលព្រះលោកនាយកកំពុងយាងទៅ ខ្ញុំមានចិត្តជ្រះថ្លា បានប្រោសផ្លុំនោះ ហើយលើកទង់ជ័យក្នុងទីនោះ ។ ក្នុងកប្បទី៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយទង់ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយទង់ ។ ក្នុងកប្បទី ៤ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេច ព្រះនាមសុធជៈ ទ្រង់មានកម្លាំងច្រើន ទ្រង់បរិបូណ៌ដោយអាការៈទាំងពួង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះវិជសម្ពុទ្ធកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ វិជសម្ពុទ្ធកត្ថេរាបទាន ។

## កក្ការុប្បជកត្ថេរាបទាន ទី ៤

(៥៤) ខ្ញុំជាទេវបុត្រ បានបូជាចំពោះព្រះពុទ្ធជានាយកព្រះនាមសិខី ខ្ញុំកាន់យកផ្កាល្ពៅ បូជាថ្វាយព្រះពុទ្ធ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃពុទ្ធបូជា ។

ឥតោ ច ចតុត្ថេ កប្បេ រាជា សត្តុត្តមោ អហុ
សត្តរតនសម្បន្នោ ចក្កវត្តី មហព្ពលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា កណ្ណារបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កណ្ណារបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

## បញ្ចមំ មន្ទារវបុប្ផិយត្ថេរាបទានំ

(៨៨) ទេវបុត្តោ អហំ សន្តោ បូជយិំ សិខិនាយកំ
មន្ទារវេន បុប្ផេន ពុទ្ធស្ស អភិរោបយិំ ។
សត្តាហំ ធារណំ អាសិ ទិព្វមាលំ តថាគតេ
សព្វេ ជនា សមាគន្ត្វា នមស្សឹសុ តថាគតំ ។
ឯកត្តិំសេ ឥតោ កប្បេ យំ បុប្ផមភិរោបយិំ
ទុគ្គតិំ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។



ក្នុងកប្បទី ៤ អំពីកប្បនេះ ខ្ញុំបានជាស្តេចចក្រពត្តិ ៧ ជាតិ ទ្រង់មានកម្លាំងច្រើន ទ្រង់ឧត្តម បរិបូណ៌ដោយកែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះកណ្ណារបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កណ្ណារបុប្ផិយត្ថេរាបទាន ។

## មន្ទារវបុប្ផិយត្ថេរាបទាន ទី ៥

(៨៨) ខ្ញុំជាទេវបុត្ត បានបូជាចំពោះព្រះពុទ្ធ ជានាយក ព្រះនាមសិខី ខ្ញុំបានបូជា ចំពោះព្រះពុទ្ធដោយផ្កាមន្ទារៈ ។ ផ្កាឈើទិព្វ ជាគ្រឿងប្រដាប់លើព្រះតថាគត អស់ ៧ ថ្ងៃ ពួកជនទាំងអស់មកប្រជុំគ្នាហើយ នមស្ការព្រះតថាគត ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។

ឥតោ ច នវុតេ កប្បេ  រាជាហោសិ ជុតិន្ធរោ
សត្តរតនសម្បន្នោ  ចក្កវត្តិ មហព្វលោ ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនន្តិ ។
ឥត្ថំ សុទំ អាយស្មា  មន្ទារវបុប្ផិយោ ថេរោ
ឥមា គាថាយោ អភាសិត្ថាតិ ។

មន្ទារវបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

## ឆដ្ឋំ កុមុទបុប្ផិយត្ថេរាបទានំ

(៨៦) ហិមវន្តស្សាវិទូរេ  កុក្កុដោ នាម បព្វតោ
តម្ហិ បព្វតបាទម្ហិ  សត្ត ពុទ្ធា វសន្តិ តេ ។
គច្ឆន្តំ បុប្ផិតំ ទិស្វា  ទីបរាជំវ ឧគ្គតំ
ឧភោ ហត្ថេហិ បគ្គយ្ហ  សត្ត ពុទ្ធេ សមោកិរឹ ។
ឆន្នវុតេ ឥតោ កប្បេ  យំ បុប្ផមភិរោបយឹ
ទុគ្គតឹ នាភិជានាមិ  ពុទ្ធបូជាយិទំ ផលំ ។



ក្នុងកប្បទី ៩០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមជុតិន្ធរៈ ទ្រង់មានកម្លាំងច្រើន បរិបូណ៌ដោយកែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះមន្ទារវបុប្ផិយត្ថេរមានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មន្ទារវបុប្ផិយត្ថេរាបទាន ។

## កុមុទបុប្ផិយត្ថេរាបទាន ទី ៦

(៨៦) ភ្នំឈ្មោះកុក្កុដៈ មានក្នុងទីជិតភ្នំហិមពាន្ត ព្រះពុទ្ធ ៧ ព្រះអង្គនោះ តែងគង់នៅទៀបជើងភ្នំនោះ ខ្ញុំបានឃើញដើមកុមុទដែលមានផ្ការីកស្រស់ស្អាយ ដូចព្រះអាទិត្យរះឡើង ទើបកាន់យកដោយដៃទាំងពីរ ហើយរោយរាយថ្វាយព្រះពុទ្ធទាំង ៧ អង្គ ។ ក្នុងកប្បទី ៩៦ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។

ទ្វេនវុតេ ឥតោ កប្បេ សត្តាសុំ បុប្ផនាមកា
សត្តរតនសម្បន្នា ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា កទម្ពពុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កទម្ពបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

## សត្តមំ តិណសូលកត្ថេរាបទានំ

(៩៧) ហិមវន្តស្សាវិទូរេ ភូតគណោ នាម បព្វតោ
វសតេកោ ជិនោ តត្ថ សយម្ភូ លោកនិស្សដោ ។
តិណសូលំ គហេត្វាន ពុទ្ធស្ស អភិរោបយឹ
ឯកូនសតសហស្ស- កប្បំ ន វិនិបាតកោ ។
ឥតោ ឯកាទសេ កប្បេ ឯកោសិ ធរណីរុហោ
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្ពលោ ។



ក្នុងកប្បទី ៩២ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ ៧ ជាតិ ព្រះនាមបុប្ផៈដូចគ្នា ទ្រង់មានកម្លាំងច្រើន បរិបូណ៌ដោយកែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះកទម្ពបុប្ផិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កទម្ពបុប្ផិយត្ថេរាបទាន ។

## តិណសូលកត្ថេរាបទាន ទី ៧

(៩៧) ភ្នំឈ្មោះភូតគណៈ មានក្នុងទីជិតភ្នំហិមពាន្ត ព្រះជិនស្រី សយម្ភូ ទ្រង់លោសចេញចាកលោក ទ្រង់គង់មួយអង្គឯងក្នុងទីនោះ ។ ខ្ញុំយកផ្កាម្លិះរួតតាំងឡាយ បូជាព្រះពុទ្ធ ខ្ញុំមិនដែលទៅកើតជាវិនិបាត អស់ ៩៩ ពាន់កប្ប ព្រោះកុសលនេះ ។ ក្នុងកប្បទី ១១ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ មួយអង្គ ព្រះនាមធរណីរុហៈ ទ្រង់មានកម្លាំងច្រើន ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ។

បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា តិណសូលកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តិណសូលកត្ថេរស្ស អបទានំ សមត្តំ ។

## អដ្ឋមំ នាគបុប្ផិយត្ថេរាបទានំ

(៨៨) សុវច្ឆោ នាម នាមេន   ព្រាហ្មណោ មន្តបារគូ
បុរក្ខតោ សសិស្សេហិ   វសតិ បព្ពតន្តរេ ។
បទុមុត្តរោ នាម ជិនោ   អាហុតីនំ បដិគ្គហោ
មមុទ្ធរិតុកាមោ សោ   អាគច្ឆិ មម សន្តិកំ ។
វេហាយសេ ចង្កមតិ   ធូបិតោ បជ្ជលិតោ យថា
ហាសំ មមំ វិទិត្វាន   បក្កាមិ បាចិនាមុខោ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតិណសូលកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តិណសូលកត្ថេរាបទាន ។

## នាគបុប្ផិយត្ថេរាបទាន ទី ៨

(៨៨) ព្រាហ្មណ៍ឈ្មោះសុវច្ឆៈ ជាអ្នកដល់នូវត្រើយនៃមន្ត មានពួកសិស្សចោមរោម តែងនៅក្នុងចន្លោះភ្នំ ។ ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ទ្រង់គួរទទួលនូវគ្រឿងបូជា ព្រះអង្គមានប្រាថ្នាដើម្បីស្រោចស្រង់នូវខ្ញុំ ទើបស្តេចមកកាន់សំណាក់ខ្ញុំ ។ ទ្រង់ចង្ក្រមលើអាកាស ដូចប្រទីប រុងរឿង ទ្រង់ជ្រាបច្បាស់ នូវសេចក្តីត្រេកអររបស់ខ្ញុំ ហើយមានព្រះភក្ត្របែរទៅទិសខាងកើត ស្តេចចៀសចេញទៅ ។

តញ្ច អដ្ឋិយំ ទិស្វា    អត្តានំ លោមហំសនំ
ឋាតបុប្ផំ គហេត្វាន    កកមក្កដ្ឋិ និក្ខិរឹ ។
សតសហស្សេ ឥតោ កប្បេ យំ បុប្ផំ និក្ខិរឹ អហំ
តេន ចិត្តប្បសាទេន    ទុគ្គតឹ នុបបជ្ជហំ ។
ឯកត្តឹសេ ឥតោ កប្បេ ភពា អាសឹ មហារថោ
សត្តរតនសម្បន្នោ    ចក្កវត្តិ មហព្វលោ ។
បដិសម្ភិទា ចតស្សោ    វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឋាតបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តនបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

## នវមំ បុន្នាគបុប្ផិយត្ថេរាបទានំ

(៨៩) កាននំ វនមោគ្គយ្ហ    វសាមិ លុទ្ទកោ អហំ
បុន្នាគំ បុប្ផិតំ ទិស្វា    ពុទ្ធសេដ្ឋំ អនុស្សរឹ ។





ចំណែកកាលខ្ញុំ ឃើញព្រះធាតុសាស្តារបស់ម្ចាស់ ខ្ពស់ជាទីក្រៃលែងនោះហើយ ក៏កាន់យកផ្កាតិណទុំ ពោយកយលើផ្នូរដែលព្រះអង្គទ្រង់បានទៅ ។ ក្នុងកប្ប ទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបាចរាយផ្កា ដោយចិត្តជ្រះថ្លានោះ ខ្ញុំមិនដែលទៅកើតក្នុងទុគ្គតិ ។ ក្នុងកប្ប ទី ៣១ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមមហារថៈ ទ្រង់មានកម្លាំងច្រើន បរិបូណ៌ដោយកែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតនបុប្ផិយត្ថេរមានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តនបុប្ផិយត្ថេរាបទាន ។

## បុន្នាគបុប្ផិយត្ថេរាបទាន ទី ៩

(៨៩) ខ្ញុំជាអ្នកព្រាន បានចូលទៅនៅអាស្រ័យ ក្នុងព្រៃធំ បានឃើញដើមបុន្នាគរីក ដែលមានផ្ការីកស្គុះស្គាយ ហើយនឹករលឹកចំពោះព្រះពុទ្ធ ជាបុគ្គលដ៏ប្រសើរ ។

តំ បុប្ផំ ឱចិនិត្វាន សុកតំ គន្ធគន្ធិកំ(១)
ថូបំ ការិត្វាន បុលិនេ ពុទ្ធស្ស អភិរោបយិំ ។
ចតុន្នវុតេ ឥតោ កប្បេ យំ បុប្ផំ អភិបូជយិំ
ទុគ្គតិំ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
ឯកម្ហិ នវុតេ កប្បេ ឯកោ អាសិំ គរោមានុទោ
សត្តរតនសម្បន្នោ ចក្កវត្តី មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា បុប្ផថូបិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បុប្ផថូបិយត្ថេរស្ស អបទានំ សមត្តំ ។

## ទសមំ កុមុទទាយកត្ថេរាបទានំ

(៦០) ហិមវន្តស្សាវិទូរេ មហាជាតស្សរោ អហុ
បទុមុប្បលសញ្ឆន្នោ បុណ្ឌរីកសមោហិតោ(*) ។

---

● ម. បុណ្ឌរីកសមោត្ថតោ ។



ខ្ញុំបេះផ្កានោះ ដែលមានក្លិនក្រអូប យ៉ាងល្អក្រៃលែង ហើយធ្វើជាព្រះស្តូប លើផែនខ្សាច់ បូជាចំពោះព្រះពុទ្ធ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១ អង្គ ព្រះនាមគរមានុទៈ ប្រកបដោយកម្លាំងច្រើន បរិបូណ៌ដោយកែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបុប្ផថូបិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បុប្ផថូបិយត្ថេរាបទាន ។

## កុមុទទាយកត្ថេរាបទាន ទី ១០

[៦០] មានស្រះកើតឯងដ៏ធំ ក្នុងទីជិតភ្នំហិមពាន្ត ជាស្រះដេរដាសដោយឈូកនិងឧប្បល ព្រោងព្រាតដោយផ្កាឈូកស ។

## ទសមំ កុមុទទាយកត្ថេរាបទានំ

កកុធោ(១) នាម នាមេន តត្ថាសឹ សកុណោ តទា
សីលវា ពុទ្ធិសម្បន្នោ បុញ្ញាបុញ្ញេសុ កោវិទោ ។
បទុមុត្តរោ លោកវិទូ អាហុតីនំ បដិគ្គហោ
ជាតស្សរស្សាវិទូរេ សញ្ចរិត្ថ មហាមុនិ ។
ជលជំ កុមុទំ ឆេត្វា(២) ឧបនេសឹ មហេសិនោ
មម សង្កប្បមញ្ញាយ បដិគ្គហិ មហាមុនិ ។
តញ្ច ទានំ ទទិត្វាន សុក្កមូលេន ចោទិតោ
កប្បានំ សតសហស្សំ ទុគ្គតឹ នុបបជ្ជហំ ។
សោឡសិតោ កប្បសតេ អាសុំ វរុណនាមកា
អដ្ឋ ឯតេ ជនាធិបា ចក្កវត្តី មហព្វលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា កុមុទទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កុមុទទាយកត្ថេរស្ស អបទានំ ទសមំ ។

---

១ ឱ. កក្កុធោ ។ ២ ឆេត្វា ។



## កុមុទទាយកត្ថេរាបទាន ទី ១០

ក្នុងកាលនោះ ខ្ញុំកើតជាបក្សី ជាសកុណជាតិ នៅជិតស្រះនោះ ជាសត្វមានសីល ប្រកបដោយប្រាជ្ញា ឈ្លាសវៃក្នុងអំពើបុណ្យនិងបាប ។ ព្រះពុទ្ធជាមហាមុនី ព្រះនាមបទុមុត្តរៈ ជ្រាបច្បាស់នូវលោក ទ្រង់គួរទទួលនូវគ្រឿងបូជា ត្រាច់ទៅក្នុងទីមិនឆ្ងាយអំពីជាតស្រះនោះ ។ ខ្ញុំបានកាច់ផ្កាកុមុទ ដែលកើតក្នុងទឹក បង្អោនចូលមកថ្វាយព្រះមហេសី ។ ព្រះពុទ្ធជាមហាមុនី ទ្រង់ជ្រាបនូវសេចក្តីត្រិះរិះរបស់ខ្ញុំ ទ្រង់ក៏ទទួលយក ។ ខ្ញុំត្រូវកុសលមូលដាស់តឿន ព្រោះបានឲ្យទាននោះ ខ្ញុំក៏មិនទៅកើតក្នុងទុគ្គតិ អស់មួយសែនកប្ប ។ ក្នុងកប្បទី ១១៦ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៨ ជាតិ ព្រះនាមវរុណៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះកុមុទទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កុមុទទាយកត្ថេរាបទាន ។

## ឧទ្ទានំ

ពន្ធុជីវតម្ពបុប្ផិ  វីថិកក្ការុបុប្ផិយោ
មន្ទារវោ កទម្ពី ច  សូលកោ នាគបុប្ផិយោ
បុន្នាគោ កោមុទី គាថា  ឆប្បញ្ញាសា បកិត្តិតា ។

ពន្ធុជីវកវគ្គោ សោឡសមោ ។

---



## ឧទ្ទាន

ពន្ធុជីវកត្ថេរាបទាន ១ តម្ពបុប្ផិយត្ថេរាបទាន ១ វីថិសម្មជ្ជកត្ថេរាបទាន ១ កក្ការុបុប្ផិយត្ថេរាបទាន ១ មន្ទារវបុប្ផិយត្ថេរាបទាន ១ កទម្ពបុប្ផិយត្ថេរាបទាន ១ សូលកត្ថេរាបទាន ១ នាគបុប្ផិយត្ថេរាបទាន ១ បុន្នាគបុប្ផិយត្ថេរាបទាន ១ កុមុទទាយកត្ថេរាបទាន ១ គាថា (ពាក្យនេះ) មាន៥៦ ដែលលោកសម្តែងទុកហើយ ។

ចប់ពន្ធុជីវកវគ្គ ទី ១៦ ។

---

## សត្តរសមោ សុបារិចរិយវគ្គោ

### បឋមំ សុបារិចរិយត្ថេរាបទានំ

(៦១) បទុមោ នាម នាមេន ទិបទិន្ទោ នរាសភោ
បវនា អភិនិក្ខម្ម ធម្មំ ទេសេតិ ចក្ខុមា ។
យក្ខានំ សមយោ អាសិ អវិទូរេ មហេសិនោ
យេន កិច្ចេន សម្បត្តា អជ្ឈាបេក្ខិំសុ(១) តាវទេ ។
ពុទ្ធស្ស គិរមញ្ញាយ អមតស្ស ច ទេសនំ
បសន្នចិត្តោ សុមនោ អប្ផោដេត្វា ឧបដ្ឋហិំ ។
សុចិណ្ណស្ស ផលំ បស្ស ឧបដ្ឋានស្ស សត្ថុនោ
តិំសកប្បសហស្សេសុ ទុគ្គតិំ នោបបជ្ជហំ ។
ឩនត្តិំសេ កប្បសតេ សមលង្កតនាមកោ
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្ពលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

១ ម. អជ្ឈុបេក្ខិំសុ ។

## សុបារិចរិយវគ្គ ទី ១៧

### សុបារិចរិយត្ថេរាបទាន ទី ១

(៦១) ព្រះពុទ្ធព្រះនាមបទុមៈ ព្រះអង្គជាធំជាងសត្វជើងពីរ ជានរាសភៈ ទ្រង់មានបញ្ញាចក្ខុ ទ្រង់ចេញចាកព្រៃគឺតណ្ហា តែងសំដែងធម៌ ។ ពួកយក្សបានប្រជុំគ្នាក្នុងទីជិតព្រះពុទ្ធមហេសី ដោយកិច្ចដែលពួកយក្សទាំងនោះមកជួបជុំគ្នា ហើយក្រឡេកមើល (នូវព្រះសម្ពុទ្ធ) ក្នុងខណៈនោះ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តត្រេកអរ ដឹងច្បាស់នូវពាក្យរបស់ព្រះពុទ្ធ ជាគ្រឿងសំដែងនូវព្រះនិព្វាន ឈ្មោះអមតៈ ទះដៃហើយ ចូលទៅបម្រើ ។ ខ្ញុំដឹងនូវផលនៃការបម្រើ ដែលខ្ញុំសន្សំល្អហើយ ចំពោះព្រះសាស្ដា ក្នុងកប្បទី ៣ ម៉ឺន ខ្ញុំមិនដែលទៅកើតក្នុងទុគ្គតិឡើយ ។ ក្នុងកប្បទី ១២៩ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ ព្រះនាមសមលង្កតៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា សុធាបិណ្ឌិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សុធាបិណ្ឌិយត្ថេរស្ស អបទានំ សមត្តំ ។

## ទុតិយំ កណវេរបុប្ផិយត្ថេរាបទានំ

(៦៦) សិទ្ធត្ថោ នាម ភគវា លោកជេដ្ឋោ នរាសភោ
បុរក្ខតោ សាវកេហិ នគរំ បដិបជ្ជថ ។
រញ្ញោ អន្តេបុរេ អាសិំ គោបកោ អភិសម្មតោ
បាសាទេ ឧបវិដ្ឋោហំ អទ្ទសំ លោកនាយកំ ។
កណវេរំ គហេត្វាន ភិក្ខុសង្ឃេ សមោកិរិំ
ពុទ្ធស្ស វិសុំ កត្វាន តតោ ភិយ្យោ សមោកិរិំ ។
ចតុន្នវុតេ ឥតោ កប្បេ យំ បុប្ផមភិបូជយិំ
ទុគ្គតិំ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
សត្តាសីតិម្ហិតោ កប្បេ ចតុរាសុំ មហិទ្ធិកា
សត្តរតនសម្បន្នា ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។



បានឮថា ព្រះសុធាបិណ្ឌិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សុធាបិណ្ឌិយត្ថេរាបទាន ។

## កណវេរបុប្ផិយត្ថេរាបទាន ទី ២

[៦៦] ព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ ជាច្បងក្នុងលោក ជានរាសភៈ មានពួកសាវកហែហមហើយ ទ្រង់ស្តេចមកកាន់ក្រុង ។ ខ្ញុំជាអ្នកគ្រប់គ្រងក្នុងខាងក្នុងបុរី របស់ស្តេច ដែលស្តេចតែងតាំង ខ្ញុំចូលទៅក្នុងប្រាសាទ បានឃើញព្រះពុទ្ធជាលោកនាយក ។ ខ្ញុំយកផ្កាល្ហោ រោយរាយចំពោះភិក្ខុសង្ឃ រោយរាយចំពោះព្រះពុទ្ធ ធ្វើឲ្យផ្សេងច្រើនក្រៃលែងជាងនោះ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៨៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ឈ្មោះមហិទ្ធិកៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា កណវេរបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កណវេរបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

## តតិយំ ខជ្ជកទាយកត្ថេរាបទានំ

(៦៣) តិស្សស្សខោ ភគវតោ បុព្វេ ផលមទាសហំ
នាឡិកេរញ្ច បាទាសឹ ខជ្ជកំ អភិសម្មតំ ។
ពុទ្ធស្ស តមហំ ទត្វា តិស្សស្ស តុ មហេសិនោ
មោទាមហំ កាមកាមី ឧបបជ្ជឹ យមិច្ឆកំ ។
ទ្វេនវុតេ ឥតោ កប្បេ យំ ទានមទទឹ តទា
ទុគ្គតឹ នាភិជានាមិ ផលទានស្សិទំ ផលំ ។
ឥតោ តេរសកប្បម្ហិ រាជា ឥន្ទសមោ អហុ
សត្តរតនសម្បន្នោ ចក្កវត្តី មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។





បានឮថា ព្រះកណវេរបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កណវេរបុប្ផិយត្ថេរាបទាន ។

## ខជ្ជកទាយកត្ថេរាបទាន ទី ៣

(៦៣) ក្នុងកាលពីដើម ខ្ញុំបានថ្វាយផ្លែឈើ បានថ្វាយផ្លែដូង ដែលគេសន្មតថាជាចំណីឆ្ងាញ់ ចំពោះព្រះមានព្រះភាគ ព្រះនាមតិស្សៈ ។ លុះខ្ញុំថ្វាយផ្លែឈើនោះ ចំពោះព្រះពុទ្ធ ព្រះនាមតិស្សៈជាមហេសីហើយ ក៏រីករាយ ខ្ញុំមានសេចក្តីប្រាថ្នាក្នុងកាម ក៏បានទៅកើតតាមសេចក្តីប្រាថ្នា ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ក្នុងគ្រានោះ ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការឲ្យនូវផ្លែឈើ ។ ក្នុងកប្បទី ១៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមឥន្ទសមៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា ខជ្ជកទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ខជ្ជកទាយកត្ថេរស្ស អបទានំ សមត្តំ ។

## ឆដ្ឋំ ទេសបូជកត្ថេរាបទានំ

(៦៦) អត្ថទស្សី តុ ភគវា លោកជេដ្ឋោ នរាសភោ
អព្ភុគ្គន្ត្វាន វេហាសំ ចង្កមិ អនិលញ្ជសេ ។
យម្ហិ ទេសេ ឋិតោ សត្ថា អព្ភុគ្គច្ឆិ មហាមុនិ
តាហំ ទេសំ អបូជេសិំ បសន្នោ សេហិ បាណិភិ ។
អដ្ឋារសេ កប្បសតេ អទ្ទសំ យំ មហាមុនិំ
ទុគ្គតិំ នាភិជានាមិ ទេសបូជាយិទំ ផលំ ។
ឯកាទសេ កប្បសតេ គោសុជាតសនាមកោ
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្ពលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។



បានឮថា ព្រះខជ្ជកទាយកត្ថេរមានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ខជ្ជកទាយកត្ថេរាបទាន ។

## ទេសបូជកត្ថេរាបទាន ទី ៦

(៦៦) ព្រះមានព្រះភាគ ព្រះនាមអត្ថទស្សី ជាច្បងក្នុងលោក ជានរាសភៈ ហោះទៅកាន់អាកាស ស្តេចទៅក្នុងផ្លូវអាកាស ។ ព្រះសាស្តាជាមហាមុនី ឋិតនៅក្នុងប្រទេសណា ហើយស្តេចហោះទៅ ខ្ញុំជ្រះថ្លា បានបូជាចំពោះប្រទេសនោះ ដោយដៃរបស់ខ្លួន ។ ក្នុងកប្បទី ១៨០០ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានឃើញព្រះមហាមុនី ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាចំពោះប្រទេស ។ ក្នុងកប្បទី ១១០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិព្រះនាមគោសុជាត ប្រកបដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា ទេសបូជកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ទេសបូជកត្ថេរស្ស អបទានំ សមត្តំ ។

## បញ្ចមំ កណិការបុប្ផិយត្ថេរាបទានំ

(៦៩) វេស្សភូ នាម សម្ពុទ្ធោ លោកជេដ្ឋោ នរាសភោ
ទិវា វិហារាយ មុនិ ឱគាហយិ មហាវនំ ។
កណិការំ ឱចិនិត្វា ឆត្តំ កត្វានហំ តទា
បុប្ផច្ឆទនំ កត្វាន ពុទ្ធស្ស អភិរោបយឹ ។
ឯកត្តិំសេ ឥតោ កប្បេ យំ បុប្ផំ អភិរោបយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
ឥតោ វីសតិកប្បម្ហិ សោណ្ណាភា អដ្ឋ ខត្តិយា
សត្តរតនសម្បន្នា ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។





បានឮថា ព្រះទេសបូជកត្ថេរមានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ទេសបូជកត្ថេរាបទាន ។

## កណិការបុប្ផិយត្ថេរាបទាន ទី ៥

(៦៩) ព្រះសម្ពុទ្ធ ព្រះនាមវេស្សភូ ជាច្បងក្នុងលោក ជានរាសភៈ ជាអ្នកប្រាជ្ញ ទ្រង់ស្តេចចូលទៅកាន់មហាវ័ន ដើម្បីសម្រាកក្នុងវេលាថ្ងៃ ។ ក្នុងកាលនោះ ខ្ញុំកាច់ផ្កាកណិ-ការធ្វើជាឆ័ត្រ លុះខ្ញុំធ្វើឲ្យជាដំបូលដោយផ្កាហើយ ទើប បូជាចំពោះព្រះពុទ្ធ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះ ហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃពុទ្ធបូជា ។ ក្នុងកប្បទី ២០ អំពីកប្បនេះ ខ្ញុំបានកើតជា ស្តេចចក្រពត្តិ ៨ ជាតិ ព្រះនាមសោណ្ណាភៈដូចគ្នា ទ្រង់បរិ-បូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា កណិការច្ឆទនិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កណិការច្ឆទនិយត្ថេរស្ស អបទានំ សមត្តំ ។

## ឆដ្ឋំ សប្បិទាយកត្ថេរាបទានំ

(៦៦)ផុស្សោ នាមាសិ ភគវា អាហុតីនំ បដិគ្គហោ
គច្ឆតេ វីថិយា វីរោ និព្វាបេន្តោ មហាជនំ ។
អនុបុព្វេន ភគវា អាគច្ឆិ មម សន្តិកំ
តតោហំ បត្តំ បគ្គយ្ហ សប្បិតេលំ អទាសហំ ។
ឆន្នវុតេ ឥតោ កប្បេ យំ សប្បិមទទិំ តទា
ទុគ្គតិំ នាភិជានាមិ សប្បិទានស្សិទំ ផលំ ។
ឆប្បញ្ញាសេ ឥតោ កប្បេ ឯកោ អាសឹ សមោទកោ
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។



បានឮថា ព្រះកណិការច្ឆទនិយត្ថេរមានអាយុ បានសំដែង នូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កណិការច្ឆទនិយត្ថេរាបទាន ។

## សប្បិទាយកត្ថេរាបទាន ទី ៦

(៦៦) ព្រះមានព្រះភាគ ព្រះនាមផុស្សៈ ទ្រង់គួរទទួល នូវគ្រឿងបូជា ព្រះអង្គជាវីរបុរស ស្ដេចទៅតាមផ្លូវ ញ៉ាំង មហាជនឲ្យរលត់ទុក្ខ ។ ព្រះមានព្រះភាគ ក៏ស្ដេចមកកាន់ សំណាក់របស់ខ្ញុំតាមលំដាប់ ក្នុងកាលនោះ ខ្ញុំទទួលយក បាត្រ ហើយបានថ្វាយទឹកដោះថ្លានិងប្រេង ។ ក្នុងកប្ប ទី ៩៦ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានថ្វាយទឹកដោះថ្លា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃ ការថ្វាយទឹកដោះថ្លា ។ ក្នុងកប្បទី ៥៦ អំពីកប្បនេះ ខ្ញុំ បានកើតជាស្ដេចចក្រពត្តិ មួយអង្គ ព្រះនាមសមោទកៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យ ជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបាន ប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា សប្បិទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សប្បិទាយកត្ថេរស្ស អបទានំ សមត្តំ ។

## សត្តមំ យុធិកបុប្ផិយត្ថេរាបទានំ

(៦៧) ចន្ទភាគានទីតីរេ អនុសោតំ វជាមហំ
សយម្ភុំ អទ្ទសំ តត្ថ សាលរាជំវ ផុល្លិតំ ។
បុប្ផំ យុធិកមាទាយ ឧបគច្ឆឹ មហាមុនឹ
បសន្នចិត្តោ សុមនោ ពុទ្ធស្ស អភិរោបយឹ ។
ឆន្នវុតេ ឥតោ កប្បេ យំ បុប្ផំ អភិរោបយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
សត្តសដ្ឋិម្ហិតោ កប្បេ ឯកោ សាមុទ្ទរោ អហុ
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្ពលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។





បានឮថា ព្រះសប្បិទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សប្បិទាយកត្ថេរាបទាន ។

## យុធិកបុប្ផិយត្ថេរាបទាន ទី ៧

(៦៧) ខ្ញុំទៅតាមទីបណ្តោយខ្សែទឹក ទៀបឆ្នេរស្ទឹងឈ្មោះចន្ទភាគា ខ្ញុំបានឃើញព្រះពុទ្ធ សយម្ភូ ដូចសាល-រាជព្រឹក្ស ដែលមានផ្ការីកស្គុះស្គាយ ជិតស្ទឹងនោះ ។ ខ្ញុំកាន់យកផ្កាផ្តកទិម ហើយចូលទៅគាល់ព្រះមហាមុនី ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានបូជាចំពោះព្រះពុទ្ធ ។ ក្នុងកប្បទី ៩៦ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៦៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិមួយអង្គ ព្រះនាមសាមុទ្ទរៈ ប្រដាប់ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះសម្ពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា យុធិកបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

យុធិកបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

## អដ្ឋមំ ទុស្សទាយកត្ថេរាបទានំ

[៦៨] តិវរាយំ បុរេ រម្មេ    រាជបុត្តោ អហំ តទា
បណ្ណាការំ លភិត្វាន    ឧបសន្តស្សទាសហំ ។
អធិកសេសំ តតោ    វត្ថុំ(១) ហត្ថេន អាមសិ
សិទ្ធត្ថោ អធិកសេត្វា    វេហាសំ នភមុគ្គមិ ។
ពុទ្ធស្ស គច្ឆមានស្ស    ទុស្សា ធាវន្តិ បច្ឆតោ
តត្ថ ចិត្តំ បសាទេសិំ    ពុទ្ធោ នោ អគ្គបុគ្គលោ ។
ចតុន្នវុតេ ឥតោ កប្បេ    យំ ទុស្សមទទឹ តទា
ទុគ្គតឹ នាភិជានាមិ    ទុស្សទានស្សិទំ ផលំ ។
សត្តសដ្ឋិម្ហិតោ កប្បេ    ចក្កវត្តិ តទា អហុ
បរិសុទ្ធោតិ នាមេន    មនុជិន្ទោ មហព្វលោ ។

១ ម. ឥទំ ។



បានឮថា ព្រះយុធិកបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ យុធិកបុប្ផិយត្ថេរាបទាន ។

## ទុស្សទាយកត្ថេរាបទាន ទី ៨

[៦៨] ក្នុងកាលនោះ ខ្ញុំជារាជបុត្តក្នុងបុរីឈ្មោះតិវរ ជាទីក្រេកក្រើករាយ ខ្ញុំបាននូវបណ្ណាការ ហើយថ្វាយព្រះពុទ្ធ ព្រះអង្គជាបុគ្គលស្ងប់រម្ងាប់ ។ ព្រះមានព្រះភាគ ទ្រង់ទទួល ហើយទ្រង់កាន់សំពត់ដោយព្រះហស្ត លុះព្រះពុទ្ធព្រះនាមសិទ្ធត្ថៈទទួលហើយ ក៏ហោះទៅកាន់អាកាសវេហាស៍ ។ កាលព្រះពុទ្ធស្តេចទៅ សំពត់ទាំងឡាយក៏អណ្តែតទៅតាមក្រោយ ខ្ញុំញុំាងចិត្តឲ្យជ្រះថ្លាចំពោះព្រះពុទ្ធនោះថា ព្រះពុទ្ធជាអគ្គបុគ្គលរបស់យើង ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយសំពត់ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយសំពត់ ។ ក្នុងកប្បទី ៦៧ អំពីកប្បនេះ ក្នុងកាលនោះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមបរិសុទ្ធៈ ជាធំជាងមនុស្ស ទ្រង់មានកម្លាំងច្រើន ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។
ឥត្ថំ សុទំ អាយស្មា ទុស្សទាយកោ ថេរោ
ឥមា គាថាយោ អភាសិត្ថាតិ ។

ទុស្សទាយកត្ថេរស្ស អបទានំ សមត្តំ ។

## នវមំ សមាទបកត្ថេរាបទានំ

(៦៩) នគរេ ពន្ធុមតិយា មហាបូគគណោ អហុ
តេសាហំ បវរោ អាសឹ មម ពទ្ធចរា(១) ច តេ ។
តេ សព្វេ សន្និបាតេត្វា បុញ្ញកម្មេ សមាទយឹ
មាឡំ ការេស្សាម សង្ឃស្ស បុញ្ញក្ខេត្តំ អនុត្តរំ ។
សាធូតិ តេ បដិស្សុត្វា មម ឆន្ទវសានុគា
និដ្ឋាបេត្វា ច តំ មាឡំ វិបស្សិស្ស អទាសយុំ ។
ឯកនវុតេ ឥតោ កប្បេ យំ មាឡមទទឹ តទា
ទុគ្គតឹ នាភិជានាមិ មាឡទានស្សិទំ ផលំ ។

១ ម. គរុបកា ច តេ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះទុស្សទាយកត្ថេរមានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ទុស្សទាយកត្ថេរាបទាន ។

## សមាទបកត្ថេរាបទាន ទី ៩

(៦៩) ខ្ញុំជាអ្នកមានពួកគណៈច្រើនក្នុងក្រុងពន្ធុមតី ជាបុគ្គលប្រសើរ ជាងពួកជនទាំងនោះ ពួកជនទាំងនោះ សុទ្ធតែប្រព្រឹត្តតាមបង្គាប់ក្រោមបញ្ជារបស់ខ្ញុំ ។ ខ្ញុំប្រជុំពួកជនទាំងអស់នោះ ហើយបបួលឲ្យធ្វើបុណ្យកម្មថា យើងនឹងធ្វើរោងសម្រាប់ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់ព្រះសង្ឃ ។ ពួកជនទាំងនោះ ក៏ទទួលស្តាប់ថា ប្រពៃ ហើយប្រព្រឹត្តតាមអំណាចសេចក្តីត្រេកអររបស់ខ្ញុំ លុះធ្វើរោងនោះឲ្យសម្រេចហើយ ក៏ថ្វាយដល់ព្រះពុទ្ធ ព្រះនាមវិបស្សី ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយរោង ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយរោង ។

ឯកូនសត្តតិកប្បម្ហិ(១) ឯកោ អាសិ ជនាធិបោ
សាកលោ នាម(២) នាមេន ចក្កវត្តិ មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សុមនាវេឡិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សុមនាវេឡិយត្ថេរស្ស អបទានំ សមត្តំ ។

## ទសមំ បញ្ចង្គុលិយត្ថេរាបទានំ

(៧០) តិស្សោ នាមាសិ ភគវា លោកជេដ្ឋោ នរាសភោ
បវិសន្តំ(៣) គន្ធកុដឹ វិហារកុសលំ មុនឹ(៤)
សុគន្ធមាល្យមាទាយ អគមាសឹ ជិនន្តិកំ
អប្បសន្នោ(៥) ច សម្ពុទ្ធំ បញ្ចង្គុលិមទាសហំ ។

---

១ ម. ឯកូនសត្តតិកប្បេ ។ ២ ម. សាកេយ្យោ នាម ។ ៣ ម. បវិសតិ ។ ៤ ម. វិហារកុសលេក មុនិ ។ ៥ ម. អសម្បត្តោ ។



ក្នុងកប្បទី ៦៩ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិមួយអង្គ ព្រះនាមសាកលៈ ទ្រង់ជាធំជាងជន មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសុមនាវេឡិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សុមនាវេឡិយត្ថេរាបទាន ។

## បញ្ចង្គុលិយត្ថេរាបទាន ទី ១០

(៧០) ព្រះមានព្រះភាគ ព្រះនាមតិស្សៈ ជាទីពឹងនៃសត្វលោក ជានាយក: ខ្ញុំបានឃើញព្រះពុទ្ធមហាមុនី ព្រះអង្គជាអ្នកឈ្លាសវៃក្នុងវិហារធម៌ កំពុងចូលគន្ធកុដិ ទើបកាន់យកនូវផ្កាប្រកបដោយក្លិនក្រអូប ហើយដើរទៅកាន់សំណាក់ព្រះជិនស្រី ។ ខ្ញុំមានសណ្ដានចិត្តបរិសុទ្ធ បានថ្វាយនូវគ្រឿងក្រអូប ប្រស់ព្រំដោយម្រាមដៃប្រាំ ចំពោះព្រះសម្ពុទ្ធ ។

ទសមំ បញ្ចង្គុលិយត្ថេរាបទានំ

ទ្វេនវុតេ ឥតោ កប្បេ យំ កម្មមកិរយឹ
ទុគ្គតឹ នាភិជានាមិ បញ្ចង្គុលិស្សិទំ ផលំ ។
ទ្វេសត្តតិម្ហិតោ កប្បេ រាជា អាសឹ សយម្បភោ
សត្តរតនសម្បន្នោ ចក្កវត្តី មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បញ្ចង្គុលិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បញ្ចង្គុលិយត្ថេរស្ស អបទានំ សមត្តំ ។



បញ្ចង្គុលិយត្ថេរាបទាន ទី ១០

ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយគ្រឿងក្រអូប ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃគ្រឿងក្រអូប ដែលប្រស់ព្រំដោយម្រាមដៃប្រាំ ។ ក្នុងកប្បទី ៧២ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមសយម្បភៈ ប្រកបទៅដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបញ្ចង្គុលិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បញ្ចង្គុលិយត្ថេរាបទាន ។

## ឧទ្ទានំ

សុបារិចរិយកណវេរី ខជ្ជកោ ទេសបូជកោ
កណិការោ សប្បិទទោ យូថិកោ ទុស្សទាយកោ
មាលោ ច បញ្ចង្គុលិកោ ចតុបញ្ញាសគាថកា ។

សុបារិចរិយវគ្គោ សត្តរសមោ ។

---



## ឧទ្ទាន

សុបារិចរិយត្ថេរាបទាន ១ កណវេរបុប្ផិយត្ថេរាបទាន ១ ខជ្ជកទាយកត្ថេរាបទាន ១ ទេសបូជកត្ថេរាបទាន ១ កណិការច្ឆត្តិយត្ថេរាបទាន ១ សប្បិទាយកត្ថេរាបទាន ១ យូថិកបុប្ផិយត្ថេរាបទាន ១ ទុស្សទាយកត្ថេរាបទាន ១ សមាទបកត្ថេរាបទាន ១ បញ្ចង្គុលិយត្ថេរាបទាន ១ មានគាថា ៥៤ ។

ចប់ សុបារិចរិយវគ្គ ទី ១៧ ។

---

## អដ្ឋារសមោ កុមុទវគ្គោ

### បឋមំ កុមុទមាលិយត្ថេរាបទានំ

[៧១] បព្វតេ ហិមវន្តម្ហិ  មហាជាតស្សរោ អហុ
តត្ថជោ រក្ខសោ អាសិ  ឃោររូបោ មហព្វលោ ។
កុមុទំ បុប្ផិតំ តត្ថ  ចក្កមត្តានិ ជាយរេ
ឱចិនាមិ ចតំ បុប្ផំ  ពលិនោ សមិតឹ តទា ។
អត្ថទស្សី តុ ភគវា  ទិបទិន្ទោ នរាសភោ
បុប្ផំ សង្កោចិតំ ទិស្វា  អាគច្ឆិ មម សន្តិកេ ។
ឧបាគតញ្ច សម្ពុទ្ធំ  ទេវទេវំ នរាសភំ
សព្វញ្ច បុប្ផំ បគ្គយ្ហ  ពុទ្ធស្ស អភិរោបយឹ ។
យាវតា ហិមវន្តន្តា  យាវ មាលា តទា អហុ(១)
តាវច្ឆទនសម្បន្នោ  អគមាសិ តថាគតោ ។
អដ្ឋារសេ កប្បសតេ  យំ បុប្ផមភិរោបយឹ
ទុគ្គតឹ នាភិជានាមិ  ពុទ្ធបូជាយិទំ ផលំ ។

---

(១) ម. យាវតា ហិមវន្តន្តា បរិសា សា តទា អហុ ។

## កុមុទវគ្គ ទី ១៨

### កុមុទមាលិយត្ថេរាបទាន ទី ១

[៧១] មានស្រះកើតឯងដ៏ធំ នៅជៀបភ្នំហិមពាន្ត ខ្ញុំជារាក្សស កើតក្នុងស្រះនោះ មានរូបគួរខ្លាច មានកម្លាំងច្រើន ។ ផ្កាកុមុទរីកស្គុះស្គាយកើតក្នុងស្រះនោះ ផ្កាកុមុទ ប្រមាណប៉ុនកង់រទេះ កើតឡើងក្នុងស្រះនោះ ខ្ញុំតែងបេះផ្កាផង ផ្លែផង ជារឿយ ៗ ។ គាប់ជួន ព្រះមានព្រះភាគ ព្រះនាមអត្ថទស្សី ជាធំជាងសត្វជើងពីរ ជានរាសភៈ ទ្រង់ឃើញផ្កា ដែលខ្ញុំបេះទុក ក៏ស្តេចមកក្នុងសំណាក់របស់ខ្ញុំ ។ លុះ (ខ្ញុំឃើញ) នូវព្រះសម្ពុទ្ធ ជាទេវតារបស់ទេវតា ជានរាសភៈហើយ ខ្ញុំក៏យកផ្កាទាំងអស់ មកបូជាព្រះពុទ្ធ ។ ក្នុងកាលនោះ ផ្កាប្រមាណប៉ុន្មាន ក៏ទៅជាគ្រឿងប្រក់ថ្វាយព្រះតថាគត ដែលស្តេចយាងទៅទៀបភ្នំហិមពាន្ត ។ ក្នុងកប្បទី ១១៨ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។

ឥតោ បណ្ណរសេ កប្បេ សត្តាហេសុំ ជនាធិបា
សហស្សរថនាមា តេ ចក្កវត្តី មហព្ពលា
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ។

ឥត្ថំ សុទំ អាយស្មា កុមុទមាលិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កុមុទមាលិយត្ថេរស្ស អបទានំ សមត្តំ ។

## ទុតិយំ និស្សេណីទាយកត្ថេរាបទានំ

(៧២) កោណ្ឌញ្ញស្ស ភគវតោ លោកជេដ្ឋស្ស តាទិនោ
អារោហត្ថាយ ទាសាហំ និស្សេណី ការិតា មយា
តេន ចិត្តប្បសាទេន អនុភោត្វាន សម្បទា
ធារេមិ អន្តិមំ ទេហំ សម្មាសម្ពុទ្ធសាសនេ ។



ក្នុងកប្បទី ១៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៧ ជាតិ ជាតិជាតិដែល ព្រះនាមសហស្សរថ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះកុមុទមាលិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កុមុទមាលិយត្ថេរាបទាន ។

## និស្សេណីទាយកត្ថេរាបទាន ទី ២

(៧៦) ខ្ញុំបានឲ្យគេធ្វើជណ្តើរសម្រាប់ឡើងកាន់ប្រាសាទ ថ្វាយព្រះមានព្រះភាគព្រះនាមកោណ្ឌញ្ញៈ ជាទីពឹងនៃសត្វ-លោក ទ្រង់ប្រកបដោយតាទិគុណ ។ ខ្ញុំបានបំពេញសម្បត្តិ (នៃបុណ្យ) ដោយសេចក្តីជ្រះថ្លានៃចិត្តនោះ ទើបខ្ញុំទ្រទ្រង់នូវកាយជាទីបំផុត ក្នុងសាសនា នៃព្រះសម្មាសម្ពុទ្ធ ។

ឯកត្តិំសេ កប្បម្ហិ សោឡសាសុំ សុវាហនា(១)
សត្តរតនសម្បន្នា ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។
ឥត្ថំ សុទំ អាយស្មា និសេណ្ណិកាបោ(?) ថេរោ
ឥមា គាថាយោ អភាសិត្ថាតិ ។

និសេណ្ណិកាបោ...ស្ស អបទានំ ទុតិយំ ។

## គាថា វដ្តិយបុប្ផិយត្ថេរាបទានំ

(៤៣) មិគលុទ្ទោ បុរេ អាសិំ អរញ្ញេ កាននេ អហំ
វិបស្សិំ អទ្ទសំ ពុទ្ធំ ទេវទេវំ នរាសភំ ។
វដ្តិកំ បុប្ផិតំ ទិស្វា កុដជំ ធរណីរុហំ
សមូលំ បគ្គហេត្វាន អាហរិំ បាហេសិតោ ។
ឯកនវុតេ ឥតោ កប្បេ យំ ពុទ្ធមភិបូជយិំ
ទុគ្គតិំ នាភិជានាមិ បុប្ផបូជាយិទំ ផលំ ។

---
១ ម. សោឡស ។



វដ្តិយបុប្ផិយត្ថេរាបទាន ទី ២

ក្នុងកប្បទី ១.២០៤ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រ-ពត្តិ ១៦ ជាតិ ព្រមដោយរតនៈ ៧ ប្រការ ប្រកបដោយកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះមានអាយុ ...ត្ថេរ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ... ។

## វដ្តិយបុប្ផិយត្ថេរាបទាន ទី ៣

(៤៣) ក្នុងកាលមុន ខ្ញុំជាព្រានម្រឹគ នៅក្នុងព្រៃធំ ខ្ញុំបានឃើញព្រះពុទ្ធ ព្រះនាមវិបស្សី ជាទេវតារបស់ទេវតា ជានរាសភៈ ។ ខ្ញុំបានឃើញដើមឈើវដ្តិកៈ ដែលមានផ្កាស្កុះស្គាយ ប្រកបដោយសេចក្ដីត្រេកអរ ហើយកាត់យកទាំងឫស មកបូជាព្រះពុទ្ធ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃការបូជាផ្កា ។

ឥតោ ច អដ្ឋមេ កប្បេ សុប្បសន្នសនាមកោ
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្វលោ(១) ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា រត្តិយបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ

រត្តិយបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

## ចតុត្ថំ ឧទបានទាយកត្ថេរាបទានំ

[៧៤] វិបស្សិនោ ភគវតោ ឧទបានោ កតោ មយា
បិណ្ឌបាតំ គហេត្វាន និយ្យាទេសឹ អហំ តទា ។
ឯកនវុតេ ឥតោ កប្បេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ ឧទបានស្សិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

១ ម. រាជាហោសិ មហព្វលោ ។



ក្នុងកប្បទី ៨ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិព្រះនាមសុប្បសន្នៈ ប្រកបដោយរតនៈ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះរត្តិយបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ រត្តិយបុប្ផិយត្ថេរាបទាន ។

## ឧទបានទាយកត្ថេរាបទាន ទី ៤

(៧៤) ខ្ញុំបានធ្វើអណ្តូង ថ្វាយចំពោះព្រះមានព្រះភាគ ព្រះនាមវិបស្សី ក្នុងកាលនោះ ខ្ញុំយកបិណ្ឌបាតថ្វាយ (ថែមទៀត) ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានធ្វើបុណ្យកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយអណ្តូង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា ឱសធទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឱសធទាយកត្ថេរស្ស អបទានំ សមត្តំ ។

# បញ្ចមំ សីហាសនទាយកត្ថេរាបទានំ

(៨៥) និព្វុតេ លោកនាថម្ហិ បទុមុត្តរនាយកេ
បសន្នចិត្តោ សុមនោ សីហាសនមទាសហំ ។
ពហូហិ គន្ធមាលេហិ ឥធលោកសុខាវហោ(១)
តត្ថ បូជំ ករិត្វាន និព្វាយតិ ពហុជ្ជនោ ។
បសន្នចិត្តោ សុមនោ វន្ទិត្វា ពោធិមុត្តមំ
កប្បានំ សតសហស្សំ ទុគ្គតឹ នុបបជ្ជហំ ។
បណ្ណរសសហស្សម្ហិ កប្បានំ អដ្ឋ អាសុ តេ(២)
សិលុច្ចយសនាមា ច រាជានោ ចក្កវត្តិនោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

១ ម. ទិដ្ឋធម្មសុខាវហោ ។ ២ ម. អាសយុំ ។



បានឮថា ព្រះឱសធទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឱសធទាយកត្ថេរាបទាន ។

# សីហាសនទាយកត្ថេរាបទាន ទី ៥

(៨៥) កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ ជានាយក ជាទីពឹងនៃលោក បរិនិព្វានហើយ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយសីហាសនៈ ។ សេចក្តីពិត ជនមានប្រមាណច្រើននាក់ បាននូវសេចក្តីសុខក្នុងបរលោក ហើយរលត់ទុក្ខបាន ព្រោះធ្វើនូវការបូជា ដោយគ្រឿងក្រអូបនិងផ្កាកម្រងជាច្រើន ក្នុងទីបរិនិព្វាននោះ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ ថ្វាយបង្គំនូវពោធិព្រឹក្សដ៏ឧត្តម ខ្ញុំមិនទៅកើតក្នុងទុគ្គតិ អស់មួយសែនកប្ប ព្រោះកុសលនេះ ។ ក្នុងកប្បទី ១៥.០០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៨ ជាតិ ព្រះនាមសិលុច្ចយៈដូចគ្នា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា សីហាសនទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សីហាសនទាយកត្ថេរស្ស អបទានំ សមត្តំ ។

## ឆដ្ឋំ មគ្គទត្តិកត្ថេរាបទានំ

(៧៦) អនោមទស្សី ភគវា   ទិបទិន្ទោ នរាសភោ
ទិដ្ឋធម្មសុខត្ថាយ   អព្ភោកាសម្ហិ ចង្កមិ ។
ឧទ្ធរេ បាទេ បុប្ផានិ   សោភំ(១) មុទ្ធនិ តិដ្ឋរេ
បសន្នចិត្តោ សុមនោ   វន្ទិត្វា ពុទ្ធមោក្កមិំ ។
វីសកប្បសហស្សម្ហិ   ឥតោ បញ្ច ជនា អហុំ
បុប្ផច្ឆទនិយា នាម   ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា មគ្គទត្តិកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

មគ្គទត្តិកត្ថេរស្ស អបទានំ សមត្តំ ។

១ ម. សីសេ ។



បានឮថា ព្រះសីហាសនទាយកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សីហាសនទាយកត្ថេរាបទាន ។

## មគ្គទត្តិកត្ថេរាបទាន ទី ៦

(៧៦) ព្រះមានព្រះភាគព្រះនាមអនោមទស្សី ជាធំជាងសត្វជើងពីរ ជាឧសភៈ ទ្រង់ចង្ក្រមក្នុងទីវាលស្រឡះ ដើម្បីប្រយោជន៍ដល់សេចក្តីសុខ ក្នុងបច្ចុប្បន្ន ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយបង្គំព្រះពុទ្ធ ដែលទ្រង់លើកឡើង ហើយខ្ញុំរោយផ្កាទាំងឡាយដែលល្អឋិតលើកំពូលក្បាល មករោយថ្វាយ ។ ក្នុងកប្បទី ២០.០០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៥ ជាតិ ព្រះនាមបុប្ផច្ឆទនិយៈដូចគ្នា មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះមគ្គទត្តិកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មគ្គទត្តិកត្ថេរាបទាន ។

## សត្តមំ ឯកទីបិយត្ថេរាបទានំ

(៤៧) បទុមុត្តរស្ស មុនិនោ   សលលេ ពោធិមុត្តមេ
បសន្នចិត្តោ សុមនោ   ឯកទីបំ អទាសហំ ។
ភវេ និព្វត្តមានម្ហិ   និព្វត្តេ បុញ្ញសញ្ចយេ
ទុក្ខំ នាភិជានាមិ   ទីបទានស្សិទំ ផលំ ។
សោឡសេ កប្បសហស្សេ   ឥតោ តេ ចតុរោ ជនា
ចន្ទាភា នាម នាមេន   ចក្កវត្តី មហព្វលា ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឯកទីបិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឯកទីបិយត្ថេរស្ស អបទានំ សត្តមំ ។

សត្តមំ ភាណវារំ ។



## ឯកទីបិយត្ថេរាបទាន ទី ៧

(៤៧) ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយប្រទីបមួយដល់ព្រះពុទ្ធ ព្រះនាមបទុមុត្តរៈ ទៀបដើមស្រល់ជាពោធិព្រឹក្សដ៏ប្រសើរ ។ កាលខ្ញុំកើតក្នុងភព កាលណាសន្សំបុណ្យកើតហើយ ខ្ញុំក៏មិនដែលស្គាល់ទុក្ខ នេះជាផលនៃការថ្វាយប្រទីប ។ ក្នុងកប្បទី ១៦ ពាន់ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៤ ជាតិ ព្រះនាមចន្ទាភៈ ប្រកបដោយកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកទីបិយត្ថេរ មានអាយុ បានសម្តែងនូវគាថានេះ ដោយប្រការដូច្នេះ ។

ចប់ ឯកទីបិយត្ថេរាបទាន ។

ចប់ ភាណវារៈ ទី ៧ ។

## អដ្ឋមំ មណិបូជកត្ថេរាបទានំ

(៨៨) ឱរេន ហិមវន្តស្ស នទិកា(១) សម្បវត្តថ
តស្សា ចានុបខេត្តម្ហិ សយម្ភូ វសតេ តទា ។
មណឹ បគ្គយ្ហ បល្លង្កំ សាធុចិត្តំ មនោរមំ
បសន្នចិត្តោ សុមនោ ពុទ្ធស្ស អភិរោបយឹ ។
ចតុន្នវុតេ ឥតោ កប្បេ យំ មណឹ អភិរោបយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
ឥតោ ច ទ្វាទសេ កប្បេ សតរំសីសនាមកា
អដ្ឋ តេ ឯកនាមា អាសុំ ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា មណិបូជកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

មណិបូជកត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. នទិកា ។





## មណិបូជកត្ថេរាបទាន ទី ៨

(៨៨) ស្ទឹងតែងតែហូរចេញអំពីខាងណាយភ្នំហិមពាន្ត គាប់ចួនគ្រានោះ ព្រះពុទ្ធសយម្ភូ ទ្រង់គង់នៅក្បែរខ្លួនជាបន្ទាប់ នៃស្ទឹងនោះ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ យកបល្ល័ង្កកែវមណី ដែលគេរចនាដោយប្រពៃ ជាទីត្រេកអរនៃចិត្ត ថ្វាយចំពោះព្រះពុទ្ធ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានថ្វាយបល្ល័ង្កកែវមណី ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ១២ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៨ ជាតិ ព្រះនាមសតរំសីដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ព្រះសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះមណិបូជកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មណិបូជកត្ថេរាបទាន ។

## ទសមំ តិកិច្ឆកត្ថេរាបទានំ

(៧៨) នគរេ ពន្ធុមតិយា | វេជ្ជោ អាសឹ សុសិក្ខិតោ
អាតុរានំ សុទុក្ខានំ(១) | មហាជនសុខាវហោ ។
ព្យាធិតំ សមណំ ទិស្វា | សីលវន្តំ មហាជុតឹ
បសន្នចិត្តោ សុមនោ | ភេសជ្ជមទទឹ តទា ។
អរោគោ អាសិ តេនេវ | សមណោ សំវុតិន្ទ្រិយោ
អសោកោ នាម នាមេន | ឧបដ្ឋាកោ វិបស្សិនោ ។
ឯកនវុតេ ឥតោ កប្បេ | យំ ឱសធមទាសហំ
ទុគ្គតឹ នាភិជានាមិ | ភេសជ្ជស្ស ឥទំ ផលំ ។
ឥតោ ច អដ្ឋមេ កប្បេ | សព្វោសធសនាមកោ
សត្តរតនសម្បន្នោ | ចក្កវត្តិ មហព្វលោ ។
បដិសម្ភិទា ចតស្សោ | វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា | កតំ ពុទ្ធស្ស សាសនន្តិ ។

---
១ ម. សទុក្ខានំ ។



## តិកិច្ឆកត្ថេរាបទាន ទី ៩

(៧៨) ខ្ញុំជាពេទ្យមានវេជ្ជសាស្រ្តសិក្សាល្អហើយ នៅក្នុងនគរពន្ធុមតី ជាអ្នកនាំមកនូវសេចក្តីសុខដល់មហាជន ពិសេសចំពោះពួកជនអ្នកមានជម្ងឺ មានទុក្ខខ្លាំង ។ ខ្ញុំឃើញសមណៈអ្នកមានសីល មានសេចក្តីរុងរឿងច្រើន ដែលកំពុងឈឺថ្កាត់ ក្នុងកាលនោះ ក៏មានចិត្តជ្រះថ្លា មានចិត្តរីករាយ បានប្រគេនភេសជ្ជៈ ។ សមណៈនោះ ឈ្មោះអសោកៈ មានឥន្ទ្រិយសង្រួមល្អ ជាឧបដ្ឋាករបស់ព្រះវិបស្សីសម្ពុទ្ធ ក៏សះជារោគ ដោយភេសជ្ជៈនោះ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានប្រគេនឱសថ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃភេសជ្ជៈ ។ ក្នុងកប្បទី ៨ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមសព្វោសថៈ ប្រកបដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា តិកិច្ឆកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តិកិច្ឆកត្ថេរស្ស អបទានំ សមត្តំ ។

## ទសមំ សង្ឃុបដ្ឋាកត្ថេរាបទានំ

(៨០) វេស្សភុស្ស ភគវតោ    អាសឹ អារាមិកោ អហំ(១)
បសន្នចិត្តោ សុមនោ    ឧបដ្ឋឹ សង្ឃមុត្តមំ ។
ឯកត្តឹសេ ឥតោ កប្បេ    យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ    ឧបដ្ឋានស្សិទំ ផលំ ។
ឥតោ តេ សត្តមេ កប្បេ    សត្តេកសុំ សមោទកា
សត្តរតនសម្បន្នា    ចក្កវត្តី មហព្វលា ។
បដិសម្ភិទា ចតស្សោ    វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនន្តិ ។

១ ម. ឧបដ្ឋាកោ ។



បានឮថា ព្រះតិកិច្ឆកត្ថេរ មានអាយុ បានសម្តែងនូវគាថា ទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តិកិច្ឆកត្ថេរាបទាន ។

## សង្ឃុបដ្ឋាកត្ថេរាបទាន ទី ១០

(៨០) ខ្ញុំជាអារាមិកជន (អ្នកទំនុកបម្រុងការក្នុងអារាមវត្ត) ក្នុងសំណាក់ព្រះមានព្រះភាគ ព្រះនាមវេស្សភូ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានបម្រើព្រះសង្ឃដ៏ឧត្តម ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងគ្រានោះ ព្រោះហេតុដែលខ្ញុំបានធ្វើនូវកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបម្រើ ។ ក្នុងកប្បទី ៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៧ ដង ព្រះនាមសមោទកៈដូចគ្នា ប្រកបដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

ទ្ទាំ

ឥត្ថំ សុទំ អាយស្មា សង្ឃុបដ្ឋាកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សង្ឃុបដ្ឋាកត្ថេរស្ស អបទានំ សមត្តំ ។

## ឧទ្ទានំ

កុមុទោ អថ និស្សេណី រត្តិកោ ឧទបានទោ
សីហាសនី មគ្គទទោ ឯកទីបី មណិប្បទោ
តិកិច្ឆកោ ឧបដ្ឋាកោ ឯកូនបញ្ញាសគាថកាតិ ។

កុមុទវគ្គោ អដ្ឋារសមោ ។

---



ទ្ទាន

បានឮថា ព្រះសង្ឃុបដ្ឋាកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សង្ឃុបដ្ឋាកត្ថេរអបទាន ។

## ឧទ្ទាន

កុមុទមាលិយត្ថេរអបទាន ១ និស្សេណីទាយកត្ថេរអបទាន ១ រត្តិយបុប្ផិយត្ថេរអបទាន ១ ឧទបានទាយកត្ថេរអបទាន ១ សីហាសនទាយកត្ថេរអបទាន ១ មគ្គទត្តិកត្ថេរអបទាន ១ ឯកទីបិយត្ថេរអបទាន ១ មណិបូជកត្ថេរអបទាន ១ តិកិច្ឆកត្ថេរអបទាន ១ សង្ឃុបដ្ឋាកត្ថេរអបទាន ១ មានគាថា ៤៩ ។

ចប់ កុមុទវគ្គ ទី ១៨ ។

---

## ឯកូនវីសតិមោ កុដជបុប្ផិយវគ្គោ

## បឋមំ កុដជបុប្ផិយត្ថេរាបទានំ

(៨០) សុវណ្ណវណ្ណំ សម្ពុទ្ធំ　សតរំសឹវ ឧគ្គមំ(១)
ទិសំ អនុវិលោកេន្តំ　គច្ឆន្តំ អនិលញ្ជសេ ។
កុដជំ បុប្ផិតំ ទិស្វា　សំវិត្ថតសមោត្ថតំ
រុក្ខតោ ឱចិនិត្វាន　ផុស្សស្ស អភិរោបយឹ(២) ។
ឯកនវុតេ ឥតោ កប្បេ　យំ បុប្ផំ អភិរោបយឹ
ទុគ្គតឹ នាភិជានាមិ　បុប្ផបូជាយិទំ ផលំ ។
ឥតោ សត្តរសេ កប្បេ　តយោ អាសឹសុ បុប្ផិតា
សត្តរតនសម្បន្នា　ចក្កវត្តី មហព្វលា ។
បដិសម្ភិទា ចតស្សោ　វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា　កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា កុដជបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កុដជបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

១ ម. ឧគ្គតំ ។ ២ ម. ផុស្សស្សាភិរោបយឹ ។

## កុដជបុប្ផិយវគ្គ ទី ១៩

## កុដជបុប្ផិយត្ថេរាបទាន ទី ១

(៨០) (ខ្ញុំឃើញ) នូវព្រះផុស្សសម្ពុទ្ធ ទ្រង់មានវណ្ណៈដូចមាស ទ្រង់រុងរឿងដូចព្រះអាទិត្យ ទ្រង់ក្រឡេកមើលទិស ទ្រង់ស្តេចក្នុងដំណើរទៅឯអាកាស ។ ខ្ញុំបានឃើញដើមខ្ទឹងដ៏មានផ្ការីក ហើយបេះផ្ការីកនិងផ្កាក្រពុំអំពីដើម បូជាដល់ព្រះផុស្សសម្ពុទ្ធ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ១៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៣ ជាតិ ព្រះនាមបុប្ផិតៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះកុដជបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កុដជបុប្ផិយត្ថេរាបទាន ។

## ទុតិយំ ពន្ធុជីវកត្ថេរាបទានំ

(៤៦) សោភិតោ នាម សម្ពុទ្ធោ សយម្ភូ សត្តិវណ្ណិតោ
សមាធិំ សោ សមាបន្នោ និសីទិ បព្វតន្តរេ ។
ជាតស្សរេ គវេសន្តោ ទកជំ បុប្ផមុត្តមំ
ពន្ធុជីវកបុប្ផានិ អទ្ទសំ សមនន្តរំ ។
ឧភោ ហត្ថេហិ បគ្គយ្ហ ឧបគច្ឆិំ មហាមុនិំ
បសន្នចិត្តោ សុមនោ សោភិតស្សាភិរោបយិំ(១) ។
ចតុន្នវុតេ ឥតោ កប្បេ យំ បុប្ផមភិរោបយិំ
ទុគ្គតិំ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
ឥតោ ចតុទ្ទសេ កប្បេ ឯកោ អាសឹ ជនាធិបោ
សមុទ្ទកប្បោ នាមេន ចក្កវត្តី មហព្ពលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ពន្ធុជីវកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ពន្ធុជីវកត្ថេរស្ស អបទានំ សមត្តំ ។

១ ឱ. សម្ពុទ្ធស្សាភិរោបយឹ ។



## ពន្ធុជីវកត្ថេរាបទាន ទី ២

(៤៦) ព្រះសម្ពុទ្ធ ព្រះនាមសោភិតៈ ជាព្រះសយម្ភូ ដែលសព្វសត្វសរសើរហើយ ព្រះអង្គស្ដេចចូលសមាធិ គង់នៅចន្លោះភ្នំ ។ ខ្ញុំកំពុងតែស្វែងរកផ្កាដ៏ប្រសើរ ដែលកើតក្នុងទឹកនៅជាតស្រះ ក៏បានឃើញផ្កាចង្ការ ក្នុងលំដាប់ស្មើ ។ ខ្ញុំកាន់យកផ្កាដោយដៃទាំងពីរ ចូលទៅគាល់ព្រះមហាមុនី ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានបូជាដល់ព្រះសោភិតសម្ពុទ្ធ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ១៤ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិមួយអង្គ ព្រះនាមសមុទ្ទកប្បៈ ជាធំជាងជន មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះពន្ធុជីវកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ពន្ធុជីវកត្ថេរាបទាន ។

## តតិយំ កោដុម្ពរិយត្ថេរាបទានំ

(៨៣) កណិការំវ ជោតន្តំ និសិន្នំ បព្វតន្តរេ
អប្បមេយ្យំវ ឧទធឹ វិត្ថតំ(១) ធរណឹ យថា
បុរេក្ខតំ ទេវសង្ឃេន និសភាជានិយំ យថា
ហដ្ឋោ ហដ្ឋេន ចិត្តេន ឧបគច្ឆិំ នរុត្តមំ ។
សត្ត បុប្ផានិ បគ្គយ្ហ កោដុម្ពំ សមាកុលំ
ពុទ្ធស្ស អភិរោបេសិំ សិទ្ធត្ថលោកពន្ធុនោ ។
ឯកត្តឹសេ ឥតោ កប្បេ យំ បុប្ផមភិរោបយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
ឥតោ វីសតិកប្បម្ហិ មហាមេលសនាមកោ
ឯកោ អាសឹ(២) មហាតេជោ ចក្កវត្តិ មហព្ពលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា កោដុម្ពរិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កោដុម្ពរិយត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. វិត្ថតំ ។ ២ ម. អាសិំ ។



## កោដុម្ពរិយត្ថេរាបទាន ទី ៣

(៨៣) ខ្ញុំមានចិត្តរីករាយ ចូលទៅរកព្រះសិទ្ធត្ថៈ ទ្រង់រុងរឿងដូចផ្កាកណិការ ដែលគង់នៅត្រង់ចន្លោះភ្នំ ដូចជាសមុទ្រប្រមាណមិនបាន ឬដូចផែនដីដ៏ក្រាស់ ព្រះអង្គមានពួកទេវតាហែហមហើយ ទ្រង់ដូចជាសេះអាជានេយ្យដ៏ប្រសើរ ទ្រង់ជានរៈដ៏ឧត្តម ។ ខ្ញុំយកផ្កា ៧ ទង និងសំពត់កោដុម្ព ដែលល្អ បូជាដល់ព្រះសម្ពុទ្ធ ព្រះនាមសិទ្ធត្ថ ជាលោកពន្ធុ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៦០ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ មួយអង្គ ព្រះនាមមហាមេលៈ ទ្រង់មានតេជៈច្រើន មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះកោដុម្ពរិយត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កោដុម្ពរិយត្ថេរាបទាន ។

## ឆដ្ឋំ បញ្ញហត្ថិយត្ថេរាបទានំ

(៥៦) តិស្សោ នាមាសិ ភគវា លោកជេដ្ឋោ នរាសភោ

បុរក្ខតោ សាវកេហិ រថិយំ បដិបជ្ជថ ។
បញ្ច ខ្យលហត្ថា ច ចតុនិស្សិតា មយា(១)
អាហុតី ជាតុតាគេហំ បុត្តោ ក្វិ ហាកសិទ្ធិយា(២) ។
សុវណ្ណវណ្ណំ សម្ពុទ្ធំ គច្ឆន្តំ អន្តរាបណេ
តុដ្ឋីសិហំ ផុដ្ឋាត្តិ ថូបេសិ និបតុត្តមំ ។
ទ្វេនវុតេ ឥតោ កប្បេ យំ បុប្ផមភិបូជយិំ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
ឥតោ តេរសកប្បម្ហិ បញ្ចសុលកសម្មតា
សត្តរតនសម្បន្នា ចក្កវត្តី មហព្វលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា បញ្ញហត្ថិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បញ្ញហត្ថិយត្ថេរស្ស អបទានំ សមត្តំ ។

---

១. ឆ. [illegible] ។ ២. ឆ. [illegible] ។



## បញ្ញហត្ថិយត្ថេរាបទាន ទី ៦

(៥៦) ព្រះមានព្រះភាគ ព្រះនាមតិស្សៈ ជាច្បងក្នុងលោក ជានរាសភៈ ដែលពួកសាវ័កចោមរោម ស្ដេចទ្រង់ចូលដំណើរទៅក្នុងផ្លូវ ។ ខ្ញុំកាន់នូវផ្កាមួយដុំ ៤ ក្ដាប់ ឬ ៦ ក្ដាប់ ខ្ញុំជាគ្នាខាងការណែនាំធ្លាប់សិទ្ធិ ព្រោះចំណង់ហួយក្រៀមក្រំ ។ ខ្ញុំដែលស្ដីព្រះពុទ្ធពាល់ត្រាហើយ បានបូជាព្រះសម្ពុទ្ធ ទ្រង់មានវណ្ណៈដូចជាមាស ទ្រង់ចូលដំណើរទៅក្នុងចន្លោះផ្សារ ព្រះអង្គទ្រង់មានជំនឿសព្វដើមដែល ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ១៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ ៥ ជាតិ ព្រះនាមសុលកសម្មតៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបញ្ញហត្ថិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បញ្ញហត្ថិយត្ថេរាបទាន

## បញ្ចមំ និសិន្នុដ្ឋាយកត្ថេរាបទានំ

(៨៩) ឧទេន្តំ សតរំសិំវ   បីតរំសិំវ ភាណុមំ
កកុធំ វិលសន្តំ(១)   បទុមុត្តរនាយកំ ។
និសិន្នំ បិមន្តេត្វា(២)   បទុមុទ្ធំ អធិលកោ
បាសាទេវ ឋិតោ សន្តោ   អជ្ឈាសិំ លោកនាយកំ ។
អដ្ឋសតសហស្សានិ   អហេសុំ ពុទ្ធសាវកា
សព្វេសំ បត្តំ បូរេត្វា   តតោ ភិយ្យោ ពហុំ ករិំ ។
តេន ចិត្តប្បសាទេន   សុក្កមូលេន ចោទិតោ
កប្បានំ សតសហស្សំ   ទុគ្គតិំ នុបបជ្ជហំ ។
សដ្ឋិម្ហិ សហស្សេ   កប្បានំ អដ្ឋតិំសតេ
មហិសមន្តនាមកោ(៣)   ចក្កវត្តី មហព្ពលោ ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា និសិន្នុដ្ឋាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

និសិន្នុដ្ឋាបកត្ថេរស្ស អបទានំ សមត្តំ ។

---

១ ឱ. វិលគ្គំ វ ។ ២ ម. និសិន្នុដ្ឋាបិ សិត្វា ។ ៣ ម. និសិន្នុសមាមនេ ។





## និសិន្នុត្ថាយកត្ថេរាបទាន ទី ៥

(៨៩) ខ្ញុំបាននិមន្តព្រះបទុមុត្តរៈជានាយក ទ្រង់មានរស្មី ដូចព្រះអាទិត្យដែលទើបនឹងរះឡើង ឬដូចព្រះចន្ទមានរស្មីលឿង ទ្រង់ល្អស្អាត ដូចដើមចាន់ក្រឡាញ់ ។ ខ្ញុំឋិតនៅលើប្រាសាទ បាននិមន្តព្រះអង្គដែលគង់ឲ្យក្រោកឈរហើយថ្វាយផ្កាឈូកដែលមិនមានធូលី ដល់ព្រះពុទ្ធជាលោកនាថ ។ ពុទ្ធសាវកមានចំនួន ៨ សែន ខ្ញុំញុំាងបាត្រ របស់ពុទ្ធសាវកទាំងអស់ឲ្យពេញ ម្យ៉ាងទៀត ខ្ញុំបានធ្វើនូវតែច្រើនលើសជាងនោះទៀត ។ ខ្ញុំត្រូវកុសលមូលដាស់តឿន ខ្ញុំមិនដែលទៅកើតក្នុងទុគ្គតិ អស់មួយសែនកប្ប ដោយចិត្តជ្រះថ្លានោះ ។ ក្នុងកប្បទី ៦០.០៣៨ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមមហិសមន្តៈ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះនិសិន្នុដ្ឋាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ និសិន្នុដ្ឋាយកត្ថេរាបទាន ។

## ឆដ្ឋំ ពោធិឧបដ្ឋាយកត្ថេរាបទានំ

(៥៦) នគរេ រម្មវតិយេ អាសឹ មុរជវាទកោ
និច្ចុបដ្ឋានយុត្តោម្ហិ គតោហំ ពោធិមុត្តមំ ។
សាយំ បាតំ ឧបដ្ឋិត្វា សុក្ខត្វាលេន ពោធិតោ
អដ្ឋារសេ កប្បសតេ ពុទ្ធំ ឧបដ្ឋហិំ ។
ពញ្ចុនសេ កប្បសតេ ឥតោ ហោសិ ជនាធិបោ
ឧទេតោ នាម (១) នាមេន ចក្កវត្តិ មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ពោធិឧបដ្ឋាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ពោធិឧបដ្ឋាយកត្ថេរស្ស អបទានំ សមត្តំ ។

១ ម. ផុតោ នាម ។



## ពោធិឧបដ្ឋាយកត្ថេរាបទាន ទី ៦

(៥៦) ខ្ញុំជាអ្នកវាយស្គរ ក្នុងនគររម្មវតី បាននៅប្រកបការបម្រើជានិច្ច នូវដើមពោធិព្រឹក្ស ដ៏ប្រសើរ ។ ខ្ញុំបម្រើល្ងាចព្រឹក ស្រស់ក្រៀមល្អលើជាស់តឿនហើយ ក្នុងកប្បទី ១.៨០០ ខ្ញុំមិនដែលទៅកើតក្នុងទុគ្គតិ ។ ក្នុងកប្បទី ១.៨០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ជាធំជាងជន មានព្រះនាមឧទេនៈ មានកម្លាំងដ៏ច្រើន ។ បដិ-សម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះពោធិឧបដ្ឋាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ពោធិឧបដ្ឋាយកត្ថេរាបទាន ។

## សត្តមំ ឯកបិដ្ឋិកត្ថោបទានំ

(៨៧) យទា ទេវោ(១) ទេវកាយា ចវតិ(២) អាយុសង្ខយា

តយោ សទ្ទា និច្ឆរន្តិ ទេវានំ អនុមោទតំ

ឥតោ ភោ សុគតឹ គច្ឆ មនុស្សានំ សហព្យតំ

មនុស្សភូតោ សទ្ធម្មេ លភ សទ្ធំ អនុត្តរំ ។

សា តេ សទ្ធា និវិដ្ឋស្ស មូលជាតា បតិដ្ឋិតា

យាវជីវំ អសំហីរា សទ្ធម្មេ សុប្បវេទិតេ ។

កាយេន កុសលំ កត្វា វាចាយ កុសលំ ពហុំ

មនសា កុសលំ កត្វា អព្យាបជ្ឈំ និរូបធឹ ។

តតោ ឱបធិកំ(៣) បុញ្ញំ កត្វា ទានេន តំ ពហុំ

អញ្ញេបិ មច្ចេ សទ្ធម្មេ ព្រហ្មចរិយេ និវេសយ ។

ឥមាយ អនុកម្បាយ ទេវា ទេវំ យទា វិទូ

ឯហិ ទេវ បុនប្បុនំ ។

១ ម. ទេវោ ។ ២ ម. ចវតិ ។ ៣ ម. ឱបធិកំ ។





## ឯកបិដ្ឋិកត្ថោបទាន ទី ៧

[៨៧] កាលណា ទេវតាច្យុតចាកពួកទេវតា ព្រោះអស់អាយុ សំឡេង ៣ យ៉ាង របស់ពួកទេវតាកាលអនុមោទនា តែងលាន់ឮឡើងថា ម្នាលអ្នកដ៏ចំរើន អ្នកច្យុតអំពីទេវលោកនេះ ហើយទៅកាន់សុគតិ នៅជាមួយនឹងពួកមនុស្ស លុះកើតជាមនុស្សហើយ ចូរបាននូវសទ្ធាដ៏ប្រសើរ ក្នុងព្រះសទ្ធម្ម សទ្ធារបស់អ្នកដែលតាំងខ្ជាប់ខ្ជួនហើយនោះ នឹងកើតជាមូលតាំងនៅមាំនោះ ជាសទ្ធាមិនកម្រើក ក្នុងព្រះសទ្ធម្មដែលព្រះសុគតសំដែងល្អហើយ ដរាបដល់អស់ជីវិត ។ អ្នកត្រូវធ្វើកុសលដោយកាយ ធ្វើកុសលឲ្យច្រើនដោយវាចា ធ្វើកុសល និងមិនព្យាបាទ មិនមានឧបធិដោយចិត្ត ។ តពីនោះ អ្នកត្រូវធ្វើបុណ្យនោះ ដែលខំសន្សំហើយឲ្យច្រើន ដោយការឲ្យទានមួយវិញទៀត ត្រូវញុំាងពួកសត្វដទៃ ឲ្យតាំងនៅក្នុងព្រះសទ្ធម្ម និងព្រហ្មចរិយធម៌ ។ ទេវតាជាអ្នកប្រាជ្ញទាំងឡាយ តែងតែកាលបើនឹងអ្នកដ៏ចំរើន ដែលជាទេវតាវិសេស ដោយសេចក្តីអនុគ្រោះនេះថា ម្នាលទេវតា អ្នកចូរមកញយ ៗ ។

សត្តមំ ឯកចិត្តិកត្ថេរាបទានំ

សីវេត្ថាហំ(១) តទា អាសិំ ទេវទេវស្ស សាវកោ
គិសុ ធាម អកំ ហោតិ អភិសម្ពុទ្ធ ជនោ ធុតោ ។
ចប សំវេគបញ្ញាយ សរមានោ ការិតេត្ថយោ
ចក្ខុវិតុធាតោ សោ អាគច្ឆិ មម សន្តិកេ ។
សុខេតោ ជាម ជាមេន បត្តមត្តាសវេកោ
អត្តនា ឧសាសិតា សំវេជសិ មម តទា ។
គសេហំ ចេតំ សុត្វា ពុទ្ធេ ចិត្តំ បសាទយិំ
អភិវាទេត្វាន សម្ពុទ្ធំ(២) តត្ថ កាលំ កតោ អហំ ។
ឧបបជ្ជិំ ស តត្ថេវ សុញ្ញមុពេទ ចោទិតោ
កប្បានំ សតសហស្សំ ទុគ្គតិំ នុបបជ្ជហំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ឯកចិត្តិកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឯកចិត្តិកត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. សីវិត្ថា ។ ២ ម. តំ ធីរំ អភិវាទេត្វា ។



ឯកចិត្តិកត្ថេរាបទាន ទី ៧

កាលខ្ញុំនៅភាគទុកប្រព្រឹត្ត គ្រានោះ ខ្ញុំមានសេចក្តីសង្វេគ ជា អាត្មាអញ ព្រួតគោកអត្តភាពនេះ ហើយទើបនៅកាន់ គំនើតអំពើ ។ មានសមណៈមួយរូប មានវេទ្រិយស្រគត់ ស្រគំ ព្រោះសេចក្តីបង្វើតរបស់ខ្ញុំ លោកមានប្រាជ្ញាអំពី ស្រឹងខ្ញុំ បំបន្ទមគេគំរលាក់របស់ខ្ញុំ ។ គង់កាលនោះ សមណៈនោះ មាននាមថា សុមនៈ ជាសាវ័ករបស់ព្រះ បទុមុត្តរសម្ពុទ្ធ លោកបានប្រាប់អត្ថធម៌ ធ្វើឲ្យខ្ញុំកើត សង្វេគ ។ ខ្ញុំបានស្តាប់ពាក្យ របស់សមណៈនោះហើយ ក៏ ញ៉ាំងចិត្តឲ្យជ្រះថ្លាក្នុងព្រះពុទ្ធ បានថ្វាយបង្គំព្រះសម្ពុទ្ធហើយ ធ្វើកាលកិរិយាក្នុងទីនោះ ។ ខ្ញុំនោះ ត្រូវកុសលមូលដាស់ តឿន ក៏ចូលទៅកើតក្នុងទេវលោកនោះឯងដែល ខ្ញុំមិនដែល ទៅកាន់ទុគ្គតិ អស់មួយសែនកប្ប ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកចិត្តិកត្ថេរ មានអាយុ បានសម្តែងនូវគាថា ទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឯកចិត្តិកត្ថេរាបទាន ។

## អដ្ឋមំ តិកណ្ណិបុប្ផិយត្ថេរាបទានំ

(៤៨) ទេវភូតោ អហំ សន្តោ អច្ឆរាហិ បុរក្ខតោ
បុព្វកម្មំ សរិត្វាន ពុទ្ធសេដ្ឋំ អនុស្សរឹ ។
តិកណ្ណិបុប្ផំ(១) បគ្គយ្ហ សកំ ចិត្តំ បសាទយឹ
ពុទ្ធម្ហិ អភិរោបេសឹ វិបស្សិម្ហិ នរាសភេ ។
ឯកនវុតេ ឥតោ កប្បេ យំ បុប្ផំ អភិរោបយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
តេសត្តតិម្ហិតោ កប្បេ ចតុរោសុំ(២) រមុត្តមា
សត្តរតនសម្បន្នា ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា តិកណ្ណិបុប្ផិយោ(៣) ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តិកណ្ណិបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. កិង្កណិបុប្ផំ ។ ២ ម. ចតុរាសុំ ។ ៣ ម. កិង្កណិកបុប្ផិយោ ។





## តិកណ្ណិបុប្ផិយត្ថេរាបទាន ទី ៨

(៤៨) ខ្ញុំកើតជាទេវតា មានពួកស្រីអប្សរហែមរោម រឭកនូវបុព្វកម្ម (របស់ខ្លួន) ហើយរឭកនូវព្រះពុទ្ធដ៏ប្រសើរ ។ ខ្ញុំកាន់យកផ្កាតិកណ្ណិព្រឹក្ស ធ្វើចិត្តរបស់ខ្លួនឲ្យជ្រះថ្លា បានបូជាដល់ព្រះពុទ្ធ ព្រះនាមវិបស្សី ជានរាសភៈ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃពុទ្ធបូជា ។ ក្នុងកប្បទី ៧៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៤ ជាតិ ព្រះនាមរមុត្តមៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតិកណ្ណិបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តិកណ្ណិបុប្ផិយត្ថេរាបទាន ។

## នវមំ ឯកចារិយត្ថេរាបទានំ

(៨៩) តាវត្តឹសេសុ ទេវេសុ មហាឃោសោ តទា អហុ
ពុទ្ធោ ច លោកេ និព្វាតិ មយញ្ចម្ហ សរាគិនោ ។
តេសំ សំវេគជាតានំ សោកសល្លសមប្បិតំ
សពលេន ឧបត្ថទ្ធោ អគមំ ពុទ្ធសន្តិកេ ។
មន្ទារវំ គហេត្វាន សង្គីតំ អភិនិម្មិតំ
បរិនិព្វានកាលម្ហិ ពុទ្ធស្ស អភិរោបយឹ ។
សព្វេ ទេវានុមោទឹសុ អច្ឆរាយោ ច មេ តទា
កប្បានំ សតសហស្សំ ទុគ្គតឹ នុបបជ្ជហំ ។
សដ្ឋិកប្បសហស្សម្ហិ ឥតោ សោឡស តេ អហុ
មហាមល្លជនា នាម ចក្កវត្តី មហព្វលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឯកចារិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឯកចារិយត្ថេរស្ស អបទានំ សមត្តំ ។



## ឯកចារិយត្ថេរាបទាន ទី ៩

(៨៩) ក្នុងកាលនោះ មានសម្លេងខ្លាំង ក្នុងពួកទេវតា ជាន់តាវត្តិង្សថា ព្រះពុទ្ធបរិនិព្វាន ក្នុងលោកផង ពួកយើង នៅមានរាគៈផង ។ កាលទេវតាទាំងនោះ កើតសេចក្តីសង្វេគ ប្រកបដោយសរ គឺសេចក្តីសោក ខ្ញុំជាអ្នកដ៏ប៉ុន ដោយកម្លាំងរបស់ខ្លួន ក៏បានទៅក្នុងសំណាក់នៃព្រះពុទ្ធ ។ ខ្ញុំយកផ្កាមន្ទារវៈ ដែលពួកទេវតានិម្មិតជាកម្រង បានបូជា ដល់ព្រះពុទ្ធ ក្នុងកាលដែលទ្រង់បរិនិព្វាន ។ កាលនោះ ពួកទេវតាទាំងអស់ និងពួកទេពអប្សរ ក៏ត្រេកអរចំពោះខ្ញុំ ខ្ញុំមិនដែលទៅកើតក្នុងទុគ្គតិ អស់មួយសែនកប្ប ។ ក្នុងកប្បទី ៦០.០០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១៦ ជាតិ ព្រះនាមមហាមល្លជនៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកចារិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឯកចារិយត្ថេរាបទាន ។

## ទសមំ ធរណិប្បុប្ផិយត្ថេរាបទានំ

(៩០) អភិក្កំ ថេរំ បសិន្យាន(១) សាលេ សន្តុដ្ឋ តេ មយិ(២)
តេសំ និជ្ឈាយមានានំ បរិឡាហោ អជាយថ ។
សុនន្ទោ នាម នាមេន ពុទ្ធស្ស សាវកោ តទា
ធម្មទស្សិស្ស មុនិនោ អាគញ្ឆិ មម សន្តិកេ ។
យេ មេ បដ្ឋកា(៣) អាសុំ តេ មេ បុប្ផំ អទុំ តទា
តាហំ បុប្ផំ គហេត្វាន សាវកេ អភិរោបយិំ ។
សោហំ កាលំ ករោត្វ បុនាបិ ឧបបជ្ជហំ
អដ្ឋារសេ កប្បសតេ វិនិបាតំ ន គច្ឆហំ ។
តេរសេតោ កប្បសតេ អដ្ឋាសុំ ធូមកេតុនោ
សត្តរតនសម្បន្នា ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

១ ម. អភិភូតំ បរិដ្ឋិ ។ ២ ម. មយំ ។ ៣ ម. តទុបដក ។





## ធរណិប្បុប្ផិយត្ថេរាបទាន ទី ១០

(៩០) យើងតាំងអស់គ្នា ដើរទៅសំឡឹងមើលនូវព្រះថេរៈ ឈ្មោះអភិភូ កាលយើងតាំងអស់គ្នា កំពុងសំឡឹងមើល សេចក្តីក្តៅក្រហាយក៏កើតឡើង ។ កាលនោះ ព្រះថេរៈ ឈ្មោះសុនន្ទៈ ជាសាវ័ករបស់ព្រះសម្ពុទ្ធ ព្រះនាមធម្មទស្សីជាមហាមុនី និមន្តមកក្នុងសំណាក់របស់ខ្ញុំ ។ ក្នុងកាលនោះ ពួកជនណាស្និទ្ធស្នាលនឹងខ្ញុំ ពួកជននោះបានឲ្យផ្កាមកខ្ញុំ ។ ក៏យកផ្កានោះ ទៅបូជាដល់សាវ័ក ។ ខ្ញុំនោះធ្វើកាលកិរិយាហើយ ទៅកើតក្នុងទីដែលធ្លាប់នោះទៀត ខ្ញុំមិនដែលទៅកើតក្នុងវិនិបាត អស់ ១.៨០០ កប្ប ។ ក្នុងកប្បទី ១.៣០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៤ ជាតិ ព្រះនាមធូមកេតុជាដើម ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា និគ្គុណ្ឌិបុប្ផិយោ(១) ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

និគ្គុណ្ឌិបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

## ឧទ្ទានំ

កុដជោ ពន្ធុជីវី ច  កោដុម្ពរិកហត្ថិយោ(២)
ឥសិមុគ្គោ ច ពោធិ ច  ឯកចម្បី តិកណ្ឌិកោ(៣)
ឯកចារី និគ្គុណ្ឌី(៤) ច  គាថា សដ្ឋី បកិត្តិតា ។

កុដជបុប្ផិយវគ្គោ អដ្ឋារសមោ ។

១ ម. តិវណ្ឌិបុប្ផិយោ ។ ២ ម. កោដុម្ពរិយហត្ថិយោ ។ ៣ ម. តិកណ្ណិកោ ។ ៤ ម. តិវណ្ឌិ ។



បានឮថា ព្រះនិគ្គុណ្ឌិបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ និគ្គុណ្ឌិបុប្ផិយត្ថេរាបទាន ។

## ឧទ្ទាន

កុដជបុប្ផិយត្ថេរាបទាន ១ ពន្ធុជីវកត្ថេរាបទាន ១ កោដុម្ពរិយត្ថេរាបទាន ១ បញ្ចហត្ថិយត្ថេរាបទាន ១ ឥសិមុគ្គទាយកត្ថេរាបទាន ១ ពោធិឧបដ្ឋាយកត្ថេរាបទាន ១ ឯកចម្បកត្ថេរាបទាន ១ តិកណ្ឌិបុប្ផិយត្ថេរាបទាន ១ ឯកចារិយត្ថេរាបទាន ១ និគ្គុណ្ឌិបុប្ផិយត្ថេរាបទាន ១ មានគាថា ៦០ ដែលលោកសម្តែងទុកហើយ ។

ចប់ កុដជបុប្ផិយវគ្គ ទី ១៨ ។

## វីសតិមោ តមាលបុប្ផិយវគ្គោ

### បឋមំ តមាលបុប្ផិយត្ថេរាបទានំ

(៩១) ចុល្លាសីតិសហស្សានិ ថម្ភា សោវណ្ណយា អហុ
ទេវលដ្ឋិបដិច្ឆន្នំ វិមានំ មេ សុនិម្មិតំ ។
តមាលបុប្ផំ បគ្គយ្ហ វិប្បសន្នេន ចេតសា
ពុទ្ធស្ស អភិរោបេសឹ សិខិនោ លោកពន្ធុនោ ។
ឯកត្តឹសេ ឥតោ កប្បេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
ឥតោ វីសតិមេ កប្បេ ចន្ទតិត្តោតិ ឯកកោ
សត្តរតនសម្បន្នោ ចក្កវត្តី មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។
ឥត្ថំ សុទំ អាយស្មា តមាលបុប្ផិយោ ថេរោ
ឥមា គាថាយោ អភាសិត្ថាតិ ។

តមាលបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

## តមាលបុប្ផិយវគ្គ ទី ២០

### តមាលបុប្ផិយត្ថេរាបទាន ទី ១

(៩១) វិមានរបស់ខ្ញុំ មានសសរ ៨៤.០០០ ជាវិការៈនៃមាស ដែលបុគ្គលនិម្មិតល្អហើយ មានដំណែកប្រៀបដូចលដ្ឋិនៃទេព្យានរបស់ទេវតា ។ ខ្ញុំមានចិត្តជ្រះថ្លាយកផ្កាស្វាទៀ បូជាដល់ព្រះពុទ្ធ ព្រះនាមសិខី ជាលោកពន្ធុ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ២០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិមួយព្រះអង្គ ព្រះនាមចន្ទតិត្តៈ ប្រកបដោយរតនៈ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតមាលបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តមាលបុប្ផិយត្ថេរាបទាន ។

## ទុតិយំ តិណសន្ថារទាយកត្ថេរាបទានំ

(៩២) យទា វនកសិកោ(១) ឥសិ តិណំ លាយាមិ(២)
សត្ថុនោ

សព្វេ ឧបគន្ធិណាវត្តា ឋវត្យា ឋិបតិសុ តេ ។
គហេហំ តិណមាទាយ សន្ថរឹ ធរណិមុត្តមេ(៣)
តីណេវ តាលបត្តានិ អាហរិត្វានហំ តទា
តិណន្នេ ឆទនំ កត្វា សិទ្ធត្ថស្ស អទាសហំ
សត្តាហំ ធារយុំ តត្ថ(៤) ទេវមនុស្សា សត្ថុនោ ។
ចតុន្នវុតេ ឥតោ កប្បេ យំ តិណំ អទទឹ តទា
ទុគ្គតឹ នាភិជានាមិ តិណទានស្សិទំ ផលំ ។
បញ្ចសដ្ឋិម្ហិតោ កប្បេ ចត្តារោសុំ មហទ្ធនា
សព្វរតនសម្បន្នា ចក្កវត្តី មហព្វលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា តិណសន្ថារទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តិណសន្ថារទាយកត្ថេរស្ស អបទានំ សមត្តំ ។

១ ឱ. វនិសិ ។ ២ ឱ. លាយតិ ។ ៣ ឱ. ធរណុត្តមេ ។ ៤ ឱ. តស្ស ។



## តិណសន្ថារទាយកត្ថេរាបទាន ទី ២

(៩២) ក្នុងកាលដែលខ្ញុំកើតជាឥសី ទៅអាស្រ័យក្នុងព្រៃ តែងច្រូតស្មៅថ្វាយព្រះសាស្តា ស្មៅទាំងអស់នោះធ្លាក់ចុះលើផែនដី វិលទៅតាមទិសស្តាំ ។ ក្នុងកាលនោះ ខ្ញុំយកស្មៅនោះ ក្រាលលើធរណីដ៏ឧត្តម ហើយខ្ញុំយកស្លឹកត្នោត ៣ ធាងធ្វើជាដំបូល លើកណាត់ឈើ ៣ ដើម ថ្វាយដល់ព្រះសិទ្ធត្ថសម្ពុទ្ធ ទេវតានិងមនុស្សទាំងឡាយ ទ្រថ្វាយព្រះសាស្តាអស់ ៧ ថ្ងៃ ក្នុងទីនោះ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានថ្វាយស្មៅ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយស្មៅ ។ ក្នុងកប្បទី ៦៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៤ ជាតិ ព្រមដោយមហាធនៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតិណសន្ថារទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តិណសន្ថារទាយកត្ថេរាបទាន ។

## តតិយំ ខណ្ឌផុល្លិយត្ថេរាបទានំ

(៤៣) ផុស្សស្ស ខោ ភគវតោ ថូបោ អាសិ មហាវនេ

កុញ្ជរេហិ តទា ភិន្នោ   បរូឡ្ហោ បាទបោ តហឹ ។
វិសមញ្ច សមំ កត្វា   សុធាបិណ្ឌំ អទាសហំ
តិលោកគរុនោ តស្ស   គុណេហិ បរិតោសិតោ ។
ទ្វេនវុតេ ឥតោ កប្បេ   យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ   សុធាបិណ្ឌស្សិទំ ផលំ ។
សត្តសត្តតិកប្បម្ហិ   ជិតសេនាសុំ សោឡស
សត្តរតនសម្បន្នា   ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ខណ្ឌផុល្លិយោ(១) ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ខណ្ឌផុល្លិយត្ថេរស្ស អបទានំ តតិយំ ។

១ ម. ខណ្ឌផុល្លិយោ ។



## ខណ្ឌផុល្លិយត្ថេរាបទាន ទី ៣

(៤៣) ព្រះស្តូបរបស់ព្រះមានព្រះភាគ ព្រះនាមផុស្សៈ នៅក្នុងព្រៃធំ ក្នុងកាលនោះ (ព្រះស្តូបនោះ) ត្រូវពួកដំរីកម្ទេចហើយ ដើមឈើដុះឡើងប្រេះប្រាស ក្នុងទីនោះ ។ ខ្ញុំធ្វើកន្លែងដែលមិនរាបស្មើ (ឲ្យរាប) ឲ្យស្មើ ហើយលាបបាយអ ខ្ញុំត្រេកអរដោយគុណទាំងឡាយ របស់សម្តេចព្រះត្រៃលោក ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃដុំបាយអ ។ ក្នុងកប្បទី ៧៧ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១៦ ជាតិ ព្រះនាមជិតសេនៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះខណ្ឌផុល្លិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ខណ្ឌផុល្លិយត្ថេរាបទាន ។

## បាឡី អសោកបូជកត្ថេរាបទានំ

(៩៤) តិវរាយំ(១) បុរេ រម្មេ រាជុយ្យានំ អហុ តទា
ឧយ្យានបាលោ តត្ថាសឹ រញ្ញោ ពន្ធុមតោ អហំ ។
បទុមោ នាម នាមេន សយម្ភូ សប្បភោ អហុ
និសិន្នំ បុណ្ឌរីកម្ហិ ឆាយា ន ជហិ តំ មុនឹ ។
អសោកំ បុប្ផិតំ ទិស្វា បិណ្ឌិភារំ សុទស្សនំ
ពុទ្ធស្ស អភិរោបេសឹ ជលជុត្តមនាមិនោ ។
ចតុន្នវុតេ ឥតោ កប្បេ យំ បុប្ផំ អភិរោបយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
សត្តតឹសេ ឥតោ កប្បេ សោឡស អរណញ្ជហា
សត្តរតនសម្បន្នា ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា អសោកបូជកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អសោកបូជកត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. តិវកាយំ ។

## អសោកបូជកត្ថេរាបទាន ទី ៤

(៩៤) កាលនោះ មានរាជឧទ្យាន ១ ក្នុងតិវរបុរី ជាទីរីករាយ ខ្ញុំជាអ្នកយាមឧទ្យាន ជាអ្នកស៊ីឈ្នួលនៃស្តេចពន្ធុម នោះ ។ ព្រះសយម្ភូព្រះនាមបទុមៈ ស្តេចមក (ក្នុងឧទ្យាន នោះ) ម្លប់មិនលះបង់ព្រះមុនី ទ្រង់គង់លើផ្កាឈូកស ។ ខ្ញុំឃើញដើមអសោក មានផ្ការីក មានចង្កោមគួររមិលមើល ទើបខ្ញុំបូជាដល់ព្រះពុទ្ធ ព្រះនាមបទុមៈ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៣៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១៦ ជាតិ ព្រះនាមអរណញ្ជហៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអសោកបូជកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អសោកបូជកត្ថេរាបទាន ។

## បញ្ចមំ អង្កោលកត្ថេរាបទានំ

(៤៩) អង្កោលំ បុប្ផិតំ ទិស្វា មាលាវរសមោកតំ

ឱចិនិត្វាន តំ បុប្ផំ អគមំ ពុទ្ធសន្តិកំ ។

សិទ្ធត្ថោ តម្ហិ សមយេ បដិលីនោ មហាមុនិ

មុហុត្តំ បដិមានេត្វា គុហាយំ បុប្ផមោកិរឹ ។

ចតុន្នវុតេ ឥតោ កប្បេ យំ បុប្ផំ អភិរោបយឹ

ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។

ឆត្តឹសម្ហិ ឥតោ កប្បេ អាសេកោ ទេវគន្ធិកោ

សត្តរតនសម្បន្នោ ចក្កវត្តី មហព្ពលោ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា អង្កោលកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អង្កោលកត្ថេរស្ស អបទានំ សមត្តំ ។



## អង្កោលកត្ថេរាបទាន ទី ៥

(៤៩) ខ្ញុំឃើញដើមអង្កោលមានផ្ការីក សំយុងចុះជារបៀបដ៏ល្អ ហើយបេះផ្កានោះយកទៅ ក្នុងសំណាក់ព្រះសម្ពុទ្ធ ។ ក្នុងសម័យនោះ ព្រះសិទ្ធត្ថមហាមុនីទ្រង់ពួនសម្ងំ ខ្ញុំរង់ចាំមួយរំពេច ហើយរោយផ្កាក្នុងគុហា ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៣៦ អំពីកប្បនេះ ខ្ញុំកើតជាស្តេចចក្រពត្តិ ព្រះនាមអាសេកទេវគន្ធិកៈ ប្រកបដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអង្កោលកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អង្កោលកត្ថេរាបទាន ។

## ចប់ កិលេសយបូជកណ្ឌបាទ

(៩៦) ឯតេវ ទ្វារសិយា   ធាលាវេទ្ធា មមំ អហុ
ទុឥតោ ច ឥតោ   ទានបាន វិកេហតោ ។
សាតលេខ ទុមត្ថោ   សិទ្ធត្ថោ អបរាជិតោ
មហាទុកឱ្យនាតោ សោ   កច្ចេក អចិលញ្ញសេ ។
អញ្ញំ ករិញ្ញ ច បស្សាមិ   ឬជាយេហ៍ មហេសិនោ
អសោកបល្លវំ និស្វា   អាកាសេ ទុក្ខិមំ អហំ ។
ពុទ្ធស្ស តេ កិសលយា   កច្ចោ យត្ថិ ខច្ចោ
តាហំ និស្វាន សំវេធិ   អហោ ពុទ្ធស្សុឡារតា ។
ចតុន្នវុតេ ឥតោ កប្បេ   បល្លវំ អភិបូជយិំ
ទុគ្គតិំ នាភិជានាមិ   ពុទ្ធបូជាយិទំ ផលំ ។
សត្តវីសេ ឥតោ កប្បេ   ឯកោ ឯកិស្សរោ អហុ
សត្តរតនសម្បន្នោ   ចក្កវត្តិ មហព្ពលោ ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។



## កិលេសយបូជកណ្ឌបាទ ទី ៦

(៩៦) ក្នុងជាតិរបស់ខ្ញុំនៅក្នុងភ្នាក់គី ខាងតំណាន់ទីកន្លែងដើមឈើ គឺជាកន្លែងនេះតែង ព្រះសិទ្ធត្ថសម្ពុទ្ធ ទ្រង់ឈ្មោះជាទ្រង់ទើបប្រហែលជាយកឈ្មោះព្រះអង្គ ព្រះសិទ្ធត្ថសម្ពុទ្ធនោះ ទ្រង់អនុគ្រោះជាមួយខ្ញុំ និងយាងទៅក្នុងអាកាស ។ ខ្ញុំនឹងរបស់ក៏មួយនៅផ្ទៃដែលនាំមក ជល់ព្រះមហាសី ស្រាប់តែឃើញត្រួយអសោក (ខ្ញុំកាច់) បោះឡើងទៅក្នុងអាកាស ។ ត្រួយអសោកទាំងនោះ អណ្ដែតទៅតាមក្រោយព្រះសម្ពុទ្ធ ដែលកំពុងនិមន្តទៅ ខ្ញុំឃើញហេតុអស្ចារ្យនោះហើយ សង្វេគថា ឱ! ការនៃព្រះពុទ្ធជាទីឡូវិសេសណាស់ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានបូជាត្រួយអសោក ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ២៧ អំពីកប្បនេះ ខ្ញុំកើតជាស្ដេចចក្រពត្តិមួយអង្គ ព្រះនាមឯកិស្សរៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា កិសលយបូជកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កិសលយបូជកត្ថេរស្ស អបទានំ សមត្តំ ។

## សត្តមំ តិន្ទុកទាយកត្ថេរាបទានំ

(៩៧) គិរិទុគ្គចរោ អាសិំ មក្កដោ ថាមវេគិកោ
ផលិនំ តិន្ទុកំ ទិស្វា ពុទ្ធសេដ្ឋំ អនុស្សរឹ ។
និក្ខមិត្វា កតិបាហំ វិចិនឹ លោកនាយកំ
បសន្នចិត្តោ សុមនោ សិទ្ធត្ថំ តិភវន្តគុំ ។
មម សង្កប្បមញ្ញាយ សត្ថា លោកេ អនុត្តរោ
ខីណាសវសហស្សេហិ អាគច្ឆិ មម សន្តិកេ ។
បាមុជ្ជំ ជនយិត្វាន ផលហត្ថោ ឧបាគមឹ
បដិគ្គហេសិ ភគវា សព្វញ្ញូ វទតំ វរោ ។



បានឮថា ព្រះកិសលយបូជកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កិសលយបូជកត្ថេរាបទាន ។

## តិន្ទុកទាយកត្ថេរាបទាន ទី ៧

(៩៧) ខ្ញុំកើតជាស្វា ជាសត្វមានកម្លាំងនិងសន្ទុះ ត្រាច់ទៅលើភ្នំ ដែលគេទៅបានដោយកម្រ ឃើញដើមទន្លាប់មានផ្លែ ក៏នឹកព្រះសម្ពុទ្ធដ៏ប្រសើរ ។ ខ្ញុំចេញទៅបាន ២,៣ ថ្ងៃ ពិនិត្យមើលព្រះលោកនាយក ក៏មានចិត្តជ្រះថ្លា មានចិត្តរីករាយ ចំពោះព្រះសិទ្ធត្ថសម្ពុទ្ធ ទ្រង់ដល់ទីបំផុតនៃត្រៃភព ។ ព្រះសាស្តា ព្រះអង្គប្រសើរ ក្នុងលោក ទ្រង់ជ្រាបតម្រិះរបស់ខ្ញុំ ទើបស្តេចមកកាន់សំណាក់របស់ខ្ញុំ ជាមួយនឹងព្រះខីណាស្រព មួយពាន់អង្គ ។ ខ្ញុំកើតត្រេកអរ កាន់យកនូវផ្លែឈើ ចូលទៅគាល់ព្រះមានព្រះភាគ ជាសព្វញ្ញូ ទ្រង់ប្រសើរជាងពួកអ្នកប្រាជ្ញ ទ្រង់ទទួល (នូវផ្លែឈើនោះ) ។

ចតុន្នវុតេ ឥតោ កប្បេ យំ ផលំ អទទិំ តទា
ទុគ្គតិំ នាភិជានាមិ ផលទានស្សិទំ ផលំ ។
សត្តបញ្ញាសកប្បម្ហិ ឯកជ្ឈោ នាម ខត្តិយោ
សត្តរតនសម្បន្នោ ចក្កវត្តី មហព្ពលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា តិន្ទុកផលិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តិន្ទុកផលិយត្ថេរស្ស អបទានំ សមត្តំ ។

## អដ្ឋមំ គិរិនេលមុដ្ឋិបុប្ផិយត្ថេរាបទានំ

(៨៩) សុមេធោ នាម នាមេន លោកជេដ្ឋោ នរាសភោ
បច្ចិមេ អនុកម្បាយ បធានំ បទហិ ជិនោ ។
តស្ស ចង្កមមានស្ស និបន្នស្ស តាទិនោ
គិរិនេលស្ស បុប្ផានំ មុដ្ឋិំ ពុទ្ធស្ស ខេបយិំ ។





ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុ ដែលខ្ញុំបានថ្វាយផ្លែឈើ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃការថ្វាយផ្លែឈើ ។ ក្នុងកប្បទី ៥៧ អំពីកប្បនេះ ខ្ញុំបាន កើតជាស្តេចចក្រពត្តិ ព្រះនាមឯកជ្ឈ ទ្រង់បរិបូណ៌ដោយ កែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំង សាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតិន្ទុកផលិយត្ថេរ មានអាយុ បានសម្តែងនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តិន្ទុកផលិយត្ថេរាបទាន ។

## គិរិនេលមុដ្ឋិបុប្ផិយត្ថេរាបទាន ទី ៨

(៨៩) ព្រះជិនស្រី មានព្រះនាម ព្រះនាមសុមេធៈ ជាច្បង ក្នុងលោក ជានរាសភៈ ទ្រង់តាំងព្យាយាម ដើម្បីអនុគ្រោះ ពួកសត្វជាន់ក្រោយ ។ ព្រះសុមេធៈអង្គនោះ ជាធំជាង សត្វជើងពីរ ទ្រង់មិនញាប់ញ័រដោយលោកធម៌ ស្តេចកំពុង ចង្រ្កម ខ្ញុំបូជាផ្កាគិរិនេលព្រឹក្សមួយក្តាប់ ដល់ព្រះសម្ពុទ្ធ ។

តេន ចិត្តប្បសាទេន សុក្កមូលេន ចោទិតោ
តិំសកប្បសហស្សានិ ទុគ្គតិំ នុបបជ្ជហំ ។
តេវីសតិកប្បសតេ សុនន្ទោ នាម ខត្តិយោ
សត្តរតនសម្បន្នោ ឯកោ អាសិ មហព្ពលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា គិរិនេលមុដ្ឋិបុប្ផិយត្ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

គិរិនេលមុដ្ឋិបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

## នវមំ និគ្គុណ្ឌិបុប្ផិយត្ថេរាបទានំ

(៨៨) សុមង្គលោតិ នាមេន សយម្ភូ អបរាជិតោ
បវនា(១) និក្ខមិត្វាន នគរំ បាវិសិ ជិនោ ។
បិណ្ឌចារំ ចរិត្វាន និក្ខម្ម នគរា មុនិ
កតកិច្ចោវ សម្ពុទ្ធោ សោ វសិ វនមន្តរេ ។

---
១ ម. វិបិនា ។



ខ្ញុំត្រូវកុសលមូលដាស់តឿន ខ្ញុំមិនដែលទៅកាន់ទុគ្គតិ អស់ ៣០.០០០ កប្ប ដោយចិត្តជ្រះថ្លានោះ ក្នុងកប្បទី ៦.៣០០ ខ្ញុំបានកើតជាស្តេចចក្រពត្តិមួយអង្គ ព្រះនាមសុនន្ទៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះគិរិនេលមុដ្ឋិបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ គិរិនេលមុដ្ឋិបុប្ផិយត្ថេរាបទាន ។

## និគ្គុណ្ឌិបុប្ផិយត្ថេរាបទាន ទី ៩

(៨៨) ព្រះជិនស្រីសយម្ភូ ទ្រង់ឈ្នះមារ ព្រះនាមសុមង្គលៈ ស្តេចចេញអំពីព្រៃ ហើយចូលទៅកាន់ទីក្រុង ។ ព្រះមុនី ស្តេចទៅបិណ្ឌបាត្រ ហើយចេញអំពីទីក្រុង លុះព្រះសម្ពុទ្ធអង្គនោះ ទ្រង់ធ្វើកិច្ចរួចហើយ ក៏គង់ក្នុងចន្លោះព្រៃ ។

អដ្ឋមំ តិកណ្ណិបុប្ផិយត្ថេរាបទានំ

តិកណ្ណិបុប្ផំ(១) បគ្គយ្ហ ពុទ្ធស្ស អភិរោបយឹ

បសន្នចិត្តោ សុមនោ សយម្ភុស្ស មហេសិនោ ។

ឯកនវុតេ ឥតោ កប្បេ យំ បុប្ផមភិរោបយឹ

ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។

ឯកាសីតិតោ កប្បេ អបរសេនសនាមកោ(២)

សត្តរតនសម្បន្នោ ចក្កវត្តី មហព្ពលោ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា តិកណ្ណិបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តិកណ្ណិបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. តិកណ្ណិកំ ។ ២ ម. អបិណ្ណសំសនាមកោ ។



តិកណ្ណិបុប្ផិយត្ថេរាបទាន ទី ៨

ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានយកផ្កាតិកណ្ណិក្រើក បូជាដល់ព្រះពុទ្ធសយម្ភូ ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៨១ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ មួយអង្គ ព្រះនាម អបរសេនៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតិកណ្ណិបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តិកណ្ណិបុប្ផិយត្ថេរាបទាន ។

## ទសមំ យូថិកបុប្ផិយត្ថេរាបទានំ

(១០០) បទុមុត្តរោ នាម ជិនោ អាហុតីនំ បដិគ្គហោ

បវនា និក្ខមិត្វាន វិហារំ យាតិ ចក្ខុមា ។

ឧភោហត្ថេហិ បគ្គយ្ហ យូថិកំ បុប្ផមុត្តមំ

ពុទ្ធស្ស អភិរោបេសឹ មេត្តចិត្តស្ស តាទិនោ ។

តេន ចិត្តប្បសាទេន អនុភោត្វាន សម្បទា

កប្បានំ សតសហស្សំ ទុគ្គតឹ នុបបជ្ជហំ ។

ឥតោ បញ្ញាសកប្បេសុ ឯកោ អាសឹ ជនាធិបោ

សមិតនន្ទនោ នាម ចក្កវត្តី មហព្វលោ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា យូថិកបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

យូថិកបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។





## យូថិកបុប្ផិយត្ថេរាបទាន ទី ១០

(១០០) ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ទ្រង់មានបញ្ញាចក្ខុ ព្រះអង្គទ្រង់ទទួលគ្រឿងបូជា ទ្រង់ចេញអំពីព្រៃហើយស្តេចទៅកាន់វិហារ ។ ខ្ញុំកាន់ផ្កាយូថិកាដ៏ប្រសើរ ដោយដៃទាំងពីរ យកទៅបូជាដល់ព្រះសម្ពុទ្ធ ទ្រង់មានព្រះហឫទ័យប្រកបដោយមេត្តា មិនញាប់ញ័រដោយលោកធម៌ ។ ខ្ញុំបានសម្បទាហើយ ។ មិនដែលទៅកាន់ទុគ្គតិ អស់មួយសែនកប្ប ដោយចិត្តជ្រះថ្លានោះ ។ ក្នុងកប្បទី ៥០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិមួយអង្គ ជាធំជាងជន ព្រះនាមសមិតនន្ទនៈ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះយូថិកបុប្ផិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ យូថិកបុប្ផិយត្ថេរាបទាន ។

## ឧទ្ទានំ

តមាលិ តិណសន្ថារោ ខណ្ឌផុល្លិ អសោកិយោ
អង្កោលកោ កិសលយោ(១) តិន្ទុកោ នេលបុប្ផិយោ
កិង្កណិកោ ច យូថិកោ(២) គាថា បញ្ញាស អដ្ឋ ច ។

តមាលបុប្ផិយវគ្គោ វីសតិមោ ។

## អថ វគ្គុទ្ទានំ

ភិក្ខាទាយី បរិវារោ សេរេយ្យោ(៣) សោភិតោ តថា
ឆត្តោ(៤) ច ពន្ធុជីវី ច សុបារិចរិយោបិ ច
កុមុទោ កុដជោ ចេវ តមាលិ ទសមោ កតោ
ឆ សតានិ ច គាថានំ ឆសដ្ឋី ច តទុត្តរិ ។

ភិក្ខាវគ្គទសកំ ទុតិយសតកំ សមត្តំ ។

---

១ ម. បល្លវា ច ។ ២ ម. កិង្កណិកបុប្ផិយោ ច ។ ៣ ម. សេរេយ្យោ ។ ៤ ម. ឆត្តំ ។



## ឧទ្ទាន

តមាលបុប្ផិយត្ថេរាបទាន ១ តិណសន្ថារទាយកត្ថេរាបទាន ១ ខណ្ឌផុល្លិយត្ថេរាបទាន ១ អសោកបូជកត្ថេរាបទាន ១ អង្កោលកត្ថេរាបទាន ១ កិសលយបូជកត្ថេរាបទាន ១ តិន្ទុកទាយកត្ថេរាបទាន ១ នេឡបុប្ផិយបូជកត្ថេរាបទាន ១ កិង្កណិបុប្ផិយត្ថេរាបទាន ១ យូថិកបុប្ផិយត្ថេរាបទាន ១ មាន គាថា ៥៨ ។

ចប់ តមាលបុប្ផិយវគ្គ ទី ២០ ។

## មួយទៀត ឧទ្ទាននៃវគ្គ

ភិក្ខាទាយិវគ្គ ១ មហាបរិវារវគ្គ ១ សេរេយ្យវគ្គ ១ សោភិតវគ្គ ១ ឆត្តវគ្គ ១ ពន្ធុជីវកវគ្គ ១ សុបារិចរិយវគ្គ ១ កុមុទវគ្គ ១ កុដជវគ្គ ១ តមាលបុប្ផិយវគ្គ ១ ត្រូវជា ១០ វគ្គ មានគាថា ៦៦៦ ។

ចប់ ភិក្ខាវគ្គទសកៈ និង ទុតិយសតកៈ ។

# ឯកវីសតិមោ កណិការបុប្ផិយវគ្គោ

## បឋមំ កណិការបុប្ផិយត្ថេរាបទានំ

(១០១) កណិការំ(១) បុប្ផិតំ ទិស្វា ឱចិនិត្វានហំ តទា

តិស្សស្ស អភិរោបេសឹ ឱឃតិណ្ណស្ស តាទិនោ ។

ទ្វេនវុតេ ឥតោ កប្បេ យំ បុប្ផមភិរោបយឹ

ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។

បញ្ចត្តឹសេ ឥតោ កប្បេ អរុណបាណីតិ វិស្សុតោ

សត្តរតនសម្បន្នោ ចក្កវត្តិ មហព្វលោ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា កណិការបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កណិការបុប្ផិយត្ថេរស្ស អបទានំ បឋមំ ។

---

១ ម. កណិកំ ។

# កណិការបុប្ផិយវគ្គ ទី ២១

## កណិការបុប្ផិយត្ថេរាបទាន ទី ១

(១០១) ក្នុងកាលនោះ ខ្ញុំឃើញដើមកណិការមានផ្ការីក ហើយបេះយកទៅបូជាព្រះតិស្សសម្ពុទ្ធ ទ្រង់ឆ្លងឱឃផុតហើយ មិនញាប់ញ័រដោយលោកធម៌ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៣៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៣ ជាតិ ព្រះនាមអរុណបាណ ល្បីល្បាញ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះកណិការបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កណិការបុប្ផិយត្ថេរាបទាន ។

## ទុតិយំ មិឡេលបុប្ផិយត្ថេរាបទានំ

សុវណ្ណវណ្ណោ ភគវា សតរំសី បភាករោ(១)
ចង្កមនំ សមារុឡ្ហោ មេត្តចិត្តោ សិខី សភោ ។
បសន្នចិត្តោ សុមនោ ជោមេត្វា ញាណមុត្តមំ
មិឡេលបុប្ផំ បគ្គយ្ហ ពុទ្ធស្ស អភិរោបយឹ ។
ឯកត្តឹសេ ឥតោ កប្បេ យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
ឯកូនត្តឹសេ កប្បម្ហិ សុមេឃឃនវាហនោ
សត្តរតនសម្បន្នោ ចក្កវត្តី មហព្ពលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា មិឡេលបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

មិឡេលបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. បតាបវា ។



## មិឡេលបុប្ផិយត្ថេរាបទាន ទី ២

[១០៦] ព្រះមានព្រះភាគ ព្រះនាមសិខី ទ្រង់មានវណ្ណៈ ដូចមាស មានរស្មីច្រើន មានពន្លឺដ៏ប្រសើរ មានមេត្តាចិត្ត មានព្រះស្មារតី ស្តេចទៅកាន់ទីចង្ក្រម ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ សរសើរនូវញាណដ៏ឧត្តម ហើយយកនូវផ្កាមិឡេលព្រឹក្ស ទៅបូជាដល់ព្រះសម្ពុទ្ធ ។ គន្លងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ គន្លងកប្បទី ៦៩ ខ្ញុំបានកើតជាស្តេចចក្រពត្តិមួយអង្គ ព្រះនាមសុមេឃឃនៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបាន ប្រតិបត្តិហើយ ។

បានឮថា ព្រះមិឡេលបុប្ផិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មិឡេលបុប្ផិយត្ថេរាបទាន ។

## តតិយំ កឹកណិកបុប្ផិយត្ថេរាបទានំ

[១០៣] កាញ្ចនគ្ឃិយសង្កាសោ សព្វញ្ញូ លោកនាយកោ

ឧទកំ ឧហមោគ្គយ្ហ សិនាយិ លោកនាយកោ ។
បគ្គយ្ហ កឹកណិបុប្ផំ វិបស្សិស្សាភិរោបយឹ
ឧទគ្គចិត្តោ សុមនោ ទិបទិន្ទស្ស តាទិនោ ។
ឯកនវុតេ ឥតោ កប្បេ យំ បុប្ផមភិរោបយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
សត្តវីសតិកប្បម្ហិ រាជា ភិមរថោ អហុ
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា កឹកណិកបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កឹកណិកបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។





## កឹកណិកបុប្ផិយត្ថេរាបទាន ទី ៣

[១០៣] ព្រះសព្វញ្ញូ លោកនាយក ប្រាកដស្មើដោយគ្រឿងបូជាដ៏វិការៈនៃមាស ព្រះលោកនាយក ស្តេចចុះកាន់ទឹកស្រះហើយទ្រង់ស្រង់ ។ ខ្ញុំមានចិត្តត្រេកអរ មានចិត្តរីករាយ កាន់យកនូវផ្កាកណ្ណិង ទៅបូជាដល់ព្រះវិបស្សី ជាធំជាងសត្វជើងពីរ ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ២៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមភិមរថ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះកឹកណិកបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កឹកណិកបុប្ផិយត្ថេរាបទាន ។

## ចតុត្ថំ តរណិយត្ថេរាបទានំ

(១០៦) អត្ថទស្សី តុ ភគវា ទិបទិន្ទោ នរាសភោ
បុរក្ខតោ សាវកេហិ គង្គាតីរំ ឧបាគមិ ។
សមតិត្តិ កាកបេយ្យា គង្គា អាសិ ទុរុត្តរា
ឧត្តារយឹ ភិក្ខុសង្ឃំ ពុទ្ធញ្ច ទិបទុត្តមំ ។
អដ្ឋារសេ កប្បសតេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ តរណាយ ឥទំ ផលំ ។
តេរសេ កប្បសតេ បញ្ច សព្វោភវា អហុំ
សត្តរតនសម្បន្នា ចក្កវត្តី មហព្ពលា(១) ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា តរណិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តរណិយត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. ឥតោ យំ បច្ឆិមកេ ភវេ អស្មឹ ជាតោហំ ព្រាហ្មណោ កុលេ សទ្ធឹ តីហិ សហាយេហិ បព្វជឹ សត្ថុ សាសនេតិ ទិស្សន្តិ ។



## តរណិយត្ថេរាបទាន ទី ៤

(១០៦) ព្រះមានព្រះភាគ ព្រះនាមអត្ថទស្សី ជាធំជាងសត្វជើងពីរ ជាអាសភៈ មានពួកសាវ័កហែហម ស្តេចចូលទៅកាន់ឆ្នេរទន្លេគង្គា ។ ឯទន្លេគង្គា មានទឹកពេញប្រៀបល្មមក្អែកផឹកបាន ជាស្ទឹងដែលគេឆ្លងបានដោយក្រ ខ្ញុំបានចម្លងភិក្ខុសង្ឃផង ព្រះពុទ្ធដ៏ឧត្តមជាងសត្វជើងពីរផង ។ ក្នុងកប្បទី ១,៨០០ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការចម្លង ។ ក្នុងកប្បទី ១,៣០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៥ ជាតិ ព្រះនាមសព្វោភវៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតរណិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តរណិយត្ថេរាបទាន ។

## បញ្ចមំ និគ្គុណ្ឌិបុប្ផិយត្ថេរាបទានំ

(១០៨) វិបស្សិស្ស ភគវតោ អាសឹ អារាមិកោ អហំ
និគ្គុណ្ឌិបុប្ផំ បគ្គយ្ហ ពុទ្ធស្ស អភិរោបយឹ ។
ឯកនវុតេ ឥតោ កប្បេ យំ បុប្ផមភិរោបយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
បញ្ចត្តឹសេ ឥតោ កប្បេ ឯកោ អាសឹ ជនាធិបោ
មហាបតាបោ នាមេន ចក្កវត្តិ មហព្ពលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា និគ្គុណ្ឌិបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

និគ្គុណ្ឌិបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។



## និគ្គុណ្ឌិបុប្ផិយត្ថេរាបទាន ទី ៥

(១០៨) ខ្ញុំជាអារាមិកជនរបស់ព្រះមានព្រះភាគ ព្រះនាម វិបស្សី បានយកផ្កាឈើគន្លឹង ទៅបូជាដល់ព្រះពុទ្ធ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៣៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ មួយអង្គ ជាធំជាងជន ព្រះនាមមហាបតាបៈ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះនិគ្គុណ្ឌិបុប្ផិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ និគ្គុណ្ឌិបុប្ផិយត្ថេរាបទាន ។

## ឆដ្ឋំ ឧទកទាយកត្ថេរាបទានំ

(១០៦) ភុញ្ជន្តំ សមណំ ទិស្វា វិប្បសន្នមនាវិលំ
ឃដេនោទកមាទាយ សិទ្ធត្ថស្ស មហេសិនោ ។
និម្មលោ ហោមហំ អជ្ជ វិមលោ ខីណសំសយោ
ភវេ និព្វត្តមានម្ហិ(១) ផលំ និព្វត្តេ មម(២) ។
ចតុន្នវុតេ ឥតោ កប្បេ ឧទកំ អទទឹ តទា(៣)
ទុគ្គតឹ នាភិជានាមិ ទកទានស្សិទំ(៤) ផលំ ។
ឯកសដ្ឋិម្ហិតោ កប្បេ ឯកោវ វិមលោ អហុ
សត្តរតនសម្បន្នោ ចក្កវត្តី មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ឧទកទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឧទកទាយកត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. និព្វត្តមានកម្មេ ។ ២ ម. សុភំ ។ ៣ ម. ចតុន្នវុតិតោ កប្បេ ឧទកំ យមទាសហំ ។ ៤ ម. ទកទានស្សិទំ ។



## ឧទកទាយកត្ថេរាបទាន ទី ៦

(១០៦) ខ្ញុំឃើញ (នូវព្រះសិទ្ធត្ថសម្ពុទ្ធ) ជាសមណៈ កំពុងឆាន់ បានដងទឹកថ្វាយមួយក្អម ថ្វាយដល់ព្រះសិទ្ធត្ថៈ ។ ក្នុងថ្ងៃនេះ ខ្ញុំមិនមានមន្ទិល ប្រាសចាកមន្ទិល អស់សេចក្ដីសង្ស័យ ក្នុងភពដែលខ្ញុំកើតហើយ ផលរមែងកើតដល់ខ្ញុំ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានថ្វាយទឹក ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយទឹក ។ ក្នុងកប្បទី ៦១ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិមួយអង្គ ព្រះនាមវិមលៈ ប្រកបដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឧទកទាយកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឧទកទាយកត្ថេរាបទាន ។

## សត្តមំ សលឡមាលិយត្ថេរាបទានំ

(១០៧) កណិការំវ ជោតន្តំ និសិន្នំ បព្វតន្តរេ
ឱភាសេន្តំ ទិសា សព្វា សិទ្ធត្ថំ នរសារថឹ ។
ធនុំ អទេជ្ជំ(១) កត្វាន ឧសុំ សន្ធាយហំ តទា(២)
បុប្ផំ សវណ្ដំ ឆេត្វាន ពុទ្ធស្ស អភិរោបយឹ ។
ចតុន្នវុតេ ឥតោ កប្បេ យំ បុប្ផមភិរោបយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
ឯកបញ្ញាសិតោ កប្បេ ឯកោ អាសិំ ជុតិន្ធរោ
សព្វរតនសម្បន្នោ ចក្កវត្តី មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា សលឡមាលិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សលឡមាលិយត្ថេរស្ស អបទានំ សត្តមំ ។

---

១ ម. អទេជ្ឈំ ។ ២ ម. ឧសុំ សន្នយ្ហ ហន្តទា ។



## សលឡមាលិយត្ថេរាបទាន ទី ៧

(១០៧) (ខ្ញុំបានឃើញ) ព្រះសិទ្ធត្ថសម្ពុទ្ធ ព្រះអង្គជាសារថីទូន្មាននរជន ទ្រង់រុងរឿងដូចផ្កាកណិការ គង់នៅក្រឡុំភ្នំ ទ្រង់ញ៉ាំងទិសទាំងពួងឲ្យភ្លឺស្វាង កាលនោះខ្ញុំសៀតព្រួញ ធ្វើធ្នូមិនឲ្យបែកជាពីរ បានកាច់ផ្កាទាំងទង បូជាព្រះពុទ្ធ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៥១ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ មួយអង្គ ព្រះនាមជុតិន្ធរៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសលឡមាលិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សលឡមាលិយត្ថេរាបទាន ។

## អដ្ឋមំ កោរណ្ឌបុប្ផិយត្ថេរាបទានំ

(១០៨)អក្កន្តញ្ច បទំ ទិស្វា ចក្កាលង្ការភូសិតំ
បទេនានុបទំ យន្តោ វិបស្សិស្ស មហេសិនោ ។
កោរណ្ឌំ បុប្ផិតំ ទិស្វា សមូលំ បូជិតំ មយា
ហដ្ឋោ ហដ្ឋេន ចិត្តេន អវន្ទិំ បទមុត្តមំ ។
ឯកនវុតេ ឥតោ កប្បេ យំ បុប្ផមភិបូជយិំ
ទុគ្គតិំ នាភិជានាមិ បទបូជាយិទំ ផលំ ។
សត្តបញ្ញាសកប្បម្ហិ ឯកោ វីតមលោ អហុ
សត្តរតនសម្បន្នោ ចក្កវត្តី មហព្ពលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា កោរណ្ឌបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កោរណ្ឌបុប្ផិយត្ថេរស្ស អបទានំ អដ្ឋមំ ។



## កោរណ្ឌបុប្ផិយត្ថេរាបទាន ទី ៨

(១០៨) ខ្ញុំឃើញស្នាមព្រះបាទ ដែលទ្រង់ជាន់ទុក ប្រដាប់ដោយគ្រឿងអលង្ការគឺចក្រ ហើយដើរទៅតាមលំដាប់ នៃស្នាមព្រះបាទ របស់ព្រះមហាឥសីព្រះនាមវិបស្សី ។ ខ្ញុំបានឃើញផ្កាសៅកន្ធុ ដែលរីកល្អ ហើយបូជាទាំងឫស ខ្ញុំជាអ្នកមានចិត្តរីករាយ បានថ្វាយបង្គំ ស្នាមព្រះបាទដ៏ប្រសើរ ដោយចិត្តរីករាយ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃការបូជា ។ ក្នុងកប្បទី ៥៧ ខ្ញុំបានកើតជាស្តេចចក្រពត្តិមួយអង្គ ព្រះនាមវីតមលៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ នឹងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះកោរណ្ឌបុប្ផិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កោរណ្ឌបុប្ផិយត្ថេរាបទាន ។

## នវមំ អាហារទាយកត្ថេរាបទានំ

[១០៩] អាហារំ មយា ទិន្នំ សិទ្ធត្ថេ លោកពន្ធុនោ

ជាយេថ បវរំ សត្ថំ ភោគេលំ វសុធំ ឥមំ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

ធារេមិ អន្តិមំ ទេហំ សម្មាសម្ពុទ្ធសាសនេ ។

សត្តសដ្ឋេ ឥតោ កប្បេ អហេសុំ ចតុរោ ជនា

សមន្តវរុណា នាម ចក្កវត្តី មហព្វលា ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា អាហារទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អាហារទាយកត្ថេរស្ស អបទានំ សមត្តំ ។



## អាហារទាយកត្ថេរាបទាន ទី ៩

(១០៩) ខ្ញុំបានថ្វាយនូវអាហារ ដល់ព្រះសិទ្ធត្ថ ជាលោកពន្ធុ (ដោយកុសលកម្មនោះ) ខ្ញុំត្រេចទៅកើតលើផែនដីទាំងមូលនោះ ។ ខ្ញុំផុតចំណងកិលេសទាំងឡាយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំត្រេចទៅកើតកាយជាទីបំផុត ក្នុងសាសនា របស់ព្រះសម្មាសម្ពុទ្ធ ។ ក្នុងកប្បទី ៦៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៦ ជាតិ ព្រះនាមសមន្តវរុណដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអាហារទាយកត្ថេរ មានអាយុ បានសម្តែងគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អាហារទាយកត្ថេរាបទាន ។

## ទសមំ បាបនិវារិយត្ថេរាបទានំ

(១១០) តិស្សស្ស ហិ ភគវតោ ទេវទេវស្ស តាទិនោ

ឯកច្ឆត្តំ មយា ទិន្នំ វិប្បសន្នេន ចេតសា ។
និវុតំ ហោតិ មេ បាបំ កុសលស្សុបសម្បទា
អាកាសេ ឆត្តំ ធារេន្តិ បុព្វកម្មស្សិទំ ផលំ ។
ចរិមំ វត្តតេ មយ្ហំ ភវា សព្វេ សមូហតា
ធារេមិ អន្តិមំ ទេហំ សម្មាសម្ពុទ្ធសាសនេ ។
ទ្វេនវុតេ ឥតោ កប្បេ យំ ឆត្តមទទឹ តទា
ទុគ្គតឹ នាភិជានាមិ ឆត្តទានស្សិទំ ផលំ ។
ទ្វេសត្តតិ ឥតោ កប្បេ អដ្ឋាសីសុ ជនាធិបា
មហានិធាននាមេន រាជានោ ចក្កវត្តិនោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បាបនិវារិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បាបនិវារិយត្ថេរស្ស អបទានំ សមត្តំ ។



## បាបនិវារិយត្ថេរាបទាន ទី ១០

(១១០) ខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយឆត្រមួយ ដល់ព្រះមានព្រះភាគព្រះនាមតិស្សៈ ជាទេវតា របស់ទេវតា ជាតាទិបុគ្គល ។ ខ្ញុំបានឃាត់អំពើបាប ហើយបំពេញនូវអំពើកុសល ទៅតាមនិមិត្តនៃឆត្រ (ខ្ញុំ) ក្នុងអាកាស នេះជាផលនៃបុព្វកម្ម ។ ភពជាទីបំផុតរបស់ខ្ញុំ កំពុងប្រព្រឹត្តទៅ ភពទាំងអស់ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំទ្រទ្រង់នូវកាយជាទីបំផុត ក្នុងសាសនា នៃព្រះសម្មាសម្ពុទ្ធ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយឆត្រ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយឆត្រ ។ ក្នុងកប្បទី ៧២ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៨ ជាតិ ជាធំជាងជន ព្រះនាមមហានិទាន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបាបនិវារិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បាបនិវារិយត្ថេរាបទាន ។

## ឧទ្ទានំ

កណិការោ មិនេលញ្ច កិំកណិ តរណេន ច

និគ្គុណ្ឌិបុប្ផី ឧទកោ សលឡោ ច កុរណ្ឌកោ

អាធារកាធំ បាទបញ្ច អដ្ឋតាឡីស គាថិកា ។

កណិការបុប្ផិយវគ្គោ វីសតិមោ ។

---



## ឧទ្ទាន

កណិការបុប្ផិយត្ថេរាបទាន ១ មិនេលបុប្ផិយត្ថេរាបទាន ១

កឹកណិកបុប្ផិយត្ថេរាបទាន ១ តរណិយត្ថេរាបទាន ១

និគ្គុណ្ឌិបុប្ផិយត្ថេរាបទាន ១ ឧទកទាយកត្ថេរាបទាន ១

សលឡមាលិយត្ថេរាបទាន ១ កោរណ្ឌបុប្ផិយត្ថេរាបទាន ១

អាធារទាយកត្ថេរាបទាន ១ បាបនិកិរិយត្ថេរាបទាន ១

មានគាថា ៤៨ ។

ចប់ កណិការបុប្ផិយវគ្គ ទី ២០ ។

---

## ពាវីសតិមោ ហត្ថិវគ្គោ

## បឋមំ ហត្ថិទាយកត្ថេរាបទានំ

(១១១) សិទ្ធត្ថស្ស ភគវតោ ទិបទិន្ទស្ស តាទិនោ
នាគសេដ្ឋោ មយា ទិន្នោ ឦសាទន្តោ ឧរូឡ្ហវា ។
ឧត្តមត្ថំ អនុភោមិ សន្តិបទមនុត្តរំ
នាគទានំ[១] មយា ទិន្នំ សព្វលោកហិតេសិនោ ។
ចតុន្នវុតេ ឥតោ កប្បេ យំ នាគមទទឹ តទា[២]
ទុគ្គតឹ នាភិជានាមិ នាគទានស្សិទំ ផលំ ។
អដ្ឋសត្តតិកប្បម្ហិ សោឡសាសឹសុ ខត្តិយា
សមន្តបាសាទិកា នាម ចក្កវត្តី មហព្វលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ហត្ថិទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ហត្ថិទាយកត្ថេរស្ស អបទានំ សមត្តំ ។

---

១ ឱ. ភទ្ទកំ ។ ២ ម. តទទឹតទា ។

## ហត្ថិវគ្គ ទី ២២

## ហត្ថិទាយកត្ថេរាបទាន ទី ១

(១១១) ខ្ញុំបានថ្វាយដំរីប្រសើរ មានភ្លុកវែង មានកម្ពស់ ក្សាយាមក្លាហាន ដល់ព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ជាធំជាងសត្វជើងពីរ ជាតាទិបុគ្គល ។ ខ្ញុំបានដល់ប្រយោជន៍ដ៏ឧត្តម គឺសន្តិបទដ៏ប្រសើរនេះឯង ព្រោះខ្ញុំបានថ្វាយដំរីដល់ព្រះសម្ពុទ្ធ ទ្រង់ស្វែងរកនូវប្រយោជន៍ ដល់សត្វលោកទាំងពួង ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានថ្វាយដំរី ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយដំរី ។ ក្នុងកប្បទី ៧៨ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១៦ ជាតិ ព្រះនាមសមន្តបាសាទិកៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះហត្ថិទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ហត្ថិទាយកត្ថេរាបទាន ។

## ទុតិយំ បាទបីឋិយត្ថេរាបទានំ

[១១៦] អរញ្ញកស្ស ឈាយិនោ(១) មេត្តចិត្តកបស្សិនោ(២)

ឧច្ចស្ស ភាវិតត្តស្ស  អទាសិំ បាទបីឋំ អហំ ។
តេន កម្មេន ទិបទិន្ទ  លោកជេដ្ឋ នរាសភ
និព្វាយាមិ អនុកោមិ  ពុទ្ធកម្មស្សិទំ ផលំ ។
ចតុន្នវុតេ ឥតោ កប្បេ  យំ កម្មមករិំ តទា
ទុគ្គតិំ នាភិជានាមិ  បាទបីឋស្ស ឥទំ ផលំ ។
សត្តសត្តតិតោ កប្បេ  អដ្ឋ អាសិំសុ ខត្តិយា
សុយាមា នាម នាមេន  ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា បាទបីឋិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បាទបីឋិយត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. វនិតោ ។ ២ ម. ចិត្តកបស្សិនោ ។



## បាទបីឋិយត្ថេរាបទាន ទី ២

(១១៦) ខ្ញុំបានថ្វាយកៅអីទ្រជើងដល់សម្ពុទ្ធ អ្នកមានមេត្តាចិត្ត មានសមាធិ នៅក្នុងព្រៃ ចម្រើនឈាន ចម្រើនធម៌ ។ បពិត្រព្រះអង្គជាធំជាងសត្វជើងពីរ ជាបុរសប្រសើរក្នុងលោក ជានរាសភៈ ខ្ញុំនឹងបាននូវព្រះនិព្វាន ដោយកម្មនោះ នេះជាផលនៃពុទ្ធកម្ម ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃកៅអីទ្រជើង ។ ក្នុងកប្បទី ៧៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៨ ជាតិ ព្រះនាមសុយាមៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបាទបីឋិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បាទបីឋិយត្ថេរាបទាន ។

## តតិយំ សទ្ទសញ្ញកត្ថេរាបទានំ

(១១៣) វេស្សភូ នាម នាមេន កិត្តិសទ្ទបុរេក្ខតោ

ទេសេតិ អរិយសច្ចានិ និព្វាបេន្តោ មហាជនំ ។

បរមការុញ្ញបត្តម្ហិ សមិតឹ អគមាសហំ

សោហំ និសិន្នកោ សន្តោ ធម្មំ អស្សោសិ សត្ថុនោ ។

តស្សាហំ ធម្មំ សុត្វាន ទេវលោកំ អគច្ឆហំ

តឹស កប្បានិ ទេវេសុ អវសឹ តត្ថហំ បុរេ ។

ឯកត្តឹសេ ឥតោ កប្បេ យំ សញ្ញមលភឹ តទា

ទុគ្គតឹ នាភិជានាមិ សទ្ទសញ្ញាយិទំ ផលំ ។

ឆសដ្ឋិ ឥតោ កប្បេ ឯកោ អាសឹ ជនាធិបោ

ឯកផុស្សិតនាមោ ចក្កវត្តី មហព្វលោ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សទ្ទសញ្ញកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សទ្ទសញ្ញកត្ថេរស្ស អបទានំ សមត្តំ ។



## សទ្ទសញ្ញកត្ថេរាបទាន ទី ៣

(១១៣) ព្រះមានព្រះភាគព្រះនាមវេស្សភូ មានកិត្តិសព្ទ ដោយការទ្រង់សម្តែងអរិយសច្ច ញ៉ាំងមហាជនឲ្យរលត់ទុក្ខ ។ ខ្ញុំដល់នូវសេចក្តីករុណា បាននៅកាន់ទីប្រជុំ ខ្ញុំនោះអង្គុយស្តាប់ធម៌របស់ព្រះសាស្តា ។ លុះខ្ញុំស្តាប់ធម៌របស់ព្រះសាស្តានោះហើយ ក៏បានទៅកាន់ទេវលោក ខ្ញុំនៅក្នុងបុរីក្នុងទេវលោកនោះ អស់ ៣០ កប្ប ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបាននូវសញ្ញា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសទ្ទសញ្ញា ។ ក្នុងកប្បទី ៦៦ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិមួយអង្គ ជាធំជាងជន ព្រះនាមឯកផុស្សិតៈ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសទ្ទសញ្ញកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សទ្ទសញ្ញកត្ថេរាបទាន ។

## ចតុត្ថំ ឯកសញ្ញកត្ថេរាបទានំ

(១១៦) ទុមគ្គេ បំសុកូលិកំ លគ្គំ ទិស្វាន សត្ថុនោ
អញ្ជលឹ បគ្គហេត្វាន បំសុកូលំ អវន្ទហំ ។
ឯកត្តឹសេ ឥតោ កប្បេ យំ សញ្ញមលភឹ តទា
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
បញ្ចវីសេ ឥតោ កប្បេ ឯកោ អាសឹ ជនាធិបោ
អមិត្តមទ្ទនោ នាម ចក្កវត្តី មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឯកសញ្ញកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឯកសញ្ញកត្ថេរស្ស អបទានំ សមត្តំ ។

## បញ្ចមំ រំសិសញ្ញកត្ថេរាបទានំ

(១១៧) ឧទេន្តំ សតរំសឹវ បីតរំសឹវ ភាណុមំ
ព្យគ្ឃូសភំវ បវរំ សុជាតំ បព្វតន្តរេ ។



## ឯកសញ្ញកត្ថេរាបទាន ទី ៤

(១១៦) ខ្ញុំឃើញសំពត់បង្សុកូល ដែលទ័រលើចុងឈើ ក៏ផ្គងអញ្ជលីថ្វាយសំពត់បង្សុកូលរបស់ព្រះសាស្តា ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបាននូវសញ្ញា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ២៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិមួយអង្គ ជាធំជាងជន ព្រះនាមអមិត្តមទ្ទនៈ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកសញ្ញកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឯកសញ្ញកត្ថេរាបទាន ។

## រំសិសញ្ញកត្ថេរាបទាន ទី ៥

(១១៧) (ខ្ញុំបានឃើញ) ព្រះសុគតសម្ពុទ្ធ ទ្រង់មានរស្មីច្រើន ដូចព្រះអាទិត្យដែលទើបនឹងរះ ឬដូចព្រះចន្ទ្រមានរស្មីលឿង ព្រោះអង្គប្រសើរ ដូចខ្លាធំនិងគោឧសភ ត្រង់ចន្លោះភ្នំ ។

### បាលី វិសេសញ្ញូថេរាបទាន

ពុទ្ធស្ស អានុភាវេន សោ ជិនោ ធម្មក្ខន្ធេ
វិសេ ចិត្តំ បសាទេត្វា កប្បំ សត្តុធិ ពោធយំ ។
អវសេសេសុ កប្បេសុ កុសលំ ការិតំ មយា
តេន ចិត្តប្បសាទេន ពុទ្ធានុស្សតិយាបិច ។
តិំសកប្បសហស្សេតោ យំ សញ្ញមលភឹ តទា
ទុគ្គតឹ នាភិជានាមិ ពុទ្ធសញ្ញាយិទំ ផលំ ។
សត្តបញ្ញាសកប្បម្ហិ ឯកោ អាសឹ ជនាធិបោ
សុជាតោ នាម នាមេន ចក្កវត្តិ មហព្ពលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។
ឥត្ថំ សុទំ អាយស្មា វិសេសញ្ញូ ថេរោ ឥមា
គាថាយោ អភាសិត្ថាតិ ។

វិសេសញ្ញូថេរស្ស អបទានំ សមត្តំ ។



### វិសេសញ្ញូថេរាបទាន ទី ៨

អានុភាពរបស់ព្រះពុទ្ធនោះ ប្រឹងធ្វើដល់ព្រះនាងអ្នក ខ្ញុំធ្វើចិត្ត
ឲ្យជ្រះថ្លាក្នុងសេដ្ឋីហើយ ក៏បានទៅកើតក្នុងឋានសួគ៌ អស់
មួយកប្ប ។ ក្នុងកប្បទាំងឡាយដ៏សេស ខ្ញុំបានធ្វើកុសល
ដោយចិត្តជ្រះថ្លានោះផង ដោយការរលឹកព្រះពុទ្ធគុណផង ។ ក្នុង
កប្បទី ៣០.០០០ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុ
ដែលខ្ញុំ បានធ្វើសញ្ញា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល
នៃសេចក្តីសំគាល់ក្នុងព្រះពុទ្ធ ។ ក្នុងកប្បទី ៨៧ អំពីកប្ប
នេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ មួយអង្គ ជាធំជាងជន
ព្រះនាមសុជាត ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤
វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ
ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះវិសេសញ្ញូត្ថេរ មានអាយុ បានសំដែងនូវ
គាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ វិសេសញ្ញូត្ថេរាបទាន ។

# ឆដ្ឋំ សញ្ញិកត្ថេរាបទានំ

(១០៦) អស្សត្ថេ ហរិតោភាសេ សំវិរូឡ្ហម្ហិ បាទបេ

ឯកំ ពុទ្ធគតំ សញ្ញំ អលភិំ បតិស្សតោ ។

ឯកត្តិំសេ ឥតោ កប្បេ យំ សញ្ញមលភិំ តទា

តស្សា សញ្ញាយ វាហសា បត្តោ មេ អាសវក្ខយោ ។

ឥតោ តេរសកប្បម្ហិ ធនិដ្ឋោ នាម ខត្តិយោ

សត្តរតនសម្បន្នោ ចក្កវត្តិ មហព្វលោ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ។

ឥត្ថំ សុទំ អាយស្មា សញ្ញិកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សញ្ញិកត្ថេរស្ស អបទានំ ឆដ្ឋំ ។



# សញ្ញកត្ថេរាបទាន ទី ៦

(១០៦) ខ្ញុំមានស្មារតីបាននូវសញ្ញាមួយ ដែលជាទីនៅ ក្នុងព្រះពុទ្ធ ត្រង់ដើមអស្សត្ថព្រឹក្ស ដែលមានស្លឹកខៀវ ដុះឡើងស្រួបស្រួល ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បាននូវសញ្ញា ខ្ញុំដល់នូវការអស់ទៅនៃអាសវៈ ដោយអំណាចនៃសញ្ញានោះ ។ ក្នុងកប្បទី ១៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមធនិដ្ឋៈ ប្រកបដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសញ្ញកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សញ្ញកត្ថេរាបទាន ។

## សត្តមំ តាលវណ្ដទាយកត្ថេរាបទានំ

(១០៧) តាលវណ្ដំ មយា ទិន្នំ តិស្សស្ស ទិច្ចពន្ធុនោ

គិម្ហនិព្វាបនត្ថាយ បរិឡាហោបសន្តិយា ។

សន្និព្វាបេមិ រាគគ្គឹ ទោសគ្គិញ្ច តទុត្តរឹ

និព្វាបេមិ ច មោហគ្គឹ តាលវណ្ដស្សិទំ ផលំ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

ធារេមិ អន្តិមំ ទេហំ សម្មាសម្ពុទ្ធសាសនេ ។

ទ្វេនវុតេ ឥតោ កប្បេ យំ កម្មមការឹ តទា

ទុគ្គតឹ នាភិជានាមិ តាលវណ្ដស្សិទំ ផលំ ។

តេសដ្ឋិម្ហិ ឥតោ កប្បេ មហានាមសនាមកោ

សត្តរតនសម្បន្នោ ចក្កវត្តី មហព្វលោ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា តាលវណ្ដទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តាលវណ្ដទាយកត្ថេរស្ស អបទានំ សត្តមំ ។



## តាលវណ្ដទាយកត្ថេរាបទាន ទី ៧

(១០៧) ខ្ញុំបានថ្វាយផ្លិតស្លឹកត្នោត ដល់ព្រះបរមពុទ្ធ ព្រះនាមតិស្សៈ ទ្រង់ជាទិច្ចពង្ស ដើម្បីរលត់កម្ដៅ និងរម្ងាប់សេចក្ដីក្រវល់ក្រវាយ ។ ខ្ញុំបានរំលត់ភ្លើងគឺរាគៈផង ភ្លើងគឺទោសៈផង រំលត់ភ្លើងគឺមោហៈផង ដែលជាភ្លើងក្ដៅក្រៃលែងជាងនោះ នេះជាផល នៃផ្លិតស្លឹកត្នោត ។ ខ្ញុំដុតបំផ្លាញកិលេសទាំងឡាយ គាស់រំលើងភពទាំងអស់ ខ្ញុំទ្រទ្រង់នូវកាយជាទីបំផុត ក្នុងសាសនា របស់ព្រះសម្មាសម្ពុទ្ធ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផ្លិតស្លឹកត្នោត ។ ក្នុងកប្បទី ៦៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ មួយអង្គ ព្រះនាមមហានាមៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតាលវណ្ដទាយកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តាលវណ្ដទាយកត្ថេរាបទាន ។

## អដ្ឋមំ កុសាដកទាយកត្ថេរាបទានំ

(១១៨) កុសាដកំ គហេត្វាន ឧបជ្ឈាយស្ស តាទិនោ(១)

មន្តញ្ញ អនុសំកាមិ      កណ្ហាគេធស្ស(២) បត្តិយា ។

អទ្ទសំ វិរជំ ពុទ្ធំ      អាកាសេ ចង្កមិតំ

ផុស្សំ បវរំ អគ្គំ      តិស្សំ ពុទ្ធំ គណុត្តមំ(៣) ។

កុសាដកំ បត្ថរិតំ      អក្កមន្តំ នរុត្តមំ

សមុគ្គតំ មហាវីរំ      លោកជេដ្ឋំ នរាសភំ ។

ទិស្វា តំ លោកបជ្ជោតំ វិមលំ ចន្ទសន្និភំ

អវន្ទិំ សត្ថុនោ បាទេ      វិប្បសន្នេន ចេតសា ។

ចតុន្នវុតេ ឥតោ កប្បេ យំ អទាសិំ កុសាដកំ

ទុគ្គតិំ នាភិជានាមិ      កុសាដកស្សិទំ ផលំ ។

សត្តសដ្ឋិម្ហិតោ កប្បេ ឯកោ អាសិំ ជនាធិបោ

សុនន្ទោ នាម នាមេន      ចក្កវត្តី មហព្វលោ ។

---

១ ម. ឧបជ្ឈាយស្សហំ តុម ។ ២ ឥ. ធម្ម គេធស្ស ។ ៣ ម. គណុត្តមំ ។





## កុសាដកទាយកត្ថេរាបទាន ទី ៨

(១១៨) ខ្ញុំយកសាដកតាក្រក់ (សាដកសាច់ក្រាស់) ហើយសំគាល់ចំពោះ ក្នុងទិសទាំងបួននៃព្រះឧបជ្ឈាយ៍ ដើម្បីដល់នូវការទ្រាយន្ទូរកល ។ ខ្ញុំបានឃើញព្រះពុទ្ធព្រះនាមតិស្សៈ ទ្រង់ប្រាសចាកធូលីគឺកិលេស ល្អទទួលនូវគ្រឿងបូជា ព្រះអង្គខ្ពង់ខ្ពស់ ប្រសើរលើសលុប ទ្រង់ត្រាស់ដឹងនូវសច្ចៈ ឧត្តមជាទីពឹង ។ លុះខ្ញុំបានឃើញព្រះមហាវីរៈ ជានរៈដ៏ឧត្តម ខ្ពង់ខ្ពស់បំផុត ជាច្បងក្នុងលោក ជាគនសោភៈ ទ្រង់ជាន់សំពត់សាដកគឺតាក្រក់ ដែលខ្ញុំក្រាលហើយ ព្រះអង្គបំភ្លឺលោក ដូចព្រះចន្ទ ទ្រង់ប្រាសចាកមន្ទិល បានថ្វាយបង្គំព្រះបាទ របស់ព្រះសាស្ដាដោយចិត្តជ្រះថ្លា ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយសាដកតាក្រក់ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយសាដកតាក្រក់ ។ ក្នុងកប្បទី ៦៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិមួយអង្គ ជាធំជាងជន ព្រះនាមសុនន្ទៈ ទ្រង់មានកម្លាំងច្រើន ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា អក្កន្តសញ្ញកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អក្កន្តសញ្ញកត្ថេរស្ស អបទានំ សមត្តំ ។

## នវមំ សប្បិទាយកត្ថេរាបទានំ

(១១៩) និសិន្នោ បាសាទវរេ នារីគណបុរក្ខតោ
ព្យាធិតំ សមណំ ទិស្វា អភិនាមេសហំ ឃរំ
ឧបវិដ្ឋំ មហាវីរំ ទេវទេវំ នរាសភំ
សប្បិតេលំ មយា ទិន្នំ សិទ្ធត្ថស្ស មហេសិនោ ។
បស្សទ្ធទរថំ ទិស្វា វិប្បសន្នមុខិន្ទ្រិយំ
វន្ទិត្វា សត្ថុនោ បាទេ អនុសំសាវយឹ បុរេ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអក្កន្តសញ្ញកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អក្កន្តសញ្ញកត្ថេរាបទាន ។

## សប្បិទាយកត្ថេរាបទាន ទី ៩

(១១៩) ខ្ញុំអង្គុយក្នុងប្រាសាទដ៏ប្រសើរ មានពួកនារីចោមរោម បានឃើញព្រះសមណៈជាមហាវីរៈ ជាទេវតាដ៏ប្រសើរ ជានរាសភៈ ទ្រង់មានអាពាធ ស្តេចចូលមកជិត ខ្ញុំក៏នាំមកកាន់ផ្ទះ ខ្ញុំបានថ្វាយសប្បិនិងប្រេង ដល់ព្រះសិទ្ធត្ថមហេសី ។ ខ្ញុំឃើញ (ព្រះអង្គ) មានក្រវល់ក្រវាយរម្ងាប់ហើយ មានមុខិន្ទ្រិយស្រស់បស់ ក៏ថ្វាយបង្គំព្រះបាទារបស់ព្រះសាស្តា ហើយដើរទៅខាងមុខ ។

ទិស្វា មំ សុបសន្នំ ឧគ្គិយក តាវទេ កតោ

ឧគំ អព្ភុគ្គមិ វីរោ ហំសរាជាវ អម្ពរេ ។

ឆន្នវុតេ ឥតោ កប្បេ យំ ទានមទទឹ តទា

ទុគ្គតឹ នាភិជានាមិ សប្បិតេលស្សិទំ ផលំ ។

ឥតោ សត្តរសេ កប្បេ ទុតិតេជនាមកោ

សត្តរតនសម្បន្នោ ចក្កវត្តី មហព្ពលោ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា សប្បិទាយកោ ថេរោ

ឥមា គាថាយោ អភាសិត្ថាតិ ។

សប្បិទាយកត្ថេរស្ស អបទានំ សមត្តំ ។



ព្រះវីរសមណៈ ទ្រង់ដល់នូវត្រើយនៃធម៌ ទ្រង់ឃើញខ្ញុំនោះ មានសេចក្តីជ្រះថ្លាស្មោះ ក៏ហោះឡើងកាន់អាកាស ដូចស្តេចហង្សហើរទៅក្នុងអាកាស ។ ក្នុងកប្បទី ៩៦ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយសប្បិនិងប្រេង ។ ក្នុងកប្បទី ១៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ មួយអង្គ ព្រះនាមទុតិទេវៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសប្បិទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សប្បិទាយកត្ថេរាបទាន ។

## ទសមំ តាបនិវារិយត្ថេរាបទានំ

(១៦០) បិយទស្សិស្ស ភគវតោ ចង្កមំ សោធិតំ មយា
ឧល្លោកេហិ បដិច្ឆន្នំ   វាតាតបនិវារណំ ។
តាហំ វិជ្ជុត្ថាយ   កុសលស្សូបសម្បទា
កិលេសានំ បហានាយ   បទហឹ សត្ថុសាសនេ ។
ឥតោ ឯកាទសេ កប្បេ   អគ្គិទេវោតិ វិស្សុតោ
សត្តរតនសម្បន្នោ   ចក្កវត្តី មហព្ពលោ ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា តាបនិវារិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តាបនិវារិយត្ថេរស្ស អបទានំ សមត្តំ ។



## តាបនិវារិយត្ថេរាបទាន ទី ១០

(១៦០) ខ្ញុំផ្សារទីចង្ក្រម បិទបាំងដោយដើមបបុស ជាគ្រឿងការពារខ្យល់និងកម្តៅថ្ងៃ ដើម្បីព្រះមានព្រះភាគព្រះនាមបិយទស្សី ។ ខ្ញុំតម្កល់ទុកនូវការបំពេញកុសល ដើម្បីប្រយោជន៍ដល់ការរៀននូវវិជ្ជា ដើម្បីលះបង់នូវកិលេសទាំងឡាយ ក្នុងសាសនានៃព្រះសាស្តា ។ ក្នុងកប្បទី ១១ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមអគ្គិទេវៈ ប្រកបដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតាបនិវារិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តាបនិវារិយត្ថេរាបទាន ។

## ឧទ្ទានំ

ហត្ថិ បានធិ សច្ចញ្ច ឯកសញ្ញី ច រំសិយោ(១)
សន្ធិតោ តាលវណ្ដី(២) ច តថា អក្កន្តសញ្ញកោ(៣)
សប្បិ បាបនិវារី ច ចតុបញ្ញាស គាថកាតិ ។

ហត្ថិវគ្គោ ឆត្តឹសតិមោ ។

---

១ ឱ. រំសិកោ ។ ២ ម. តាលវណ្ដិ ។ ៣ ម. អក្កន្តសញ្ញិកោ ។



## ឧទ្ទាន

ហត្ថិទាយកត្ថេរាបទាន ១ បានធិទាយកត្ថេរាបទាន ១ សច្ចសញ្ញកត្ថេរាបទាន ១ ឯកសញ្ញកត្ថេរាបទាន ១ រំសិសញ្ញកត្ថេរាបទាន ១ សន្ធិតត្ថេរាបទាន ១ តាលវណ្ដទាយកត្ថេរាបទាន ១ អក្កន្តសញ្ញកត្ថេរាបទាន ១ សប្បិទាយកត្ថេរាបទាន ១ បាបនិវារិយត្ថេរាបទាន ១ មានគាថា ៥៤ ។

ចប់ ហត្ថិវគ្គ ទី ៣៦ ។

## ខេមសិការោ អាលម្ពនទាយកវគ្គោ

## បឋមំ អាលម្ពនទាយកត្ថេរាបទានំ

(១៦១) អត្ថទស្សិស្ស ភគវតោ លោកជេដ្ឋស្ស តាទិនោ
អាលម្ពនំ មយា ទិន្នំ ទ្វិបទិន្ទស្ស តាទិនោ ។
ធរណឹ បដិបជ្ជាមិ វិបុលំ សាគរូបមំ
បាណេសុ ច ឥស្សរិយំ វត្តេមិ វសុធាយ ច ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
ឥតោ ទ្វេសដ្ឋិកប្បម្ហិ តយោ អាសិំសុ ខត្តិយា
ឯកាបស្សិតនាមា តេ ចក្កវត្តី មហព្វលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា អាលម្ពនទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អាលម្ពនទាយកត្ថេរស្ស អបទានំ សមត្តំ ។

## អាលម្ពនទាយកវគ្គ ទី ២៣

## អាលម្ពនទាយកត្ថេរាបទាន ទី ១

(១៦១) ខ្ញុំបានថ្វាយបង្អែកដៃ ដល់ព្រះមានព្រះភាគព្រះនាមអត្ថទស្សី ជាច្បងក្នុងលោក ទ្រង់នឹងធឹង ជាធំជាងពួកសត្វជើងពីរ ជាតាទិបុគ្គល ។ ខ្ញុំគ្រប់គ្រងផែនដីធំទល់នឹងសាគរ ញុំាងឥស្សរិយយសឲ្យប្រព្រឹត្តទៅក្នុងពួកសត្វផង លើផែនដីសុទ្ធផង ។ ខ្ញុំដុតបំផ្លាញកិលេសទាំងឡាយហើយ គាស់រំលើងភពទាំងពួងចោលហើយ បានដល់វិជ្ជា ៣ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ព្រោះកុសលកម្មនេះ ។ ក្នុងកប្បទី ៦២ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៣ អង្គ ព្រះនាមឯកាបស្សិតៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអាលម្ពនទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អាលម្ពនទាយកត្ថេរាបទាន ។

## ទុតិយំ អជិនទាយកត្ថេរាបទានំ

(១៦៦) ឯកត្តឹសេ ឥតោ កប្បេ គណសត្ថារកោ អហំ

អទ្ទសំ វិរជំ ពុទ្ធំ អាហុតីនំ បដិគ្គហំ ។
ចម្មខណ្ឌំ មយា ទិន្នំ សិខិនោ លោកពន្ធុនោ
តេន កម្មេន ទ្វិបទិន្ទ លោកជេដ្ឋ នរាសភ ។
សម្បត្តឹ អនុភោត្វាន កិលេសេ ឈាបយឹ អហំ
ធារេមិ អន្តិមំ ទេហំ សម្មាសម្ពុទ្ធសាសនេ ។
ឯកត្តឹសេ ឥតោ កប្បេ អជិនំ យំ អទាសហំ
ទុគ្គតឹ នាភិជានាមិ អជិនស្ស ឥទំ ផលំ ។
ឥតោ បញ្ចសតេ កប្បេ រាជា អាសឹ សុទាយកោ
សត្តរតនសម្បន្នោ ចក្កវត្តី មហព្ពលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។





## អជិនទាយកត្ថេរាបទាន ទី ២

(១៦៦) ក្នុងកប្បទី ៣១ អំពីកប្បនេះ ខ្ញុំបានកើតជាបុរសអ្នកក្រាលកម្រាលសម្រាប់គណៈ បានឃើញព្រះពុទ្ធ ទ្រង់ប្រាសចាកធូលីគឺរាគៈ ជាទីទទួលនូវគ្រឿងបូជា ។ ខ្ញុំបានថ្វាយកំណាត់ស្បែកខ្លា ដល់ព្រះសិខីជាលោកពន្ធុ បពិត្រព្រះអង្គជាធំជាងសត្វជើងពីរ ជាច្បងក្នុងលោក ជានរាសភៈ ខ្ញុំបានទទួលនូវសម្បត្តិ ហើយដុតបំផ្លាញ នូវពួកកិលេស ដោយកម្មនោះ ខ្ញុំទ្រទ្រង់នូវកាយជាទីបំផុត ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះតែខ្ញុំបានថ្វាយស្បែកខ្លា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយស្បែកខ្លា ។ ក្នុងកប្បទី ៥០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ ព្រះនាមសុទាយកៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា អជិនទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អជិនទាយកត្ថេរស្ស អបទានំ សមត្តំ ។

## តតិយំ ទ្វេរតនិយត្ថេរាបទានំ

(១៦៣) មិគលុទ្ទោ បុរេ អាសិំ អរញ្ញេ កាននេ អហំ
អទ្ទសំ វិរជំ ពុទ្ធំ អាហុតីនំ បដិគ្គហំ ។
មំសបេសិំ មយា ទិន្នា វិបស្សិស្ស មហេសិនោ
សទេវកស្មិំ លោកស្មិំ ឥស្សរំ ការយាមហំ ។
ឥមិនា មំសទានេន រតនំ និព្វត្តតេ មម
ទុវេ មេ រតនា លោកេ ទិដ្ឋធម្មស្ស បត្តិយា ។
តេហំ សព្វេ អនុភោមិ(១) មំសទានស្ស បត្តិយា
គត្តញ្ច មុទុកំ មយ្ហំ បញ្ញា និបុណវេទិនី ។
ឯកនវុតេ ឥតោ កប្បេ យំ មំសមទទិំ តទា(២)
ទុគ្គតិំ នាភិជានាមិ មំសទានស្សិទំ ផលំ ។

១ ម. អនុភោមិ ។ ២ ឱ. អទំ ។





បានឮថា ព្រះអជិនទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថា ទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អជិនទាយកត្ថេរាបទាន ។

## ទ្វេរតនិយត្ថេរាបទាន ទី ៣

(១៦៣) កាលពីមុន ខ្ញុំកើតជាព្រានម្រឹគនៅក្នុងព្រៃធំ បានឃើញព្រះសម្ពុទ្ធ ទ្រង់ប្រាសចាកធូលីគឺកិលេស ជាទីទទួលនូវគ្រឿងបូជា ។ ខ្ញុំបានថ្វាយដុំសាច់ដល់ព្រះវិបស្សីមហេសី ខ្ញុំបាននូវភាពជាធំក្នុងលោក ព្រមទាំងទេវលោក ។ រតនៈកើតឡើងដល់ខ្ញុំ ដោយការថ្វាយនូវសាច់នេះ រតនៈពីរយ៉ាងក្នុងលោក កើតឡើងដល់ខ្ញុំ ដោយចំណែកនៃផលបច្ចុប្បន្ន ។ ខ្ញុំប្រើប្រាស់នូវរតនៈទាំងអស់នោះ ដោយចំណែកនៃការថ្វាយសាច់ ខ្លួនរបស់ខ្ញុំទន់ផង ទាំងបញ្ញា (របស់ខ្ញុំ) ក៏ជឿនូវធម៌ដ៏ល្អិតផង ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយសាច់ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃមំសទាន ។

ឥតោ ឆដ្ឋកេ កប្បេ ឯកោ អាសិំ ជនាធិបោ
មហារោហិតនាមោ សោ ចក្កវត្តី មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ទ្វេរតនិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ទ្វេរតនិយត្ថេរស្ស អបទានំ សមត្តំ ។
ទសមំ ភាណវារំ ។

## បញ្ចមំ អារក្ខទាយកត្ថេរាបទានំ

(១៦៦) សិទ្ធត្ថស្ស ភគវតោ វេទិកា ការិតា(១) មយា
អារក្ខោ ច មយា ទិន្នោ សុគតស្ស មហេសិនោ ។
តេន កម្មវិសេសេន ន បស្សេ(២) ភយភេរវំ
កុហិញ្ចិ ឧបបន្នស្ស តាសោ មយ្ហំ ន វិជ្ជតិ ។
ចតុន្នវុតេ ឥតោ កប្បេ យំ វេទិំ ការយិំ បុរេ
ទុគ្គតិំ នាភិជានាមិ វេទិកាយ ឥទំ ផលំ ។

---
១ ម. មេ ការាបិតា ។ ២ ម. ន បស្សិំ ។



ក្នុងកប្បទី ៦ អំពីកប្បនេះ ខ្ញុំនោះបានកើតជាស្តេចចក្រពត្តិ មួយអង្គ ជាធំជាងជន ព្រះនាមមហារោហិត ទ្រង់មាន កម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះទ្វេរតនិយត្ថេរ មានអាយុ បានសម្តែងនូវគាថា ទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ទ្វេរតនិយត្ថេរាបទាន ។
(១៦៨) មានភ្នំមួយឈ្មោះរោមសៈ នៅជិតព្រៃហិមពាន្ត ព្រះពុទ្ធជាសមណៈមួយអង្គ មានឥន្ទ្រិយស្រេចស្រង់ (គង់នៅ) ជើងភ្នំនោះ ។ ខ្ញុំយកដំឡូងនិវេទ្ឋា ទៅប្រគេនព្រះសមណៈ ឯព្រះសយម្ភូ ជាមហាវីរៈ ទ្រង់ឈ្នះកិលេស បានអនុមោទនាថា អ្នកមានចិត្តជ្រះថ្លា បានថ្វាយដំឡូងនិវេទ្ឋា ផលនាអនាគត ផលនៃដំណើរកើតឡើងដល់អ្នក ក្នុងកាលដែលអ្នកកើត ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយដំឡូង ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃដំឡូងនិវេទ្ឋា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះវិឡាលិទាយកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ វិឡាលិទាយកត្ថេរាបទាន ។

## ឆដ្ឋំ មច្ឆទាយកត្ថេរាបទានំ

(១៦៦) ចន្ទភាគានទីតីរេ អហោសឹ ឧក្កុសោ តទា
មហន្តំ មច្ឆំ បគ្គយ្ហ សិទ្ធត្ថស្ស មុនិនោ អទំ ។
ចតុន្នវុតេ ឥតោ កប្បេ យំ មច្ឆមទទឹ តទា
ទុគ្គតឹ នាភិជានាមិ មច្ឆទានស្សិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា មច្ឆទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

មច្ឆទាយកត្ថេរស្ស អបទានំ សមត្តំ ។



## មច្ឆទាយកត្ថេរាបទាន ទី ៦

(១៦៦) ក្នុងកាលនោះ ខ្ញុំកើតជាសត្វឆ្មក នៅលើឆ្នេរស្ទឹងចន្ទភាគា ខ្ញុំបានយកត្រីធំ ថ្វាយដល់ព្រះមុនីព្រះនាមសិទ្ធត្ថ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានថ្វាយត្រី ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយត្រី ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះមច្ឆទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មច្ឆទាយកត្ថេរាបទាន ។

## តតិយំ ជវហង្សកត្ថេរាបទានំ

(១៦៧) ចន្ទភាគានទីតីរេ អាសឹ វនចរោ តទា

សិទ្ធត្ថំ អទ្ទសំ ពុទ្ធំ គច្ឆន្តំ អនិលញ្ជសេ ។

អញ្ជលឹ បគ្គហេត្វាន ឱរោហេត្វា មហាមុនឹ

សកំ ចិត្តំ បសាទេត្វា អភិវន្ទឹ លោកនាយកំ ។

ចតុន្នវុតេ ឥតោ កប្បេ យំ អវន្ទឹ នរាសភំ

ទុគ្គតឹ នាភិជានាមិ វន្ទនាយ ឥទំ ផលំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ជវហង្សកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ជវហង្សកត្ថេរស្ស អបទានំ សមត្តំ ។





## ជវហង្សកត្ថេរាបទាន ទី ៣

(១៦៧) កាលនោះ ខ្ញុំត្រាច់ទៅក្នុងព្រៃ ក្បែរឆ្នេរស្ទឹងចន្ទភាគា បានឃើញព្រះពុទ្ធព្រះនាមសិទ្ធត្ថ និមន្តទៅក្នុងអាកាស ។ ខ្ញុំផ្គងអញ្ជលី ហើយក្រាបទូលព្រះមហាមុនី ហើយញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា បានថ្វាយបង្គំព្រះលោក-នាយក ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយបង្គំនូវព្រះនរាសភៈ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយបង្គំ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះជវហង្សកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ជវហង្សកត្ថេរាបទាន ។

## អដ្ឋមំ សលលបុប្ផិយត្ថេរាបទានំ

(១៦៨) ចន្ទភាគានទីតីរេ អហោសិំ កិន្នរោ តទា
វិបស្សឹ អទ្ទសំ ពុទ្ធំ រំសិជាលសមាកុលំ ។
បសន្នចិត្តោ សុមនោ បរមាយ ច បីតិយា
បគ្គយ្ហ សលលំ បុប្ផំ វិបស្សិស្ស ឱកិរឹ អហំ ។
ឯកនវុតេ ឥតោ កប្បេ យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សលលបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សលលបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។



## សលលបុប្ផិយត្ថេរាបទាន ទី ៨

(១៦៨) ក្នុងកាលនោះ ខ្ញុំកើតជាកិន្នរ នៅក្បែរឆ្នេរស្ទឹងចន្ទភាគា បានឃើញព្រះពុទ្ធ ព្រះនាមវិបស្សី ទ្រង់បរិបូណ៌ដោយបណ្តាញនៃរស្មី ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយដោយបីតិយ៉ាងក្រៃលែង បានកាន់យកផ្កាស្រល់ រោយរាយថ្វាយចំពោះព្រះវិបស្សី ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសលលបុប្ផិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សលលបុប្ផិយត្ថេរាបទាន ។

## នវមំ ឧបាគតាសយត្ថេរាបទានំ

(១៦៩) ហិមវន្តស្ស បស្សម្ហិ សរោ អាសិ សុនិម្មិតោ
តត្ថាហំ រក្ខសោ អាសិំ ហេឋសីលោ ភយានកោ ។
អនុកម្បកោ ការុណិកោ វិបស្សី លោកនាយកោ
មមុទ្ធរិតុកាមោ សោ អាគញ្ឆិ មម សន្តិកោ ។
ឧបាគតំ មហាវីរំ ទេវទេវំ នរាសភំ
អាសយា អភិនិក្ខម្ម អវន្ទឹ សត្ថុនោ អហំ ។
ឯកនវុតេ ឥតោ កប្បេ យំ វន្ទឹ បុរិសុត្តមំ
ទុគ្គតឹ នាភិជានាមិ វន្ទនាយ ឥទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ឧបាគតាសយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឧបាគតាសយត្ថេរស្ស អបទានំ សមត្តំ ។



## ឧបាគតាសយត្ថេរាបទាន ទី ៩

(១៦៩) មានស្រះដែលធម្មជាតិនិម្មិតល្អហើយ នៅកណ្ដាលព្រៃហិមពាន្ត ឯខ្ញុំកើតជារាក្សសក្នុងស្រះនោះ ជាអ្នកមានក្រាលសំឡុតគួរខ្លាច ។ ព្រះលោកនាយក ព្រះនាមវិបស្សី ទ្រង់មានសេចក្ដីអនុគ្រោះ មានសេចក្ដីករុណា ប្រាថ្នានឹងស្រង់ខ្ញុំ ព្រះអង្គស្ដេចយាងមក ក្នុងសំណាក់របស់ខ្ញុំ ។ ខ្ញុំ (ឃើញ) ព្រះមហាវីរៈ ជាទេវតាដ៏ក្រៃលែង ទ្រង់ជានរាសភៈ ស្ដេចចូលមកហើយ ទើបខ្ញុំចេញអំពីលំនៅ បានថ្វាយបង្គំចំពោះព្រះសាស្ដា ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានថ្វាយបង្គំព្រះសម្ពុទ្ធជាបុរសប្រសើរ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃការថ្វាយបង្គំ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឧបាគតាសយត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឧបាគតាសយត្ថេរាបទាន ។

## ទសមំ តរណិយត្ថេរាបទានំ

[១៧០] សុវណ្ណវណ្ណោ សម្ពុទ្ធោ វិបស្សី នាម
នាយកោ(១)
នទីតីរេ ឋិតោ សត្ថា ភិក្ខុសង្ឃបុរក្ខតោ ។
នាវា ច វិជ្ជតេ តត្ថ សន្តារណី មហណ្ណវេ
នទិយា អភិនិក្ខម្ម តារេសិំ លោកនាយកំ ។
ឯកនវុតេ ឥតោ កប្បេ យំ តារេសិំ នរុត្តមំ
ទុគ្គតិំ នាភិជានាមិ តារណាយ ឥទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា តរណិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តរណិយត្ថេរស្ស អបទានំ សមត្តំ ។

១ ម. វិបស្សី ទក្ខិណារហានំ វិទូតិ ។



## តរណិយត្ថេរាបទាន ទី ១០

[១៧០] ព្រះសម្ពុទ្ធលោកនាយកជាសាស្តា ព្រះនាមវិបស្សី មានវណ្ណៈដូចមាស មានភិក្ខុសង្ឃចោមរោម ទ្រង់ឋិតនៅឆ្នេរស្ទឹង ។ ទូកសម្រាប់ចម្លងក្នុងស្ទឹង ដែលមានអន្លង់ធំនោះក៏មិនមាន ទើបខ្ញុំចេញអំពីស្ទឹង មកចម្លងព្រះលោកនាយក ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានចម្លងព្រះនរុត្តមសម្ពុទ្ធ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការចម្លង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតរណិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តរណិយត្ថេរាបទាន ។

## ឧទ្ទានំ

អឌ្ឍចន្ទី តេលចន្ទី ច ទីបទោ ច វិឡាលិទោ មច្ឆោ ជវហំសសឡលទោ រក្ខសោ តរណោ ធម្ម- រុចិ គាថាយោ ចេត្ថ សង្ខាតា តាឡីសមេកាធិ ច ។

អឌ្ឍចន្ទិវគ្គោ សត្តមោ ។

---





## ឧទ្ទាន

អាកាសុក្ខិបិយត្ថេរាបទាន ១ តេលមក្ខិយត្ថេរាបទាន ១ អឌ្ឍចន្ទិយត្ថេរាបទាន ១ ទីបទាយកត្ថេរាបទាន ១ វិឡា- លិទាយកត្ថេរាបទាន ១ មច្ឆទាយកត្ថេរាបទាន ១ ជវហ- ង្សកត្ថេរាបទាន ១ សឡលបុប្ផិយត្ថេរាបទាន ១ ឧបាគត- ហាសនិយត្ថេរាបទាន ១ តរណិយត្ថេរាបទាន ១ ត្រូវ ជា ១០ និងគាថា ៦១ លោកអ្នកប្រាជ្ញបានរាប់ហើយ ក្នុងវគ្គនេះ ។

ចប់ អឌ្ឍចន្ទិយវគ្គ ទី ៥៥ ។

---

## អដ្ឋវីសតិមោ សុវណ្ណពិព្ពោហនវគ្គោ

## បឋមំ សុវណ្ណពិព្ពោហនិយត្ថេរាបទានំ

(១៩១) ឯកាសនំ មហាមនិ បសន្នោ សេហិ បាណិហិ
ពិព្ពោហនញ្ច ទទាសិំ ឧត្តមត្ថស្ស បត្តិយា ។
ឯកនវុតេ ឥតោ កប្បេ ពិព្ពោហនមទាសហំ
ទុគ្គតឹ នាភិជានាមិ ពិព្ពោហនស្សិទំ ផលំ ។
ឥតោ តេសដ្ឋិមេ កប្បេ អសមោ នាម ខត្តិយោ
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សុវណ្ណពិព្ពោហនិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សុវណ្ណពិព្ពោហនិយត្ថេរស្ស អបទានំ សមត្តំ ។

## សុវណ្ណពិព្ពោហនវគ្គ ទី ២៨

## សុវណ្ណពិព្ពោហនិយត្ថេរាបទាន ទី ១

(១៧១) ខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយកាសនៈមួយ ដោយដៃរបស់ខ្លួន និងថ្វាយខ្នើយ ដើម្បីសម្រេចប្រយោជន៍ដ៏ខ្ពង់ខ្ពស់ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយខ្នើយ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃខ្នើយ ។ ក្នុងកប្បទី ៦៣ អំពីកប្បនេះ ខ្ញុំបានកើតជាក្សត្រចក្រពត្តិ ព្រះនាមអសមៈ ប្រកបដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសុវណ្ណពិព្ពោហនិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សុវណ្ណពិព្ពោហនិយត្ថេរាបទាន ។

# ទុតិយំ តិលមុដ្ឋិយត្ថេរាបទានំ

(១៧៦) មម សង្កប្បមញ្ញាយ សត្ថា លោកគ្គនាយកោ

មនោមយេន កាយេន ឥទ្ធិយា ឧបសង្កមិ ។

សក្ការំ ឧបសង្កន្តិំ វន្ទិត្វា បុរិសុត្តមំ

បសន្នចិត្តោ សុមនោ តិលមុដ្ឋិមទាសហំ ។

ឯកនវុតេ ឥតោ កប្បេ យំ ទានមទទឹ តទា

ទុគ្គតឹ នាភិជានាមិ តិលមុដ្ឋិយិទំ ផលំ ។

ឥតោ សោឡសកប្បម្ហិ កន្ទិយោ នាម(១) ខត្តិយោ

សត្តរតនសម្បន្នោ ចក្កវត្តិ មហព្ពលោ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា តិលមុដ្ឋិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តិលមុដ្ឋិយត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. សន្និភោ នាម ។



# តិលមុដ្ឋិយត្ថេរាបទាន ទី ២

(១៧៦) ព្រះសាស្តាជាអគ្គនាយកក្នុងលោក ទ្រង់ជ្រាបនូវសេចក្តីត្រិះរិះរបស់ខ្ញុំ បានស្តេចមកដោយកាយសម្រេចដោយចិត្ត ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ ក៏ថ្វាយបង្គំព្រះសាស្តា ជាបុរសប្រសើរបំផុត ដែលកំពុងស្តេចចូលមក ហើយថ្វាយល្ង មួយក្តាប់ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានថ្វាយល្ង ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃល្ងមួយក្តាប់ ។ ក្នុងកប្បទី ១៦ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមកន្ទិយៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតិលមុដ្ឋិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តិលមុដ្ឋិយត្ថេរាបទាន ។

## តតិយំ បញ្ញោធិកិយត្ថេរាបទានំ

(១៧៣) មហាសមុទ្ទំ និស្សាយ វសតិ បព្វតុត្តរេ

បច្ចុគ្គមន កាមហំ   ធញ្ញោជកមជាសហំ ។

សិទ្ធត្ថស្ស មហេសិនោ   សយម្ភុស្សានុកម្បកោ(១)

បុប្ផធញ្ញោជកំ ធត្វា   កាចំ សក្កច្ចំ មោធហំ ។

ចតុន្នវុតេ ឥតោ កប្បេ   ធញ្ញោជកមទំ តទា

ទុគ្គតឹ នាភិជានាមិ   ធញ្ញោជកស្សិទំ ផលំ ។

បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ធញ្ញោជកិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បញ្ញោធិកិយត្ថេរស្ស អបទានំ សមត្តំ ។

១ ឱ. សព្វសត្តានុកម្បកោ ។



## បញ្ញោធិកិយត្ថេរាបទាន ទី ៣

(១៧៣) ព្រះសមុទ្ទខាងកើតដ៏នៅត្រើយខាងក្នុង អាស្រ័យមហាសមុទ្ទ ខ្ញុំបានជាអ្នកបុណ្យ ក្រោកទៅទទួល ហើយបានប្រគេនប្រគល់ ខ្ញុំបានប្រគេនប្រគល់ ដល់ព្រះសយម្ភូ ព្រះនាមសិទ្ធត្ថៈ ព្រះអង្គស្វែងរកគុណធំ ទ្រង់មានសេចក្តីអនុគ្រោះហើយ បានទទួលយកនូវហត្ថសម្ពិ ផល់មួយកប្ប ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានថ្វាយប្រគល់ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃប្រគល់ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបញ្ញោធិកិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បញ្ញោធិកិយត្ថេរាបទាន ។

## បត្តំ អក្កមនទាយកត្ថេរាបទានំ

(១៧៤) កោណ្ឌញ្ញស្ស ភគវតោ លោកជេដ្ឋស្ស តាទិនោ

អកក្កសស្ស ចិត្តស្ស(១) និព្ពុតស្ស ឈាយិនោ។

សព្ពោកាសវិភត្តស្ស   សព្ពលោកហិតេសិនោ

អក្កមនំ មយា ទិន្នំ   និព្ពុតស្ស តាទិនោ ។

អបរិមេយ្យេ ឥតោ កប្បេ   អក្កមនមទាសហំ

ទុគ្គតឹ នាភិជានាមិ   អក្កមនស្សិទំ ផលំ ។

ឥតោ បណ្ណរសេ កប្បេ   វិបុលា នាម(២) ខត្តិយោ

សត្តរតនសម្បន្នោ   ចក្កវត្តិ មហព្ពលោ ។

បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនំ។

ឥត្ថំ សុទំ អាយស្មា អក្កមនទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អក្កមនទាយកត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. អកក្កសចិត្តស្ស ។ ២ ម. វិបុលា នាម ។



## អក្កមនទាយកត្ថេរាបទាន ទី ៤

(១៧៤) ខ្ញុំបានថ្វាយជាំបន្ទក់ឡែក ដល់ព្រះមានព្រះភាគ ព្រះនាមកោណ្ឌញ្ញៈ ព្រះអង្គមានពលៈទៅគ្រប់ហើយ ជាតាទិបុគ្គល មានព្រះទ័យមិនកក្រក់ មិនមានដំណើរយឺត យូរពីកិលេស ព្រះអង្គមានឈាន ប្រព្រឹត្តក្នុងឱកាសៈទាំងពួង ទ្រង់ស្វែងរកប្រយោជន៍ ដល់សត្វលោកទាំងពួង ព្រះអង្គជាធំជាងសត្វដទៃ ទ្រង់មិនញាប់ញ័រ ។ ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុតែខ្ញុំ បានថ្វាយជាំបន្ទក់ឡែក ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃជាំបន្ទក់ឡែក ។ ក្នុងកប្បទី ១៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមវិបុលៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអក្កមនទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អក្កមនទាយកត្ថេរាបទាន ។

## បញ្ចមំ ឯកញ្ជលិយត្ថេរាបទានំ

(១៧៩) ឧទុម្ពរេ វសន្តស្ស និយកេ បណ្ណសន្ថរេ
វុត្ថាកាសោ មយា ទិន្នោ សមណស្ស មហេសិនោ ។
វិបស្សិស្ស និបកស្ស លោកជេដ្ឋស្ស តាទិនោ
អញ្ជលិំ បគ្គហេត្វាន សន្ថរំ ពុទ្ធសន្ថរំ ។
ឯកនវុតេ ឥតោ កប្បេ យំ ការំ ពុទ្ធសន្ថរំ
ទុគ្គតិំ នាភិជានាមិ សន្ថរស្ស ឥទំ ផលំ ។
ឥតោ ចុទ្ទសកប្បម្ហិ អហោសិំ មនុជាធិបោ
ឯកញ្ជលិកោ នាម ចក្កវត្តិ មហព្ពលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ឯកញ្ជលិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឯកញ្ជលិយត្ថេរស្ស អបទានំ សមត្តំ ។



## ឯកញ្ជលិយត្ថេរាបទាន ទី ៥

(១៧៩) ខ្ញុំបានប្រគេនឱកាសជាទីនៅ លើកម្រាលស្លឹកឈើដែលខ្ញុំតាំងទុក ដល់ព្រះសមណៈ (ព្រះនាមវិបស្សី) ទ្រង់ស្វែងរកគុណធំ កាលគង់នៅជិតដើមល្វា ។ ខ្ញុំផ្គងអញ្ជលី ហើយក្រាលកម្រាលស្លឹក ថ្វាយព្រះវិបស្សីសម្ពុទ្ធ ជាធំជាងសត្វលើផែនដី ជាទីពឹងនៃសត្វលោក ជាតាទិបុគ្គល ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានធ្វើកម្រាលស្លឹក ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃកម្រាល ។ ក្នុងកប្បទី ១៤ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ជាធំជាងពួកមនុស្ស ព្រះនាមឯកអញ្ជលិកៈ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកញ្ជលិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឯកញ្ជលិយត្ថេរាបទាន ។

## ឆដ្ឋំ បោត្ថទាយកត្ថេរាបទានំ

(១៩៦) សត្ថារំ ធម្មមារព្ភ សង្ឃញ្ចាបិ មហេសិនោ
បោត្ថទានំ មយា ទិន្នំ ទក្ខិណេយ្យេ អនុត្តរេ ។
ឯកនវុតេ ឥតោ កប្បេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ បោត្ថទានស្សិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បោត្ថទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បោត្ថទាយកត្ថេរស្ស អបទានំ សមត្តំ ។

## សត្តមំ ចិតកបូជកត្ថេរាបទានំ

(១៩៧) ចន្ទភាគានទីតីរេ អនុសោតំ វជាមហំ
សត្ត មាលុវបុប្ផានិ ចិតការោបយឹ អហំ ។
ចតុន្នវុតេ ឥតោ កប្បេ ចិតកំ យំ អបូជយឹ
ទុគ្គតឹ នាភិជានាមិ ចិតបូជាយិទំ ផលំ ។



## បោត្ថទាយកត្ថេរាបទាន ទី ៦

(១៩៦) ខ្ញុំប្រារព្ធព្រះសាស្តាផង ព្រះធម៌ផង ព្រះសង្ឃផង បានប្រគេនបោត្ថទាន (សម្ពត់សំបកឈើ) ដល់ព្រះសម្ពុទ្ធមហេសី ជាទក្ខិណេយ្យបុគ្គល ដ៏ប្រសើរ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបោត្ថទាន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបោត្ថទាយកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បោត្ថទាយកត្ថេរាបទាន ។

## ចិតកបូជកត្ថេរាបទាន ទី ៧

(១៩៧) ខ្ញុំដើរទៅតាមទីបណ្ដោយខ្សែទឹក លើឆ្នេរស្ទឹងចន្ទភាគា ខ្ញុំបានយកផ្កាជ្រៃ ៧ ដាក់បូជាជើងថ្ករ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាជើងថ្ករ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាជើងថ្ករ ។

សត្តសដ្ឋិម្ហិតោ កប្បេ បដិជគ្គសនាមកោ
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្វលោ(១) ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។
ឥត្ថំ សុទំ អាយស្មា ចិតកបូជកោ ថេរោ ឥមា
គាថាយោ អភាសិត្ថាតិ ។

ចិតកបូជកត្ថេរស្ស អបទានំ សមត្តំ ។

## អដ្ឋមំ អាលុវទាយកត្ថេរាបទានំ

(១៧៨) បព្ភារេ ហិមវន្តម្ហិ មហាសិន្ធុ សុទស្សនោ
តត្ថទ្ទសំ វីតរាគំ សប្បភាសំ(២) សុទស្សនំ ។
បរោបសមេ យុត្តំ ទិស្វា វិម្ហិតមានសោ
អាលុវំ តស្ស បាទាសិំ បសន្នោ សេហិ បាណិភិ ។

១ ម. សត្តាសុំ បញ្ញត្តិនោតិ ទិស្សតិ ។ ២ ម. សុបភាសំ ។





កន្លងកប្បទី ៦៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមបដិជគ្គៈ ប្រកបដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះចិតកបូជកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ចិតកបូជកត្ថេរាបទាន ។

## អាលុវទាយកត្ថេរាបទាន ទី ៨

(១៧៨) មានស្ទឹងធំមួយ ឈ្មោះសុទស្សនៈ នៅក្បែរភ្នំហិមពាន្ត ខ្ញុំបានឃើញព្រះសម្ពុទ្ធ ព្រះនាមសុទស្សនៈ មានរស្មីល្អ ប្រាសចាករាគៈ គង់នៅក្បែរស្ទឹងនោះ ។ លុះខ្ញុំឃើញព្រះអង្គ ប្រកបដោយសេចក្តីស្ងប់រម្ងាប់ យ៉ាងក្រៃលែង ខ្ញុំមានចិត្តស្ងើចជ្រះថ្លា បានថ្វាយល្មើក ជាស្បៀង ដល់ព្រះសុទស្សនៈអង្គនោះ ដោយដៃរបស់ខ្លួន ។

ឯកត្តឹសេ ឥតោ កប្បេ យំ អាលុវមទាសហំ
ទុគ្គតឹ នាភិជានាមិ អាលុវស្ស ឥទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា អាលុវទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អាលុវទាយកត្ថេរស្ស អបទានំ សមត្តំ ។

## នវមំ បុណ្ឌរីកត្ថេរាបទានំ

(១៩៤) កោមសោ នាម នាមេន សយម្ភូ សព្វកោ(១) តទា
បុណ្ឌរីកំ មយា ទិន្នំ វិប្បសន្នេន ចេតសា ។
ឯកត្តឹសេ ឥតោ កប្បេ បុណ្ឌរីកមទទឹ តទា
ទុគ្គតឹ នាភិជានាមិ បុណ្ឌរីកស្សិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

១ ម. សុព្ពតោ ។



ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានថ្វាយផ្លែល្ហុង ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផ្លែល្ហុង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអាលុវទាយកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អាលុវទាយកត្ថេរាបទាន ។

## បុណ្ឌរីកត្ថេរាបទាន ទី ៩

(១៩៤) ក្នុងកាលនោះ ព្រះសយម្ភូ ព្រះនាមកោមសៈ មានរស្មីល្អ ខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយផ្កាឈូកស ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានថ្វាយផ្កាឈូកស ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយឈូកស ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា បុណ្ណកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បុណ្ណកត្ថេរស្ស អបទានំ សមត្តំ ។

## ទសមំ តរណិយត្ថេរាបទានំ

(១៨០) មហាបថម្ហិ វិសមេ សេតុ ការាបិតំ មយា
តរណត្ថាយ លោកស្ស បសន្នោ សេហិ បាណិភិ ។
ឯកនវុតេ ឥតោ កប្បេ យំ សេតុំ ការយិំ មយា
ទុគ្គតិំ នាភិជានាមិ សេតុទានស្សិទំ ផលំ ។
ចតុបញ្ញាសិតោ កប្បេ ឯកោ អាសិំ សមោគធោ(១)
សត្តរតនសម្បន្នោ ចក្កវត្តី មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា តរណិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តរណិយត្ថេរស្ស អបទានំ សមត្តំ ។

១ ម. សមោគតោ ។



បានឮថា ព្រះបុណ្ណកត្ថេរ មានអាយុ បានសម្តែងនូវគាថា ទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បុណ្ណកត្ថេរាបទាន ។

## តរណិយត្ថេរាបទាន ទី ១០

(១៨០) ខ្ញុំមានចិត្តជ្រះថ្លា បានស្ថាបនាស្ពាន ត្រង់ផ្លូវធំ ដែលមានជង្ហុក ដើម្បីប្រយោជន៍ដល់ការឆ្លង នៃសត្វលោក ដោយដៃរបស់ខ្លួន ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានស្ថាបនាស្ពាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការធ្វើស្ពាន ។ ក្នុងកប្បទី ៥៤ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិមួយអង្គ ព្រះនាមសមោគធៈ ប្រកបដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតរណិយត្ថេរ មានអាយុ បានសម្តែងនូវគាថា ទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តរណិយត្ថេរាបទាន ។

## ឧទ្ទានំ

សោវណ្ណំ តិលមុដ្ឋិ ច   ចង្កោដកាព្ភញ្ជមញ្ជលិ
ពោត្ថកោ ចិតកាលុវោ   ឯកបុណ្ឌរិ តរណោ
ឆចត្តាឡីស គាថាយោ   គណិតាយោ វិភាវិភិ ។

សុវណ្ណពិម្ពោហនវគ្គោ អដ្ឋចត្តាលីសមោ ។

ឯកាទសមំ ភាណវារំ ។

---



## ឧទ្ទាន

សុវណ្ណពិម្ពោហនិយត្ថេរាបទាន ១ តិលមុដ្ឋិយត្ថេរាបទាន ១
ចង្កោដកិយត្ថេរាបទាន ១ អព្ភញ្ជនទាយកត្ថេរាបទាន ១
ឯកញ្ជលិយត្ថេរាបទាន ១ ពោត្ថទាយកត្ថេរាបទាន ១ ចិត-
កបូជកត្ថេរាបទាន ១ អាលុវទាយកត្ថេរាបទាន ១ បុណ្ឌរីក-
ត្ថេរាបទាន ១ តរណិយត្ថេរាបទាន ១ ជាគាថា ៤៦
ដែលអ្នកប្រាជ្ញរាប់ហើយ ។

ចប់ សុវណ្ណពិម្ពោហនវគ្គ ទី ៤៨ ។

ចប់ ភាណវារៈ ទី ១១ ។

---

## ឯកូនតឹ្តសោ បណ្ណទាយកវគ្គោ

## បឋមំ បណ្ណទាយកត្ថេរាបទានំ

(១៨១) បណ្ណសាលេ និសិន្នោម្ហិ បណ្ណភោជនភោជនោ

ឧបវិដ្ឋញ្ច មំ សន្តំ ឧបាគញ្ឆិ មហាឥសិ ។

សិទ្ធត្ថោ លោកបជ្ជោតោ សព្វលោកតិកិច្ឆកោ

តស្ស បណ្ណំ មយា ទិន្នំ និសិន្នស្ស បណ្ណសន្ថរេ ។

ចតុន្នវុតេ ឥតោ កប្បេ យំ បណ្ណមទទឹ តទា

ទុគ្គតឹ នាភិជានាមិ បណ្ណទានស្សិទំ ផលំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា បណ្ណទាយកោ ថេរោ

ឥមា គាថាយោ អភាសិត្ថាតិ ។

បណ្ណទាយកត្ថេរស្ស អបទានំ សមត្តំ ។

## បណ្ណទាយកវគ្គ ទី ២៩

## បណ្ណទាយកត្ថេរាបទាន ទី ១

(១៨១) ខ្ញុំអង្គុយនៅក្នុងបណ្ណសាលា បរិភោគនូវស្លឹកឈើជាភោជន ព្រះសម្ពុទ្ធជាមហាឥសី ស្តេចចូលមកកាន់ខ្ញុំដែលកំពុងអង្គុយ ។ ព្រះសម្ពុទ្ធព្រះនាមសិទ្ធត្ថ ជាប្រទីបក្នុងលោក ព្រះអង្គជាគ្រូពេទ្យ នៃសត្វលោកទាំងអស់ ខ្ញុំបានថ្វាយស្លឹកឈើចំពោះព្រះអង្គ ដែលទ្រង់គង់នៅលើកម្រាលស្លឹកឈើ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានថ្វាយស្លឹកឈើ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយស្លឹកឈើ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបណ្ណទាយកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បណ្ណទាយកត្ថេរាបទាន ។

## ទុតិយំ ផលទាយកត្ថេរាបទានំ

(១៨៦) សិនេរុសមសន្តោសោ ធរណីធរសាទិសោ(១)

វុដ្ឋហិត្វា សមាធិម្ហា ភិក្ខាយ មមុបដ្ឋិតោ ។
ហរីតកំ អាមលកំ អម្ពំ ជម្ពុំ វិភេតកំ
កោលំ ភល្លាតកំ ពេល្លំ ផារុសកផលានិ ច ។
សិទ្ធត្ថស្ស មហេសិស្ស សព្វលោកានុកម្បិនោ
តញ្ច សព្វំ មយា ទិន្នំ វិប្បសន្នេន ចេតសា ។
ចតុន្នវុតេ ឥតោ កប្បេ យំ ផលំ អទទឹ តទា
ទុគ្គតឹ នាភិជានាមិ ផលទានស្សិទំ ផលំ ។
សត្តបញ្ញាសិតោ កប្បេ ឯកជ្ឈោ នាម ខត្តិយោ
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្ពលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ផលទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ផលទាយកត្ថេរស្ស អបទានំ សត្តមំ ។

១ ម. ធរណីសមសាទិសោ ។





## ផលទាយកត្ថេរាបទាន ទី ២

(១៨៦) ព្រះសម្ពុទ្ធព្រះនាមសិទ្ធត្ថ មានព្រះទ័យសន្តោស ស្មើដោយភ្នំសិនេរុ ធ្ងន់ប្រៀបដោយធរណី ស្ដេចចេញចាកសមាធិ ហើយទ្រង់ស្ដេចចូលទៅរកខ្ញុំដើម្បីភិក្ខា ។ ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេនផ្លែឈើទាំងអស់នោះគឺ ផ្លែសម៉ កន្ទួតព្រៃ ស្វាយ ព្រីង ផ្លែសម៉ពិភេក ពុទ្រា ពពាល ស្រគំ ព្នៅ និងផ្លែមាក់ប្រាង ដល់ព្រះមហាឥសីព្រះនាមសិទ្ធត្ថ ព្រះអង្គមានសេចក្ដីអនុគ្រោះ ដល់សត្វលោកទាំងពួង ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែឈើ ។ ក្នុងកប្បទី ៥៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ ព្រះនាមឯកជ្ឈៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះផលទាយកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ផលទាយកត្ថេរាបទាន ។

## តតិយំ បច្ចុគ្គមនិយត្ថេរាបទានំ

[១៨៣] សីហំ យថា វនចរំ និសភាជានិយំ យថា

កកុធំ វិលសន្តំវ អាគច្ឆន្តំ នរាសភំ ។

សិទ្ធត្ថំ លោកបជ្ជោតំ សព្វលោកតិកិច្ឆកំ

អកាសឹ បច្ចុគ្គមនំ វិប្បសន្នេន ចេតសា ។

ចតុន្នវុតេ ឥតោ(១) កប្បេ បច្ចុគ្គមំ អកាសហំ

ទុគ្គតឹ នាភិជានាមិ បច្ចុគ្គមនិទំ ផលំ ។

សត្តវីសេ ឥតោ កប្បេ ឯកោ អាសឹ ជនាធិបោ

បរិកេតិ នាមេន ចក្កវត្តិ មហព្វលោ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បច្ចុគ្គមនិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បច្ចុគ្គមនិយត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. ឯកនវុតិតោ ។



## បច្ចុគ្គមនិយត្ថេរាបទាន ទី ៣

(១៨៣) ខ្ញុំមានចិត្តជ្រះថ្លា បានធ្វើនូវការក្រោកទទួលព្រះសម្ពុទ្ធ ព្រះនាមសិទ្ធត្ថ ព្រះអង្គជាប្រទីបរបស់លោក ជាអ្នកព្យាបាលសត្វលោកទាំងពួង ទ្រង់ជានរាសភៈ ទ្រង់ស្តេចមក ដូចសត្វសីហៈត្រាច់ទៅក្នុងព្រៃ ឬដូចនិសភាជានេយ្យ ឬក៏ដូចលំពង់ដ៏ថ្កាន់ល្អាស់ល្អន់ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានក្រោកទទួលព្រះនរាសភៈ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការក្រោកទទួល ។ ក្នុងកប្បទី ២៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិមួយអង្គ ព្រះនាមបរិកេតៈ ជាធំជាងជន ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបច្ចុគ្គមនិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បច្ចុគ្គមនិយត្ថេរាបទាន ។

## ចតុត្ថំ ឯកបុប្ផិយត្ថេរាបទានំ

(១៨៤) ឧក្កិណម្ហិ ទុករម្ហិ បិសាចោ អាសហំ តទា
អទ្ទសំ វិរជំ ពុទ្ធំ បីតរំសិំវ ភាណុមំ ។
វិបស្សិស្ស នរគ្គស្ស សព្វលោកហិតេសិនោ
ឯកបុប្ផំ មយា ទិន្នំ ទិបទិន្ទស្ស តាទិនោ ។
ឯកនវុតេ ឥតោ កប្បេ យំ បុប្ផមទទឹ តទា
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឯកបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឯកបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។





## ឯកបុប្ផិយត្ថេរាបទាន ទី ៤

(១៨៤) កាលនោះ ខ្ញុំកើតជាបិសាចនៅត្រង់ទីច្រាំងស្ទឹង បានឃើញព្រះសម្ពុទ្ធ ព្រះអង្គមិនមានធូលីគឺរាគៈ ដូចជាព្រះអាទិត្យមានរស្មីលឿង ។ ខ្ញុំបានថ្វាយផ្កាមួយ ចំពោះព្រះវិបស្សី ព្រះអង្គប្រសើរជាងនរៈ ទ្រង់ស្វែងរកនូវប្រយោជន៍ដល់សត្វលោកទាំងពួង ព្រះអង្គជាធំជាងសត្វជើងពីរ ប្រកបដោយតាទិគុណ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកបុប្ផិយត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឯកបុប្ផិយត្ថេរាបទាន ។

## បញ្ចមំ មយវិបុប្ផិយត្ថេរាបទានំ

(១៨៩) ចន្ទភាគនទិយា តីរេ សយម្ភូ អបរាជិតោ

សមាធឹ សោ សមាបន្នោ វិប្បសន្នោ អនាវិលោ ។

ទិស្វា បសន្នោ សុមនោ សម្ពុទ្ធំ អបរាជិតំ

តាហំ មយវិបុប្ផេន សយម្ភុំ ពូជយឹ តទា ។

ឯកនវុតេ ឥតោ កប្បេ យំ ពុប្ផមភិពូជយឹ

ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា មយវិបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

មយវិបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។



## មយវិបុប្ផិយត្ថេរាបទាន ទី ៥

(១៨៩) ព្រះសយម្ភូ ដែលពួកមារផ្ចាញ់មិនបាន មានឥន្ទ្រិយជាទីថ្លាស្អាត មិនមានកករល្អក់ ព្រះអង្គទ្រង់ចូលកាន់សមាធិ ក្បែរឆ្នេរស្ទឹងចន្ទភាគា ។ កាលនោះ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានឃើញព្រះសម្ពុទ្ធដែលពួកមារផ្ចាញ់មិនបាន ហើយបូជាព្រះសយម្ភូអង្គនោះ ដោយផ្កាមយ–ព្រឹក្ស ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះមយវិបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មយវិបុប្ផិយត្ថេរាបទាន ។

## ឆដ្ឋំ ឧបដ្ឋាយិកត្ថេរាបទានំ

[១៨៦] រថិយំ បដិបជ្ជន្តំ អាហុតីនំ បដិគ្គហំ
វិបស្សិំ មហាវីរំ លោកជេដ្ឋំ នរាសភំ ។
បញ្ញាសាបិយតស្សាហំ(១) សព្វលោកហិតេសិនោ
ឧបដ្ឋាកោ មយា ទិន្នោ សិទ្ធត្ថស្ស មហេសិនោ ។
បដិគ្គហេត្វាន សម្ពុទ្ធោ និយ្យាតេសិ មហាមុនិ(២)
ឧដ្ឋាយ អាសនា តម្ហា បក្កាមិ បាចីនាមុខោ ។
ចតុន្នវុតេ ឥតោ កប្បេ ឧបដ្ឋាកមទំ តទា
ទុគ្គតឹ នាភិជានាមិ ឧបដ្ឋានស្សិទំ ផលំ ។
សត្តបញ្ញាសិតោ កប្បេ ពលសេនសនាមកោ
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្ពលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

១ ម. បក្កាមិ សក្កសស្សាហំ ។ ២ ម. មហាឥសិ ។



## ឧបដ្ឋាយិកត្ថេរាបទាន ទី ៦

(១៨៦) ខ្ញុំបានឃើញព្រះមហាវីរ ព្រះអង្គជាធំជាងសត្វជើងពីរ ជាច្បងក្នុងលោក ទ្រង់ជានរាសភៈ ទ្រង់ទទួលនូវគ្រឿងបូជា ស្តេចទៅតាមច្រក ។ ខ្ញុំបានថ្វាយឧបដ្ឋាកម្នាក់ ដល់ព្រះមហេសី ព្រះនាមសិទ្ធត្ថ ដែលខ្ញុំបានឲ្យគេនិមន្ត ព្រះអង្គស្វែងរកនូវប្រយោជន៍ ដល់សត្វលោកទាំងពួង ។ ព្រះសម្ពុទ្ធជាអ្នកប្រាជ្ញប្រសើរ ទ្រង់ទទួលហើយប្រគល់ឲ្យវិញ ទ្រង់ក្រោកចាកអាសនៈនោះ មានព្រះភក្ត្របែរចេញទៅកាន់បូព៌ទិស ហើយទ្រង់ចៀសចេញទៅ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានថ្វាយឧបដ្ឋាក ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយឧបដ្ឋាក ។ ក្នុងកប្បទី ៥៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមពលសេនៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា ពុទ្ធុបដ្ឋាយិកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ពុទ្ធុបដ្ឋាយិកត្ថេរស្ស អបទានំ សមត្តំ ។

## សត្តមំ អបទានិយត្ថេរាបទានំ

(១៨៧) អបទានំ សុគតានំ កិត្តយិហំ មហេសិនំ
បាទេ ច សិរសា វន្ទឹ បសន្នោ សេហិ បាណិហិ ។
ទេ្វនវុតេ ឥតោ កប្បេ អបទានំ បកិត្តយឹ
ទុគ្គតឹ នាភិជានាមិ កិត្តនាយ ឥទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា អបទានិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អបទានិយត្ថេរស្ស អបទានំ សមត្តំ ។





បានឮថា ព្រះពុទ្ធុបដ្ឋាយិកត្ថេរ មានអាយុ បានសម្តែងនូវគាថា ទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ពុទ្ធុបដ្ឋាយិកត្ថេរាបទាន ។

## អបទានិយត្ថេរាបទាន ទី ៧

(១៨៧) ខ្ញុំមានចិត្តជ្រះថ្លា សម្តែងនូវអបទាន (រឿង) របស់ ព្រះសុគតទាំងឡាយ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ហើយ ក៏ថ្វាយបង្គំព្រះបាទាទាំងពីរ ដោយត្បូងនិងដៃរបស់ខ្លួន ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុ ដែលខ្ញុំ បានសម្តែង នូវអបទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការសម្តែង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអបទានិយត្ថេរ មានអាយុ បានបន្លឺនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អបទានិយត្ថេរាបទាន ។

# អដ្ឋមំ សត្តាហបព្វជិតត្ថេរាបទានំ

(១៤៨) វិបស្សិស្ស ភគវតោ សង្ឃោ សក្កតមានិតោ
ព្យសនំ មេ អនុប្បត្តំ ញាតិភេទោ(១)តទា អហុ
បព្វជ្ជំ ឧបគន្ត្វាន ព្យសនូបសមាយហំ
សត្តាហាភិរតោ តត្ថ សត្ថុសាសនកម្យតា ។
ឯកនវុតេ ឥតោ កប្បេ យមហំ បព្វជឹ តទា
ទុគ្គតឹ នាភិជានាមិ បព្វជ្ជាយ ឥទំ ផលំ ។
សត្តសដ្ឋិម្ហិតោ កប្បេ សត្ត អាសុំ មហីបតី
សុនេក្ខម្មាតិ ញាយន្តិ ចក្កវត្តី មហព្វលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សត្តាហបព្វជិតោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សត្តាហបព្វជិតត្ថេរស្ស អបទានំ សមត្តំ ។

---

១ ឱ. ញាតិភេទោ ។



# សត្តាហបព្វជិតត្ថេរាបទាន ទី ៨

(១៤៨) ក្នុងកាលមុន មានព្រះសង្ឃរបស់ព្រះមានព្រះភាគ ព្រះនាមវិបស្សី ដែលទេវតានិងមនុស្សធ្វើសក្ការៈ រាប់អានហើយ ខ្ញុំដល់នូវសេចក្ដីវិនាស ព្រោះបែកពួកញាតិ ខ្ញុំចូលទៅកាន់ផ្នួស ដើម្បីរម្ងាប់ទុក្ខព្រួយព្រោះសេចក្ដីវិនាសនោះ ខ្ញុំត្រេកអរក្នុងផ្នួសនោះ អស់ ៧ ថ្ងៃ ព្រោះប្រាថ្នាបំពេញកិច្ចក្នុងសាសនារបស់ព្រះសាស្ដា ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានបួស ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃបព្វជ្ជា ។ ក្នុងកប្បទី ៦៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ ៧ ជាតិ ជាម្ចាស់ផែនដី គេតែងស្គាល់ថា ព្រះបាទសុនេក្ខម្មៈ ប្រកបដោយកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសត្តាហបព្វជិតត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សត្តាហបព្វជិតត្ថេរាបទាន ។

## នវមំ ពុទ្ធុបដ្ឋាយិកត្ថេរាបទានំ

(១៨៩) វេតម្ភិនីតិ(១) មេ នាមំ បិតុ សន្តំ មមំ តទា
មម ហត្ថំ គហេត្វាន ឧបានយិ មហាមុនឹ
ឥមេ ចំ ឧទ្ទិសិយន្តិ ពុទ្ធា លោកគ្គនាយកា
តេហំ ឧបដ្ឋឹ សក្កច្ចំ បសន្នោ សេហិ បាណិហិ ។
ឯកត្តឹសេ ឥតោ កប្បេ ពុទ្ធេ បរិចរឹ តទា
ទុគ្គតឹ នាភិជានាមិ ឧបដ្ឋានស្សិទំ ផលំ ។
តេវីសតិ ឥតោ កប្បេ ចតុរោ អាសុ ខត្តិយា
សមណុបដ្ឋកា នាម ចក្កវត្តី មហព្វលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ពុទ្ធុបដ្ឋាយិកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ពុទ្ធុបដ្ឋាយិកត្ថេរស្ស អបទានំ សមត្តំ ។

១ ម. វេតម្ភិនិ ។



## ពុទ្ធុបដ្ឋាយិកត្ថេរាបទាន ទី ៩

(១៨៩) កាលនោះ ខ្ញុំឈ្មោះវេតម្ភុនី បិតារបស់ខ្ញុំក៏ឈ្មោះវេតម្ភុនីដែរ បិតាខ្ញុំដឹកដៃខ្ញុំចូលទៅរកព្រះមហាមុនី ឯព្រះមហាមុនី សម្ដែងប្រាប់ខ្ញុំថា ព្រះពុទ្ធទាំងឡាយនេះ ជាអគ្គនាយកក្នុងលោក ខ្ញុំជ្រះថ្លា បានបម្រើព្រះពុទ្ធទាំងនោះ ដោយគោរព ដោយដៃរបស់ខ្លួន ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានបម្រើព្រះពុទ្ធទាំងឡាយ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបម្រើ ។ ក្នុងកប្បទី ២៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ ៤ ជាតិ មានព្រះនាមសមណុបដ្ឋាកៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះពុទ្ធុបដ្ឋាយិកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ពុទ្ធុបដ្ឋាយិកត្ថេរាបទាន ។

## ទសមំ បុព្វង្គមនិយត្ថេរាបទានំ

(១៨០) ចុល្លាសីតិសហស្សានិ  បព្វជិំសុ អកិញ្ចនា
តេសំ បុព្វង្គមោ អាសិំ  ឧត្តមត្ថស្ស បត្តិយា ។
សកា សមោហា(១) ចេតេ  វិបស្សន្នមនាវិលំ
ឧបដ្ឋហិំសុ សក្កច្ចំ  បសន្នា សេហិ បាណិហិ ។
ទិណាសក វត្តពោសា  ការកាត្វា មហាសក
ជរីសុ ខេត្តចិត្តេន  សយម្ភូ អបរាជិតា ។
តេសំ ឧបដ្ឋហិត្វាន  សម្ពុទ្ធានំ បដិស្សតោ
មរណញ្ច អនុប្បត្តា  ទេវត្តញ្ច អគច្ឆសេ ។
ឆត្តុវេ តតោ កាលេ  យំ សីលមនុបាលយិំ
ទុក្កតី ជាតិជាតិ  សញ្ញមស្ស ឥទំ ផលំ ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនន្តិ ។

១ ម. សហិ ។



## បុព្វង្គមនិយត្ថេរាបទាន ទី ១០

(១៨០) ពួកយើង ៨៤.០០០ នាក់ មិនមានសេចក្តីកង្វល់ បានបួសហើយ ដើម្បីសម្រេចនូវប្រយោជន៍ដ៏ខ្ពង់ខ្ពស់ ខ្ញុំឯង ជាប្រធាន របស់កុលបុត្រទាំងនោះ ។ ឯកុលបុត្រទាំងនោះនៅ មានកនៈនឹងមោហៈ តែមានចិត្តជ្រះថ្លា បានបម្រើព្រះសម្ពុទ្ធ ដែលមានតម្រិះថ្លាស្អាត មិនមានកករល្អក់ ដោយគោរព ដោយដៃរបស់ខ្លួន ។ ព្រះសយម្ភូទាំងឡាយដែលពួកមារ ផ្ចាញ់មិនបាន ព្រះអង្គធ្វើព្រះទីណាស្រេក មានទោសៈធ្លាក់ចោលហើយ មានសោឡសកិច្ចធ្វើរួចហើយ មិនមានអាសវៈ តែងឲ្យយាមរក្សាចិត្ត ។ ពួកយើងបានបម្រើព្រះសម្ពុទ្ធទាំងនោះ ដោយសេចក្តីគោរពក្រែង លុះដល់មរណៈក៏បាន ទៅកាន់អត្តភាពជាទេវតា ។ ក្នុងកប្បទី ៨៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានរក្សាសីល ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការសង្រួមក្នុងសីល ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

ទសមំ

ឥត្ថំ សុទំ អាយស្មា បុព្វង្គមនិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បុព្វង្គមនិយត្ថេរស្ស អបទានំ សមត្តំ ។

## ឧទ្ទានំ

បណ្ណំ ផលំ ឧគ្គមនិយោ ឯកបុប្ផី ច មាឃវោ

ឧបដ្ឋាកោបទានញ្ច បព្វជ្ជា ច ឧបដ្ឋិតំ ។

បុព្វង្គោ ច គាថាយោ អដ្ឋតាលីស កិត្តិតា ។

បណ្ណទាយកវគ្គោ ឯកូនបញ្ញាសោ ។

---



ទី១០

បានឮថា ព្រះបុព្វង្គមនិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បុព្វង្គមនិយត្ថេរាបទាន ។

## ឧទ្ទាន

បណ្ណទាយកត្ថេរាបទាន ១ ផលទាយកត្ថេរាបទាន ១ បច្ចុគ្គមនិយត្ថេរាបទាន ១ ឯកបុប្ផិយត្ថេរាបទាន ១ មឃវបុប្ផិយត្ថេរាបទាន ១ ឧបដ្ឋាយិកត្ថេរាបទាន ១ អបទានិយត្ថេរាបទាន ១ សត្តាហបព្វជិតត្ថេរាបទាន ១ ពុទ្ធុបដ្ឋាយិកត្ថេរាបទាន ១ បុព្វង្គមនិយត្ថេរាបទាន ១ មានគាថា ៤៨ ដែលលោកប្រជុំសម្តែងទុកហើយ ។

ចប់ បណ្ណទាយកវគ្គ ទី ៤៩ ។

---

## ចិតកបូជកវគ្គោ

### បឋមំ ចិតកបូជកត្ថេរាបទានំ

(១៩១) អជិតោ នាម នាមេន អហោសិ ព្រាហ្មណោ តទា
អាហុតឹ យិដ្ឋុកាមោហំ នានាបុប្ផំ សមានយឹ ។
ជលន្តំ ចិតកំ ទិស្វា សិខិនោ លោកពន្ធុនោ
តញ្ច បុប្ផំ សមានេត្វា ចិតកេ ឱកិរឹ អហំ ។
ឯកត្តឹសេ ឥតោ កប្បេ យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
សត្តវីសេ ឥតោ កប្បេ សត្តាសុំ ផុជាចិតា
សុបជ្ជលិតនាមា តេ ចក្កវត្តី មហព្វលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ចិតកបូជកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ចិតកបូជកត្ថេរស្ស អបទានំ សមត្តំ ។

## ចិតកបូជកវគ្គ ទី ៣០

### ចិតកបូជកត្ថេរាបទាន ទី ១

(១៩១) កាលនោះ ខ្ញុំកើតជាព្រាហ្មណ៍ ឈ្មោះអជិតៈ ខ្ញុំប្រាថ្នានឹងបូជានូវគ្រឿងបូជា បានប្រមូលផ្កាផ្សេងៗ ។ ខ្ញុំឃើញជើងថ្ករ ដែលកំពុងឆេះរឿង របស់ព្រះពុទ្ធ ព្រះនាមសិខី ព្រះអង្គជាផៅពង្សនៃសត្វលោក ហើយយកផ្កានោះមករោយលើជើងថ្ករ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ២៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ ៧ ជាតិ ជាធំជាងពួកមនុស្ស ព្រះនាមសុបជ្ជលិតៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះចិតកបូជកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ចិតកបូជកត្ថេរាបទាន ។

## ទុតិយំ បុប្ផធារកត្ថេរាបទានំ

(១៩៦) វាកចីរធរោ អាសឹ  អជិនុត្តរវាសិតោ
អភិញ្ញា បញ្ច និព្វត្តា  ចន្ទស្ស បរិមជ្ជកោ ។
វិបស្សឹ លោកបជ្ជោតំ  ទិស្វា អភិគតំ មមំ
បារិច្ឆត្តកបុប្ផានិ  ធារេសឹ សត្ថុនោ អហំ ។
ឯកនវុតេ ឥតោ កប្បេ  យំ បុប្ផមភិធារយឹ
ទុគ្គតឹ នាភិជានាមិ  ធារណាយ ឥទំ ផលំ ។
សត្តាសីតិម្ហិតោ កប្បេ  ឯកោ អាសឹ មហីបតិ
សមន្តធរណោ នាម  ចក្កវត្តី មហព្វលោ ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បុប្ផធារកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បុប្ផធារកត្ថេរស្ស អបទានំ សមត្តំ ។



## បុប្ផធារកត្ថេរាបទាន ទី ២

(១៩៦) ខ្ញុំស្លៀកសម្ពត់សម្បកឈើ ដណ្តប់សម្ពត់ស្បែកខ្លា ញ៉ាំងអភិញ្ញា ៥ ឲ្យកើត ជាអ្នកស្ទាបអង្អែលព្រះចន្ទបាន ។ ខ្ញុំបានឃើញព្រះវិបស្សី ព្រះអង្គបំភ្លឺលោក ដែលកំពុងស្តេចមកកាន់សំណាក់របស់ខ្ញុំ ទើបខ្ញុំបាំងផ្កាបារិច្ឆត្តកព្រឹក្សថ្វាយព្រះសាស្តា ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានបាំងផ្កាថ្វាយ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបាំងផ្កា ។ ក្នុងកប្បទី ៨៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ មួយអង្គ ជាម្ចាស់ផែនដី ព្រះនាមសមន្តធរណៈ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបុប្ផធារកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បុប្ផធារកត្ថេរាបទាន ។

# តតិយំ ឆត្តទាយកត្ថេរាបទានំ

(១៨៣) បុត្តោ មម បព្វជិតោ កាសាយវសនោ តទា
សោ ច ពុទ្ធត្តសម្បត្តោ និព្វុតោ លោកបូជិតោ ។
វិចិនន្តោ សកំ បុត្តំ អាគមឹ[១] បច្ឆតោ អហំ[២]
និព្វុតស្ស មហន្តស្ស ចិតកំ អគមាសហំ ។
បគ្គយ្ហ អញ្ជលឹ តត្ថ វន្ទិត្វា ចិតកំ អហំ
សេតច្ឆត្តញ្ច បគ្គយ្ហ អារោបេសឹ អហំ តទា ។
ទ្វេនវុតេ ឥតោ កប្បេ យំ ឆត្តមភិរោបយឹ
ទុគ្គតឹ នាភិជានាមិ ឆត្តទានស្សិទំ ផលំ ។
បញ្ចវីសេ ឥតោ កប្បេ សត្ត អាសុំ ជនាធិបា
មហារហសនាមា តេ ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ឆត្តទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឆត្តទាយកត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. អគមឹ ។ ២ ម. តហំ ។





# ឆត្តទាយកត្ថេរាបទាន ទី ៣

(១៨៣) កាលនោះ កូនរបស់ខ្ញុំបួស ស្លៀកសំពត់កាសាយៈ កូននោះបានដល់ភាពជាព្រះពុទ្ធ ដែលសត្វលោកបូជា បានបរិនិព្វានហើយ ។ ខ្ញុំស្វែងរកកូនរបស់ខ្លួន ក៏ទៅកាន់ជើងថ្ករ របស់ព្រះពុទ្ធដ៏ប្រសើរ ជាកូនរបស់ខ្ញុំ ដែលបរិនិព្វានហើយ នៅខាងក្រោយគេ ។ កាលនោះ ខ្ញុំផ្គងអញ្ជលី ថ្វាយបង្គំជើងថ្ករត្រង់កន្លែងនោះ ហើយខ្ញុំកាន់ស្វេតច្ឆត្រថ្វាយ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាឆត្រ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយឆត្រ ។ ក្នុងកប្បទី ២៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ ៧ ជាតិ ជាធំជាងជន ព្រះនាមមហារហៈ ដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឆត្តទាយកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឆត្តទាយកត្ថេរាបទាន ។

## ចតុត្ថំ សព្វសញ្ញកត្ថេរាបទានំ

(១៩៤) អនុត្តរត្ថិ អាមិតេ្ច បសាទោ វិបុលោ អហុ
ពុទ្ធសេដ្ឋស្ស លោកម្ហិ ជាតុការេ មហេសិនោ ។
សព្វមសេ្សាសយាំ(១) តត្ថ ឧឧបស្សាមិ តំ ជិនំ
អរណញ្ញេ អនុប្បត្តោ ពុទ្ធសញ្ញមនុស្សរឹ ។
ចតុន្នវុតេ ឥតោ កប្បេ យំ សញ្ញមលភឹ តទា
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សព្វសញ្ញកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សព្វសញ្ញកត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. យោកសាមសេ្សាសយាំ ទិស្សតិ ។



## សព្វសញ្ញកត្ថេរាបទាន ទី ៤

(១៩៤) កាលព្រះអាទិត្យមិនទាន់រះឡើង សេចក្តីជ្រះថ្លា យ៉ាងទូលាយ ចំពោះព្រះពុទ្ធដ៏ប្រសើរ ព្រះអង្គស្វែងរកគុណធំ កំពុងកើតមានក្នុងលោក ។ ខ្ញុំបានឮសំឡេង ប្រកាសថា ព្រះពុទ្ធច្រាស់ហើយ ក្នុងពេលនោះ តែខ្ញុំមិនបាន ឃើញព្រះជិនស្រីនោះឡើយ លុះដល់ខ្ញុំជិតនឹងមរណកាល ខ្ញុំបានចាប់យកនឹកដល់ព្រះពុទ្ធ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានខ្ជាប់ពុទ្ធសញ្ញា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសព្វសញ្ញកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សព្វសញ្ញកត្ថេរាបទាន ។

## បញ្ចមំ កោសិសនិក្ខេបកត្ថេរាបទានំ

(១៩៨) អាភមទ្វាភ ចិត្តម្ម   កោសិសំ សន្ថតំ មយា

អនុភោមិ សកំ កម្មំ   បុព្វកម្មស្សិទំ ផលំ ។

អាជានិយា ភគជក   សិវិកា សីឃវាហនា

អនុភោមិ សព្វមេតំ   កោសិសស្ស ឥទំ ផលំ ។

អហោ ការំ បរមការំ   សុខេត្តេ សុកតំ មយា

សង្ឃេ កតស្ស ការស្ស   ន អញ្ញំ កលមគ្ឃតិ ។

ចតុន្នវុតេ ឥតោ កប្បេ   យំ សិសំ សន្ថរឹ អហំ

ទុគ្គតឹ នាភិជានាមិ   សន្ថរស្ស ឥទំ ផលំ ។

ចតុសត្តតិកប្បម្ហិ   សុបតិដ្ឋិតនាមកោ

ឯកោ អាសឹ មហាតេជោ   ចក្កវត្តី មហព្វលោ ។

បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។





## កោសិសនិក្ខេបកត្ថេរាបទាន ទី ៥

(១៩៨) ខ្ញុំបានក្រាលកម្រាលប្រដាប់ជើង ចេញអំពីផ្កា តាក (ក្នុងចំពោះសង្ឃ) ខ្ញុំបានសោយផលកុសលកម្មរបស់ខ្លួន នេះ នេះជាផលនៃបុព្វកម្ម ។ ខ្ញុំបាននូវយានៈទាំងអស់ នុះ គឺសេះអាជានេយ្យ រថនិងសិវិកា និងសេះលឿន ជាពាហនៈដ៏លឿន នេះជាផលនៃកម្រាលប្រដាប់ជើង ។ ឱ គ្រឿងសក្ការៈជាសក្ការៈដ៏ឧត្តម ដែលខ្ញុំបានធ្វើហើយដោយប្រពៃ ចំពោះបុញ្ញក្ខេត្តដ៏ល្អ គ្រឿងសក្ការៈដទៃមិនដល់មួយចំណិតនៃសក្ការៈ ដែលខ្ញុំធ្វើចំពោះសង្ឃឡើយ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានក្រាលកម្រាលប្រដាប់ជើង ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃកម្រាល ។ ក្នុងកប្បទី ៧៤ ខ្ញុំបានកើតជាស្តេចចក្រពត្តិ មួយអង្គ ព្រះនាមសុបតិដ្ឋិតៈ ទ្រង់មានតេជៈច្រើន មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា កោសិសនិក្ខេបកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កោសិសនិក្ខេបកត្ថេរស្ស អបទានំ សមត្តំ ។

## ឆដ្ឋំ ចន្ទនបូជកត្ថេរាបទានំ

[១៩៦] បព្វតេ ហិមវន្តម្ហិ   អហោសិំ កិន្នរោ តទា
អទ្ទសំ វិរជំ ពុទ្ធំ   បីតរំសិំវ ភាណុមំ ។
ឧបេតោមិ តទា ពុទ្ធំ   វិបស្សិំ លោកនាយកំ
ចន្ទំ តគរំ ភចំ   បាទេ ឱសិញ្ចហំ តទា ។
ឯកនវុតេ ឥតោ កប្បេ   យំ ជនំ អភិបូជយិំ
ទុគ្គតិំ នាភិជានាមិ   ពុទ្ធបូជាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ចន្ទនបូជកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ចន្ទនបូជកត្ថេរស្ស អបទានំ សមត្តំ ។





បានឮថា ព្រះកោសិសនិក្ខេបកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កោសិសនិក្ខេបកត្ថេរាបទាន ។

## ចន្ទនបូជកត្ថេរាបទាន ទី ៦

[១៩៦] កាលនោះ ខ្ញុំកើតជាកិន្នរ នៅភ្នំហិមពាន្ត បានឃើញព្រះសម្ពុទ្ធ ព្រះអង្គប្រាសចាកធូលីកិលេស ដូចជាព្រះអាទិត្យមានរស្មីលឿង ។ កាលនោះ ខ្ញុំចូលទៅគាល់ព្រះពុទ្ធ ព្រះនាមវិបស្សី ព្រះអង្គជានាយកនៃសត្វលោក ហើយប្រោះនូវខ្លឹមចន្ទន៍និងក្រស្នា លើព្រះបាទាក្នុងកាលនោះ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាព្រះពុទ្ធ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាព្រះពុទ្ធ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះចន្ទនបូជកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ចន្ទនបូជកត្ថេរាបទាន ។

## សត្តមំ ទេសកិត្តកត្ថេរាបទានំ

(១៤៨) ឧបសាឡ្ហកនាមោហំ អហោសឹ ព្រាហ្មណោ
តទា

កាននំ វនមោគ្គយ្ហ  លោកជេដ្ឋំ អបស្សហំ
ទិស្វាន វន្ទឹ បាទេសុ  លោកាហុតិបដិគ្គហំ
បសន្នចិត្តោ សុមនោ  ពុទ្ធោ អនុត្តរោ អយំ ។
កាននា អភិនិក្ខម្ម  ពុទ្ធសេដ្ឋំ អនុស្សរឹ
[illegible] កិត្តយិត្វាន  កប្បំ សគ្គម្ហិ មោទហំ ។
ចតុន្នវុតេ ឥតោ កប្បេ  យំ ពុទ្ធមភិកិត្តយឹ
ទុគ្គតឹ នាភិជានាមិ  កិត្តនាយ ឥទំ ផលំ ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ទេសកិត្តកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ទេសកិត្តកត្ថេរស្សាបទានំ សត្តមំ ។

៦៣៦



## ទេសកិត្តកត្ថេរាបទាន ទី ៧

(១៤៨) ក្នុងកាលនោះ ខ្ញុំកើតជាព្រាហ្មណ៍ ឈ្មោះ ឧបសាឡ្ហកៈ ខ្ញុំចូលទៅកាន់ព្រៃធំ បានឃើញព្រះលោកនាថ ជាធំលោកៈ ជាប្រសើរបំផុតរបស់សត្វលោក ហើយខ្ញុំក្រាបថ្វាយបង្គំទៀបព្រះបាទ ព្រះពុទ្ធទ្រង់ប្រោស ជាខ្ញុំមានចិត្តជ្រះថ្លាហើយ ក៏ចេញចាកទៅ ។ ខ្ញុំចេញចាកព្រៃនោះ ក៏បានរលឹកដល់ព្រះពុទ្ធដ៏ប្រសើរ ខ្ញុំបានសរសើរនូវព្រះអង្គនោះ ហើយរីករាយក្នុងឋានសួគ៌ អស់មួយកប្ប ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានកោតសរសើរនូវព្រះអង្គ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការសរសើរ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះទេសកិត្តកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ទេសកិត្តកត្ថេរាបទាន ។

## អដ្ឋមំ សរណាគមនិយត្ថេរាបទានំ

(១៩៨) បព្វតេ ហិមវន្តម្ហិ អហោសិំ លុទ្ទកោ តទា
វិបស្សិំ អទ្ទសំ ពុទ្ធំ លោកជេដ្ឋំ នរាសភំ ។
ឧបាសិត្វាន សម្ពុទ្ធំ វេយ្យាវច្ចមកាសហំ
សរណញ្ច ឧបាគច្ឆិំ ទិបទិន្ទស្ស តាទិនោ ។
ឯកនវុតេ ឥតោ កប្បេ យំ សរណំ អគច្ឆហំ(១)
ទុគ្គតិំ នាភិជានាមិ សរណាយ ឥទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា សរណាគមនិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សរណាគមនិយត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. សរណំ ឧបគច្ឆហំ ។



## សរណាគមនិយត្ថេរាបទាន ទី ៨

(១៩៨) កាលនោះ ខ្ញុំកើតជាព្រានព្រៃ នៅតាមភ្នំហិមពាន្ត បានឃើញព្រះពុទ្ធ ព្រះនាមវិបស្សី ព្រះអង្គជាច្បងក្នុងលោក ជានរាសភៈ ។ ខ្ញុំចូលទៅជិតព្រះសម្ពុទ្ធ ធ្វើនូវការបម្រើ ទាំងបានថ្វាយខ្លួនជាឧបាសក ដល់សរណៈ (ក្នុងសំណាក់) នៃព្រះសម្ពុទ្ធ ព្រះអង្គជាធំជាងសត្វជើងពីរ ប្រកបដោយតា-ទិគុណ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានដល់សរណៈ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសរណៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសរណាគមនិយត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សរណាគមនិយត្ថេរាបទាន ។

## នវមំ អម្ពបិណ្ឌិយត្ថេរាបទានំ

(៥៩៩) រោមសោ នាម នាមេន ទានវេ ឥតិ វិស្សុតោ
អម្ពបិណ្ឌោ មយា ទិន្នោ វិបស្សិស្ស មហេសិនោ ។
ឯកនវុតេ ឥតោ កប្បេ យំ អម្ពមទទឹ តទា
ទុគ្គតឹ នាភិជានាមិ អម្ពទានស្សិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។
ឥត្ថំ សុទំ អាយស្មា អម្ពបិណ្ឌិយោ ថេរោ ឥមា
គាថាយោ អភាសិត្ថាតិ ។

អម្ពបិណ្ឌិយត្ថេរស្ស អបទានំ សមត្តំ ។

## ទសមំ អនុសំសាវកត្ថេរាបទានំ

(៦០០) បិណ្ឌាយ ចរមានាហំ វិបស្សឹ អទ្ទសំ ជិនំ
ឧឡុង្គភិក្ខំ អទាសឹ ទិបទិន្ទស្ស តាទិនោ ។



## អម្ពបិណ្ឌិយត្ថេរាបទាន ទី ៩

(៥៩៩) ខ្ញុំឈ្មោះរោមសៈ ដែលគេស្គាល់គ្នាថាទានវៈ ខ្ញុំបានថ្វាយផ្លែស្វាយមួយដុំ ដល់ព្រះពុទ្ធ ព្រះនាមវិបស្សី ព្រះអង្គដែលស្វែងរកគុណដ៏ធំ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានថ្វាយផ្លែស្វាយ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែស្វាយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអម្ពបិណ្ឌិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អម្ពបិណ្ឌិយត្ថេរាបទាន ។

## អនុសំសាវកត្ថេរាបទាន ទី ១០

(៦០០) ខ្ញុំបានឃើញព្រះជិនស្រី ព្រះនាមវិបស្សី កំពុងត្រាច់ទៅបិណ្ឌបាត បានថ្វាយបាយមួយវែក ដល់ព្រះសម្ពុទ្ធ ព្រះអង្គជាធំជាងសត្វជើងពីរ ទ្រង់ប្រកបដោយតាទិគុណ ។

បសន្នចិត្តោ សុមនោ អភិវាទេសហំ តទា
អនុសំសាវយី ពុទ្ធំ ឧត្តមត្ថស្ស បត្តិយា ។
ឯកនវុតេ ឥតោ កប្បេ អនុសំសាវយី អហំ
ទុគ្គតិំ នាភិជានាមិ អនុសំសាវនាផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា អនុសំសាវកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អនុសំសាវកត្ថេរស្ស អបទានំ សមត្តំ ។

## ឧទ្ទានំ

ចិតកំ ចារិឆត្តញ្ច សទ្ទំ គោសីសសន្ថរំ
បទំ បទេសំ សរណំ អនុសំសាវកោបិច
សត្តតាឡីសគាថាយោ(១) គណិតាយោ វិភាវិភិ ។

ចិតកបូជកវគ្គោ ទសមោ ។

១ ម. អដ្ឋតាឡីសគាថាយោតិ ទិស្សតិ ។





កាលនោះ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយបង្គំ ពោលសរសើរព្រះសម្ពុទ្ធ ដើម្បីសម្រេចនូវប្រយោជន៍ដ៏ខ្ពង់ខ្ពស់ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានសរសើរព្រះពុទ្ធ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការសរសើរ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអនុសំសាវកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អនុសំសាវកត្ថេរាបទាន ។

## ឧទ្ទាន

ចិតកបូជកត្ថេរាបទាន ១ បុប្ផធារកត្ថេរាបទាន ១ ឆត្តធារកត្ថេរាបទាន ១ សទ្ទសញ្ញកត្ថេរាបទាន ១ គោសីសនិក្ខេបកត្ថេរាបទាន ១ បទបូជកត្ថេរាបទាន ១ ទេសកិត្តិកត្ថេរាបទាន ១ សរណគមនិយត្ថេរាបទាន ១ អម្ពបិណ្ឌិយត្ថេរាបទាន ១ អនុសំសាវកត្ថេរាបទាន ១ មានគាថា ៤៧ ដែលលោកអ្នកប្រាជ្ញរាប់ហើយ ។

ចប់ ចិតកបូជកវគ្គ ទី ៣០ ។

## អដ្ឋិ វគ្គទានំ

កណិកាលេ ហត្ថិនោ អាលម្ពុឧកាសរំ
កុរុំ ជោមកោ ចេវ ឧព្ភេទំ សីសុបចាទិ ។
បណ្ណកោ ចិត្តម្ពី ច កាជាយោ ចេវ សព្វសោ
ចត្តារិ ច សកាមីហ ឯកាបញ្ញាសចេវ ច ។
ពញ្ចសេ សត សព្វ ត្ថាសត្តតិ គន្ធារិ
តិស សតានិ បតានិ កណិកា អត្ថសង្ខិតា ។

និដ្ឋិតំ សតកំ សមត្តំ ។

---





## មួយទៀត ឧទ្ទាននៃវគ្គ

គណីកាឡុម្ពិយវគ្គ ១ ហត្ថិវគ្គ ១ កាលម្ពុនតាយកវគ្គ ១ ទទ-
កាសនតាយវគ្គ ១ កុរុតាយវគ្គ ១ ជោមកវគ្គ ១ ឧព្ភេទ-
វគ្គ ១ សីសុបតានវគ្គ ១ បណ្ណតាយវគ្គ ១ ចិត្តកម្ពុជកវគ្គ
១ គន្ធីវគ្គនេះ មានគាថា ៦៩១ ដោយសព្វគ្រប់ ។ គាថា
ទាំងអស់ ១៦៨ វគ្គ លើសពីនោះ ៧៦ ទៀតផង នៃបទ
១៣០ ដែលអ្នកប្រាជ្ញ ជាអ្នកឃើញនូវប្រយោជន៍ បាន
ពោលហើយ ។

ចប់ សត្តកៈទី ៣១ ។

---